# ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០២០

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 30-11-2020

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៦និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់នេះ មាន ១-ឈ្មោះ ហុង នឹម ភេទស្រី អាយុ ៣៧ឆ្នាំ រស់នៅភូមិអូជុំ ឃុំកូនសាត់ ស្រុកទឹកឈូ ខេត្តកំពត, ២-ឈ្មោះ រិន ចំប៉ា ភេទស្រី អាយុ ៤២ឆ្នាំ រស់នៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង, ៣-ឈ្មោះ សំ ស្រីម៉ៅ ភេទស្រី អាយុ ៣៧ឆ្នាំ រស់នៅភូមិជើងគោ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ, ៤-ឈ្មោះ សុះ សួស ភេទស្រី អាយុ ២៩ឆ្នាំ, ៥-ឈ្មោះ ជូន ស្រីមុំ ភេទស្រី អាយុ ៣៤ឆ្នាំ រស់នៅភូមិជ្រាវ ឃុំព្រៃកន្លោង ស្រុកពោធិ៍រៀង ខេត្តព្រៃវែង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៦នាក់

https://www.facebook.com/GDIOfficial 30-11-2020

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៦នាក់ ស្រី ៤៥នាក់៕

## វៀតណាមចំពេញការប្តេជ្ញាចិត្តក្នុងការធានានូវការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 1 ខែ ធ្នូ ឆ្នាំ 2020

AKP ភ្នំពេញថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០២០ – កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ក្រសួងការបរទេសវៀតណាម និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានរួមគ្នារៀបចំសន្និសីទមួយ ស្តីពីការអនុវត្តការកតិកាសញ្ញាជាសកលសម្រាប់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព មានសណ្តាប់ធ្នាប់ និងទៀងទាត់ (GCM) នៅទីក្រុងហាណូយ។សន្និសីទនេះមានការចូលរួមពីគណៈប្រតិភូជាង ១១០នាក់ មកពីក្រសួង ទីភ្នាក់ងារ និងមូលដ្ឋាន និងអង្គការអន្តរជាតិនានា។

នៅក្នុងសុន្ទរកថារបស់អនុរដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម លោក Toh Anh Dung បាននិយាយថា ផែនការអនុវត្ត GCM របស់ប្រទេសវៀតណាម គឺបានដាក់ចេញនូវដំណោះស្រាយរួម និងគ្រប់ជ្រុងជ្រោយសម្រាប់បញ្ហាចំណាកស្រុកអន្តរជាតិនាពេលបច្ចុប្បន្ននេះ ជាមួយនឹងបញ្ហាយេនឌ័រ និងការអភិវឌ្ឍប្រកបដោយចីរភាពដែលត្រូវបានយកចិត្តទុកដាក់ផងដែរ។ លោកបាននិយាយថា នេះគឺជាការបោះជំហានទៅមុខយ៉ាងរឹងមាំមួយរបស់ប្រទេសវៀតណាមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការធ្វើចំណាកស្រុក ដោយបង្ហាញនូវការប្តេជ្ញាចិត្តរបស់ប្រទេសនេះ និងស្មារតីទទួលខុសត្រូវក្នុងការថែរក្សា និងបង្រួបបង្រួមបរិយាកាសចំណាកស្រុកប្រកបដោយតម្លាភាព និងសុវត្ថិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ មន្ត្រីរូបនោះបាននិយាយបន្ថែមថា សន្និសីទនេះបានផ្តល់ឱកាសក្នុងការពិនិត្យមើលឡើងវិញនូវការធ្វើចំណាកស្រុករបស់ពលករវៀតណាមទៅកាន់ប្រទេសក្រៅ ក៏ដូចជាការគ្រប់គ្រងរបស់វៀតណាមនៅក្នុងបញ្ហានេះ។

លោកស្រី Park Mi-hyung ប្រធានបេសកកម្មរបស់អង្គការ IOM ប្រចាំប្រទេសវៀតណាម បាននិយាយថា ការដាក់ចេញនូវផែនការនេះគឺជាការឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តខ្ពស់របស់ប្រទេសវៀតណាមក្នុងការលើកកម្ពស់ការយល់ឃើញរួម និងការចែករំលែកការទទួលខុសត្រូវចំពោះការធ្វើចំណាកស្រុកដើម្បីជាប្រយោជន៍ដល់ប្រជាជនទាំងអស់។ សន្និសីទនេះក៏ជាឱកាសមួយផងដែរសម្រាប់គណៈប្រតិភូធ្វើការផ្លាស់ប្តូរបទពិសោធន៍គ្នា និងធ្វើការរួមគ្នាដើម្បីបង្កើតគោលនយោបាយគ្រប់ជ្រុងជ្រោយក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ជនចំណាកស្រុក ទន្ទឹមនឹងការបង្កើនកិច្ចសម្របសម្រួលក្នុងការគ្រប់គ្រងការធ្វើចំណាកស្រុកនៅកម្រិតផ្សេងៗគ្នា ជាពិសេសនៅក្នុងបរិបទនៃការរាតត្បាតជំងឺកូវីដ-១៩ ហើយប្រទេសជាច្រើនកំពុងពិចារណាក្នុងការបើកដំណើរការព្រំដែនរបស់ពួកគេឡើងវិញ៕ (ប្រភព VNA បកប្រែដោយលោក យា ចិន្តាខន្តី)

## នារីខ្មែរម្នាក់ យំសុំឱ្យសម្តេចនិងអង្គការសិទ្ធិមនុស្សជួយ ក្រោយពីត្រូវគ្រួសារ និងប្តីចិនឃុំឃាំងបង្ខំរួមភេទ

https://www.cen.com.kh/ December 1, 2020

នារីរងគ្រោះដែលបានចាញ់បោកមេខ្យល់ទៅកាន់ប្រទេសចិននោះមានឈ្មោះ ធួក សុភី អាយុ២០ឆ្នាំ មានស្រុកកំណើតនៅ ភូមិឃ្សីក្រៅ ឃុំឃ្សីក្រៅ ស្រុកស្នួលខេត្តក្រចេះ បច្ចុប្បន្នជាប់នៅប្រទេសចិន។ នាងបានប្រើប្រាស់គណនីហ្វេសប៊ុកមួយដែលមានឈ្មោះថា (វាសនា កូនស្រី ទីបួន) ដោយបានបង្ហោះកាលពីថ្ងៃទី២៩-៣០ វិច្ឆិកា ឆ្នាំ២០២០ ម្សិលមិញរៀបរាប់ថា ខ្លួនត្រូវបានចាញ់បោកមេខ្យល់ទៅកាន់ប្រទេសចិន ហើយម៉ែឪប្តីចិនបានឃុំនាងមិនឱ្យចេញក្រៅមានសេរីភាពជួបគ្រួសានៅខ្មែរទេ។ អ្វីដែលឈឺចាប់ទៀតនោះ ស្នូនរបស់នាងបានរងការឈឺចាប់យ៉ាងខ្លាំងដោយកាបង្ខំរួមភេទ ដោយនាងគ្មានលទ្ធភាពតតាំងវិញឡើយ សូម្បីតែទូរស័ព្ទដែលកំពុងប្រើប្រាស់នេះ ក៏មិនដឹងថាគេដកយកវិញពេលណាទេ។ នាងបានបញ្ជាក់ទៀតថា នាងបានចាញ់បោកមេខ្យល់ ហើយត្រូវគេបង្ខំឱ្យយកប្តីនៅទីនោះ បើមិនយកទេគេនឹងយកនាងទៅលក់ក្នុងហាងស្រីខូច។ ហើយទូរស័ព្ទគ្មានស៊ីម និងត្រូវគេផ្តាច់ខ្សែសំឡេងទៀត និយាយអត់កើត បានតែសរសេរ ហើយបច្ចុប្បន្ននាងកំពុងជាប់នៅខេត្តនៅខេត្តហឺនណាន។

ជាចុងក្រោយនាងបានអំពាវនាវយ៉ាងទទូចថា «សូមពុកម៉ែបងប្អូនជួយស៊ែរបន្តឱ្យបានដល់សម្តេច ហ៊ុន សែន និងបងៗខាងសិទ្ធិមនុស្សបានឃើញនិងជួយយកខ្ញុំចេញពីប្រទេសចិនឆាប់ៗផងខ្ញុំមិនចង់នៅទេ ខ្ញុំចង់មានសេរីភាព ចង់ជួបគ្រួសាខ្ញុំវិញ ពេលនេះខ្ញុំសម្តាធខ្លាំងណាស់ត្រូវគេបិតសេរីភាព ហើយគេបង្ខំឱ្យមានកូនឆាប់ៗទៀត ខាងក្រោមនេះជាឈ្មោះប្តីចិននិងអាសយដ្ឋាន៕ **ដោយៈ កូលាប ក្រហម**

# ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០២០

## សមត្ថកិច្ចកំពុងអន្តរាគមន៍ជួយស្ត្រីខ្មែរម្នាក់ ដែលត្រូវបានមេខ្យល់ឆបោកយកទៅនៅប្រទេសចិន ដោយរូបភាពរៀបការប្ដីជនជាតិចិន

http://cambodiapolice.com/policekh/ 8:38 pm 1 ធ្នូ 2020

**ភ្នំពេញ៖** ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជាក់ឲ្យដឹងថា កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នាយកដ្ឋានបានទទួលព័ត៌មានពីក្រុមការងារប្រតិកម្មរហ័សរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធនឹងការចុះផ្សាយលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុករបស់គណនីឈ្មោះ វាសនាកូនស្រី ទីបួន ដោយបានសរសេរខ្លឹមសារបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមថា ពុំមានសេរីភាពក្នុងការរស់នៅ បន្ទាប់ពីចាញ់បោកមេខ្យល់រៀបការប្ដីជនជាតិចិន និងទទួចសំណូមពរឲ្យអាជ្ញាធរកម្ពុជាអន្តរាគមន៍ជួយសង្គ្រោះត្រឡប់មករស់នៅប្រទេសកម្ពុជាវិញ។ ក្នុងខ្លឹមសារសំណេរបញ្ជាក់ថា នាងមានឈ្មោះ ជួក សុភី អាយុ២០ឆ្នាំ នៅភូមិឃ្សឹបក្រៅ ឃុំឃ្សឹបក្រៅ ស្រុកស្នួល ខេត្តក្រចេះ។

អនុវត្តតាមមតិចង្អុលដឹកនាំរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងឯកឧត្តម លោកជំទាវ អគ្គស្នងការរងទទួលផែនការងារជំនាញ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ កម្លាំងជំនាញរបស់នាយកដ្ឋាន សហការជាមួយស្នងការដ្ឋាននគរបាលខេត្តក្រចេះ ស្រាវជ្រាវស្វែងរកឃើញសាច់ញាតិ និងបានសាកសួរព័ត៌មានលម្អិត ដើម្បីស្រាវជ្រាវ កំណត់អត្តសញ្ញាណជនសង្ស័យជាមេខ្យល់ និងបានស្របសម្រួលឱ្យម្ដាយនារីរងគ្រោះមកដាក់ពាក្យបណ្តឹងនៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអន្តរាគមន៍សង្គ្រោះកូនស្រីរបស់គាត់ឱ្យត្រឡប់មកប្រទេសកំណើតវិញ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា បច្ចុប្បន្ន នាយកដ្ឋានបានសហការជាមួយក្រុមលេខាធិការដ្ឋានមេគង្គឡានឆាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកតម្រុយ និងទីកន្លែងស្នាក់នៅរបស់ជនរងគ្រោះខាងលើ ដើម្បីមានមូលដ្ឋានពិតប្រាកដក្នុងការអនុវត្តនីតិវិធីអន្តរាគមន៍សង្គ្រោះនារីរងគ្រោះខាងលើ ត្រឡប់មកប្រទេសកំណើតវិញ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ មន្ត្រីជំនាញរបស់នាយកដ្ឋាន បានបញ្ជូនព័ត៌មានបន្ថែមទៀត រួមមានគណនីហ្វេសប៊ុក ដែលមានអាសយដ្ឋាន អត្តសញ្ញាណបណ្ណប្តីជនជាតិចិន ឲ្យទៅក្រុមការងារលេខាធិការដ្ឋានមេគង្គឡានឆាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីមានមូលដ្ឋានក្នុងការស្រាវជ្រាវសង្គ្រោះ។

ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ក្នុងនាមថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្នុងនាមនាយកដ្ឋានជំនាញ សូមថ្លែងអំណរគុណចំពោះសាធារណជន អ្នកសារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គម ដែលតែងតែចូលរួមចំណែកក្នុងកិច្ចការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនិងក៏ដូចជាការចូលរួមចំណែកស្វែងរកយុត្តិធម៌សង្គម ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៥នាក់

https://www.facebook.com/GDIOfficial 01-11-2020

នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ចង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ

និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៥នាក់ ស្រី ៣០នាក់៕

## ថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ២០២០

## ក្រសួងរកឃើញមាន ជនរងគ្រោះពីការជួញដូរមនុស្ស ជាង ១ ពាន់នាក់រយៈពេល ១១ ខែ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 02 December 2020 | 17:30 ICT

**ភ្នំពេញៈ** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានរកឃើញជនរងគ្រោះ និង ងាយរងគ្រោះដោយសាអំពើជួញដូរមនុស្សមានជាង១ពាន់នាក់ ក្នុងរយៈពេល ១១ ខែឆ្នាំនេះ ក្នុងនោះស្រី ៩០ នាក់ កុមារា ៤០៨នាក់ កុមារី៥៩៧ នាក់ ក៏ប៉ុន្តែករណីបំពានផ្លូវភេទផ្ទាល់បានថយចុះ ខណៈបំពានតាមអនឡាញកើនឡើង ។ យោងតាមរបាយការណ៍ ស្តីពីលទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០២០ របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្មជនរងគ្រោះនៃក្រសួង សង្គមកិច្ច ដែលភ្នំពេញ ប៉ុស្តិ៍ ទទួលបាន នៅថ្ងៃទី ២ ធ្នូនេះ ឱ្យដឹងថា តួលេខជនរងគ្រោះ និង ងាយរងគ្រោះពីការជួញដូរមនុស្សទាំងនេះទទួលបានពីមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត និង អង្គការដៃគូទូទាំងប្រទេស ក្នុងរយៈពេល ១១ ខែឆ្នាំនេះ សរុបមានចំនួន ១០៩៥ នាក់ (ស្រី ៩០ នាក់ កុមារា ៤០៨ នាក់ កុមារី ៥៩៧ នាក់)។ ក្នុងនោះទទួលបានពីមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ៦០ នាក់ និង ពីអង្គការដៃគូ ១០៣៥ នាក់។ បើតាមរបាយការណ៍ជនរងគ្រោះ និង ងាយរងគ្រោះពីអំពើជួញដូរមនុស្សទាំងនេះមានករណីជួញដូរផ្លូវភេទ ២៧ នាក់ អាជីវកម្មផ្លូវភេទ ៦ នាក់ កេងប្រវ័ញ្ចផ្លូវភេទ ៣៥ នាក់ រំលោភបំពានផ្លូវភេទ ២០៨ នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ២១០ នាក់ ជួញដូរកម្លាំងពលកម្ម ៨ នាក់និង ងាយរងគ្រោះ ៦០១ នាក់។

លោក តូច ចាន់នី អ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានឱ្យដឹង នៅថ្ងៃទី ២ ធ្នូនេះថា ក្នុងអំឡុងពេល១១ខែនេះ ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សដែលបានបញ្ជូនទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូសរុប ៣៧១ នាក់ ក្នុងនោះមានបុរស ២៥ នាក់ ស្ត្រី ៧៦ នាក់ កុមារី ២២៦ នាក់ កុមារា ៤៤ នាក់។ ចំណែកជនរងគ្រោះ និង ងាយរងគ្រោះដែលត្រូវបានធ្វើសមាហរណកម្មត្រឡប់ទៅក្នុងសហគមន៍វិញ មានចំនួន១០៣ នាក់ ក្នុងនោះបុរស ៣ នាក់ ស្ត្រី ៦៦ នាក់ កុមារី ១០ នាក់ កុមារា ២៤ នាក់។ លោក ចាន់នី បានបញ្ជាក់ថា៖ «លទ្ធផលនេះ គឺក្រសួងសង្គមកិច្ច បានអនុវត្តតាមគោលនយោបាយ និង បទដ្ឋានដែលក្រសួងបានដាក់ចេញ និង ការចង្អុលបង្ហាញរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច»។

លោក សំលៀង សីលា នាយកប្រតិបត្តិអង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) បានថ្លែងនៅថ្ងៃពុធនេះដែរថា តាមការអង្កេតការកេងប្រវ័ញ្ច និង ការរំលោភបំពានផ្លូវភេទលើកុមារភាគច្រើន គឺជនល្មើសធ្វើតាមរយៈការលួងលោមដោយផ្ទាល់និងដោយប្រយោល (អនឡាញ)។ កុមារដែលងាយរងគ្រោះ គឺជាកុមារអានាថានៅតាមផ្លូវ និង កុមារដែលរស់នៅក្នុងសហគមន៍ ដោយជនល្មើសប្រើប្រាស់វិធីឧបត្ថម្ភសម្ភារឬវត្ថុដល់គ្រួសារ និង កុមាររងគ្រោះ។ លោកបានថ្លែងថា៖ «សកម្មភាពលួងលោមនេះ បានទាក់ទាញទាំងគ្រួសារ និង កុមារឱ្យមានទំនុកចិត្តចំពោះជនល្មើស ទើបជនល្មើសព្យាយាមអូសទាញកុមារទៅប្រព្រឹត្តអំពើល្មើសផ្លូវភេទ និងការកេងប្រវ័ញ្ចផ្សេងទៀត»។ យ៉ាងណាក្តី លោក សីលា បានសង្កេតឃើញថា បទល្មើសនៃការរំលោភបំពានផ្លូវភេទលើកុមារមានការថយចុះ ដោសារការអនុវត្តច្បាប់របស់សមត្ថកិច្ច និង ការដាក់ទោសទណ្ឌដល់ជនល្មើស។

លោកបង្ហាញថា រយៈពេល ១១ ខែ ឆ្នាំនេះ សមត្ថកិច្ចឃាត់ខ្លួនជនល្មើសពីការរំលោភបំពានផ្លូវភេទបានចំនួន ១៣ នាក់ ហើយកាលពីឆ្នាំ ២០១៩ ឃាត់ខ្លួនជនល្មើសបាន ១៨ នាក់។ ចំណែកកុមាររងគ្រោះពីការរំលោភបំពានផ្លូវភេទរយៈពេល ១១ ខែឆ្នាំនេះមានចំនួន ៤៨ នាក់ ខណៈកាលពីឆ្នាំ ២០១៩ មានចំនួន ៧៩ នាក់។ លោក សីលា បញ្ជាក់ថា៖ «បទល្មើសរំលោភបំពានផ្លូវភេទលើកុមារដោយផ្ទាល់មានការថយចុះក្នុងឆ្នាំនេះ ប៉ុន្តែ ការ

រំលោភបំពានតាមប្រព័ន្ធអនឡាញមានការកើនឡើងច្រើន។ បទល្មើសទាំងនោះមានដូចជាការផ្សព្វផ្សាយរូបភាព និង វីដេអូអាសអាភាសរបស់កុមារ និង ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ។ បទល្មើសតាមអនឡាញនេះ សមត្ថកិច្ចមានការលំបាកក្នុងការស្វែងរកជនល្មើស»។

លោក អំ សំអាត នាយករង អង្គការលីកាដូបានថ្លែងនៅថ្ងៃនេះដែរថា តាមការសង្កេត អំពើហិង្សាលើកុមារ ទាំងការរំលោភបំពានផ្លូវភេទនិងអំពើហិង្សាផ្សេងៗទៀត គឺស្ថិតក្នុងក្តីបារម្ភនៅឡើយ។ ពីព្រោះហេតុថាពីមួយឆ្នាំទៅមួយឆ្នាំ បទល្មើសទាំងនេះមិនមានការថយចុះទេ។ លោកថ្លែងថា៖ «ឆ្នាំនេះ អង្គការ លីកាដូ ទទួលបានការស្នើសុំឱ្យជួយទាក់ទងនឹងបញ្ហាអំពើហិង្សាលើកុមារនេះ បើគិតត្រឹម ១០ ខែ យើងមាន ១២៤ ករណីចំនួននេះ បើធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន ក៏មិនសូវខុសគ្នាដែរ។ ដូច្នេះ វានៅតែជាកង្វល់ និងការព្រួយបារម្ភនៅឡើយទេ»៕

## ជាង ៣០០នាក់ ក្នុង ១ថ្ងៃ ត្រូវបានថៃ ចាប់បញ្ជូនតាមច្រកអូរបីជាន់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ២០:១៨ ប៊ុន ធឿន

បន្ទាយមានជ័យ៖ ភាគីថៃ បានចាប់ពលករខ្មែរ បញ្ជូនតាមច្រកអូរបីជាន់ ១ថ្ងៃ ជាង ៣០០នាក់។ ក្នុងចំណោមនោះ ២៣នាក់ ត្រូវបានធ្វើចត្តាឡីស័ក ដោយជាប់សង្ស័យកើតជំងឺកូវីដ១៩ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០២០។ ច្រកព្រំដែនអូរបីជាន់ ស្ថិតឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ បានប្រាប់ថា ចាប់ពីម៉ោង ១២យប់ ដល់ ១១ ព្រឹកថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ ភាគីថៃ បានចាប់បញ្ជូនពលករខ្មែរ តាមច្រកអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ចំនួនជាង ៣០០នាក់ ក្នុងមាន ស្ត្រី ១៥០នាក់។ ក្នុងនោះ មាន ២៣នាក់ (ស្រី៣នាក់ និងកុមារម្នាក់ ) ជាប់សង្ស័យឆ្លងជំងឺកូវីដ១៩ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅមន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែត។ កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ភាគីថៃ បានចាប់បញ្ជូនពលរដ្ឋខ្មែរ តាមច្រកអូរបីជាន់ មានចំនួន ២៩៧នាក់ (ស្រី ១៣៦នាក់ )។

លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា ពលករចំណាកស្រុក ដែលភាគីថៃ ចាប់បញ្ជូនតាមច្រកអូរបីជាន់ ត្រូវបានមន្ត្រីចត្តាឡីស័កកម្ពុជា ចាំទទួល ដែលរួមមានក្រុមគ្រូពេទ្យសហការជាមួយកម្លាំងនគរបាល យោធា កងរាជអាវុធហត្ថ និងកម្លាំងនគរបាលការពារព្រំដែនគោក។ ពលករចំណាកស្រុកទាំងនោះ ត្រូវបានត្រួតពិនិត្យពិនិត្យដោយធ្វើចត្តាឡីស័ក ដោយវាស់កំដៅ ហើយបើសិនជាជាប់សង្ស័យ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែត និងអ្នកដែលមិនជាប់សង្ស័យ ត្រូវធ្វើការអប់រំណែនាំ អោយបញ្ឈប់សកម្មភាពឆ្លងដែន ដោយខុសច្បាប់ ដែលប្រឈមគ្រោះថ្នាក់ ដោយមិនត្រូវចាញ់បោកមេខ្យល់ សុំអោយត្រឡប់ទៅលំនៅដ្ឋានវិញ ត្រូវដោះសំលៀកបំពាក់បោកគក់អោយបានស្អាត និងធ្វើចត្តាឡីស័កខ្លួនឯងរយៈពេល ១៤ថ្ងៃ ដោយមិនអោយក្រុមគ្រួសារមកជិតស្និទ្ធស្នាល និងត្រូវពាក់ម៉ាស់ លាងដៃដោយអាកុលសាប៊ូ អោយបានស្អាតគ្រប់ពេល ដោយអនុវត្តតាមការណែនាំពីក្រសួងសុខាភិបាល ដើម្បីបង្ការ និងទប់ស្កាត់កូវីដ១៩៕ ប៊ុនធឿន

## ជួយសង្គ្រោះនារីខ្មែរម្នាក់នៅប្រទេសចិនបានហើយ! ដែលប្តីចិនបង្ខាំងក្នុងផ្ទះបង្ខំធ្វើបាប

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១៥:២៦

រាជធានីភ្នំពេញ ៖ នៅរសៀលថ្ងៃទី២ ធ្នូ ២០២០នេះ ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជាក់ឲ្យដឹងថា ស្ត្រីជនជាតិខ្មែរម្នាក់ ដែលបានសរសេរសារបង្ហោះលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកថា «នាងត្រូវបានមេខ្យល់ឆបោកឲ្យទៅរៀបការជាមួយប្តីជនជាតិចិន ហើយត្រូវបានគេបង្ខាំងបិទសេរីភាពក្នុងការរស់នៅ និងបានទទូចស្នើសុំឲ្យអាជ្ញាធរកម្ពុជា ជួយអន្តរាគមន៍នាំមកប្រទេស

កម្ពុជា»នោះ ត្រូវបានរកឃើញហើយ និងបានបញ្ជូនទៅអគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសចិន ដើម្បីអនុវត្តនីតិវិធីធ្វើបត្យាប័នមកកម្ពុជាវិញ ។ ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ការទទួលជោគជ័យ ក្នុងការស្រាវជ្រាវស្វែងរកអាសយដ្ឋាន ស្នាក់នៅឯប្រទេសចិនរបស់នារីរងគ្រោះខាងលើ និងបានធ្វើការសង្គ្រោះនោះ គឺបានទទួលកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងអាជ្ញាធរចិន និងអាជ្ញាធរកម្ពុជា ។

សូមរម្លឹកថា កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានទទួលព័ត៌មានពីក្រុមការងារប្រតិកម្មរហ័សរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធនឹងការចុះផ្សាយលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក របស់គណនីឈ្មោះ វាសនាកូនស្រីទី៤ ដោយបានសរសេរខ្លឹមសារបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមថា ពុំមានសេរីភាពក្នុងការរស់នៅ បន្ទាប់ពីចាញ់បោកមេខ្យល់រៀបការប្តីជនជាតិចិន និងទទួចសំណូមពរឲ្យអាជ្ញាធរកម្ពុជាអន្តរាគមន៍ជួយសង្គ្រោះត្រឡប់មករស់នៅប្រទេសកម្ពុជាវិញ។ ក្នុងខ្លឹមសារសំណេរបញ្ជាក់ថា នាងមានឈ្មោះ ធួក សុភី អាយុ ២០ឆ្នាំ នៅភូមិឃ្សឹបក្រៅ ឃុំឃ្សឹបក្រៅ ស្រុកស្នួល ខេត្តក្រចេះ ។

ក្រោយទទួលបានដំណឹងនេះ កម្លាំងជំនាញរបស់នាយកដ្ឋាន បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្តក្រចេះ ធ្វើការស្រាវជ្រាវស្វែងរកឃើញសាច់ញាតិ និងសាកសួរព័ត៌មានលម្អិត ដើម្បីធ្វើការស្រាវជ្រាវ និងកំណត់អត្តសញ្ញាណមេខ្យល់ ព្រមទាំងបានស្របសម្រួល ឲ្យម្តាយនារីរងគ្រោះមកដាក់ពាក្យបណ្តឹងនៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ ដោយឡែក នាយកដ្ឋាន បានសហការជាមួយក្រុមលេខាធិការដ្ឋានមេគង្គឡានឆាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកតម្រុយឈានទៅទីកន្លែងស្នាក់នៅរបស់ជនរងគ្រោះ ។

នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ មន្ត្រីជំនាញរបស់នាយកដ្ឋាន បានបញ្ជូនព័ត៌មានបន្ថែមទៀត រួមមានគណនីហ្វេសប៊ុក ដែលមានអាសយដ្ឋាន អត្តសញ្ញាណបណ្ណប្តីជនជាតិចិន ឲ្យទៅក្រុមការងារលេខាធិការដ្ឋានមេគង្គឡានឆាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីមានមូលដ្ឋានពិតប្រាកដក្នុងការអនុវត្តនីតិវិធីអន្តរាគមន៍សង្គ្រោះ ទើបនៅព្រឹកថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០នេះ អាជ្ញាធរចិនបានឆ្លើយតបថា បានរកឃើញនារីរងគ្រោះ និងបានសង្គ្រោះ ព្រមទាំងបានបញ្ជូនទៅកាន់អគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសចិន ដើម្បីអនុវត្តន៍នីតិវិធីបន្ត ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 02-11-2020

នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៦និង៥០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ ឈាន ដារ៉ា ភេទប្រុ អាយុ ៣២ឆ្នាំ រស់នៅភូមិអណ្តូងឫស្សី ឃុំស្រែថ្មី ស្រុករលាផ្អៀរ ខេត្តកំពង់ឆ្នាំង, ២-ឈ្មោះ ភើម សុនី ភេទប្រុស អាយុ ២៥ឆ្នាំ រស់នៅភូមិទម្លាប់ ឃុំទម្លាប់ ស្រុកគិរីវង្ស ខេត្តតាកែវ, ៣-ឈ្មោះ វង្ស សុខា ភេទស្រី អាយុ ៤០ឆ្នាំ រស់នៅភូមិចាំយាម ឃុំឥដ្ឋប៉ាក់ខ្លង ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង, ៤-ឈ្មោះ ពៅ សេង ភេទប្រុស អាយុ ៣៦ឆ្នាំ រស់នៅភូមិបឹង ឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នក

ដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបរយថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៣នាក់

https://www.facebook.com/GDIOfficial 02-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង១៥នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៣នាក់ ស្រី ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ធ្វើការឃាត់បានប្រជាពលរដ្ឋខ្មែរចំនួន ០២នាក់ ដែលបានធ្វើសកម្មភាពឆ្លងដែនដោយខុសច្បាប់

https://www.facebook.com/GDIOfficial 02-11-2020

បាត់ដំបង៖ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១១និង១០នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ធ្វើការឃាត់បានប្រជាពលរដ្ឋខ្មែរចំនួន ០២នាក់ ដែលបានធ្វើសកម្មភាពឆ្លងដែនដោយខុសច្បាប់ ចេញពីប្រទេសកម្ពុជា ទៅប្រទេសថៃ ក្នុងគោលបំណងដើម្បីទៅរកការងារធ្វើ នៅទីក្រុងបាងកក តាមរបៀងស្លាបស្តាំរបស់ប៉ុស្តិ៍។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការពន្យល់អប់រំណែនាំ ដល់ពួកគាត់ទាំង ០២នាក់ ធ្វើកិច្ចសន្យាបញ្ឈប់ការធ្វើសកម្មភាពឆ្លងដែន ដោយខុសច្បាប់តទៅទៀត និងឈប់ជឿចាញ់បោកមេខ្យល់ រួចអនុញ្ញាតឲ្យពួកគាត់ទាំង ០២នាក់ បានត្រឡប់ទៅកាន់លំនៅដ្ឋានវិញ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៤៤នាក់

https://www.facebook.com/GDIOfficial 02-11-2020

នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ចង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៤៤នាក់ ស្រី ១០០នាក់៕

# ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០២០

## យុទ្ធនាការ១៦ថ្ងៃ: បង្កើនការវិនិយោគដើម្បីទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើស្ត្រីក្នុងបរិបទកូវីដ១៩

https://www.rasmeinews.com/ បញ្ចូលអត្ថបទដោយ Ly Naa 3 December, 2020

**ដោយ: មុនីរ័ត្ន / ភ្នំពេញ:** *យុទ្ធនាការ ១៦ថ្ងៃ គឺចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ក្នុងគោលបំណងបង្កើនការវិនិយោគ ដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើស្ត្រី ក្នុងបរិបទកូវីដ-១៩។ យុទ្ធនាការនេះរៀបចំឡើងដោយក្រសួងកិច្ចការនារីដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី។*

ក្រសួងកិច្ចការនារីបានធ្វើការផ្សព្វផ្សាយឲ្យមានការចូលរួមទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើស្ត្រីពលករចំណាកស្រុក ក្នុងបរិបទកូវីដ១៩ ជាដើម។ គោលបំណងចូលរួមផ្សព្វផ្សាយ ដើម្បីលុបបំបាត់ការរើសអើស និងមាក់ងាយលើស្ត្រីពលករចំណាកស្រុក ឈ្វេងយល់ពីសេវាឆ្លើយតបអំពើហិង្សាលើស្ត្រីពលករចំណាកស្រុក។ សម្រាប់យុទ្ធនាការ១៦ថ្ងៃនេះដែរ មន្ទីរកិច្ចការនារីរាជធានីភ្នំពេញ មានដៃគូសហការជាមួយអង្គការវ៉ៃ ដែលចូលរួមឧបត្ថម្ភនៅក្នុងយុទ្ធនាការនេះ។

ប្រធានមន្ទីរកិច្ចការនារី រាជធានីភ្នំពេញលោកស្រី កាន់រតនៈ ឧប្បល បានមានប្រសាសន៍ថា នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានផ្តោតអាទិភាពលើការកែទម្រង់ និងការលើកកម្ពស់ សមត្ថភាពរបស់ក្រសួង ស្ថាប័ន ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ និងពង្រឹងប្រសិទ្ធភាព ក្នុងការអនុវត្តការងារ។ ភាពចាំបាច់ និងកត្តាជោគជ័យនៃការ អនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ អាស្រ័យលើភាពខ្លាំង រឹងមាំ និងប្រសិទ្ធភាពការងាររបស់ក្រសួងកិច្ចការនារីនិងមន្ទីរកិច្ចការនារី ។ ក្នុងបរិការណ៍នេះ កម្មវិធីអភិវឌ្ឍ សមត្ថភាពស្ថាប័ន ត្រូវធ្វើឡើងដោយឆ្លុះបញ្ចាំងនិងឆ្លើយតបនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃការវិវត្តន៍ និងបរិបទថ្មីៗរបស់សកលលោក និងនៅក្នុងប្រទេស ក៏ដូចជាការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងការធ្វើឌីជីថលភាវូបនីយកម្ម។ លោកស្រី លោកស្រី កាន់រតនៈ ឧប្បល បានបញ្ជាក់ថា យុទ្ធនាការ១៦ថ្ងៃ គោលបំណងសំខាន់ចំបងដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ និងរួមគ្នាទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ។ ជាមួយគ្នានេះ យុទ្ធសាស្ត្រ"នារីរតនៈទី៥" បន្តលើកកម្ពស់សមត្ថភាពរបស់ក្រសួងកិច្ចការ នារី និងអង្គភាពចំណុះ ក្នុងការពង្រឹងភាពស្អាតស្អំផ្នែករដ្ឋបាលសាធារណៈ និងពង្រឹងប្រសិទ្ធភាព ក្នុងការ ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តការងារ ព្រមទាំងពង្រីកយន្តការគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មានឱ្យឆ្លើយតបយេនឌ័រ ប្រកបដោយបរិយាបន្ន។

ការលើកកម្ពស់ការឆ្លើយតបបរិយាបន្ន ដល់ស្ត្រីនិងក្មេងស្រីដែលស្ថិតនៅក្នុងក្រុមដែល មានពិការភាពក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះនៅក្នុងសង្គម ជាកិច្ចការអន្តរវិស័យរបស់ក្រសួង កិច្ចការនារី ដែលជំរុញឱ្យបញ្ជ្រាបនិងមានវិធានការជាក់លាក់នៅតាមអង្គភាព និងយុទ្ធសាស្ត្រនីមួយៗ ព្រម ទាំងលើកទឹកចិត្ត គិត គូរនិងជំរុញឱ្យមាន វិធានការប្រកបដោយសមធម៌នៅក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ ៕

## អាជ្ញាធរថៃដាក់កម្លាំងពិនិត្យតឹងតែងនៅតំបន់ព្រំដែនជាប់កម្ពុជាទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩

https://www.rfa.org/khmer/news/ ដោយ វ៉ែន សុមេធ 2020-12-03

អាជ្ញាធរថៃខេត្តស្រះកែវ (Sra Keao) បានបន្ថែមកម្លាំងត្រួតពិនិត្យនៅតំបន់ព្រំដែនជាប់កម្ពុជា ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩ ក្រោយកម្ពុជាមានជំងឺកូវីដឆ្លងសហគមន៍។ មន្ត្រីសង្គមស៊ីវិលយល់ថា រឿងនេះនឹងធ្វើឱ្យប្រជាពលរដ្ឋនៅតំបន់ព្រំដែនជួបការលំបាកកាន់តែខ្លាំង ដោយសារបាត់បង់មុខរបរកប្រាក់ចំណូលដោះស្រាយជីវភាព។

អាជីវករខ្មែរមានតូបលក់ដូរនៅផ្សាររ៉ុងក្លឿ ប្រទេសថៃ ដែលសុំមិនឱ្យបញ្ចេញឈ្មោះ ថ្លែងនៅរសៀលថ្ងៃទី៣ ធ្នូថា ចាប់ពីច្រកទ្វារអន្តរជាតិប៉ោយប៉ែតដល់ផ្សាររ៉ុងក្លឿ អាជ្ញាធរថៃបានដាក់ប៉ុស្តិ៍យាមយ៉ាងតឹងតែង ៣កន្លែង ដើម្បីត្រួតពិនិត្យពលរដ្ឋខ្មែរ ដែលថៃអនុញ្ញាតឱ្យបើករថយន្តចូលទៅមើលទំនិញក្នុងផ្សារថៃមួយថ្ងៃ ៥០គ្រឿង។ ពលរដ្ឋរូបនេះបន្ថែមថា នៅគ្រប់កន្លែងត្រួតពិនិត្យនោះ មានគ្រូពេទ្យថៃយកឧបករណ៍វាស់កម្តៅ ដល់អ្នកធ្វើដំណើរ និងបាញ់ថ្នាំនៅលើកង់ឡានសម្លាប់មេរោគជាដើម៖ «និយាយវាមិនឱ្យយើងដើររហេតរហូតទេ ហើយបើពីណាអត់ពាក់ម៉ាស់អី ផាកលុយម្នាក់ ៥៣ន់បាត (៥.០០០)។ ដល់អីចឹង អ្នកណាក៏ពាក់ម៉ាស់ដែរ។ បានគេបើកឱ្យឡានខ្មែរចូល ៥០គ្រឿង ពួកខ្ញុំចូលទៅរកលុយបានតក់ៗ ខ្លះ បានអ្នកស្គាល់គ្នាគេធ្វើអីវ៉ាន់គ្រាន់បានលុយទិញម្ហូបខ្លះ ហើយ ឥឡូវនៅក្នុងគេធ្វើបាបយើង មិនឱ្យយើងដឹកអីវ៉ាន់រញ៉េរញ៉ៃទៀត»។ លោកស្រីឱ្យដឹងថា អាជ្ញាធរថៃព្រមាននឹងបិទ មិនឱ្យរថយន្តរបស់ខ្មែរចូលទៅក្នុងផ្សាររ៉ុងក្លឿនោះទេ ប្រសិនបើថៃរកឃើញពលរដ្ឋខ្មែរណាម្នាក់ឆ្លងជំងឺកូវីដ១៩។

ទូរទស្សន៍ថៃ ភីប៊ីអេស (Thai PBS) បានផ្សាយកាលពីថ្ងៃទី៣០ វិច្ឆិកាឱ្យដឹងថា អាជ្ញាធរថៃបានបន្ថែមកម្លាំងទាហានជាច្រើននាក់យាមការពារយ៉ាងតឹងតែងទាំងយប់ទាំងថ្ងៃ នៅតំបន់ព្រំដែនជាប់ខេត្តបន្ទាយមានជ័យ ដើម្បីទប់ស្កាត់ពលករខ្មែរលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់។ ប្រភពដដែលបន្ថែមថា ការធ្វើបែបនេះ ដើម្បីបង្ការកុំឱ្យមានការរាតត្បាតជំងឺកូវីដ១៩ បន្ទាប់ពីជំងឺនេះបានឆ្លងចូលនៅក្នុងសហគមន៍នៅកម្ពុជា។

ទាក់ទងនឹងបញ្ហានេះ ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់អាស៊ីសេរីថា ការរឹតបន្តឹងនេះអាជ្ញាធរថៃបានសហការគ្នាជាមួយសមត្ថកិច្ចរបស់កម្ពុជាបានអនុវត្តជាច្រើនខែមកហើយ គឺពុំមែនទើបតែអនុវត្តពេលមានឆ្លងជំងឺកូវីដនៅក្នុងសហគមន៍នោះទេ។ លោកបន្ថែមថា អំឡុងពេលនេះថៃក៏នៅតែបន្តចាប់ពលករខ្មែរប្រគល់មកឱ្យអាជ្ញាធរកម្ពុជាផងដែរ។ លោកប្រាប់ថា កាលពីថ្ងៃទី២ ធ្នូ សមត្ថកិច្ចថៃបានចាប់ពលករខ្មែរជាង ១០០នាក់បញ្ជូនត្រឡប់មកកម្ពុជាវិញតាមតាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យ៖ «តឹងរ៉ឹងទាំងខ្មែរទាំងថៃអីតឹងទាំងអស់គ្នា។ បាទគេតឹងរ៉ឹងទាំងអស់ គេខ្លាចខ្មែរយើងលួចចូលទៅ។ វាគ្រប់សព្វហ្នឹងឯង តាំងពីយើងផ្ទុះជំងឺកូវីដមក»។

ប្រធានសមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា លោក ឱន ពុទ្ធី មានប្រសាសន៍ថា ចាប់តាំងពីអាជ្ញាធរថៃបិទច្រកទ្វារព្រំដែនជាប់កម្ពុជាមកបានប៉ះពាល់ដល់ការរកប្រាក់ចំណូលរបស់ពលរដ្ឋនៅតំបន់ព្រំដែន។ លោកបន្តថា ការរឹតបន្តឹងព្រំដែននៅពេលថ្មីៗ នេះនឹងប៉ះពាល់ពលរដ្ឋកាន់តែខ្លាំងជាពិសេសអ្នកដែលមានតូបលក់ដូរនៅក្នុងប្រទេសថៃ និងពលរដ្ឋដែលស៊ីឈ្នួលលីសែងទំនិញឱ្យថៃធ្វើឱ្យបាត់បង់ប្រាក់ចំណូល៖ «ចង់និយាយថាការបិទច្រកនេះការប៉ះពាល់មានវិសាលភាពធំធេងណាស់សម្រាប់កម្មករនៅក្នុងប៉ោយប៉ែតនេះ គឺប៉ះពាល់ធ្ងន់មែនទែន។ ជីវភាពហ្នឹងគឺកាន់តែយ៉ាប់ទៅ ឥឡូវវាមហាសែនវេទនាដូចមមាចត្រូវភ្លើងអីចឹង។ ដូចខ្ញុំអីឥឡូវខ្ញីលុយគេចាយ ឥឡូវនិយាយអត់កើតទេ និយាយពីទុក្ខ លំបាករបស់ប្រជាពលរដ្ឋហ្នឹង វាវេទនាមែនទែន មិនដឹងថានិយាយយ៉ាងម៉េចកើត បើនិយាយទៅគឺនៅដដែលអីចឹង»។

អាជ្ញាធរថៃបានបិទច្រកព្រំដែនជាប់កម្ពុជាចាប់តាំងពីចុងខែមីនា ដើម្បីទប់ស្កាត់កុំឱ្យឆ្លងជំងឺកូវីដ១៩ ហើយមកទល់ថ្ងៃទី៣ ធ្នូ មិនទាន់បើកដំណើរការឡើងវិញនៅឡើយទេ។ បច្ចុប្បន្នអាជ្ញាធរកម្ពុជា និងថៃបានអនុញ្ញាតឱ្យចំពោះតែរថយន្តដឹកទំនិញ និងអ្នកបើកបរ ២នាក់ក្នុងរថយន្តមួយគ្រឿងអាចចេញចូលតាមច្រកទ្វារព្រំដែនប្រទេសទាំងពីរបានជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៨នាក់

https://www.facebook.com/GDIOfficial 03-11-2020

នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៨នាក់ ស្រី ៦០នាក់៕

## ផ្ទះសម្ពពក្លែងក្លាយបង្ខាំងស្ត្រីទុកឲ្យបុរសរំលោភយកកូនលក់

http://kampucheathmey.com/ December 3, 2020 By Sok Sovann

កាលពីថ្ងៃអង្គារ ប៉ូលិសបានវាយឆ្មក់ "រោងចក្រផលិតកូន" នីហ្សេរីយ៉ាមួយកន្លែងដែលនៅទីនោះ បុរសត្រូវបានគេជួលដើម្បីធ្វើឲ្យស្ត្រីមានកូនមុនពេលកូនទាំងនោះត្រូវបានគេលក់។ ជនរងគ្រោះចំនួន១០នាក់ត្រូវបានជួយសង្គ្រោះ។

អ្នកនាំពាក្យម្នាក់បាននិយាយកាលពីថ្ងៃពុធថា ប៉ូលិសបានជួយសង្គ្រោះកុមារ៤នាក់និងស្ត្រី៦នាក់ដែលក្នុងនោះមាន៤នាក់មានផ្ទៃពោះ ចេញពីផ្ទះសម្ពពខុសច្បាប់មួយកន្លែង។ ប្រតិបត្តិការនេះត្រូវបានធ្វើឡើងនៅទីតាំងដែលគេហៅថា "រោងចក្រផលិតកូន" នៅភាគនិរតីរដ្ឋ Ogun ដោយស្ត្រីម្នាក់កំពុងជាប់ចោទពីបទជួញដូរមនុស្សរួចទៅហើយ។ អ្នកនាំពាក្យប៉ូលិសលោក Abimbola Oyeyemi បានប្រាប់ទីភ្នាក់ងារសារព័ត៌មាន AFP ថា "ដោយធ្វើសកម្មភាពតាមការឲ្យតម្រុយ ក្រុមរបស់យើងបានវាយឆ្មក់ចូលផ្ទះសម្ពពខុសច្បាប់មួយកន្លែង និងបានជួយសង្គ្រោះមនុស្សចំនួន១០នាក់ដោយក្នុងនោះមានក្មេង៤នាក់និងស្ត្រី៦នាក់ដែល៤នាក់មានផ្ទៃពោះ"។ គាត់និយាយថា ស្ត្រីទាំងនោះបានប្រាប់ប៉ូលិសថា ម្ចាស់ផ្ទះបានជួលបុរសមកធ្វើឲ្យពួកគេមានផ្ទៃពោះហើយបន្ទាប់មកលក់កូនដែលទើបនឹងកើតដើម្បីយកប្រាក់ចំណេញ។ ទីតាំងបែបនេះច្រើនតែជាកន្លែងខុសច្បាប់ដោយក្លែងធ្វើជាគ្លីនិកឯកជនដែលមានស្ត្រីមានផ្ទៃពោះហើយបង្កើតកូនសម្រាប់លក់។ ក្នុងករណីខ្លះ ស្ត្រីវ័យក្មេងត្រូវបានគេឃុំឃាំងប្រឆាំងនឹងឆន្ទៈរបស់ពួកគេហើយចាប់រំលោភមុនពេលកូនរបស់ពួកគេត្រូវបានលក់នៅលើទីផ្សារងងឹត៕ ប្រែសម្រួលដោយ៖ Vann Vann ប្រភព៖ Daily Mail

# ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០២០

## ពលករខេត្តបាត់ដំបង ដែលវិលពីថៃទទួលបានការបណ្តុះបណ្តាល ជំនាញកសិកម្ម និងមុខរបរ

http://btv.com.kh/ 04/12/2020

បាត់ដំបង ៖ ពលករនៅក្នុងខេត្តបាត់ដំបង ដែលបាត់បង់ការងារធ្វើ និងមិនអាចត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ បាន ដោយសារវិបត្តិកូវីដ–១៩ ត្រូវបានបណ្តុះបណ្តាលជំនាញ កសិកម្ម និងចំណេះដឹងក្នុងការបើក និង ពង្រីកមុខរបរផ្សេងៗ ពីអាជ្ញាធរខេត្ត ក្រោមជំនួយឧបត្ថម្ភគាំទ្រពីអង្គការអោយអូអិម (IOM) ។

ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ក្នុងស្រុកសង្កែ កាលពីថ្ងៃទី០៣ ខែធ្នូម្សិលមិញ លោកស្រី ស៊ុំ ចិន្តា អភិបាលរង ខេត្តបាត់ដំបង ទទួលបន្ទុកការងារពលករ បានឱ្យដឹងថា ការផ្តល់នូវចំណេះដឹងផ្នែកកសិកម្ម និងមុខរបរ ដល់ពលករ គឺស្ថិតក្នុងគម្រោងក្រោមកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីឆ្លើយតបនឹងវិបត្តិកូវីដ–១៩ លើផ្នែកសេដ្ឋកិច្ច និងសង្គម តាមរយៈគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ លោកស្រី បានបញ្ជាក់ថា ពលករ និងពលរដ្ឋក្រីក្រ ត្រូវបានបណ្តុះបណ្តាលពីការចិញ្ចឹមមាន់ និង ដាំបន្លែ ហើយចំពោះជំនាញប្រកបមុខរបរនេះ សម្រាប់តែពលរដ្ឋជាពលករ មានមុខរបរលក់ដូរស្រាប់ ហើយក្នុងលក្ខណៈទ្រង់ទ្រាយតូច ឱ្យមានចំណេះដឹងសហគ្រិនភាពបន្ថែមទៀត។

ការចូលរួមជាមួយរាជរដ្ឋាភិបាល ជួយដោះស្រាយបញ្ហាជីវភាពពលរដ្ឋក្រីក្រ ស្ត្រីមេម៉ាយ ជនពិការ និងពលករខ្មែរដែលបានបាត់បង់ការងារធ្វើ ក្នុងដំណាកកាលវិបត្តិកូវីដ–១៩ នៅក្នុងខេត្តបាត់ដំបងនេះ ក៏ មានអង្គការដៃគូជាច្រើនទៀត បានបង្រៀននូវជំនាញដល់កសិករ ក៏ដូចជា ការផ្តល់នូវពូជមាន់ ពូជសត្វ ចិញ្ចឹមផ្សេងៗ និងគ្រាប់ពូជដំណាំជាបន្តបន្ទាប់ ខណៈការផ្តល់សាច់ប្រាក់ដល់ពលរដ្ឋក្រីក្រក្នុងខេត្ត ទទួល ផលប៉ះពាល់ពីវិបត្តិជំងឺដ៏កាចសាហាវនេះ មានជាង៧ម៉ឺនគ្រួសារ ៕ អត្ថបទ៖ បាន សុខរិទ្ធ

## អង្គការ ១ បង្ហាញថា ក្មេងប្រុសរងគ្រោះពីអំពើអាសអាភាសជាង ២០ នាក់ទទួលបាន សំណងជំងឺចិត្តជាង $១ ម៉ឺន

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 04 December 2020 | 09:49 ICT

**សៀមរាប:** ក្មេងប្រុសរងគ្រោះពីការប្រព្រឹត្តសកម្មភាពអាសអាភាសចំនួន ២២ នាក់នៅខេត្តសៀមរាបបានទទួលសំណងរដ្ឋប្បវេណីចំនួន ១១ ០០០ ដុល្លារអាមេរិក បន្ទាប់ពីជនល្មើសដែលបានប្រព្រឹត្តលើពួកគេ បានអនុវត្តទោសរួចរាល់ ដែលនេះជាការទទ្ទឹងរង់ចាំយុត្តិធម៌របស់ជនរងគ្រោះអស់ជាច្រើនឆ្នាំ។ នេះបើតាមអង្គការ APLE កម្ពុជាឱ្យដឹងកាលពីថ្ងៃពុធ។

សេចក្តីប្រកាសព័ត៌មានរបស់អង្គការនេះឱ្យដឹងកាលពីថ្ងៃទី ២ ធ្នូ ថានៅថ្ងៃទី ២៦ វិច្ឆិកា ក្មេងរងគ្រោះចំនួន ២២ នាក់បានទទួលសំណងជំងឺចិត្តរយៈពេល ៣ ឆ្នាំ បន្ទាប់ពីឈ្នះក្តីនៅតុលាការក្នុងសំណុំរឿង ដែលបុរសជនជាតិហូឡង់បានប្រព្រឹត្តអំពើអាសអាភាសលើកុមារទាំងនោះកាលពីឆ្នាំ ២០១៧។ អង្គការ APLE និយាយថាលោក អេវ៉ារ៉ាដ នីកូឡាស សារ៉ូត (Evrard-Nicolas Sarot) អាយុ ៥៤ ឆ្នាំគឺជាបព្វជិតសាសនា ១ រូបដែលត្រូវបានតុលាការខេត្តសៀមរាបសម្រេចផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ៥ ឆ្នាំកាលពីឆ្នាំ ២០១៨។ បុរសរូបនេះត្រូវផ្តល់សំណងជំងឺចិត្តចំនួន ១១ ០០០ ដុល្លារទៅឱ្យក្មេងប្រុសរងគ្រោះទាំង ២២ នាក់ដោយយោងតាមមាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

មេធាវីការពារក្តីកុមាររងគ្រោះរបស់អង្គការ APLE និយាយថា ដំណើរការនៃការរង់ចាំយុត្តិធម៌របស់ក្មេងរងគ្រោះ និងដើមបណ្តឹងគឺមានរយៈពេលយូរ ហើយមានការលំបាកណាស់។ លោកបន្តថាការផ្តន្ទាទោស និងការសងសំណងជំងឺចិត្តនេះគឺមានសារៈសំខាន់សម្រាប់ស្រោចស្រង់ជនរងគ្រោះឱ្យបានល្អប្រសើរ ដូចអ្វីដែលពួកគេទន្ទឹងរង់ចាំនូវយុត្តិធម៌។

បន្ទាប់ពីទទួលបានសំណងរដ្ឋប្បវេណីម្តាយក្មេងប្រុសរងគ្រោះម្នាក់សុំមិនឱ្យបញ្ចេញឈ្មោះនិយាយថា តាមរយៈសំណងជំងឺចិត្តនេះ គឺមិនអាចជួសជុសការខូចខាតរបស់កូនប្រុសខ្លួនបាននោះទេ។ សំណងជំងឺចិត្តទាំងនេះក៏មិនមានចំនួនច្រើនណាស់ណានោះដែរ។ អ្នកស្រីថា៖«លុយទាំងនេះគឺនឹងអាចប្រើប្រាស់សម្រាប់គាំទ្រដល់ការរៀនសូត្រ និងសម្រាប់គាំទ្រដល់ការរស់នៅប្រចាំថ្ងៃក្នុងរយៈពេលខ្លីប៉ុណ្ណោះ ដែលវាមិនអាចជួសជុលផលប៉ះពាល់ដែលធ្លាក់មកកូនរបស់ខ្ញុំបានច្រើននោះទេ»។

តាមអង្គការ APLE ជនល្មើសដែលប្រព្រឹត្តអំពើអាសអាភាសមកលើកុមាររងគ្រោះទាំង ២២ នាក់នេះ ត្រូវបានរកឃើញផលិតរូបភាពអាសអាភាសរបស់ក្មេងៗ។ ករណីនេះបានកើតឡើងតាំងពីឆ្នាំ ២០១៧ នៅពេលដែលក្មេងប្រុសស្ថិតក្រោមអាយុ ១៥ ឆ្នាំទាំងអស់នោះត្រូវបានជួយសង្គ្រោះដោយប៉ូលិសតាមរយៈការសហការជាមួយអង្គការ APLE បន្ទាប់ពីទទួលបានសេចក្តីរាយការណ៍ពីសមាជិកសហគមន៍នៅក្នុងខេត្តសៀមរាបជាទីកន្លែងដែលជនល្មើសប្រព្រឹត្តបទល្មើស។ អង្គការបញ្ជាក់ថា៖ «ក្នុងពេលនោះសមត្ថកិច្ចបានរកឃើញរូបថតកុមារអាក្រាតកាយជាច្រើននៅក្នុងឧបករណ៍អេឡិចត្រូនិករបស់ជនល្មើស។ ក្មេងៗទាំងនោះក៏ត្រូវបានបញ្ជូនទៅទទួលការព្យាបាល និងបានដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ក្នុងករណីនេះចាប់តាំងពីឆ្នាំ ២០១៨»។

លោក ខឹម វ៉ាន់ដូ អ្នកឯកទេសការពារកុមារនៃអង្គការ APLE ប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញ ថាក្នុងអំឡុងពេលនេះជនល្មើសបានអនុវត្តទោសរួចរាល់ ហើយក៏មិនបានបន្តនៅក្នុងប្រទេសកម្ពុជាទៀតនោះដែរ។ លោករីករាយដែលកុមាររងគ្រោះទទួលបានសំណងជំងឺចិត្ត ប៉ុន្តែករណីមួយចំនួន ជនរងគ្រោះមិនបានទទួលសំណងជំងឺចិត្តទាល់តែសោះ ក្រៅតែពីជនល្មើសទទួលទោសជាប់ពន្ធនាគារ។ លោកថ្លែងថា៖ «នៅពេលនេះ កុមាររងគ្រោះទាំងនោះ គឺបន្តរស់នៅក្នុងសហគមន៍របស់គាត់ជាធម្មតាដដែលទេ។ ក្មេងមួយចំនួនបានបន្តការសិក្សារបស់ពួកគាត់ជាធម្មតា ហើយក្មេងមួយចំនួនក៏បានជួយដល់គ្រួសារពួកគេ នៅក្នុងការប្រកបរបររកស៊ីប្រចាំថ្ងៃ»។ ករណីនេះលោក វ៉ាន់ដូ រំពឹងថាគ្រប់ជនរងគ្រោះជាពិសេសកុមារដែលទទួលរងពីអំពើបំពានផ្សេងៗគួរតែទទួលបានយុត្តិធម៌៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ចំនួន ១៨០នាក់

https://www.cen.com.kh/archives/ December 7, 2020

ព្រំដែនអន្តរជាតិអូរស្មាច់ ៖ បើទោះបីជាភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្នក្តី ក៏នៅថ្ងៃអាទិត្យមាន ពលរដ្ឋខ្មែរ ចំនួន ១៨០នាក់ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ។ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែងទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨០នាក់ ស្រី ៨១នាក់៕ **រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ**

## លោកស្រី ស៊ុំ ចិន្ដា អញ្ជើញសំណេះសំណាល និងនាំយកអំណោយរបស់ KOICA តាមរយៈអង្គការ IOM ចែកជូនប្រជាពលករ ក្នុងគម្រោងស្តារជីវភាពពលករ និងគ្រួសារ នៅសាលាស្រុកសង្កែ ខេត្តបាត់ដំបង

https://www.battambang.gov.kh/ ថ្ងៃសៅរ៍, 5 ខែធ្នូ, 2020 ដោយ Sotheavy

នៅថ្ងៃសៅរ៍ ៥រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០ លោកស្រី ស៊ុំ ចិន្ដា អភិបាលរង នៃគណៈអភិបាលខេត្ត តំណាង ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង អញ្ជើញសំណេះសំណាលជាមួយពលករដែលបានជ្រើសរើសជាគោលដៅអ្នកទទួលផលគម្រោងស្តារជីវភាពពលករ និងគ្រួសារ ដើម្បីទទួលបានអំណោយពី KOICA តាមរយៈអង្គការ IOM ចែកជូនដល់ពលករចំនួន ៥១ គ្រួសារ នៅសាលាស្រុកសង្កែ ខេត្តបាត់ដំបង ។ គម្រោងស្តារជីវពលករ និងគ្រួសារ ត្រូវបានអនុវត្តដោយលេខាធិការគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយគាំទ្រថវិកាពីអង្គការ IOM ដោយធ្វើការជ្រើសរើសយកឃុំគោលដៅចំនួន ២ រួមមាន ៖ ឃុំវត្តតាមិម ឃុំអន្លង់វិល និងភូមិចំនួន ១២ ភូមិ ដោយបានធ្វើការសម្ភាសន៍ជ្រើសរើសគ្រួសារដែលមានពលករក្នុងវិបត្តិកូវីដ ១៩ បានចំនួន ៥១ គ្រួសារ និងបានធ្វើការបណ្ដុះបណ្ដាលលើជំនាញបច្ចេកទេសចិញ្ចឹមមាន់ ដាំបន្លែ និងមុខរបរខ្នាតតូចផងដែរ ។ គួសបញ្ជាក់ផងដែរថា នៅក្នុងគម្រោងស្តារជីវភាពពលករ និងគ្រួសារ និងផ្តល់ជាពូជមាន់ គ្រាប់ពូជបន្លែ និងដើមទុនមួយចំនួនសម្រាប់បង្កើតមុខរបរខ្នាតតូចសម្រាប់ពួកគាត់នៅក្នុងបរិបទវិបត្តិកូវីដ ១៩ នេះ៕

## កិច្ចប្រជុំពិភាក្សាការងារត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២០

https://grandnewsasia.com/ ថ្ងៃសុក្រ ទី ៤ ធ្នូ ២០២០

កោះកុង÷ លោក ស្រេង ហុង អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកោះកុង បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២០ ដោយមានការចូលរួមពីតំណាងមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ នៅសាលប្រជុំ (ក) សាលាខេត្តកោះកុង។

ថ្លែងក្នុងកិច្ចប្រជុំនេះ លោក ស្រេង ហុង បានមានប្រសាសន៍ថា ដោយសារបញ្ហាជំងឺកូវីដ-១៩ ជាពិសេសនាពេលថ្មីៗនេះ មានបញ្ហាផ្ទុះឡើង នូវព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា ធ្វើឱ្យការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២០ នៅខេត្តកោះកុង ត្រូវពន្យារពេល តែទោះជាយ៉ាងណា នឹងរៀបចំទិវានេះនៅពេលស្ថានភាពនៃជំងឺនេះមានភាពធូរស្បើយ និងមានការឯកភាពពីលោកស្រីអភិបាលខេត្តកោះកុង។ លោកបានមានប្រសាសន៍បន្ថែមទៀតថា ការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២០ នឹងរៀបចំឱ្យមានពិធីប្រកាសសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកោះកុង សមាសភាពក្រុមការងារអន្តរមន្ទីរ អង្គភាព សម្រាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាសភាពរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) និងពិធីចែកប័ណ្ណសសើរ ដល់មន្ទីរ អង្គភាព រួមគ្នាតែម្តង។ ជាមួយគ្នានេះ លោកបានស្នើឱ្យសមាជិកអង្គប្រជុំទាំងអស់ពិនិត្យកិច្ចការដែលត្រូវធ្វើ និងត្រៀមលក្ខណៈឱ្យបានល្អិតល្អន់សម្រាប់ការចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២០ នេះ៕

## សមត្ថកិច្ចចាប់ខ្លួនជនជាតិចិនចំនួន ៤ នាក់ សង្ស័យថា ជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស

https://www.rfa.org/khmer/news/  ហេង រស្មី 2020-12-05

សមត្ថកិច្ចបានឃាត់ខ្លួនមនុស្សចំនួន៦ នាក់ ក្នុងនោះមានជនជាតិចិន ចំនួន ៤ នាក់ និងពីរនាក់ផ្សេងទៀត ជាជនជាតិវៀតណាម និងជនជាតិថៃ កាលពីថ្ងៃទី ៥ ធ្នូ កន្លងទៅនេះ ក្រោយពីបានសម្រុកចូលបង្ក្រាបទីតាំងហាងម៉ាស្សាមួយកន្លែង មានទីតាំងនៅក្នុងខណ្ឌសែនសុខ ក្រុងភ្នំពេញ ។ គេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិ បានផ្សាយថា សមត្ថកិច្ចសង្ស័យថា ទីតាំងម៉ាស្សា នេះជាប់ពាក់ព័ន្ធនិងការជួញដូរមនុស្ស ប៉ុន្តែមិនបានបញ្ជាក់លម្អិត ថាករណីនេះជាប់ពាក់ព័ន្ធយ៉ាងណានោះទេ។

ស្នងការរងប៉ូលិសក្រុងភ្នំពេញ ទទួលផែនការជួញដូរមនុស្ស លោក ចាន់ កិត្តិខុម មានប្រសាសន៍នៅក្នុងគេហទំព័ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិថា សមត្ថកិច្ចកំពុងរកអ្នកជួយបកប្រែភាសាចិន ដោយសារតែមានអតិថិជនម្នាក់បានចូលមករកសេវាផ្លូវភេទ ហើយសមត្ថកិច្ចក៏បានរកឃើញស្រោមអនាម័យដែលប្រើរួចចំនួនពីរផងដែរ។ សមត្ថកិច្ចបានឱ្យដឹងថា ក្នុងចំណោមជនសង្ស័យដែលត្រូវឃាត់ខ្លួននោះ មានស្ត្រីចំនួន ៥ នាក់ និងមនុស្សម្នាក់ មានអាយុចាប់ពី២៨ ឆ្នាំ រហូតដល់ ៤៧ ឆ្នាំ ហើយជនសង្ស័យត្រូវសមត្ថកិច្ចនាំខ្លួនមកឃុំឃាំងបណ្ដោះអាសន្ននៅស្នងការប៉ូលិសក្រុងភ្នំពេញដើម្បីរង់ចាំជំនុំជម្រះទោស។

ទាក់ទិននឹងរឿងបទល្មើសប្រព្រឹត្តដោយជនជាតិបរទេសនេះផងដែរ ស្នងការប៉ូលិសខេត្តព្រះសីហនុលោក ជួន ណារិន ប្រាប់អាស៊ីសេរីថា តុលាការបានសម្រេចឃុំខ្លួនជនជាតិចិនចំនួន ៣ នាក់ ពីបទមនុស្សឃាតដោយចេតនាមានស្ថានទម្ងន់ទោស ដែលបានប្រព្រឹត្តកាលពីថ្ងៃទី ២៨ ខែវិច្ឆិកា នៅក្នុងខេត្តព្រះសីហនុ។ សមត្ថកិច្ចខេត្តព្រះសីហនុ កាលពីថ្ងៃទី ១ ធ្នូ បានចាប់ខ្លួនជនជាតិចិនចំនួន៣ នាក់ ក្នុងនោះមានស្ត្រីម្នាក់ ជាប់ពាក់ព័ន្ធនឹងករណីឃាតកម្ម ទៅលើជនជាតិចិនដូចគ្នា រួចហើយយកសាកសពមកប្លុងចោលនៅក្នុងរថយន្ត។ លោក ថាជនសង្ស័យទាំង៣ នាក់ ជាសន្តិសុខ កាស៊ីណូមួយកន្លែង នៅក្នុងសង្កាត់លេខ ៤ ក្រុងព្រះសីហនុ ហើយស្ត្រីម្នាក់ក្នុងចំណោមជនសង្ស័យ អ្នកគ្រប់គ្រងបុគ្គលិកជនជាតិចិន នៅក្នុងកាស៊ីណូជាមួយគ្នា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១១នាក់

https://www.facebook.com/GDIOfficial 06-12-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង៤២នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១១នាក់ ស្រី ០៧នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែនមិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨០នាក់

https://www.facebook.com/GDIOfficial 06-12-2020

នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨០នាក់ ស្រី ៨១នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៦នាក់

https://www.facebook.com/GDIOfficial 05-12-2020

នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៦នាក់ ស្រី ៣២នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០២នាក់

https://www.facebook.com/GDIOfficial 04-12-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង១៥នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០២នាក់ ស្រី ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៥នាក់

https://www.facebook.com/GDIOfficial 04-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៥នាក់ ស្រី ៤២នាក់ រួមទាំងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០២នាក់ ស្រី ០១នាក់ និងបានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានសហការជាមួយសមត្ថកិច្ចថៃ ទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ដែលបានឆ្លងដែនដោយខុសច្បាប់

https://www.facebook.com/GDIOfficial 04-12-2020

នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១១និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានសហការជាមួយសមត្ថកិច្ចថៃ ទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ដែលបានឆ្លងដែនដោយខុសច្បាប់ ទៅរកការងារធ្វើនៅប្រទេសថៃ ដើម្បីត្រឡប់មកប្រទេសកម្ពុជាវិញ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរនេះមានឈ្មោះ អេល សីហា ភេទប្រុស អាយុ ៣៤ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអរជ្រៅ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានសហការជាមួយមន្ត្រីចត្តាឡីស័ក ធ្វើការពិនិត្យកំដៅនឹងស្រង់ព័ត៌មានរបស់គាត់ និងបានធ្វើលិខិតប្រគល់-ទទួល ពលរដ្ឋខាងលើនេះ ឲ្យទៅមន្ត្រីចត្តាឡីស័ក ចប់សព្វគ្រប់នៅវេលាម៉ោង ១២និង០០ នាទី នាថ្ងៃខែឆ្នាំដដែល ដើម្បីអនុវត្តតាមជំនាញបន្ត៕

# ថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ២០២០

## ពលរដ្ឋខ្មែរជាង ២០០ នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់មកប្រទេសវិញ ដោយការឆ្លងដែនខុសច្បាប់

https://www.postkhmer.com/ សុទ្ធ គឹមសឿន | Publication date 08 December 2020 | 10:18 ICT

**បន្ទាយមានជ័យ:** អាជ្ញាធរប្រទេសថៃ បានបញ្ជូនពលរដ្ឋខ្មែរចំនួន ២៣៤ នាក់ ឱ្យត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី ៥ និងទី ៦ ខែធ្នូ តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ខណៈរយៈពេល ៩ ខែឆ្នាំនេះថៃបញ្ជូនពលរដ្ឋខ្មែរ ៥៥ ៦១១ នាក់ ឱ្យត្រឡប់មកវិញ បន្ទាប់ពីពួកគេលួចឆ្លងដែន និងចាញ់បោកមេខ្យល់ទៅរកការងារដោយខុសច្បាប់។ នេះបើតាមរបាយការណ៍ពីម្សិលមិញ។

តាមរបាយការណ៍របស់រដ្ឋបាលស្រុកអូរជ្រៅបានឱ្យដឹងពីម្សិលមិញថា ក្នុងចំណោមពលរដ្ឋខ្មែរចំនួន ២៣៤ នាក់នោះ គឺមានស្រីចំនួន ១២០ នាក់។ ពួកគេមួយចំនួនចាញ់បោកមេខ្យល់នាំទៅរកការងារធ្វើដោយខុសច្បាប់ និងមួយចំនួនទៀតលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារនៅក្នុងប្រទេសថៃ។ របាយការណ៍បន្តថា រយៈពេល ៩ ខែក្នុងឆ្នាំនេះ ដោយគិតចាប់ពីដើមខែមេសារហូតដល់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០២០ អាជ្ញាធរប្រទេសថៃ បានចាប់

ប្រជាពលរដ្ឋខ្មែរចំនួន ៥៥ ៦១១ នាក់ (ស្រី ២៥ ១៥១ នាក់) បញ្ជូនត្រឡប់មកប្រទេសកម្ពុជា វិញតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោក លី សុវណ្ណរិទ្ធ អភិបាលស្រុកអូរជ្រៅឱ្យដឹងពីម្សិលមិញថា ពលករខ្មែរចំណាកស្រុកដែលភាគីថៃចាប់បញ្ជូនមកវិញតាមច្រកអូរបីជាន់នេះត្រូវបានមន្ត្រីជំនាញរង់ចាំទទួលឱ្យធ្វើចត្តាឡីស័ក ដោយមានក្រុមគ្រូពេទ្យសហការជាមួយកម្លាំងនគរបាល យោធា កងរាជអាវុធហត្ថ និងកម្លាំងនគរបាលការពារព្រំដែនគោកធ្វើការពិនិត្យដោយវាស់កម្ដៅ និងសាកសួរព័ត៌មានពាក់ព័ន្ធមួយចំនួនទៀត។ បើតាមលោកអភិបាលស្រុក ប្រសិនបើមានកម្ដៅខ្ពស់ត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែតបន្ទាន់។ ចំណែកអ្នកដែលមិនមានបញ្ហាសុខភាពត្រូវធ្វើការអប់រំណែនាំឱ្យបញ្ឈប់សកម្មភាពលួចឆ្លងដែនដោយខុសច្បាប់ ព្រោះប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ដោយមិនត្រូវស្ដាប់តាមការញុះញង់របស់មេខ្យល់ទៀតទេ។ លោក សុវណ្ណរិទ្ធ បញ្ជាក់ថា៖ «យើងបានណែនាំពួកគាត់ឱ្យដោះសម្លៀកបំពាក់បោកគក់ឱ្យបានស្អាត និងធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ ដោយមិនឱ្យក្រុមគ្រួសារមកជិតស្និទ្ធស្នាល ឬអ្នកដទៃទេ មុនពេលអនុញ្ញាតឱ្យពួកគាត់ត្រឡប់ទៅស្រុកកំណើតវិញ»។ លោកបានបន្ថែមថា៖ «ជាមួយនេះ យើងឱ្យគាត់ត្រូវពាក់ម៉ាស់ លាងដៃដោយអាល់កុល សាប៊ូឱ្យបានស្អាតគ្រប់ពេល ដោយអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលដែលកាតព្វកិច្ចនេះជាការបង្ការ និងទប់ស្កាត់កូវីដ ១៩»។

ដោយឡែកខេត្តឧត្តរមានជ័យមានច្រកទ្វារព្រំដែនអន្តរជាតិ ៣ ជាមួយប្រទេសថៃរួមមានច្រកទ្វារព្រំដែនអន្តរជាតិជប់គគីរ ច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ និងច្រកទ្វារព្រំដែនអន្តរជាតិជាំ។ បើតាមលោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ គឺប្រជាពលរដ្ឋខ្មែរមួយចំនួនតែងតែឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ប៉ុន្តែពលរដ្ឋខ្មែរមួយចំនួនឆ្លងដែនដោយខុសច្បាប់។ លោកអភិបាលខេត្តថ្លែងថា៖ «ពលរដ្ឋខ្មែរយើងមួយចំនួនដែលព្យាយាមឆ្លងដែនទៅថៃទាំងខុសច្បាប់ គឺអាជ្ញាធរថៃគេចាប់បញ្ជូនមកវិញតាមច្រកអន្តរជាតិទាំង ៣ នេះ ប៉ុន្តែខ្ញុំមិនទាន់មានរបាយការណ៍ប្រចាំខែលម្អិតទេ។ បើគិតជាមធ្យមគឺក្នុង ១ ថ្ងៃៗទាំងថៃបញ្ជូនមកវិញ និងគិតទាំងពួកគាត់ត្រឡប់មកវិញខ្លួនឯង គឺប្រមាណ ២០០ នាក់ ហើយអាជ្ញាធរនៅចាំទទួលតាមច្រកហ្នឹង ដោយបានអប់រំ ណែនាំពួកគាត់កុំឱ្យឆ្លងដែនខុសច្បាប់ ជាពិសេសត្រូវតែការពារ ទប់ស្កាត់ជំងឺកូវីដ ១៩»។

លោក អំ សំអាត នាយករងអង្គការសិទ្ធិមនុស្ស (LICADHO) ថ្លែងពីម្សិលមិញថា តាមលោកកត់សម្គាល់ឃើញមានពលរដ្ឋខ្មែរមួយចំនួនធ្វើចំណាកស្រុកទៅធ្វើការងារនៅប្រទេសថៃ ប៉ុន្តែក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ ១៩ ពួកគាត់ខ្លះបានត្រឡប់មកស្រុកកំណើតវិញ ដោយសារការភ័យខ្លាចឆ្លងជំងឺ និងស្របពេលថៃដាក់ប្រទេសក្នុងគ្រាមានអាសន្ន។ ពួកគាត់ត្រូវការប្រាក់ ត្រូវការការងារធ្វើ ដើម្បីរកចំណូលមកផ្គត់ផ្គង់ជីវភាពគ្រួសារ។ ដូច្នេះមួយចំនួនបានសម្រេចចិត្តឆ្លងដែនទៅប្រទេសថៃវិញ ដោយមិនគិតពីការឆ្លងដែនខុសច្បាប់ ឬមិនខ្លាចពីការឆ្លងជំងឺកូវីដ ១៩ នោះទេ ដោយសារកត្តាជីវភាពគ្រួសារ។ លោក សំអាត បញ្ជាក់ថា៖ «យើងឃើញថា កន្លងមករដ្ឋាភិបាលបានចែកជូនថវិកាមួយចំនួនឱ្យប្រជាពលរដ្ឋងាយរងគ្រោះឬក្រីក្រ ប៉ុន្តែនៅមិនទាន់ឆ្លើយតបទៅនឹងអ្វីដែលជាការលំបាករបស់ពួកគាត់ទេ។អ៊ីចឹងគួរតែពិចារណាផ្ដល់ថវិកាបន្ថែមទៀតឬយ៉ាងណា។ ខ្ញុំគិតថាក្រៅពីផ្ដល់ជាសាច់ប្រាក់ជូនគាត់មន្ត្រីជំនាញពាក់ព័ន្ធគួរតែជួយស្វែងរកការងារក្នុងស្រុកជូនពួកគាត់បន្ថែមទៀតតាមដែលអាចធ្វើបាន៕

## មន្ត្រីជំនាញ ជំរុញឱ្យពលរដ្ឋរាយការណ៍បទល្មើសជំរិតប្រាក់តាមរូបភាពអាសអាភាស

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 07 December 2020 | 10:12 ICT

**ភ្នំពេញ៖** នាយកដ្ឋានចំនួន ២ ចំណុះក្រោមក្រសួងមហាផ្ទៃជំរុញឱ្យប្រជាពលរដ្ឋ ឬជនរងគ្រោះចូលរួមរាយការណ៍មកកាន់សមត្ថកិច្ច ដើម្បីស្វែងរកជនល្មើសដែលពាក់ព័ន្ធនឹងការជំរិតទារប្រាក់ដោយប្រើប្រាស់រូបភាព ឬវីដេ

អូអាសអាភាស បៀសវាងបន្តបង់ប្រាក់ទៅឱ្យជនល្មើសទាំងនោះ។ ការអំពាវនាវនេះបានធ្វើឡើងបន្ទាប់ពីនាយកដ្ឋានទាំង ២ នេះបានសង្កេតឃើញថា បច្ចុប្បន្នមានករណីថតរូបភាព ឬវីដេអូអាសអាភាសគំរាមទារប្រាក់ជាច្រើនកំពុងកើតមាននៅក្នុងប្រទេសកម្ពុជាដែលធ្វើឱ្យជនរងគ្រោះ បន្តចាញ់បោក ដែលធ្វើឱ្យខាតបង់ទ្រព្យសម្បត្តិ និងកិត្តិយស។

នាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងមហាផ្ទៃបានបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនកាលពីថ្ងៃទី ៣ ធ្នូ ថា ជនល្មើសបានប្រើប្រាស់មធ្យោបាយមួយចំនួន ដើម្បីទទួលបានរូបភាពអាសអាភាសរបស់ជនរងគ្រោះ ហើយមធ្យោបាយទាំងនោះមានដូចជា ការប្រើប្រាស់នារីស្អាតៗ ដើម្បីទាក់ទាញជនរងគ្រោះ ធ្វើការសន្ទនាអនឡាញ ប្រើប្រាស់សកម្មភាពស្រើបស្រាល អូសទាញជនរងគ្រោះប្រព្រឹត្តសកម្មភាពរួមភេទ មុខកុំព្យូទ័រ ឬទូរស័ព្ទដៃ និងធ្វើការថតសកម្មភាពទាំងនោះ គំរាមទារប្រាក់។ នាយកដ្ឋានព័ត៌មានវិទ្យាបានបន្តថា មធ្យោបាយមួយទៀត ជនល្មើសក៏បានប្រើប្រាស់គេហទំព័រអាសអាភាស បញ្ចូលកម្មវិធីសន្ទនាអនឡាញ ឬផ្ទាំងបើកវីដេអូដែលបញ្ជា វេបខេម Webcam ដើម្បីលួចថតសកម្មភាពជនរងគ្រោះ និងធ្វើការគំរាមទារប្រាក់ និងការប្រើប្រាស់មធ្យោបាយផ្សេងៗក្នុងការចម្លងមេរោគទៅកាន់ម៉ាស៊ីនកុំព្យូទ័រ ឬទូរស័ព្ទដៃ ប្រើប្រាស់ Webcam ថតសកម្មភាពផ្សេងៗ និងធ្វើការគំរាមទារប្រាក់ផងដែរ។ នាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងមហាផ្ទៃជំរុញឱ្យប្រជាពលរដ្ឋ ឬជនរងគ្រោះប្រញាប់រាយការណ៍មកកាន់សមត្ថកិច្ច ដើម្បីដាក់ពាក្យបណ្ដឹងស្វែងរកជនល្មើស ខណៈដែលការបង់ប្រាក់ទៅជនល្មើសទាំងនោះ មិនមែនជាមធ្យោបាយល្អនោះទេ ព្រោះជនរងគ្រោះនៅតែបន្តបង់ប្រាក់ទៅឱ្យជនល្មើសជាបន្តបន្ទាប់។ នាយកដ្ឋានព័ត៌មានវិទ្យាបានបញ្ជាក់ថា៖ «ការបង់ប្រាក់មិនមែនជាមធ្យោបាយ ព្រោះអ្នកនឹងត្រូវបង់បន្តបន្ទាប់។ (ប្រសិនជាមានករណីដូចជម្រាបជូននេះ) ត្រូវធ្វើការបិទគណនីបណ្ដាញសង្គមបណ្ដោះអាសន្ន និងប្រើប្រាស់កម្មវិធីកម្ចាត់មេរោគ ស្កេន និងសម្អាតមេរោគក្នុងម៉ាស៊ីនកុំព្យូទ័រ ឬទូរស័ព្ទដៃរួមនឹងប្រើប្រាស់ស្ទិកឃ័រ Sticker បិទ Webcam នៅពេលមិនប្រើប្រាស់»។

លោក ជា ពៅ ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃបានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី ៣ ធ្នូ ដែរថា រហូតមកដល់ពេលនេះ មិនទាន់មានការសិក្សាណាមួយជាផ្លូវការថា ករណីនៃការជំរិតទារប្រាក់ដោយប្រើប្រាស់រូបភាព ឬវីដេអូអាសអាភាសនៅកម្ពុជាមានប៉ុន្មានករណីឱ្យពិតប្រាកដនោះទេ ព្រោះតែភាគច្រើននៃជនរងគ្រោះ មិនត្រូវបានរាយការណ៍បញ្ហារបស់ខ្លួនទៅកាន់សមត្ថកិច្ចឱ្យបានទាន់ពេលវេលា។ លោកបញ្ជាក់ថា បទល្មើសនៃការជំរិតទារប្រាក់ ដោយប្រើប្រាស់រូបភាព ឬវីដេអូអាសអាភាសក្រៅតែពីជនល្មើសប្រព្រឹត្តបទល្មើសតាមការគំរាម ហើយជនល្មើសគ្មានទំនាក់ទំនងជាមួយជនរងគ្រោះក៏មានករណីជាច្រើនដែរ ដែលបានកើតឡើងតាមរយៈសាច់ញាតិ ឬមិត្តភក្តិដែលបានប្រព្រឹត្តសកម្មភាពជំរិតទារប្រាក់ដោយប្រើប្រាស់រូបភាព ឬវីដេអូអាសអាភាស ។ លោកបញ្ជាក់ថា៖ «ករណីនេះគឺពិតជាមានហានិភ័យ ព្រោះវានឹងធ្វើឱ្យបាត់បង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន តាមរយៈការគំរាមដោយការទារលុយទារកាក់អីអ៊ីចឹង។ ករណីនេះ ក៏ធ្វើឱ្យជនរងគ្រោះមានការខ្លាចរអាក្នុងការថតរូបនិងបាត់ទំនាក់ទំនងគ្នារួមទាំងធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សន្តិសុខសង្គម។ ខ្ញុំសូមអំពាវនាវឱ្យអ្នកប្រើប្រាស់បណ្ដាញសង្គមមានការប្រុងប្រយ័ត្នបំផុត»។

លោក យី គឹមថាន នាយករងប្រចាំប្រទេសផ្នែកកម្មវិធីនៃអង្គការ Plan international បានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី ៣ ខែធ្នូ ថា បទល្មើសទាំងនេះ ក៏ត្រូវបានរកឃើញថា បានធ្វើឱ្យប៉ះពាល់ដល់កិច្ចការពារកុមារផងដែរ បើទោះជាការរីកចម្រើននូវបច្ចេកវិទ្យា និងប្រព័ន្ធអនឡាញបានជួយច្រើនដល់ទំនាក់ទំនងសង្គម ប៉ុន្តែវាក៏ផ្ដល់ផលពិបាកច្រើនផងដែរ ជាពិសេសកុមារ។ ការសិក្សារកឃើញថា មានករណីច្រើនដែលបានកើតឡើងបទល្មើសជំរិតទារប្រាក់នេះ បើទោះជាស្ថិតក្នុងវិបត្តិកូវីដក៏ដោយ។ ឃើញមានការធ្វើការច្រើនពីរដ្ឋាភិបាល៕

# ជនជាតិចិនថៃ និងវៀតណាម ៦ នាក់ត្រូវបញ្ជូនទៅតុលាការ ករណីបើកហាងម៉ាស្សា បង្កប់សេវាផ្លូវភេទ

https://www.postkhmer.com/ គឹម សារុំ | Publication date 07 December 2020 | 14:35 ICT

**ភ្នំពេញៈ** ជនជាតិចិនថៃ វៀតណាមប្រុស-ស្រី ៦ នាក់ ត្រូវបានសមត្ថកិច្ចបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញកាលពីម្សិលមិញ បន្ទាប់ពីឃាត់ខ្លួនកាលពីថ្ងៃទី ៥ ធ្នូ ពាក់ព័ន្ធបើកហាងម៉ាស្សាមានបង្កប់បម្រើសេវាផ្លូវភេទនៅភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ ខណៈបុរសខ្មែរ ៧ នាក់ក៏ត្រូវឃាត់ខ្លួននៅខណ្ឌឫស្សីកែវផងដែរ ករណីលេងល្បែងភ្នាល់ចាក់បាល់តាមអ៊ីនធឺណិត។

លោក កែវ ធា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញប្រាប់ពីម្សិលមិញថា ជនសង្ស័យទាំងនោះមានជនជាតិចិន ៤ នាក់ ទី១- សៀ អ៊ីរុង ភេទស្រី អាយុ ៤៧ ឆ្នាំ (មេការហាងម៉ាស្សា) ទី២- ជាំង ហ៊ុយ ភេទស្រីអាយុ ២៨ ឆ្នាំ (ស្រីម៉ាស្សា) ទី៣- ជិន ឈីងហ៊ាន ភេទប្រុស អាយុ ៤៤ ឆ្នាំ (លក់ដូរ) ទី៤ ចូ ស៊ូឈាន ភេទប្រុស អាយុ ៤៣ ឆ្នាំ (លក់ដូរ)។ ក្រៅពីនេះមានឈ្មោះ ប៉ាក ផាសៀលី ភេទស្រី អាយុ ២៦ ឆ្នាំ ជនជាតិថៃ (ស្រីម៉ាស្សា) និងម្នាក់ទៀតឈ្មោះ ង្វៀង ធីតុគុប ភេទស្រី អាយុ ៣២ ឆ្នាំ ជនជាតិវៀតណាម (ស្រីម៉ាស្សា)។ លោកថ្លែងថា៖ «សមត្ថកិច្ចរបស់ខ្ញុំបានបង្ក្រាបក្នុងបទល្មើសជាក់ស្តែងដែលស្ថិតក្នុងទីតាំងបង្កបទល្មើសហើយសមត្ថកិច្ចខ្ញុំបានចាត់ការពួកគេតាមនីតិវិធីច្បាប់។ ចំពោះចំណាត់ការបន្តទៀតនោះជានីតិវិធីរបស់តុលាការ»។

ទោះយ៉ាងណាលោក កែវ ធា មិនបានផ្តល់ព័ត៌មានលម្អិតជុំវិញប្រតិបត្តិការនេះទេ តែបើតាមមន្ត្រីនគរបាល ១ រូប នៃអធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានឱ្យដឹងពីម្សិលមិញថា ហាងម៉ាស្សាមួយកន្លែងក្នុងភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខបានបើកបម្រើម៉ាស្សាជាច្រើនខែមកហើយហើយមានថៅកែជាជនជាតិចិន។ អាជ្ញាធរខណ្ឌសែនសុខក៏បានជូនដំណឹងអំពីការបង្ការ និងចូលរួមទប់ស្កាត់ការឆ្លងជំងឺកូវីដ ១៩ ផងដែរ ប៉ុន្តែហាងម៉ាស្សាមួយកន្លែងនេះមិនបានអនុវត្តទៅតាមការណែនាំរបស់អាជ្ញាធរមូលដ្ឋានឡើយ។

បើតាមមន្ត្រីរូបនេះ ដោយមានការសង្ស័យថា ហាងម៉ាស្សាទីតាំងខាងលើអាចមានបង្កប់បម្រើសេវាផ្លូវភេទនោះទើបសមត្ថកិច្ចចម្រុះមានលោក ម៉ូវ ម៉ានិត អភិបាលខណ្ឌសែនសុខ និងលោកវរសេនីយ៍ឯក ហួរ ម៉េងវ៉ាង អធិការ នៃអធិការដ្ឋាននគរបាលខណ្ឌសែនសុខបានសហការជាមួយកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងដោយមានការសម្របសម្រួលផ្លូវច្បាប់ពីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានចុះឆែកឆេរផ្ទះលេខ F១០២ ក្នុងភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម កាលពីវេលាម៉ោងជាង ៨ យប់ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០២០។ ក្នុងការបង្ក្រាបនោះដែរក្រៅពីឃាត់ខ្លួនជនសង្ស័យ ៦ នាក់ សមត្ថកិច្ចរកឃើញស្រោមអនាម័យប្រើរួចនិងមិនទាន់ប្រើមួយចំនួន ហើយប្រមូលយករក្សាទុកជាវត្ថុតាងដើម្បីបញ្ជូនទៅតុលាការ។

ដោយឡែកកាលពីថ្ងៃទី ៥ ធ្នូ នគរបាលខណ្ឌឫស្សីកែវក៏បានបង្ក្រាបទីតាំងលេងល្បែងចាក់បាល់ខុសច្បាប់តាមប្រព័ន្ធអ៊ីនធឺណិតមួយកន្លែងស្ថិតក្នុងភូមិសាមគ្គី សង្កាត់-ខណ្ឌឫស្សីកែវ។ ក្នុងនោះសមត្ថកិច្ចឃាត់ខ្លួនបុរស-ខ្មែរជាអ្នកចូលលេងល្បែងបានចំនួន ៥ នាក់ និងបុរសជាអ្នកមើលការខុសត្រូវកន្លែងលេងល្បែងភ្នាល់ចាក់បាល់នោះបានចំនួន ២ នាក់។

លោក ហ៊ាង ថារ៉េត អធិការនគរបាលខណ្ឌឫស្សីកែវប្រាប់ពីម្សិលមិញថា ដោយអនុវត្ត និងចូលរួមបង្ក្រាបបទល្មើស ពិសេសការចូលរួមបង្ការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩ គឺអាជ្ញាធរខណ្ឌក៏ដូចជាសមត្ថកិច្ចរបស់លោកបានបង្ក្រាបល្បែងភ្នាល់លុយខុសច្បាប់ ដោយឃាត់ខ្លួនបានមនុស្ស ៧ នាក់។ ក្រៅពីនេះសមត្ថកិច្ចដកហូតបានកុំព្យូទ័រចំនួន ១៤ ឈុតម៉ូនីទ័រចំនួន ១៤ គ្រឿង និងម៉ាស៊ីនបម្រើដល់ការលេងចំនួន ១៤ គ្រឿងផង។ លោក

បញ្ជាក់ថា៖ «ជនពាក់ព័ន្ធយើងនឹងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ព្រោះល្បែងស៊ីសង ឬភ្នាល់ចាក់លុយគឺជាអំពើខុសច្បាប់»៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៩នាក់

https://www.facebook.com/GDIOfficial 07-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៩នាក់ ស្រី ២២នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៥នាក់ ស្រី ០១នាក់៕

# ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ២០២០

## ឯកឧត្តម អ៊ុនចាន់ដា ជំរុញដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវចាត់វិធានការឲ្យបានតឹងរឹងដើម្បីបញ្ឈប់អំពើអំពើហិង្សាលើស្ត្រីនិងក្មេងស្រី!

https://www.pdikampongcham.info/ ៧ ខែធ្នូ ២០២០ *អត្ថបទ៖ ជឹម សារ៉ន*

នាព្រឹកថ្ងៃទី៧ខែធ្នូឆ្នាំ២០២០ ឯកឧត្តម អ៊ុនចាន់ដា អភិបាល នៃគណៈអភិបាលខេត្តអញ្ជើញជាអធិបតីក្នុងយុទ្ធនាការ១៦ថ្ងៃបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងក្រោមប្រធាន "រួមគិត រួមធ្វើ រួមដោះស្រាយ ដើម្បីបញ្ឈប់អំពើហឹង្សាលើស្ត្រី និងក្មេងស្រី" ក្នុងនោះក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម អភិបាលរងខេត្ត លោក លោកស្រី មន្ទីរ-អង្គភាព កងកម្លាំងប្រដាប់ ដែលកម្មវិធីនេះប្រព្រឹត្តទៅនៅបរិវេនសាលាខេត្តកំពង់ចាម ។ យុទ្ធនាការនេះ ធ្វើឡើងក្នុងគោលបំណង បង្កើនការចូលរួម ទប់ស្កាត់ និងងលុបបំបាត់នូវរាល់ទម្រង់ នៃការរើសអើងលើស្ត្រី និងកុមារ ។ក្នុងកម្មវិធីនេះមានការកំណត់ការបំពាក់បូរពណ៌ស ដែលជាសញ្ញានៃការសន្យា ដើម្បីបញ្ឈប់អំពើហឹង្សាលើស្ត្រី និងក្មេងស្រី ។

ឯកឧត្តម អភិបាលខេត្ត បានមានប្រសាសន៍លើកឡើងថាយើងទាំងអស់គ្នាត្រូវចូលរួមលើកតម្លៃស្ត្រីនិងការការពារនូវសិទ្ធកុមារដែលជានាថាមិនអោយមានការរំលោភបំពានឬការកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារទាំងអស់។ដូច្នេះអាជ្ញាធរពាក់ព័ន្ធត្រូវចូលរួមធ្វើយ៉ាងទប់ស្កាត់រាល់សកម្មភាពបទល្មើសទាំងឡាយអោយមានប្រសិទ្ធភាពដែលជាសកម្មភាពរំលោភបំពានទៅលើស្ត្រីនិងកុមារ។ ជាចុងបញ្ចប់ ឯកឧត្តម បានផ្ដាំផ្ញើ ធ្វើយ៉ាងណា រួមគិត រួមធ្វើ រួមដោះស្រាយ ដើម្បីបញ្ឈប់អំពើហឹង្សាលើស្ត្រី និងក្មេងស្រី និងសំណូមពរដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវចាត់វិធានការឲ្យបានតឹងរឹងដើម្បីបញ្ឈប់អំពើអំពើហឹង្សាលើស្ត្រីកុមារ។៕

# ពលករខ្មែរត្រឡប់ពីថៃតាមច្រកអូរពាជាន់រាប់រយនាក់រាល់ថ្ងៃ

https://vodkhmer.news/ វ៉ា សុភានុត ០៦ ធ្នូ ២០២០ ម៉ោង ២១:៤៦

អាជ្ញាធរអះអាងថា ពលករខ្មែរត្រឡប់ពីប្រទេសថៃតាមច្រកអូរពាជាន់ក្នុងក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យចន្លោះពី១០០ទៅ៣០០នាក់រៀងរាល់ថ្ងៃដោយសារនៅថៃមិនមានការងារធ្វើ និងអ្នកខ្លះមកចូលរួមកម្មវិធីសាច់ញាតិនៅស្រុកកំណើត។

អភិបាលស្រុកអូរជ្រៅលោក លី សុវណ្ណារិទ្ធ បាននិយាយថា ពលករចំណាកស្រុកដែលចូលមកតាមច្រកអូរពាជាន់ ដែលមកពីតំបន់ប្រឈមត្រូវធ្វើចត្តាឡីស័កនៅឯក្រុងប៉ោយប៉ែត និងពលករមកពីតំបន់ដែលគ្មានការប្រឈមគឺត្រូវវាស់កម្ដៅហើយអនុញ្ញាតឱ្យទៅផ្ទះបើកម្ដៅធម្មតា។ លោកបន្តថា រដ្ឋាភិបាលបានត្រៀមក្រុមការងារសម្រាប់ដោះស្រាយមធ្យោបាយធ្វើដំណើរដល់ពួកគាត់ តែភាគច្រើនពលករអស់ទាំងនោះគឺធ្វើដំណើរដោយខ្លួនឯង អ្នកខ្លះមានបងប្អូនមកយក និងផ្សេងទៀតជិះរថយន្តឈ្នួលត្រឡប់ទៅផ្ទះវិញ។ លោក និយាយថា *«មធ្យោបាយខាងក្រុមការងារ គឺជូនពួកគាត់ទៅ តែកន្លងមកច្រើនតែពួកគាត់ទៅខ្លួនឯង តែយើងចេញនូវបណ្ណអោយសមាជិកមូលដ្ឋាន អោយពួកគាត់ទៀតបណ្ណលឿងមួយ។ បណ្ណគឺមានន័យថាគឺគាត់បានចូលតាមច្រកយើង បានវាស់កម្ដៅប៉ុន្មានអីប៉ុន្មាន អាយុអី ភេទ»។*

អនុប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យលោក ចេ ពិចិត្រ មានប្រសាសន៍ថា ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកពីប្រទេសថៃតំបន់ប្រឈម គឺធ្វើចត្តាឡីស័ក២ទៅ៣ថ្ងៃ ដើម្បីរងចាំលទ្ធផលធ្វើតេស្ត ប្រសិនបើអវិជ្ជមានពួកគេត្រូវបន្តធ្វើចត្តាឡីស័កនៅតាមភូមិស្រុករបស់ខ្លួនវិញ និងអ្នកដែលមកពីតំបន់គ្មានការប្រឈមគឺគ្រាន់តែវាស់កម្ដៅធម្មតា និងណែនាំពួកគេទៅផ្ទះត្រូវដាក់អោយនៅដោយឡែករយៈ១៤ថ្ងៃ ។ លោកបន្តថា ក្រុមការងាររបស់លោកក៏បានបញ្ជូនឈ្មោះពួកគេទៅតាមមូលដ្ឋានដែលពួកគេរស់នៅដើម្បីឱ្យអាជ្ញាធរមូលដ្ឋានចុះអប់រំអំពីវិធានការអនាម័យនិងតាមដានការធ្វើចត្តាឡីស័ក។ លោក និយាយថា *«លទ្ធផលនឹងអវិជ្ជមានពួកគាត់អាចធ្វើចត្តាឡីស័កនៅតំបន់គាត់ ផ្ទះគាត់ នៅមូលដ្ឋានគាត់រយៈពេល១៤ថ្ងៃ ចឹងហើយចន្លោះនឹងចន្លោះចត្តាឡីស័ក១៤ថ្ងៃនឹង បើសិនជាគាត់មានរោគសញ្ញាគឺត្រូវអោយគាត់ទៅពេទ្យដើម្បី យកសំណាកទៅវិភាគ»*

លោក យុន ថារ៉ូ មន្ត្រីគ្រប់គ្រងកម្មវិធីការងារនៅមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធមនុស្ស បាននិយាយថា អាជ្ញាធរមូលដ្ឋានអាចនឹងមានការពិបាកក្នុងការចុះតាមដាន ថាតើពួកគាត់ពិតជាបានធ្វើចត្តាឡីស័កនៅផ្ទះនិងមិនចេញទៅទីណាផ្សេងនោះ។ លោកបន្តថា រាជរដ្ឋាភិបាលគួរតែមានវិធានការដើម្បីលើកទឹកចិត្តអោយពួកគាត់ដើម្បីដាក់ខ្លួនឯងឱ្យនៅដាច់ដោយឡែករយៈ១៤ថ្ងៃ ដូចជាករណី២៨វិច្ឆិកាផងដែរ ដែលគ្រួសារក្រីក្រជាប់ពាក់ព័ន្ធត្រូវធ្វើចត្តាឡីស័កដោយទទួលបានម្នាក់២ម៉ឺនរៀលក្នុងថ្ងៃ។ លោក បញ្ជាក់ថា *«រាជរដ្ឋាភិបាលត្រូវធានាថា ពួកគាត់ត្រូវនៅដាច់ខ្លួនដោយឡែក ផ្ទះនឹងគួរតែមានការគាំទ្រគាំពារអីហ្នឹង ដូចជាការផ្ដល់ថវិកាអីផ្សេងៗ»*

លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលបាននិយាយថា ដោយកាលពីមុនការធ្វើចត្តាឡីស័កនៅដាច់ដោយឡែកពីគ្រួសារធ្វើឱ្យមានឧបសគ្គច្រើន សម្រាប់អ្នកដែលនឹកដល់ក្រុមគ្រួសារ។ លោក បញ្ជាក់ថា លុះត្រាតែអ្នកទាំងអស់នោះធ្វើតេស្តអវិជ្ជមានទើបអនុញ្ញាតអោយពួកគេ ទៅធ្វើចត្តាឡីស័កនៅតាមផ្ទះ ហើយមន្ត្រីជាប់ពាក់ព័ន្ធនឹងបញ្ជូនឈ្មោះពួកគេទៅតាមមូលដ្ឋានដែលស្នាក់នៅ ពេលដែលពលករចំណាកស្រុកអស់ទាំងនោះទៅដល់ស្រុកកំណើតរៀងៗខ្លួនហើយ អាជ្ញាធរនិងបុគ្គលិកពេទ្យ ដែលមានមូលដ្ឋាននៅទីនោះ នឹងចុះអប់រំណែនាំអំពីអនាម័យនឹងវិធីសាស្ត្រការពារការឆ្លងកូវីដទៅកាន់ពួកគេ។

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់

https://www.facebook.com/GDIOfficial 08-12-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង០០នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៩នាក់

https://www.facebook.com/GDIOfficial 08-12-2020

នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៩នាក់ ស្រី ៤១នាក់៕

## ម៉ាឡេស៊ី ផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរ និងពលករ១៤ប្រទេសទៀត តែត្រូវបង់ប្រាក់មួយចំនួន

https://thmeythmey.com/ 08, Dec 2020 , 5:49 pm ដោយ: សៅ សុខអេង

ភ្នំពេញ៖ រដ្ឋាភិបាលម៉ាឡេស៊ីបានប្រកាសផ្តល់ភាពស្របច្បាប់ដល់ពលករខុសច្បាប់ នៃប្រទេស១៥ ដោយក្នុងនោះ មានទាំងពលករខុសច្បាប់របស់កម្ពុជាផងដែរ។ ការផ្តល់ភាពស្របច្បាប់នេះ គឺសំដៅដល់កម្មករខុសច្បាប់ ដែលកំពុងបម្រើការនៅក្នុងវិស័យសំណង់ ឧស្សាហកម្ម ដាំដុះ និង កសិកម្ម នៅក្នុងប្រទេសម៉ាឡេស៊ី។

សេចក្តីជូនដំណឹងរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានបញ្ជាក់ពីលក្ខខណ្ឌថា មុននឹងនិយោជក និងកម្មករខុសច្បាប់ អាចទទួលបានសិទ្ធស្របច្បាប់នេះ គឺពួកគេ មិនត្រូវមានឈ្មោះនៅក្នុងបញ្ជីខ្មៅ(Black list) របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍, ត្រូវបង់ប្រាក់តម្កល់ ៥០០ រីងហ្គីត (ជាង១២០ដុល្លារ), បង់ថ្លៃផាកពិន័យ ១៥០០រីងហ្គីត(៣៦៩ដុល្លារ) តាមប្រព័ន្ធអនឡាញ សម្រាប់ពលករម្នាក់, ត្រូវពិនិត្យសុខភាពនៅមជ្ឈមណ្ឌល FOMEMA, ត្រូវបង់ពន្ធ, បង់សេវាដំណើរការឯកសា និង ទិដ្ឋាការ។ លក្ខខណ្ឌបន្ទាប់មកទៀត គឺ ពលករ ត្រូវមានលិខិតឆ្លងដែនដែលមានសុពលភាពយ៉ាងតិច១៨ខែ, ជាពលករដែលបានចូលទៅធ្វើការនៅម៉ាឡេស៊ីដោយប្រើទិដ្ឋាការទេសចរណ៍ (Social Visit Pass) ឬជាពលករដែលមានទិដ្ឋាការការងារផុតសុពលភាពមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ឬ ត្រូវបានរាយការណ៍ថារត់ចេញពីនិយោជក។ បន្ថែមពីនេះ ពលករត្រូវមានវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ដែលមានសុពលភាពរយៈពេល៣ថ្ងៃមុនថ្ងៃសម្ភាស។

ក្រោយពលករបានបំពេញលក្ខខណ្ឌខាងលើបានសមស្របហើយ ពលករអាចដាក់ពាក្យស្នើសុំផ្តល់ភាពស្របច្បាប់ដល់ពលករតាមរយៈអ៊ីមែលទៅកាន់ .my ។ ក្រោយមកទៀត ពលករទាំងអស់ ត្រូវទាក់ទងផ្ទាល់ជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានការងារម៉ាឡេស៊ីដោយគ្មានការពាក់ព័ន្ធជាមួយនឹងភាគីទីបី និងទីភ្នាក់ងារជ្រើសរើសពលករឡើយ។ នេះបើតាមស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ដែលអះអាងថា ការផ្តល់ភាពស្របច្បាប់ដល់ពលករខុសច្បាប់នេះ ត្រូវបានអនុវត្តពីខែវិច្ឆិកា ឆ្នាំ២០២០មក រហូតដល់ខែមិថុនា ឆ្នាំ២០២១៕

## ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០២០
## នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន អន្តរាគមន៍ជួយរំដោះ"ក្មេងស្រីខ្មែរម្នាក់បម្រើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ត្រូវម្ចាស់ផ្ទះធ្វើទារុណកម្ម និងកាត់ស្លឹកត្រចៀកយ៉ាងព្រៃផ្សៃ"

http://cambodiapolice.com/policekh/ 4:38 pm 9 ធ្នូ 2020

ក្រុមការងារប្រតិកម្មរហ័ស នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានពិនិត្យឃើញថា ថ្មីៗនេះមានការចែករំលែកជាបន្តបន្ទាប់លើបណ្តាញសង្គម ពាក់ព័ន្ធនឹងករណីហិង្សាដែលកើតឡើងលើពលការិនីជនជាតិខ្មែរអ៊ីស្លាមម្នាក់នៅប្រទេសម៉ាឡេស៊ី ។ ករណីនេះត្រូវបានដាក់ជូននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីអនុវត្តជំនាញ និងជួយអន្តរាគមន៍ ។

នៅរសៀលថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ស្ត្រីជនជាតិខ្មែរអ៊ីស្លាមម្នាក់ដែលត្រូវបានគេសរសេរសារបង្ហោះលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកថា "ក្មេងស្រីខ្មែរម្នាក់បម្រើតាមផ្ទះនៅប្រទេសម៉ាឡេស៊ីត្រូវម្ចាស់ផ្ទះធ្វើទារុណកម្ម និងកាត់ស្លឹកត្រចៀកយ៉ាងព្រៃផ្សៃ" នោះត្រូវបានជួយសង្គ្រោះដោយជោគជ័យ ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អរវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលពីស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី និងសហការជាមួយសមត្ថកិច្ចម៉ាឡេស៊ីផងដែរ ទើបឈានដល់ការរំដោះនារីរងគ្រោះ និងបានបញ្ជូនទៅសំរាកព្យាបាលនៅមន្ទីរពេទ្យ ។ ឯកឧត្តម ជីវ ផល្លី បានបញ្ជាក់បន្ថែមថា សមត្ថកិច្ចម៉ាឡេស៊ីកំពុងស៊ើបអង្កេត ដើម្បីមានចំណាត់ការបន្តលើជនដៃដល់ រីឯជនរងគ្រោះ បន្ទាប់ពីព្យាបាលជាសះស្បើយពីរបួស ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី នឹងរៀបចំសម្របសម្រួលឲ្យវិលត្រឡប់មកកម្ពុជាវិញ ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានសង្កត់ធ្ងន់ថា ជាទិសដៅនៅពេលដែលនារីរងគ្រោះខាងលើ បានត្រឡប់មកដល់ព្រះរាជាណាចក្រកម្ពុជាវិញ ជំនាញរបស់នាយកដ្ឋាន សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីធ្វើការស៊ើបអង្កេតស្វែងរកជនសង្ស័យជាមេខ្យល់នាំនារីរងគ្រោះខាងលើទៅបម្រើការងារនៅប្រទេសម៉ាឡេស៊ី ដើម្បីឈានដល់ការអនុវត្តនីតិវិធីនាំខ្លួនជនសង្ស័យមកផ្តន្ទាទោសតាមច្បាប់។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ក្នុងនាមថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្នុងនាមនាយកដ្ឋានជំនាញ សូមថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរបស់អាជ្ញាធរម៉ាឡេស៊ី និងស្ថាប័នពាក់ព័ន្ធ បានរួមចំណែកលើការងារនេះ និងសូមអរគុណចំពោះសាធារណជន អ្នកសារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមដែលតែងតែចូលរួមចំណែកក្នុងកិច្ចការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងក៏ដូចជាការចូលរួមចំណែកស្វែងរកយុត្តិធម៌សង្គម ៕

# កិច្ចប្រជុំកំពូលតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាមរួមគ្នា ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងគ្រឿងញៀន បទល្មើសឆ្លងដែន បទល្មើសព្រៃឈើ និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត

https://www.cen.com.kh/ December 9, 2020

ភ្នំពេញ៖ សម្ដេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម (CLV) លើកទី១១ តាមប្រព័ន្ធវីដេអូ។ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានគូសបញ្ជាក់ពីភាពចាំបាច់នៃការបន្តកិច្ចសហប្រតិបត្តិការរវាងប្រទេស CLV ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងគ្រឿងញៀន បទល្មើសឆ្លងដែន បទល្មើសព្រៃឈើ និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត។

នៅរសៀលថ្ងៃទី៩ធ្នូនេះ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំកំពូល CLV លើកទី១១ តាមប្រព័ន្ធវីដេអូ។ នៅក្នុងកិច្ចប្រជុំនេះ ប្រមុខដឹកនាំប្រទេសកម្ពុជា-ឡាវ-វៀតណាម បានបង្ហាញការប្ដេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការលើកកម្ពស់ការអភិវឌ្ឍតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម (CLV DTA) ជាមួយនឹងទស្សនៈក្នុងការពន្លឿនកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងវឌ្ឍនភាពសង្គម-វប្បធម៌ ដោយទាញយកនូវសក្ដានុពល កម្លាំង និងធនធានរបស់ប្រទេសសមាជិកនីមួយៗ។ ប្រមុខដឹកនាំទាំងអស់ទទួលស្គាល់ថា ជំងឺកូវីដ-១៩ បាននាំមកនូវការរំខានយ៉ាងធំធេងដល់សុខភាពសាធារណៈ និងប៉ះពាល់ដល់សេដ្ឋកិច្ច-សង្គម ដូច្នេះការពង្រឹងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ រវាងប្រទេសសមាជិកទាំងបី គឺមានសារៈសំខាន់ និងចាំបាច់ ដោយផ្ដោតលើទំនាក់ទំនងប្រពៃណី សាមគ្គីភាព ការយោគយល់ការជឿជាក់ អត្ថប្រយោជន៍រួម និងការអភិវឌ្ឍប្រកបដោយចីរភាព។

ប្រមុខដឹកនាំទាំងកម្ពុជា ឡាវ វៀតណាម បានកត់សម្គាល់ជាវិជ្ជមានលើការងារ គណៈកម្មាធិការសម្របសម្រួលចំរុះកម្ពុជា-ឡាវ-វៀតណាម ក្នុងការអនុវត្តផែនការមេដែលបានកែសម្រួលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៃការអភិវឌ្ឍតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម សម្រាប់ឆ្នាំ២០១០-២០២០។ ប្រមុខដឹកនាំបន្តលើកទឹកចិត្ត ក្នុងការសហការដោយជិតស្និទរវាងប្រទេសសមាជិក CLV ក្នុងការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្មនិងវិនិយោគ ទេសចរណ៍ សាសនា កសិកម្ម ព័ត៌មានវិទ្យា អប់រំ ការស្រាវជ្រាវ ការអភិវឌ្ឍជំនាញ ការការពារ ព្រមទាំងទំនាក់ទំនង សហប្រតិបត្តិការរវាងកម្រិតនីតិបញ្ញត្តិជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានគូសបញ្ជាក់ពីភាពចាំបាច់នៃការបន្តកិច្ចសហប្រតិបត្តិការរវាងប្រទេស CLV ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងគ្រឿងញៀន បទល្មើសឆ្លងដែន បទល្មើសព្រៃឈើ និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត រួមទាំងការបោសសំអាតមីន ព្រមទាំងការជួយសម្រួលដល់ការឆ្លងកាត់ព្រំដែនរបស់អ្នកធ្វើដំណើរផងដែរ។ កិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី១១ ថ្ងៃនេះ បានអនុម័តលើឯកសារ មួយចំនួនដូចជា ៖

១)សេចក្ដីថ្លែងការណ៍រួមនៃកិច្ចប្រជុំកំពូល CLV លើកទី១១

២)ផែនការអភិវឌ្ឍន៍សម្រាប់វិស័យទេសចរណ៍នៅក្នុង CLV DTA

៣) ផែនការអភិវឌ្ឍន៍លើវិស័យឧស្សាហកម្មកៅស៊ូប្រកបដោយចីរភាពក្នុង CLV DTA៕**រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ**

# មេសហជីព បារម្ភពីជនបរទេសដណ្តើមការងារក្រៅប្រព័ន្ធ ហើយធ្វើឲ្យពលករខ្មែរត្រូវចំណាកស្រុក

https://thmeythmey.com/ 08, Dec 2020 , 11:29 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ មេសហជីពក្រៅប្រព័ន្ធ បង្ហាញក្តីបារម្ភពីការកើនឡើងនៃចំនួនជនបរទេសមកប្រកបមុខរបរនិងធ្វើការនៅកម្ពុជា ពិសេសការងារក្រៅប្រព័ន្ធ ដែលជាកត្តាធ្វើឲ្យពលរដ្ឋខ្មែរបាត់បង់ការងារ ហើយងាកទៅធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារនៅក្រៅប្រទេស។

តាមរយៈកិច្ចសម្ភាសជាមួយសារព័ត៌មានថ្មីៗតាមទូរសព្ទ លោក វន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ស្នើឲ្យរដ្ឋាភិបាលពិនិត្យច្បាប់ការងារឡើងវិញ ពីសិទ្ធិការងាររបស់ជនបរទេស។ លោក កត់សម្គាល់ឃើញថា ចាប់តាំងពីឆ្នាំ២០១៨ ជនបរទេស ដែលប្រកបរបរក្រៅប្រព័ន្ធ មានការកើនឡើង ក្នុងនោះមានច្រើនគឺជនជាតិចិន និងវៀតណាម។ លោក បន្តថា កត្តានេះ ធ្វើឲ្យពលរដ្ឋខ្មែរពិបាកក្នុងការប្រកួតប្រជែង និងបាត់បងឱកាសការងារ។ មេសហជីពការពារកម្មករក្រៅប្រព័ន្ធរូបនេះ ថ្លែងថា៖«រដ្ឋ គួរមានវិធានការ។ សម្រាប់កម្មករជំនាញដូចជាជំនាញវិស្វករសំណង់ វិស្វករអេឡិចត្រូនិច គួរតែអនុញ្ញាតសម្រាប់បរទេស តែមុខរបរតូចតាចរដ្ឋគួរទប់ស្កាត់។ ហើយច្បាប់ស្តីពីការងារក៏បានចែងដែរថា ជនបរទេសអាចប្រកបមុខរបរក្នុងប្រទេសកម្ពុជាបានលុះត្រាតែកម្មករជំនាញ អ៊ីចឹង សម្រាប់កម្មករក្រៅប្រព័ន្ធ មិនមែនជាកម្មករជំនាញទេ។ រដ្ឋគួរគិតពីចំណុចនេះឡើងវិញ»។ លោក បន្ថែមថា កន្លងមកលោកធ្លាប់បានស្នើទៅរដ្ឋាភិបាលជាច្រើនដងដែរលើបញ្ហានេះ ប៉ុន្តែការស្នើរបស់លោកមិនឃើញការឆ្លើយតបជាវិជ្ជមានណាមួយសម្រាប់អ្នកធ្វើការក្រៅប្រព័ន្ធឡើយ។

លោក សូ ឆ្លួញ អនុប្រធានសហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើ យល់ថា រដ្ឋាភិបាលគួរបញ្ឈប់ការផ្តល់សិទ្ធិឲ្យជនបរទេសមកធ្វើការដោយសេរី ហើយគួរតែកំណត់ពេលណាមួយជាក់លាក់។ លោក ក៏សម្គាល់ឃើញមានការកើនឡើងនូវជនបរទេសធ្វើក្រៅប្រព័ន្ធដែរ ពិសេសកម្មករសំណង់ ភាគច្រើនជាជនជាតិចិន វៀតណាម បង់ក្លាដែស និងនេប៉ាល់ជាដើម។ លោកបន្តថា សព្វថ្ងៃពលរដ្ឋខ្មែរមិនទាន់មានការងារគ្រប់គ្រាន់នៅឡើយទេ ដូច្នេះលោកបារម្ភថាពួកគេ នឹងបាត់បង់ឱកាសការងារនិងងាកទៅចំណាកស្រុក។ ក្នុងកិច្ចសម្ភាសជាមួយសារព័ត៌មានថ្មីៗ លោក សូ ឆ្លួញ ដែលមេសហជីពការពារកម្មករក្រៅប្រព័ន្ធដែរនោះ លើកឡើថា៖«កម្មករសំណង់ភាគច្រើនមិនមែនមានតែជនជាតិចិននោះទេ មានវៀតណាម បង់ក្លាដែស នេប៉ាល់ ជាដើម ប៉ុន្តែខ្ញុំមិនច្បាស់ថាពួកគេមកស្របច្បាប់ឬមកតាមមេខ្យល់នាំមកឡើយ។...មិនគួរឲ្យបន្តមានជនបរទេសច្រើនឡើង មកធ្វើការនៅស្រុកយើងទេ ដោយសារប្រទេសយើងជាប្រទេសកំពុងអភិវឌ្ឍ អ៊ីចឹង តម្រូវការការងាររបស់ពលរដ្ឋមិនទាន់បានគ្រប់គ្រាន់នៅឡើយទេ។ យើងមានក្តីបារម្ភដែលជនបរទេសមកធ្វើការច្រើន ដែលធ្វើឲ្យយើងជាម្ចាស់ស្រុកបាត់បង់ឱកាសការងារសម្រាប់ធ្វើការ ហើយឈានទៅធ្វើការនៅស្រុកគេវិញ»។ លោក និយាយទៀតថា កម្មករខ្មែរនិងជនបរទេស បើទោះបីមានសមត្ថភាពដូចគ្នា ក៏កម្រិតប្រាក់ខែខុសគ្នាដែរ ពោលគឺជនបរទេសតែងបានប្រាក់ខែខ្ពស់ជាងកម្មករសំណង់ខ្មែរ។ លោកទទូចឲ្យរដ្ឋាភិបាលពិចារណាបញ្ហានេះឡើងវិញ ក្នុងករណីអនុញ្ញាតឲ្យជនបរទេសមកវិនិយោគ ហើយថែមទាំងមានកម្លាំងកម្មករបរទេសទៀត។

ទន្ទឹមនឹងនេះ លោក យុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ក៏យល់ឃើញដូចមេសហជីពទាំងពីរខាងលើដែរ។ ប៉ុន្តែអ្វីដែលលោក បារម្ភមួយទៀតនោះ គឺការមកបំពេញការងារនៅកម្ពុជា ដោយស្របច្បាប់ឬយ៉ាងណា។ ត្រង់ចំណុចនេះ លោកសង្កត់ធ្ងន់ថា រដ្ឋគួរចុះអធិការកិច្ចតាមកន្លែងដែលមានជនបរទេសធ្វើការ ពិសេសវិស័យការងារសំណង់ ដោយលោក យល់ថា ការធ្វើបែបនេះ ដើម្បីឲ្យច្បាស់ពីទិន្នន័យនិងធានាថាជនបរទេសដែលកំពុងបំពេញការងារ គឺចូលមកកម្ពុជាស្របច្បាប់ឬខុសច្បាប់។

ពាក់ព័ន្ធនឹងការប្រកបរបរខ្នាតតូចរបស់ជនបរទេសនេះ ក្រសួងការងារ កាលពីអំឡុងសីហា ឆ្នាំ២០១៩ បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយមិនអនុញ្ញាតឲ្យជនបរទេសប្រកបមុខរបរខ្នាតតូចនេះឡើង។ មុខរបរទាំងនោះរួមមាន អ្នកបើកបរយានជំនិះគ្រប់ប្រភេទ អាជីវកម្មម៉ាស្សា អ៊ុនសក់ កាត់ដេរ ប៉ះកង់ ជួសជុលយានយន្ត និង លក់វត្ថុអនុស្សាវរីយ៍ ជាដើម។ ប៉ុន្តែនៅអំឡុងដើមខែតុលា ឆ្នាំ២០១៩ ក្រសួងការងារក៏ប្រកាសអនុញ្ញាតឲ្យជនបរទេសប្រកបរបរទាំងនោះឡើងវិញ។ កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០២០នេះ ក្រសួងការងារអះអាងថា នៅកម្ពុជាអត្រានៃចំនួនអ្នកអត់ការងារគឺស្ថិតក្រោម១ភាគរយប៉ុណ្ណោះ ពោលគឺអត្រាពលរដ្ឋមានការងារធ្វើ មាន៩៩.៣ភាគរយ ដែលក្នុងនោះមានកម្លាំងពលកម្មប្រមាណ១០លាននាក់។ ក្រសួងបញ្ជាក់ថាពលរដ្ឋមានការងារធ្វើ១០លាននាក់នោះមាន១លាន៥សែននាក់ ជាអ្នកធ្វើការក្នុងប្រព័ន្ធនិង២លាន២សែននាក់ ធ្វើការផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ក្នុងរយៈពេល៩ខែ ឆ្នាំ២០២០ ជនបរទេសចូលមកកម្ពុជាជាង១លាន៦សែននាក់ មាន២១៦សញ្ជាតិ ដែលភាគច្រើនជនជាតិចិន។ ពួកគេភាគច្រើនជាអ្នកទេសចរណ៍ ពាណិជ្ជករ និងអ្នកការទូត។ ជនបរទេសចូលមកទាំងអស់នេះ សុទ្ធតែមានឯកសារគ្រប់គ្រាន់និងចូលមកស្របច្បាប់។ នេះបើតាមការអះអាងរបស់លោក កែវ វណ្ណថន អ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រាប់សារព័ត៌មានថ្មីៗតាមប្រព័ន្ធ Telegram ដោយលោកបញ្ជាក់បន្ថែមថា ជនបរទេសមួយចំនួនដែលប្រព្រឹត្តខុសច្បាប់និងរស់នៅខុសច្បាប់ ក្នុងរយៈពេល៩ខែឆ្នាំ២០២០នេះ ត្រូវបានបណ្តេញជាង៥០០នាក់ មាន៤០សញ្ជាតិ ភាគច្រើន លួចស្នាក់នៅខុសច្បាប់ លើសទិដ្ឋាការ និងគ្មានលិខិតឆ្លងដែន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ២០នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 09-12-2020

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២០នាក់ ស្រី ១៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ០១នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial 09-12-2020

កោះកុង៖ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៦និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះ មានឈ្មោះ គ្រី ឈុនលីម ភេទប្រុស អាយុ ៣៦ឆ្នាំ នៅភូមិឈូក ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាពពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៧១នាក់

https://www.facebook.com/GDIOfficial 09-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧១នាក់ ស្រី ២៩នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៤នាក់៕

## ទាហានថៃនៅខេត្តស្រះកែវចាប់បានពលករខ្មែរលួចឆ្លងដែនចូលទឹកដីថៃដោយខុសច្បាប់តាមរយៈមេខ្យល់

https://www.facebook.com/ ទឹកចិត្ត-ពលករ-ឆ្ល ៩-១២-២០២០

មិញៗនេះ ៩-១២-២០២០ ទាហានថៃនៅ ខេត្តស្រះកែវ ចាប់បានពលករខ្មែរលួចឆ្លងដែនចូលទឹកដីថៃដោយខុសច្បាប់តាមរយៈមេខ្យល់ ទាហានថៃចាប់បានមេខ្យល់ជនជាតិខ្មែរព្រមទាំងម៉ូតូ២គ្រឿង ម៉ូតូជាម៉ូតូថៃតែអ្នកបើកម៉ូតូជាជនជាតិខ្មែរបានដឹកពលករខ្មែរឆ្លងដែនចេញពីទឹកដីខ្មែរចូលទឹកដីថៃ តាមច្រករបៀង ត្រូវទាហានថៃចាប់បានយកទៅផ្ដន្ទាទោសតាមផ្លូវច្បាប់។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

# ថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ២០២០

## ប្រជាពលរដ្ឋ១០២នាក់ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១៦:៣៥ ស្រី គំនិត

ខេត្តឧត្តរមានជ័យ ៖ យោងតាមរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង១៥និង០០នាទី ភាគីថៃ នៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្នមិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩ ។ អគ្គនាយកដ្ឋានបានបន្តថា ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែងទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន ។ ចំណែកឯពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន១០២នាក់ ស្រី ៤៩នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ៤០នាក់ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 10-12-2020

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមកមានចំនួន៤០នាក់ ស្រី១១នាក់ និងកុមារ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែនមិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ១០២នាក់

https://www.facebook.com/GDIOfficial 10-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់ ស្រី ៤៩នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់៕

## ទាហានថៃឃាត់ខ្លួនពលរដ្ឋខ្មែរ១១នាក់និងពលរដ្ឋថៃម្នាក់ដែលឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 10-12-2020

ខេត្តបន្ទាយមានជ័យ៖ សមត្ថកិច្ចស្រុកតាព្រះយ៉ា បានចាប់ខ្លួនពលរដ្ឋខ្មែរចំនួន១១នាក់ ដែលឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់។ការចាប់ខ្លួនពលរដ្ឋខ្មែរពីសំណាក់សមត្ថកិច្ចថៃធ្វើឡើងកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ នៅចំណុចឈរជើងស្ថិតតាមបន្ទាត់ព្រំដែនក្នុងស្រុកគោកឃ្សូងខេត្តស្រះកែវប្រទេសថៃ។

យោងតាមប្រភពព័ត៌មានពីសមត្ថកិច្ចថៃបានឲ្យដឹងថា ស្របពេលដែលប្រទេសថៃកំពុងជាក់ក្នុងភាពអាសន្ន ដោយការរាតត្បាតនៃជំងឺកូវីដ-១៩ តាមច្រកព្រំដែននានារវាងប្រទេសកម្ពុជា-ថៃត្រូវបានបិទ ពលរដ្ឋប្រទេសទាំងពីរត្រូវបានកាត់ផ្តាច់មិនឲ្យមានការឆ្លងកាត់ទៅមក។ស្របពេលដែលកំពុងរឹតបន្តឹងការរីករាលជំងឺកូវីដ-១៩នេះដែរ គេបានឃើញពលរដ្ឋខ្មែរមួយចំនួនបានលួចឆ្លងដែនតាមបន្ទាត់ព្រំដែនចូលជ្រៅទៅក្នុងភូមិ ណងយែន ឃុំណងមួង ស្រុកគោកឃ្សូងខេត្តស្រះកែវ ដើរទិញមាន់-ទា ដូងនិងទិញម៉ូតូដើម្បីនាំឆ្លងដែនដោយខុសច្បាប់មកកម្ពុជា។ ដោយមើលឃើញដូចនេះ សមត្ថកិច្ចថៃបានចាប់ឃុំខ្លួនពលរដ្ឋខ្មែរទាំងនោះសរុប១១នាក់ ដោយចោទពីបទជាបុគ្គលបរទេសជនជាតិខ្មែរ ចូលមកនិងស្នាក់នៅក្នុងរាជាណាចក្រថៃដោយមិនបានទទួលការអនុញ្ញាត។ សមត្ថកិច្ចថៃក៏បានបញ្ជាក់ផងដែរថាក្រោយពីធ្វើការសួរនាំ ជនត្រូវចោទបានទទួលសារភាពថា ពួកគេពិតជាធ្វើខុសច្បាប់មែន ទើបសមត្ថកិច្ចឃាត់ខ្លួនត្រួតពិនិត្យសីតុណ្ហភាព និងបានបញ្ជូនទៅឲ្យជំនាញស្រុកគោកឃ្សូង និងនគរបាលអន្តោប្រវេសន៍ខេត្តស្រះកែវ ដើម្បីចាត់ការតាមផ្លូវច្បាប់ ។

ពលរដ្ឋខ្មែរដែលបានឃាត់ខ្លួនទាំងអស់ រួមមាន ៖ ១-ឈ្មោះ មិត្ត ម៉ារីន អាយុ៣០ឆ្នាំ ២-ឈ្មោះ ចាន់ ងៀម អាយុ២៥ឆ្នាំ៣-ឈ្មោះឡេង អួន អាយុ២៨ឆ្នាំ៤-ឈ្មោះ រៀន វ៉ាន់ អាយុ២៨ឆ្នាំ ៥-ឈ្មោះ គីន យ៉ា អាយុ៣០ឆ្នាំ៦-ឈ្មោះ ថន ម៉េះ អាយុ៤៥ឆ្នាំ ៧-ឈ្មោះ ឆាយ អាយុ២០ឆ្នាំ ៨-ឈ្មោះ ពៀ សេង អាយុ២៣ឆ្នាំ ៩-ឈ្មោះ សន អាយុ ១៨ឆ្នាំ ១០-ឈ្មោះ គីន ម៉ៃ អាយុ១៤ឆ្នាំ និង១១-ឈ្មោះ ម៉ះ លិលី អាយុ១៣ឆ្នាំ។ក្រៅពីនោះ សមត្ថកិច្ចស្រុកតាព្រះយ៉ា នៅបានទទួលសេចក្តីប្រកាសពីស្មៀនស្រុកគោកឃ្សូង ថានឹងមានការនាំម៉ូតូខុសច្បាប់ឆ្លងទៅប្រទេសកម្ពុជា ផងដែរដោយដឹកតាមរថយន្តបិកអាប់មានឃ្លុប ហើយករណីនេះសមត្ថកិច្ចក្រុមចល័តរហ័ស ស្រុកតាប្រាយ៉ា បានសហការជាមួយអាជ្ញាធរដែនដី,នគរបាលអន្តោប្រវេសន៍ខេត្តស្រះកែវ ,ទាហាន និងនគរបាលស្រុកគោកឃ្សូង បានស្កាត់ចាប់រថយន្តដែលជាគោលដៅមួយគ្រឿងខាងលើ ដោយអ្នកបើករថយន្តមានឈ្មោះ វាំងសាក់ ចៃម៉ាផាក់ឌី អាយុ២៩ឆ្នាំ ជនជាតិថៃ។

សមត្ថកិច្ចចាប់ខ្លួនបាននៅចំណុចស្កាត់ចាប់របស់អាជ្ញាធរភូមិ ណងយ៉ាកែវ ឃុំ គោកឃ្សូង ស្រុកគោកឃ្សូង ខេត្តស្រះកែវដោយដកហូតវត្ថុតាងរថយន្តឯកជនម៉ាក អ៊ីស៊ុយហ្ស៊ុយ ព៌ណស ពាក់ស្លាកលេខ ឍឍ-6595 ក្រុងថេប មួយគ្រឿង។ក្រោយពីធ្វើការត្រួតពិនិត្យក្នុងរថយន្ត រកឃើញម៉ូតូ ម៉ាកហុងដា adv 150ពណ៌ស-ផ្កាឈូក មិនមានពាក់ស្លាកលេខ,ម៉ូតូឃីហោ ហុងដា ACF 110 ពណ៌ស-ក្រហម មិនមានពាក់ស្លាកលេខ,ម៉ូតូ ហុងដា ស្កូពី ពណ៌ទឹកប៊ិក ពាក់ស្លាកលេខ 1កឈ-6853ស្រះកែវ ដោយជនត្រូវចោទបានប្រាប់ថា ខ្លួនស៊ីឈ្នួលទូទៅ ដោយទទួលបានការជួលពីស្វាមី ភរិយា ខាងក្រុមដែលមានឈ្មោះថា"ខែដាំ ឈើង"ជាក្រុមបិទមុខ មានសមាជិក១៨៣នាក់ ដោយបានណាត់ទទួលម៉ូតូនៅប៉ាន់ ណាំ ម៉ាន់ខាលថេក ក្នុងស្រុកទីរួមខេត្ត ឆះឆឹង សៅ ដោយឲ្យថ្លៃជួល១,៨០០បាត ដោយឲ្យដឹកទៅឯភូមិ ណង យ៉ាកែវ ស្រុកគោកឃ្សូង ដោយនៅពេលទៅដល់ឲ្យទាក់ទងជាមួយ ចៃ វ៉ាន់ ដែលមានលេខទូរសព្ទ័084-562759 ដើម្បីបញ្ជូនម៉ូតូបន្ត តែត្រូវសមត្ថកិច្ចចាប់បានមុន ទើបសមត្ថកិច្ចចោទពីបទ ព្យាយាមនាំឬដឹករបស់ដែលនៅមិនទាន់បានបង់ពន្ធ ឬរបស់ត្រូវហាម ឬមិនទាន់បានឆ្លងកាត់និតិវិធីរបស់គយ ចេញក្រៅព្រះរាជាណាចក្រថៃ ដោយជនត្រូវចោទបានសារភាពថា ខ្លួនបានធ្វើខុសពិតមែន ទើបបញ្ជូនទៅឲ្យជំនាញស្រុកគោកឃ្សូង ចាត់ការតាមច្បាប់៕

## ច្រករបៀងប៉ុស្តិ៍ស្វាយចេក ហៅ( ច័ន្ទគិរី ) កំពុងបើកដៃអោយពលករឆ្លងដែនចូលទឹកដីថៃ ដូចហែរកមិនគ្មានច្បាប់!

https://www.facebook.com/neakmeasnews/ 11-12-2020

(ខេត្តបាត់ដំបង) ៖ ពលករខ្មែរ និងក្រុមអាជីវករកំពុងសម្រុកឆ្លងដែនចូលទៅក្នុងទឹកដីថៃយ៉ាងពពាក់ពពូនដូចក្បួនដង្ហែអង្គកឋិនទានខណៈដែលប្រទេសថៃកំពុងរឹតបន្តឹងអំពីជម្ងឺ កូវីដ-១៩ នេះក៏ដោយសារតែមានការបើកដៃដើម្បីទទួលផលពីសំណាក់លោកមេប៉ុស្តិ៍ នៃច្រករបៀងនោះយ៉ាងពិតប្រាកដទើបក្រុមប្រជាពលរដ្ឋហ៊ានដើរឆ្លងខ្សែបន្ទាត់ព្រំដែន ដោយមិនមានការខ្លាចរអា។ យោងតាមប្រភពច្បាស់ការណ៍មួយដែលបានផ្តិតយករូបភាពជាភស្តុតាង នាព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០នេះ បានអោយដឹងថា មានប្រជាពលរដ្ឋជាច្រើនក្នុងនោះក៏មានពលករ និងអាជីវករបាននាំគ្នាសម្រុកឆ្លងដែនចូលទៅក្នុងទឹកដីថៃតាមច្រករបៀង ប៉ុស្តិ៍ស្វាយចេកហៅ (ច័ន្ទគិរី) ក្រោមការគ្រប់គ្រងរបស់លោកមេប៉ុស្តិ៍ យ៉ង សម្បត្តិ ចំណុះអោយនគរបាលវរសេនាតូច ការពារព្រំដែនគោកលេខ៨១៩ រួមនិងកម្លាំងសឹករងស្រុក ដែលច្រកនេះស្ថិតក្នុងភូមិបឹងរាំង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ប្រភពដដែលបានបន្តថា ការធ្វើដំណើរឆ្លងដែនចូលទៅក្នុងទឹកដីថៃនេះ គឺត្រូវបង់ប្រាក់ទៅអោយកម្លាំងដែលឈរជើងនៅតំបន់នោះចាប់ពី១០០ ទៅ២០០ បាត ជាថ្នូរទៅនឹងការបើកច្រកដើម្បីបានចូលទៅក្នុងទឹកដីថៃទិញទំនិញនានា ឬក៏ទៅស៊ីឈ្នួលធ្វើការងារប្រចាំថ្ងៃនៅទីនោះ។

តាមរយៈទូរស័ព្ទនៅព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ នេះដែរលោកមេប៉ុស្តិ៍ យ៉ង សម្បត្តិ បានលើកឡើងថា លោកមិនបានចំហរឬបើកភ្លើងខៀវអោយពលករខ្មែរចេញ ដោយសេរីនោះទេតាមពិតច្រករបៀងប៉ុស្តិ៍ស្វាយចេកឬ ច្រកច័ន្ទគិរីនេះ ត្រូវបានថ្នាក់ដឹកនាំបញ្ជាអោយបើក ដើម្បីទទួលយកពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ដោយសារតែច្រកតំបន់ឬច្រកអន្តរជាតិបានបិទអស់ហើយ។ លោកបានបន្តថា នៅក្នុងខណៈពេលដែលច្រកនេះ បើកចាំទទួលពលករខ្មែរវិលត្រឡប់មកស្រុកកំណើតនេះ ក៏មានបងប្អូនប្រជាពលរដ្ឋដែលរស់នៅក្បែព្រំដែនបានសុំ ឆ្លងចូលទៅផ្សារ ថៃដើម្បីទិញទំនិញផ្សេងៗផង ឯខ្លះទៀតក៏សុំឆ្លងចូលទៅធ្វើការងារអោយថៃ ដើម្បីចិញ្ចឹមជីវភាព គ្រួសារ ដោយចូលព្រឹកចេញមកវិញពេលល្ងាចតែប៉ុណ្ណោះ។ បើទោះបីជមានការបកស្រាយ និងបំភ្លឺពីសំណាក់ លោកមេប៉ុស្តិ៍ក៏ដោយ ក៏មានមជ្ឈដ្ឋានជាច្រើនបានលើកឡើងថា នេះគឺជាការធូរលុងរបស់កម្លាំងដែលឈរជើងនៅ ទីនោះស្របពេលដែលបច្ចុប្បន្នមេរោគកូវីដកំពុងផ្ទុះឡើងយ៉ាងធ្ងន់ធ្ងរវាងប្រទេសនានាលើពិភពលោក ក៏ដូចជានៅ ក្នុងប្រទេសថៃដែរដែលបញ្ហានេះចាំបាច់ត្រូវមានការពង្រឹងតាមខ្សែបន្ទាត់ព្រំដែនអោយបានម៉ត់ចត់ ៕ មួន រិទ្ធីយ៉ា

## ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០២០

## កម្មវិធីទប់ស្កាត់ការជួញដូរមនុស្ស នឹងត្រូវបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ

http://btv.com.kh/ 11/12/2020

ភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិទប់ស្កាត់ការជួញដូរមនុស្ស បានឱ្យដឹងថា ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ កំពុងរៀបចំឯកសារ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស ដើម្បីបញ្ចូលទៅក្នុងកម្មវិធីសិក្សា ខណៈ បញ្ហាការជួញដូរមនុស្សនេះ នៅមានការព្រួយបារម្ភនៅឡើយចំពោះរាជរដ្ឋាភិបាល។

នៅក្នុងកិច្ចសម្ភាសន៍ជាមួយBTV កាលពីថ្ងៃទី១០ ខែធ្នូ ម្សិលមិញ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិទប់ស្កាត់ការជួញដូរមនុស្ស បានឱ្យដឹងថា ការជួញ ដូរមនុស្សនៅតែបន្តកើតមាន ទោះបីបិតក្នុងអំឡុងពេល នៃការរាតត្បាតនៃកូវីដ–១៩ ដែលបណ្តាប្រទេស ជិតខាង កម្ពុជា បានបិទច្រកចេញចូលក៏ដោយ។ ពួកឱកាសនិយម បានលួងលោមប្រជាពលរដ្ឋតាមរូប ភាពផ្សេងៗ ដើម្បី ផលប្រយោជន៍ផ្ទាល់ខ្លួន ដោយនាំទៅ ធ្វើការនៅក្រៅប្រទេសតាមផ្លូវកាត់ប្រកបដោយ គ្រោះថ្នាក់ និងតាមរយៈ អាពាហ៍ពិពាហ៍ជាមួយប្តីបរទេស ជាដើម។ លោកជំទាវ បានអំពាវនាវជាថ្មីម្តងទៀតដល់ជនរួមជាតិទាំងអស់ កុំឱ្យ ចាញ់បោកមេខ្យល់ ដែលនាំទៅធ្វើការដោយខុសច្បាប់ ដែលអាចនឹងធ្វើឱ្យជួបនូវបញ្ហាច្រើន ពិសេសគ្រោះថ្នាក់ ដោយសារការឆ្លងមេរោគកូវីដ–១៩ អំឡុងពេលនេះ ។

លោក ឯក សំអុល តំណាងអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ប្រចាំកម្ពុជា បានឱ្យដឹងថា អង្គការ នេះ តែងតែធ្វើការគាំទ្រសកម្មភាពរបស់រាជរដ្ឋាភិបាលជានិច្ច ក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ព្រោះបញ្ហានេះ គឺ តម្រូវឱ្យមានការរួមគ្នាពីគ្រប់ភាគីទាំងអស់ ដោយមិនត្រូវទម្លាក់ដៃចោលនោះឡើយ ខណៈរាជរដ្ឋាភិបាល បាននឹង កំពុងបន្តស្វែងរកចាប់ខ្លួនមេខ្យល់ ដើម្បីយកមកផ្តន្ទាទោសទៅតាមច្បាប់។

រហូតមកដល់ថ្ងៃទី១០ ខែធ្នូ នេះ មានពលករខ្មែរចំណាកស្រុក ទៅធ្វើការនៅប្រទេសថៃ ចំនួន ជាង១២ម៉ឺន នាក់ បានវិលមកវិញ ហើយពួកគេទាំងនោះ ពុំត្រូវបានរកឃើញថាមានករណីកូវីដ–១៩ដែរ តែទោះជាយ៉ាងណា រាជរដ្ឋាភិបាល នៅតែមានការព្រួយបារម្ភចំពោះពួកគេនៅឡើយ ដោយសារតែពួកគេ ងាយត្រូវបានបោកប្រាស់ ដោយពួកឱកាសនិយម ឱ្យវិលត្រឡប់ទៅធ្វើការនៅក្រៅប្រទេសវិញ ដោយផ្សង នឹងគ្រោះថ្នាក់ជាច្រើន៕ អត្ថបទ៖ បាន ចក់

# លីកាដូរកឃើញថា ការរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារី ដោយសាច់ញាតិកើនឡើង និងគ្មានយុត្តិធម៌ពេញលេញ

https://www.rfa.org/khmer/ ដោយ សន ចាន់រដ្ឋា 2020-12-12

អង្គការការពារសិទ្ធិមនុស្សលីកាដូ(Licadho) រកឃើញថា ករណីរំលោភសេពសន្ថវៈលើស្ត្រី និងកុមារី ប្រព្រឹត្តដោយសាច់ញាតិ កើនឡើងគួរឲ្យព្រួយបារម្ភ ហើយជនរងគ្រោះនៅតែជួបឧបសគ្គក្នុងការទទួលបានយុត្តិធម៌ ដោយសារការអនុវត្តច្បាប់របស់អាជ្ញាធរធូររលុង។ អង្គការលីកាដូ និងជនរងគ្រោះ ជំរុញឲ្យអាជ្ញាធរពង្រឹងការអនុវត្តច្បាប់ដើម្បីលុបបំបាត់ អំពើរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារី។ របាយការណ៍អង្គការលីកាដូរកឃើញថា ជិតមួយភាគបីនៃករណីរំលោភលើស្ត្រី និងកុមារី គឺជនសង្ស័យ ជាសាច់ញាតិរបស់ជនរងគ្រោះ ហើយជារឿយៗជនរងគ្រោះតែងជួបផលលំបាក ទទួលបានតម្រូវការសុវត្ថិភាព និងយុត្តិធម៌។ របាយការណ៍ដែលអង្គការលីកាដូចេញផ្សាយនៅក្នុងខែធ្នូនេះ មានចំណងជើងថា "ទម្លាយភាពស្ងៀមស្ងាត់៖ ការរំលោភសេពសន្ថវៈដោយសាច់ញាតិ និងឧបសគ្គក្នុងការទទួលបានយុត្តិធម៌" ។របាយការណ៍កម្រាស់២៥ទំព័រនេះ បង្ហាញថា នៅក្នុងករណីរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈទាំងអស់ដែលអង្គការលីកាដូបានធ្វើអន្តរាគមន៍ចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ ខែធ្នូ ឆ្នាំ២០១៩ រកឃើញថា មានចំនួន១៣៧ករណី គឺជនសង្ស័យជាសាច់ញាតិរបស់ជនរងគ្រោះ ដូចជាឪពុក ពូ ឬជីតាបង្កើត៤៦ភាគរយ និងពីអំពើហិង្សាផ្លូវភេទប្រព្រឹត្តដោយឪពុកចុង ឬសាច់ញាតិឪពុកចុង និងសាច់ថ្លៃ មាន៥៤ភាគរយ។

ចាប់តាំងពីខែមិថុនា ដល់ខែសីហា ឆ្នាំ២០២០ អង្គការលីកាដូ បានធ្វើបច្ចុប្បន្នភាពអំពីស្ថានភាព ឬលទ្ធផលរបស់ករណីនីមួយៗទាំង១៣៧ ឡើងវិញ ដោយទទួលបានព័ត៌មានថ្មីបំផុតនៃករណីចំនួន១៣៥។ ក្នុងនោះ មានករណីចំនួនលើសពីពាក់កណ្តាលបន្តិចប៉ុណ្ណោះ ឬស្មើនឹង៥៣ភាគរយ បានឈានដល់ការជំនុំជម្រះក្តី ដោយជនល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពេញលេញតាម ច្បាប់ពាក់ព័ន្ធ ។ ចំណែកចំនួនករណីតិចជាងមួយភាគប្រាំ ឬស្មើនឹង១៩ភាគរយ គឺជនល្មើសត្រូវបានផ្តន្ទាទោសក្នុងកម្រិតស្រាលដោយជាប់ពន្ធនាគាររយៈពេលខ្លី និងការកាត់ទោសកំបាំងមុខ និងមិនត្រូវបានចាប់ខ្លួន។ ក្រៅពីនេះ ករណីខ្លះ រកឃើញថា មានការដោះស្រាយបញ្ចប់ក្រៅប្រព័ន្ធតុលាការ និងពន្យារពេលកាត់ក្តី ហើយជនរងគ្រោះមានសង្ឃឹមតិចតួចទទួលបានយុត្តិធម៌។ អង្គការលីកាដូបន្តថា ឧបសគ្គក្នុងការទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះទាំងនេះដោយសារមានកត្តាជាច្រើន ដូចជាអំពើពុករលួយ កង្វះការការពារជនរងគ្រោះ សម្ពាធពីសមាជិកគ្រួសារ និងប៉ូលិសមិនឲ្យរាយការណ៍ទៅខាងក្រៅ ដើម្បីការពារកិត្តិយស អាជ្ញាធរមួយចំនួនជួយជ្រោមជ្រែងឲ្យបញ្ចប់រឿងក្រៅប្រព័ន្ធតុលាការ ការធ្វើដំណើរវែងឆ្ងាយ និងចំណាយប្រាក់ច្រើនក្នុងដំណើរការរឿងក្តីនៅតុលាការ។ ករណីខ្លះទៀត ជនរងគ្រោះសម្រេចដកបណ្តឹងវិញ ដោយសារតែជនល្មើសជាអ្នករកស៊ីផ្គត់ផ្គង់ជីវភាពគ្រួសារ។

ករណីមួយដែលបានលើកឡើងក្នុងរបាយការណ៍ គឺក្មេងស្រីម្នាក់ត្រូវបានដាក់ឈ្មោះឲ្យថា សីហា ។ នាងត្រូវបានជីតា គំរាមសម្លាប់ និងចាប់រំលោភ។ ឪពុកម្តាយរបស់កុមារីសីហា រៀបរាប់ប្រាប់លីកាដូថា ក្រោយកើតហេតុ គឺពួកគាត់ បាននាំកូនស្រីដាក់បណ្តឹងនៅប៉ុស្តិ៍ប៉ូលិស ប៉ុន្តែពេលនោះ ប៉ូលិស បានណែនាំឲ្យពួកគាត់រក្សាភាពស្ងៀមស្ងាត់សិន រហូតដល់ជនសង្ស័យរត់គេចខ្លួនបាត់៖ «ប៉ូលិសកាលណោះអត់សួរខ្វះខ្វែង។ ខ្វះខ្វែងបានតែមួយពេលកើតហេតុដំបូង ក្រោយពេលនោះមកអត់មានរវល់ជាមួយអីទៀតផង។ ប៉ូលិសថា រឿងនេះកុំឲ្យបែកខ្ចាត់ខ្ចាយធ្វើការដោយដោយស្ងប់ស្ងាត់។ខ្ញុំថា រឿងប៉ុណ្ណឹងហើយកូនខ្ញុំប៉ុណ្ណឹងហើយ ចង់ឲ្យស្ងប់ស្ងាត់អីទៀត។ ប៉ូលិសថា តើខ្ញុំចង់ទាមទារជាសំណងអីអត់? ។ខ្ញុំ ថាអត់ចង់ទាមទារជាសំណងអីទេ គឺចង់ឲ្យខាងលោក និងតុលាការ ស៊ើបអង្កេតរកមនុស្សឲ្យបាននិងដាក់ទោសតាមច្បាប់។ខ្ញុំនៅតែខឹង។ នឹកឃើញរឿងហ្នឹងចង់តែ..ក្តៅតែម្តង។ ចង់ឲ្យ ប៉ូលិសចាប់ឲ្យបានភ្លាមៗ។

អង្គការលីកាដូ កត់សម្គាល់ថា ហានិភ័យនៃការរំលោភសេពសន្ថវៈក្នុងរង្វង់គ្រួសារទំនងជាកើនឡើងច្រើន កាលពីឆ្នាំមុន ខណៈដែលសាលារៀនបានបិទ ហើយកត្តាអ្នកគ្មានការងារធ្វើគឺកើនឡើងជាមួយនឹងការរីករាលដាលនៃជំងឺកូវីត១៩ ដែលនាំឱ្យមនុស្សជាច្រើនត្រូវចំណាយពេលនៅផ្ទះច្រើន និងស្ថិតនៅក្បែរជនល្មើស។ កត្តាគួបផ្សំមួយចំនួនទៀត ដែលនាំឲ្យមានការកើនឡើងនៃករណីចាប់រំលោភផ្លូវភេទលើស្ត្រី និងកុមារី ក៏បណ្តាលមកពីការធ្លាក់ចុះសីលធម៌សង្គម ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ការខ្វះចន្លោះនៃការត្រួតពិនិត្យវីដេអូអាសអាភាស និងបញ្ហាក្រីក្រ។

នាយករងទទួលបន្ទុកផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្សនៃអង្គការលីកាដូ លោក អំ សំអាត មានប្រសាសន៍ថា ការចេញរបាយការណ៍នេះ ដោយសារថា គ្រោះថ្នាក់នៃអំពើរំលោភសេពសន្ថវៈក្នុងរង្វង់គ្រួសារ គឺកើតមានឡើងច្រើន និងគួរឲ្យព្រួយបារម្ភ ប៉ុន្តែអាជ្ញាធរនៅតែមិនទាន់ចាត់វិធានការគ្រប់គ្រាន់ដើម្បីធ្វើឱ្យប្រាកដថា ជនល្មើសត្រូវបានយកមកផ្តន្ទាទោស។ លោកបន្តថា សិទ្ធិរបស់ស្ត្រី និងក្មេងស្រី មិនត្រូវមើលរំលងឡើយ ហើយអំពើរំលោភសេពសន្ថវៈគឺជាបទល្មើសព្រហ្មទណ្ឌដែលអាចអត់ឱនឱ្យបាននោះទេ៖ «ប៉ះពាល់ទី១ គឺបាត់យុត្តិធម៌សម្រាប់ជនរងគ្រោះ ដែលជាការរំលោភដោយសាច់ញាតិនេះ បញ្ហាទី២ វាបង្កឲ្យមាននិទ្ទណ្ឌភាពកើតឡើងចំពោះករណីនេះ ហើយទី៣ ស្ត្រីនិងកុមាររងគ្រោះ ត្រូវបានមើលរំលងហើយបទល្មើសព្រហ្មទណ្ឌ មិនត្រូវបានដំណើរការទៅតាមផ្លូវច្បាប់ ដើម្បីស្វែងរកយុត្តិធម៌ ហើយគំរូអាក្រក់នេះ វាអាចកើតមានបន្តទៀត ប្រសិនបើយើងមិនបានចាត់វិធានការតឹងរ៉ឹងទប់ស្កាត់ និងដាក់ទោសទណ្ឌឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់»។ អង្គការមួយនេះ លើកឡើងថា ឧបសគ្គដែលចាក់ឬស និងមានជាយូរណាស់មកហើយក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយបានបណ្តាលឲ្យអំពើរំលោភសេពសន្ថវៈចំពោះស្ត្រីនិងកុមារី កាន់តែមានស្ថានភាពអាក្រក់ខ្លាំងឡើង។

ទាក់ទងករណីនេះរដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកការប្រឆាំងការជួញដូរមនុស្សអ្នកស្រី ជូ ប៊ុនអេង ទទួលស្គាល់អំពីការកើនឡើង នៃអំពើរំលោភសេពសន្ថវៈលើស្ត្រី និងកុមារីដែលប្រព្រឹត្តដោយសាច់ញាតិរបស់ខ្លួន ដោយសារតែការផ្សព្វផ្សាយរូបភាព និងវីដេអូអាសអាភាសនៅលើប្រព័ន្ធអ៊ីនធឺណិត (Internet) ឬអនឡាញ (Online)។ ទោះយ៉ាងណា អ្នកស្រីអះអាងថា អាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋាភិបាល មិនបានព្រងើយកន្តើយចំពោះបញ្ហាទាំងនេះទេ។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃរូបនេះ បញ្ជាក់ថា រដ្ឋាភិបាល បានបង្កើតទាំងគោលនយោបាយ និងច្បាប់ជាច្រើន ហើយពេលនេះ រដ្ឋាភិបាលកំពុងបង្កើតច្បាប់មួយទៀត ស្តីពីការគ្រប់គ្រងប្រព័ន្ធអនឡាញជាដើម ។ លើសពីនេះ អាជ្ញាធរ កំពុងបង្កើនសកម្មភាពផ្សព្វផ្សាយអប់រំដល់ពលរដ្ឋ ខណៈក្រសួងយុត្តិធម៌ ក៏បានប្តេជ្ញាធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ផងដែរ៖ «សមត្ថកិច្ច និងរដ្ឋាភិបាលកម្ពុជា មិនបានព្រងើយកន្តើយ ឬហៅថា អូសបន្លាយការងារនេះឲ្យរំលងផុតទេ បើសិនជាយើងបានដឹង គឺយើងតែងមានវិធានការ ហើយនៅពេលដែលគេរំលោភ ឬគេធ្វើការបំពានហ្នឹង គេមិនដែលឲ្យដឹងទេ ប៉ុន្តែការរំលោភបំពានហើយឬមួយមានភាពរងគ្រោះហើយទើបបានយើងដឹងទើបបានយើងចាត់វិធានការ។ នេះគឺជា រឿងដែលយើងសោកស្តាយ បានមានន័យថា វិធានការដែលយើងចាត់ គឺនៅក្រោយពេលដែលរឿងហ្នឹងវាបានកើតឡើងរួចហើយ។ ចំពោះការអប់រំយើងបានធ្វើជាប្រចាំ»។

អង្គការលីកាដូ ផ្តល់អនុសាសន៍ថា ការទប់ស្កាត់ និងលុបបំបាត់អំពើរំលោភសេពសន្ថវៈគឺនៅតែអាចធ្វើទៅបាន ប៉ុន្តែទាមទារឱ្យមានការចាត់វិធានការជាបន្ទាន់។ ការលុបបំបាត់ទំនៀមទម្លាប់យេនឌ័រគ្រោះថ្នាក់ ការបញ្ចប់វប្បធម៌ស្តីបន្ទោសជនរងគ្រោះ ការធានាអំពីការប្រើប្រាស់ច្បាប់ឱ្យបានពេញលេញនិងត្រឹមត្រូវនិងការបង្កើនកិច្ចការពារជនរងគ្រោះ ការទទួលបានសេវាកម្ម និងការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់អ្នកដែលរាយការណ៍ពីអំពើរំលោភសេពសន្ថវៈ គឺជាជំហានដ៏មានសារៈសំខាន់ខ្លាំងដើម្បីធានាថា គ្រប់គ្នាអាចរស់នៅដោយគ្មានអំពើហិង្សាផ្លូវភេទ៕

# លោក រ៉ាត់ រត្នមុនី ត្រូវបានតុលាការសម្រេចដោះលែងឲ្យមានសេរីភាព ក្រោយពីអនុវត្តទោសក្នុងពន្ធនាគាររួច

https://www.cen.com.kh/archives/ December 12, 2020

លោក រ៉ាត់ រត្នមុនី ត្រូវបានតុលាការសម្រេចដោះលែងឲ្យមានសេរីភាពឡើងវិញហើយ នៅរសៀលថ្ងៃទី១១ ធ្នូនេះ បន្ទាប់ពីលោកអនុវត្តទោសអស់រយៈពេល២ ឆ្នាំ។ ផលិតកររឿង «ម្ដាយខ្ញុំលក់ខ្ញុំ» របស់ទូរទស្សន៍រុស្ស៊ី RT គឺលោក រ៉ាត់ រត្នមុនី ត្រូវតុលាការផ្តន្ទាទោសលោកឱ្យជាប់ពន្ធនាគារ២ ឆ្នាំ ពីបទ "ញុះញង់ឱ្យមានការរើសអើង" ដោយសារលោកជួយផលិតភាពយន្តឯកសារស្តីពីការជួញដូរផ្លូវភេទនៅកម្ពុជា ឱ្យសារព័ត៌មាន RT (Russia Today) របស់រុស្ស៊ី។ លោក រ៉ាត់ រត្នមុនី ត្រូវសមត្ថកិច្ចថៃចាប់ឃាត់ខ្លួននៅទីក្រុងបាងកក កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ ខណៈលោកព្យាយាមសុំសិទ្ធិជ្រកកោននៅឯការិយាល័យសុំទិដ្ឋាការទៅប្រទេសហូឡង់ នៅប្រទេសថៃ។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្តន្ទាទោសលោកឱ្យជាប់ពន្ធនាគារចំនួន២ឆ្នាំ ក្រោមបទចោទ « ញុះញង់ឱ្យមានការរើសអើង» កាលពីថ្ងៃទី២៦ ខែមិថុនា តាមការចោទប្រកាន់របស់ដើមបណ្ដឹងចំនួន៥នាក់ គឺលោក នាក់ សុទ្ធា នាយកសាលាឥន្ទ្រទេវី, កញ្ញា គៀង ស្រីម៉េច, កញ្ញា លឹម ស្រីទី, អ្នកស្រី ទេព សាលីម និងអ្នកស្រី កែវ ម៉ាឡែ។

លោក នាក់ សុទ្ធា នាយកវិទ្យាល័យឥន្ទ្រទេវី បានបញ្ជាក់ជូនអង្គសវនាការនាពេលកន្លងមកថា លោក រ៉ាត់ រត្នមុនី បានស្នើសុំទីតាំងសាលារបស់លោក ថតវីដេអូ រឿងជីវភាពប្រជាពលរដ្ឋខ្មែរក្រោយរបបប៉ុលពត។ ផ្ទុយពីការស្នើសុំ លោក រ៉ាត់ រត្នមុនី បែរជាផលិតវីដេអូ ពាក់ព័ន្ធម្ដាយលក់កូន ឲ្យទៅបម្រើសេវាផ្លូវភេទ ដែលជាការប៉ះពាល់ដល់កិត្តិយសរបស់សាលា រហូតថ្នាក់ដឹកនាំហៅលោកទៅសាកសួរ និងស្ដីបន្ទោស ហើយតួអង្គ និងជាជនរងគ្រោះនៃសំណុំរឿងនេះ ក៏បានអះអាងដូចៗគ្នាថា មុនពេលថតវីដេអូ លោក រ៉ាត់ រត្នមុនី បានសន្យានឹងរកជំនួយជួយពួកគេឲ្យបើកមុខរបរ តាមរយៈជំនួយដែលបានពីការចាក់ផ្សាយវីដេអូនេះ។

សូមរំលឹកថា នៅក្នុងសវនាការកន្លងទៅ ជនត្រូវចោទ រ៉ាត់ រត្នមុនី បានអះអាងថា «ខ្ញុំគ្រាន់តែជាអ្នកបកប្រែឲ្យគេ ចំណែករឿងថត និងកាត់តវីដេអូ យកទៅផ្សាយ ខ្ញុំអត់បានដឹងទេ»។ ជនជាប់ចោទ បានបញ្ជាក់ទៀតថា « ហើយខ្ញុំ ក៏មិនបានស្គាល់តួអង្គក្នុងរឿងនោះដែរ គឺក្រុមអ្នកកាសែតរុស្ស៊ីទាំងអស់នោះ ជាអ្នកស្វែងរកដោយខ្លួនពួកគេ គឺក្រុមអ្នកសារព័ត៌ RT (Russia Today) របស់ប្រទេសរុស្ស៊ីទេ ដែលផលិតវីដេអូរឿង ម្ដាយខ្ញុំលក់ខ្ញុំ ដោយសន្យាជាមួយតួអង្គថា នឹងផ្តល់លុយកាក់ខ្លះ ដើម្បីចាយវាយ និងផ្តល់លុយឲ្យបើកមុខរបរតូចៗ តាមចិត្តរបស់ពួកគេប៉ងប្រាថ្នាផងដែរ»។

លើសំណុំរឿងដដែលនេះ កន្លងមក លោក សេង ឫទ្ធី ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនបុគ្គលឈ្មោះ រ៉ាត់ រត្នមុនី មានមុខងារជាទីភ្នាក់ងារសារព័ត៌មានរុស្ស៊ី (RT) គឺបន្ទាប់ពីសមត្ថកិច្ចថៃ បានចាប់ខ្លួន រួចបញ្ជូនមកឱ្យរដ្ឋាភិបាលកម្ពុជាវិញ តាមការស្នើសុំរបស់ភាគីកម្ពុជា ពាក់ព័ន្ធករណីផលិតខ្សែវីដេអូរឿង «ម្តាយខ្ញុំលក់ខ្ញុំ» ដែលជាទម្រង់ នៃការផ្សាយព័ត៌មានមិនពិត ដែលនាំដល់ការអាប់ឱនកិត្តិយសប្រទេសកម្ពុជា។ លោក សេង ឫទ្ធី បានសម្រេចបង្គាប់ឱ្យយកជនត្រូវចោទរូបនេះ ទៅដាក់ពន្ធនាគារព្រៃស ដើម្បីរង់ចាំការជំនុំជម្រះទោស នៅពេលក្រោយតាមកំណត់ច្បាប់។

សូមបញ្ជាក់ថា ខ្សែរវីដេអូ «ម្តាយខ្ញុំលក់ខ្ញុំ» បាននិយាយពីស្ត្រីខ្មែរ ដែលលក់កូនស្រីខ្លួនឯងដោយសារតែជីវភាពខ្វះខាត និងរៀបរាប់ពីស្ថានភាព នៃការប្រកបអាជីវកម្មផ្លូវភេទនៅកម្ពុជា។ ខ្សែរវីដេអូនេះ បានធ្វើឱ្យរាជរដ្ឋាភិបាល យល់ឃើញថា ជាការមួលបង្កាច់កិត្យានុភាព កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរ និងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់កម្ពុជា។ **រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ**

## ឆ្នាំ២០២០ សមត្ថកិច្ចខេត្តកំពង់ចាម បានជួយស្ត្រីខ្មែរ រៀបជាមួយជនបរទេសមិនស្របច្បាប់៣ករណី និងបានឃាត់មេខ្យល់បញ្ជូនទៅតុលាការ

https://www.pdikampongcham.info/ ១១ ខែធ្នូ ២០២០ អត្ថបទដោយ៖ លោកស្រីពុធ ធារី

មានស្ត្រីខ្មែរនៅមូលដ្ឋាន បានចាញ់បោកមេខ្យល់អូសទាញស្ត្រីខ្មែរបំរុងយកទៅរៀបការជាមួយជនបរទេស បាន៣ករណី ក្នុងនោះស្នងការនគរបាលខេត្តបានជួយរំដោះស្ត្រីរងគ្រោះបានទាំង៣ករណី រីឯមេខ្យល់ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ នេះជាការលើកឡើងរបស់ លោកវរសេនីយឯក ឈួន ចាន់ឡា នាយការិយាល័យស៊ើបអង្កេត និងអនុវត្តនិតិវិធីនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ដែលបានចូលក្នុងកម្មវិធីសន្ទនាមតិរបស់វិទ្យុជាតិភ្នំប្រុសភ្នំស្រី នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០។

លោកវរសេនីយឯក ឈួន ចាន់ឡា មានប្រសាសន៍ថា កន្លងមកនៅក្នុងខេត្តកំពង់ចាម ក៍ធ្លាប់មានករណីស្ត្រីខ្មែររៀបការជាមួយនិងជនបរទេស និងធ្លាប់កើតមានបញ្ហាមួយចំនួន ដូចជា ការក្លែងបន្លំឯកសារនានា, អាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទជាដើម ។ ក្នុងនោះអាជ្ញាធរមូលដ្ឋានរួមនិងសមត្ថកិច្ចក៏ធ្លាប់បានជួយរំដោះស្ត្រីរងគ្រោះ ដែលរៀបការជាមួយជនបរទេស ហើយរងនូវសំពាធផ្សេង ដោយមានទាំងអំពើហិង្សាបានជាច្រើនករណីទៀតផងដែរ។ លោកវរសេនីយឯក ឈួន ចាន់ឡា បន្តទៀតថា ពាក់ព័ន្ធនឹងការផ្សព្វផ្សាយឆ្នាំ២០២០នេះ ស្នងការដ្ឋានបានសហការជាមួយអាជ្ញាធរមូលដ្ឋានបានជា១០០០លើក តាមរយៈចុះចែកសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណ និងគោលការណ៍ភូមិឃុំមានសុវត្ថភាព។ គោលការណ៍បន្ត ខាងស្នងការដ្ឋាននៅតែបន្តការផ្សព្វផ្សាយអប់រំពលរដ្ឋឲ្យបានយល់ដឹងកុំឲ្យរងការចាញ់បោកមេខ្យល់តទៅទៀត។ រាជរដ្ឋាភីបាលមានការបើកឲ្យរៀបអាពាហ៍ពិពាហ៍ឡើងវិញ ក៏ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍នោះ គឺមិនត្រូវធ្វើតាមរយៈភ្នាក់ងាររើសគូស្រករ, ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្មទេ។ ជាងនេះទៅទៀត អនុក្រឹត្យតំរូវឲ្យជនបរទេសដែលមានបំណងចង់រៀបការត្រូវមកបំពេញសំណុំបែបបទដោយផ្ទាល់ខ្លួននៅក្នុងប្រទេសកម្ពុជា៕

## ឃាត់ខ្លួនពលរដ្ឋខ្មែរម្នាក់ ឆ្លងដែនចូលប្រទេសដោយខុសច្បាប់

https://www.facebook.com/GDIOfficial 13-12-2020

កោះកុង៖ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៦និង៤០នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតក្នុងភូមិសាស្ត្រស្លាបឆ្វេង ពិនិត្យឃើញពលរដ្ឋខ្មែរ ឆ្លងដែនចូលប្រទេសដោយខុសច្បាប់ចំនួន ០១នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរនេះ មានឈ្មោះ យុត សារិន ភេទប្រុស អាយុ ២៧ឆ្នាំ នៅភូមិកណ្តាល ឃុំក្រញូង ស្រុកកំចាយ មា ខេត្តព្រៃវែ និងបានធ្វើការសាកសួរ អប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័ក ប្រចាំមាត់ច្រក ដើម្បីអនុវត្តនិតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៥០នាក់

https://www.facebook.com/GDIOfficial 13-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះ

អាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥០នាក់ ស្រី ២៣នាក់៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៨៧នាក់

https://www.facebook.com/GDIOfficial 12-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៧នាក់ ស្រី ៣២នាក់៕

## ឃាត់ពលរដ្ឋខ្មែរ០២នាក់ វិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ តាមរបៀបស្លាបស្ពាំ របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 12-12-2020

បាត់ដំបង៖ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ០៩និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ធ្វើការឃាត់បានពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ តាមរបៀបស្លាបស្ពាំ របស់ប៉ុស្តិ៍ ចំនួន ០២នាក់ រួចបាននាំពួកគាត់មកកាន់ផ្នែករដ្ឋបាល-សរុប ដើម្បីសួរនាំព័ត៌មាន និងបានសហការជាមួយមន្ត្រីចត្តាឡីស័ក ធ្វើការពិនិត្យកំដៅជូនពួកគាត់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃ ទាំង០២នាក់នេះ មាន ១. ឈ្មោះ ធូត ធរ ភេទប្រុស អាយុ ២៩ឆ្នាំ, ២. ឈ្មោះ ធូត រី ភេទស្រី អាយុ ២៦ឆ្នាំ ហើយអ្នកទាំងពីរមានទីលំនៅភូមិក្រសាំង ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង។ បន្ទាប់មកកម្លាំងប៉ុស្តិ៍ បានធ្វើលិខិតប្រគល់-ទទួល ពលរដ្ឋខាងលើនេះ ឲ្យទៅមន្ត្រីចត្តាឡីស័ក ដើម្បីយកទៅពិនិត្យសំណាកធ្វើតេស្តរកវីរុសកូវីដ-១៩ នៅមណ្ឌលសុខភាពស្រុកសំពៅលូន ខេត្តបាត់ដំបង៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ០៦នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 11-12-2020

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង១០នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៦នាក់ ស្រី ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុម

ការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ០៣ នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial 11-12-2020

កោះកុង៖ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៦និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១-ឈ្មោះ ណន់ មិច ភេទប្រុស អាយុ ៣០ឆ្នាំ នៅភូមិសំរោង ឃុំសំរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង, ២-ឈ្មោះ ងួត រ៉ាត ភេទប្រុស អាយុ ៣០ឆ្នាំ, ៣-ឈ្មោះ ឡឹក រដ្ឋា ភេទស្រី អាយុ ៣០ឆ្នាំ នៅភូមិដំណាក់ចំបក់ ឃុំអូរក្រេសា ស្រុកអូរក្រេសា ខេត្តកែប និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ១១៨នាក់

https://www.facebook.com/GDIOfficial 11-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ចង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្នមិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៨នាក់ ស្រី ៤៨នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៤នាក់៕

## ពលករខ្មែរ ២ នាក់ ប្តី ប្រពន្ធ ត្រូវថៅកែថៃ ប្រើកាំភ្លើងបាញ់គំរាម

http://kampucheathmey.com/ December 11, 2020 By Bo Doula

ប្រទេសថៃ ៖ ថ្មីៗនេះមានឃ្លីបវីដេអូមួយ ត្រូវបានគេបង្ហោះឡើងនៅក្នុងប្រទេសថៃ ដែលឃ្លីបនេះបាននិយាយអំពីថៅកែថៃម្នាក់ បានប្រើប្រាស់កាំភ្លើងខ្លី ធ្វើការបាញ់គំរាម ចំនួន ១ គ្រាប់ ទៅលើពលករខ្មែរ ២នាក់ ប្តីប្រពន្ធ ដែលកំពុងធ្វើការនៅក្នុងចម្ការដំឡូងមួយកន្លែង នៅក្នុងប្រទេសថៃ ព្រមទាំងមានការប្រកែកគ្នា និងទាស់ពាក្យសម្តីគ្នាផងដែរ ។ លុះនៅព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០នេះ ទើបរឿងនេះ ត្រូវបានបែកធ្លាយដោយជនរងគ្រោះមានឈ្មោះ វេត កញ្ញា អាយុ៣២ឆ្នាំ និងប្រពន្ធឈ្មោះ ឈឿម សាវី អាយុ៣៥ ឆ្នាំ អ្នកទាំង ២ មានស្រុក

កំណើតនៅឃុំតាលាស់ ស្រុកមោង ឬស្សី ហើយបច្ចុប្បន្នក៏បានផ្លាស់ប្តូរទីលំនៅ ទៅរស់នៅភូមិឈទាល ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

តាមការរៀបរាប់នៅលើខ្សែអាត់សម្លេងបានបញ្ជាក់ថា ហេតុការណ៍នេះ បានកើតឡើង កាលពីថ្ងៃទី ៣ ខែធ្នូ ឆ្នាំ២០២០ នៅលើដីចម្ការមួយកន្លែង ស្ថិតក្នុងស្រុក ខៅសីនសន លើព្រំប្រទល់តំបន់ត្រីកោណ រវាងខេត្តស្រះកែវ ខេត្តប្រាជីនបុរី និងខេត្តឆៈឈើងសៅ។ នៅក្នុងខ្សែអាត់ដដែលបានបញ្ជាក់ថា ជនរងគ្រោះទាំង២ នាក់ដែលមានកូនតូចផង បានសុំថៅកែវិលត្រឡប់ទៅស្រុកកំណើតមួយរយៈ ដោយសារតែឪពុកមានជំងឺ ប៉ុន្តែត្រូវបានថៅកែ មិនឲ្យត្រឡប់ឡើយ ដោយចោទប្រកាន់ថា ពួកគេនៅជំពាក់លុយ៥ ពាន់បាតទៀតថ្លៃរត់ការតប៉ាស្ព័រ ។ ជនរងគ្រោះបានអះអាងថា ខ្លួនមិនបានជំពាក់មួយបាតនោះឡើយ ហើយប៉ាស្ព័ររបស់ខ្លួនត្រូវបានថៅកែដកទុកមិនព្រមប្រគល់ឲ្យវិញទេ ហើយប្រាប់ថា នឹងយកទៅរត់ការ តប៉ាស្ព័រ ថ្មីឲ្យ ប៉ុន្តែរាប់ខែមកហើយ ប៉ាស្ព័រថ្មី ក៏មិនឃើញ ឯប៉ាស្ព័រចាស់ ខ្លួនទាមទាយកមកវិញក៏មិនបានដែរ ។ ខណៈដែលកំពុងប្រកែកគ្នាបានបន្តិច ថៅកែថៃបានបើកទ្វាររថយន្តទាញយកកាំភ្លើងខ្លួន បាញ់ ១ គ្រាប់ ទៅលើដី ខាងមុខជើងបុរសជាប្តីតែម្តង ទើបធ្វើឲ្យស្ត្រីជាភរិយាទាញទូរស័ព្ទដៃ ថតផ្តិតយករូបភាពតែម្តងដើម្បីទុកជាភស្តុតាង ព្រោះខ្លាចប្តីរបស់ខ្លួនស្លាប់ដោយសារថៃបាញ់ ។

តាមការស្រាវជ្រាវរបស់អង្គការ ខ្មែរជួយខ្មែរ ប្រចាំប្រទេសថៃ ដែលមានស្នាក់ការនៅក្បែរស្ពានទូតខ្មែរ បានចុះទៅជួបនឹងជនរងគ្រោះហើយ ដើម្បីជួយអន្តរាគមន៍ ៕ **អត្ថបទ ៖ សោ និយមរ័ត្ន**

## បណ្តាញពលករកម្ពុជាប្រចាំប្រទេសថៃ កំពុងតាមដានលើករណីសំណុំរឿងថៅកែថៃប្រើប្រាស់អាវុធបាញ់គំរាម ពលករខ្មែរពីរនាក់ប្តីប្រពន្ធ

https://www.facebook.com/MigrantCambodia/ 13-12-2020

បណ្តាញពលករកម្ពុជាប្រចាំប្រទេសថៃ កំពុងតាមដានលើករណីសំណុំរឿងថៅកែថៃប្រើប្រាស់អាវុធបាញ់គំរាមពលករខ្មែរពីរនាក់ប្តីប្រពន្ធ កាលពីដើមខែធ្នូនេះជនរងគ្រោះត្រូវថៅកែបាញ់គំរាមមានឈ្មោះ រ៉េត កញ្ញា ភេទប្រុស អាយុ៣១ឆ្នាំ ស្រុកកំណើតរស់នៅឃុំតលាស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង លំនៅអចិន្ត្រៃយ៍រស់នៅភូមិឈើទាល ឃុំសេរីមានជ័យ ស្រុកសំពៅលូនខេត្តបាត់ដំបង ឈ្មោះ ឈឿម សារី ភេទស្រី អាយុ៣៦ឆ្នាំ ត្រូវជាប្រពន្ធករណីថៅកែថៃបើប្រាស់អាវុធបាញ់គំរាមពលករខ្មែរពីរនាក់ប្តីប្រពន្ធនេះ បានកើតឡើងកាលពីព្រឹកថ្ងៃព្រហស្បតិ៍ទី០៣ ខែធ្នូ ឆ្នាំ២០២០កន្លងទៅ ស្ថិតក្នុងស្រុកខៅសីនសន នៃតំបន់ត្រីកោណ នៃខេត្តឆាកឈើងសៅ ខេត្តប្រាជីនបុរីនិងខេត្តស្រះកែវ។ បច្ចុប្បន្នពលករខ្មែរ និងក្រុមគ្រួសារកំពុងភៀសខ្លួនមកស្នាក់នៅកន្លែងសុវត្ថិភាពមួយជាសាច់ញាតិនៅក្នុងប្រទេសថៃ ដើម្បីរង់ចាំការជួយអន្តរាគមន៍ពីសំណាក់អាជ្ញាធរពាក់ព័ន្ធនៅក្នុងប្រទេសថៃ ដើម្បីស្វែងរកយុត្តិធម៌ជូនពួកក្រោមការគំរាមកំហែងរបស់ថៅកែថៃរូបនោះ។

# ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ២០២០

## ការជួញដូរមនុស្សរយៈពេល៦ខែឆ្នាំ២០២០ កើនឡើងជិត១០០ករណី ខណៈកម្ពុជាកំពុងប្រឈមនឹងកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 14/12/2020 ដោយ៖ហេង សុខនី

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យដឹងថា ខណៈដែលកំពុងមានការរាតត្បាតកូវីដ១៩ ឈ្មួញជួញដូរបានឆ្លៀតឱកាសនេះ ធ្វើសកម្មភាពជួញដូរមនុស្សតាមរូបភាពឆបោកនានា ដូចជារក

ការងារឱ្យធ្វើ និងការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនៅក្រៅប្រទេសជាដើម។ រូបភាពទាំងអស់នេះ គឺជាហេតុផលដែលធ្វើឱ្យការជួញដូរមនុស្សក្នុង៦ខែឆ្នាំ ២០២០នេះ កើនឡើងជាង១០០ករណី។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រាប់វិទ្យុបារាំង RFI នៅថ្ងៃនេះថា ការជួញដូរមនុស្សនៅកម្ពុជាមានការកើនឡើងជាង១០០ករណី ក្នុងរយៈពេល៦ខែឆ្នាំ ២០២០ បើធៀបទៅនឹង៦ខែដូចគ្នា ក្នុងឆ្នាំ២០១៩ ដែលមានការជួញដូរមនុស្សត្រឹមតែជិត១០០ករណីប៉ុណ្ណោះ។ ខណៈដែលរដ្ឋាភិបាល កំពុងតាមដានយ៉ាងយកចិត្តទុកដាក់ពីស្ថានភាពកូវីដ១៩ មានឈ្មួញខិលខូច មានបំណងជួញដូរមនុស្ស បានបំផុសឱ្យប្រជាពលរដ្ឋ ធ្វើចំណាកស្រុកតាមច្រករបៀង តាមរយៈមេខ្យល់ជាអ្នកនាំផ្លូវ ដោយប្រជាពលរដ្ឋទាំងនោះ ត្រូវបង់ប្រាក់កម្រៃឱ្យទៅមេខ្យល់ ហើយក្រោយមកក៏បានក្លាយជាជនរងគ្រោះដោយសារអំពើជួញដូរទាំងនោះ។

នេះបើតាមលោកស្រី ជូ ប៊ុនអេង។ លោកស្រីបន្តថា ពួកគេមិនអាចរកការងារធ្វើបានតាមការសន្យានោះឡើយ គឺមានតែត្រូវចំណាយប្រាក់ឱ្យមេខ្យល់ ហើយពួកគេត្រូវគេទុកចោលឲ្យរស់នៅក្រៅប្រទេសទៅតាមយថាកម្មនៅប្រទេសគេ ដោយខ្លះត្រូវបានគេចាប់ និងបញ្ជូនត្រឡប់មកប្រទេសកំណើតវិញ និងមានខ្លះទៀតត្រូវមេខ្យល់នាំចេញឱ្យទៅរៀបការជាមួយជនបរទេស នៅក្រៅប្រទេសជាដើម ដែលស្ទើរតែមិនជឿសោះថា កាលៈទេសៈកូវីដ១៩បែបនេះ មានអ្នកគិតគូររឿងគួរស្រកឆ្លងដែន។ ជាមួយគ្នានេះ លោកស្រីរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក៏បានស្នើឱ្យពលរដ្ឋពិចារណាមុនធ្វើចំណាកស្រុក កុំឱ្យចាញ់បោកជនជួញដូរមនុស្ស ព្រោះការធ្វើចំណាកស្រុកពេលនេះ គឺជាការផ្សងព្រេង ដ៏ប្រថុយប្រថាន ដែលអាចទទួលបានត្រឹមតែការខាតបង់ប្រាក់កាសប៉ុណ្ណោះ។

គួរបញ្ជាក់ដែរថា ការស៊ើបអង្កេត និងស្រាវជ្រាវរបស់ក្រសួងជំនាញ បានរកឃើញស្ត្រីខ្មែរ ដែលរងគ្រោះដោយអំពើជួញដូរមនុស្សប្រមាណ២០នាក់ ចាប់តាំងពីកើតមានករណីផ្ទុះជំងឺកូវីដ១៩មក ក្នុងនោះស្ត្រីភាគច្រើនមានអាយុក្រោម១៨ឆ្នាំ ខណៈឆ្នាំកន្លងទៅ មិនមានករណីបែបនេះច្រើននោះទេ។

ឆ្លើយតបនឹងបញ្ហាប្រឈមនេះ លោកស្រី ជូ ប៊ុនអេង បញ្ជាក់ថាគណៈកម្មាធិការ ក៏ដូចជាក្រសួង នឹងបន្តវិធានការសំខាន់ៗ២ចំនុច ដែលទី១ជាការអនុវត្តន៍ច្បាប់ និងទី២ការស៊ើបរកជនជួញដូរមនុស្ស ដោយមានការស្នើឱ្យអាជ្ញាធរនៅជាប់ព្រំដែនអនុវត្តវិធានការតឹងរឹង បិទការធ្វើចរាចរណ៍តាមច្រករបៀងនានា និងតាមមធ្យោបាយអប់រំផ្សព្វផ្សាយផងដែរ ដែលការផ្សព្វផ្សាយនេះ ធ្វើឲ្យពលករចំណាកស្រុក១២ម៉ឺននាក់បានយល់ និងត្រូវបានទប់ស្កាត់៕

## ក្រសួងមហាផ្ទៃ ណែនាំឱ្យអាជ្ញាធរ នៅតាមព្រំដែនបិទការធ្វើចរាចរណ៍តាមច្រករបៀងនានា

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 14 ខែ ធ្នូ ឆ្នាំ 2020 វិទ្យុជាតិកម្ពុជា ៖លោកជួន បូណា

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានណែនាំឱ្យអាជ្ញាធរនៅតាមព្រំដែនបិទការធ្វើចរាចរណ៍តាមច្រករបៀងនានា ដើម្បីទប់ស្កាត់ការជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានស្នើឱ្យអាជ្ញាធរនៅតាមព្រំដែនអនុវត្តវិធានការតឹងរឹង និងបិទការធ្វើចរាចរណ៍តាមច្រករបៀងនានា និងស៊ើបរកមុខសញ្ញាជនជួញដូរមនុស្សយកមកផ្តន្ទាទោសតាមផ្លូវច្បាប់។ លោកជំទាវបានបញ្ជាក់ថា ការបិទការធ្វើចរាចរណ៍តាមច្រករបៀងនានានេះ ក្នុងពេលដែលកំពុងមានការរាតត្បាតជំងឺកូវី

ដ-១៩ ឈ្មួញជួញដូរបានឆ្លៀតឱកាសនេះ ធ្វើសកម្មភាពជួញដូរមនុស្សតាមរូបភាពឆបោកនានា ដូចជារកការងារឱ្យធ្វើ និងការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនៅក្រៅប្រទេសជាដើម។ លោកជំទាវមានប្រសាសន៍ថា រាជរដ្ឋាភិបាល កំពុងតាមដានយ៉ាងយកចិត្តទុកដាក់ពីស្ថានភាពកូវីដ-១៩ បែរជាឈ្មួញខិលខូច មានបំណងជួញដូរមនុស្ស បានបំផុសឱ្យប្រជាពលរដ្ឋ ធ្វើចំណាកស្រុកតាមច្រករបៀង តាមរយៈមេខ្យល់ជាអ្នកនាំផ្លូវ ដោយប្រជាពលរដ្ឋទាំងនោះ ត្រូវបង់ប្រាក់កម្រៃឱ្យទៅមេខ្យល់ ហើយក្រោយមកក៏បានក្លាយជាជនរងគ្រោះដោយសារអំពើជួញដូរទាំងនោះ។ ជាមួយគ្នានេះ លោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក៏បានស្នើឱ្យពលរដ្ឋពិចារណាមុនធ្វើចំណាកស្រុក កុំឱ្យចាញ់បោកជនជួញដូរមនុស្ស ព្រោះការធ្វើចំណាកស្រុកពេលនេះ គឺជាការផ្សងព្រេង ដ៏ប្រថុយប្រថាន ដែលអាចទទួលបានត្រឹមតែការខាតបង់ប្រាក់កាសប៉ុណ្ណោះ។

សូមបញ្ជាក់ថា ក្នុងរយៈពេល៦ខែឆ្នាំ ២០២០ ការជួញដូរមនុស្សនៅកម្ពុជាមានការកើនឡើងជាង១០០ករណី បើធៀបទៅនឹង៦ខែដូចគ្នា ក្នុងឆ្នាំ២០១៩៕

## ក្រសួងអប់រំគ្រោងបញ្ចូល មេរៀនស្តីពីការទប់ស្កាត់ការជួញដូរមនុស្សទៅក្នុងកម្មវិធីសិក្សាកម្រិតបឋមសិក្សា និងមធ្យមសិក្សា

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 14 ខែ ធ្នូ ឆ្នាំ 2020 វិទ្យុជាតិកម្ពុជា៖ សេង សុផាន់ណា

MC៖ ក្រសួងអប់រំគ្រោងបញ្ចូល មេរៀនស្តីពីការទប់ស្កាត់ការជួញដូរមនុស្សទៅក្នុងកម្មវិធីសិក្សាកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដើម្បីចូលរួមទប់ស្កាត់ការជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព និង ទូលំទូលាយ។

ឯកឧត្តម រស់ សុវាចា អគ្គ លេខាធិការ និងជាអ្នកនាំពាក្យក្រសួងអប់រំយុវជន និងកីឡា បានមានប្រសាសន៍ថា ក្រសួងអប់រំ យុវជននិងកីឡា បានសហការជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដើម្បីកសាងនូវឯកសារសម្រាប់ធ្វើការបញ្ចូលមេរៀនមួយចំនួនទៅក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា តាមរយៈការបញ្ជ្រាបជាមួយខ្លឹមសារ សិទ្ធិ ច្បាប់ អនុសញ្ញាអន្តរជាតិនានា នៅតាមមុខវិជ្ជាមួយ ចំនួនដូចជា សិក្សាសង្គម សីលធម៌ ពលរដ្ឋវិជ្ជា ភាសាខ្មែរ វិទ្យាសាស្ត្រ ដើម្បីឱ្យសិស្សានុសិស្សបានយល់ ដឹងពីវិធីបង្ការទប់ស្កាត់ការជួញដូរមនុស្សនៅក្នុងសាលា រៀន ក៏ដូចជាក្នុងចំណោមយុវវ័យផងដែរ។ ឯកឧត្តមបញ្ជាក់ថា តាមរយៈការដាក់បញ្ចូលខ្លឹមសារ នៃការយល់ដឹងលើវិធានការទប់ស្កាត់ការជួញដូរមនុស្ស ក្នុងកម្មវិធីសិក្សានេះ ក្រសួង ក៏បានដាក់បញ្ចូលនូវខ្លឹមសារពាក់ព័ន្ធផ្សេងទៀតទៅក្នុងមេរៀនការទប់ស្កាត់បទល្មើសនានាដូចជា បទល្មើសគ្រឿង ញៀន បទល្មើសព្រហ្មទណ្ឌ បទល្មើសការជួញដូរផ្លូវភេទ បទល្មើសការជួញដូរមនុស្ស ជាដើម។

«ក្រសួងអប់រំ យុវជន និងកីឡាបានបញ្ចូលខ្លឹមសារនៃការយល់ដឹងលើវិធានការទប់ស្កាត់ការជួញដូរមនុស្សក្នុងកម្មវិធីសិក្សាកម្រិតបឋម សិក្សា និងមធ្យមសិក្សា។ ជាក់ស្តែង ក្រសួងបានបញ្ជ្រាបជាមួយខ្លឹមសារ សិទ្ធិ ច្បាប់ អនុសញ្ញាអន្តរជាតិនានា នៅតាមមុខវិជ្ជាមួយចំនួនដូចជា សិក្សាសង្គម សីលធម៌ ពលរដ្ឋវិជ្ជា ភាសាខ្មែរ វិទ្យាសាស្ត្រ។ ខ្លឹមសារពាក់ព័ន្ធផ្សេងទៀតមានបញ្ចូលក្នុងមេរៀនការទប់ស្កាត់បទល្មើសនានាដូចជាបទល្មើសគ្រឿងញៀន បទល្មើសព្រហ្មទណ្ឌ បទល្មើសការជួញដូរផ្លូវភេទ បទល្មើសការជួញដូរមនុស្ស»។

សូមបញ្ជាក់ថា ការជួញដូរមនុស្សនៅតែបន្តកើតមាន ទោះបីឋិតក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ–១៩ ហើយបណ្តាប្រទេសជិតខាងកម្ពុជា បានបិទច្រកចេញចូលក៏ដោយ។ ពួកឱកាសនិយម បានលួងលោមប្រជាពលរដ្ឋ តាមគ្រប់រូបភាពផ្សេងៗ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដោយនាំទៅធ្វើការនៅក្រៅប្រទេស តាមផ្លូវកាត់ប្រកបដោយគ្រោះថ្នាក់ ឬតាមរយៈអាពាហ៍ពិពាហ៍ ជាមួយប្តីបរទេសជាដើម ៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៥១នាក់

https://www.facebook.com/GDIOfficial 14-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥១នាក់ ស្រី ២០នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៦នាក់ ស្រី ០២នាក់៕

## ទាហានថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរ ៧នាក់ ដែលលួចឆ្លងដែនខុសច្បាប់ទៅធ្វើការនៅផ្សាររោងគ្លឿ ស្រុកអរញ្ញ ខេត្តស្រះកែវ

http://www.freshnewsasia.com/ 2020-12-14 11:45am

**(បន្ទាយមានជ័យ)៖** ទាហានប៉ារ៉ាកងវរយថៃ លេខ១២០៥ និងក្រុមទាហានប៉ារ៉ាថៃ លេខ១២ និងកងកម្លាំងបូរផាបើកប្រតិបត្តិការចុះទៅត្រួតពិនិត្យទីតាំងទទួលខុសត្រូវរបស់ខ្លួន បានប្រទះឃើញពលករខ្មែរ៧នាក់ ដែលបម្រុងឆ្លងចូលប្រទេសថៃ នៅបរិវេណបង្គោលគីឡូម៉ែត TA.356139 ភូមិជងង្ង ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ។ ក្រោយពីសមត្ថកិច្ចថៃសួរនាំទើបដឹងថា ពលករទាំង៧នាក់នេះ ទៅស៊ីឈ្នួលធ្វើការងារនៅផ្សាររោងគ្លឿ ស្រុកអារញ្ញ ហើយបាននាំមកទីបញ្ជាការកងទាហានប៉ារ៉ា លេខ១២០៥ នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០នេះ។

ក្រោយពីសមត្ថកិច្ចថៃ បានបបញ្ជាក់ថា ពលករទាំង ៧នាក់រួមមានទី១៖ ហៅ បុណ្យសុង ភេទប្រុស អាយុ៣១ឆ្នាំ, ទី២៖ ឈ្មោះ រ៉េត ដុផន ភេទប្រុស អាយុ៣៥ឆ្នាំ, ទី៣៖ ឈ្មោះ លើត ណារ៉ុង ភេទប្រុស អាយុ១៥ឆ្នាំ, ទី៤៖ ឈ្មោះ ខន សុផេង ភេទប្រុស អាយុ៣០ឆ្នាំ, ទី៥៖ ឈ្មោះ ហែម ដា ភេទស្រី អាយុ៦២ឆ្នាំ និង២នាក់ទៀត មិនទាន់ស្គាល់ឈ្មោះ។ សមត្ថកិច្ចថៃ បានបបន្តថា ប្រជាពលរដ្ឋខ្មែរ៧នាក់នេះ រស់ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មិនមានលិខិតឆ្លងដែន បានបបួលគ្នាលួចឆ្លងចូលទៅប្រទេសថៃ តាមច្រករបៀង ដើម្បីទៅស៊ីឈ្នួលធ្វើការងារនៅផ្សាររោងគ្លឿ និងគ្រប់គ្នាធ្លាប់ចេញចូលប្រទេសថៃ ក្នុងម្នាក់ៗច្រើនលើកតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតខ្លងលឹក និងតាមច្រករបៀង ទើបសមត្ថកិច្ចឃុំខ្លួនបញ្ជូនទៅឱ្យនគបាលការពារព្រំដែនលេខ១២៤ ភូមិណូនម៉ាកមុន ស្រុកគោកឃ្សូង ដើម្បីឱ្យត្រឡប់ទៅប្រទេសកម្ពុជាវិញ តាមផ្លូវដែលបានឯកភាពគ្នា។

សមត្ថកិច្ចថៃ បានគូសបញ្ជាក់ថា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ កងកម្លាំងទាហានបូរផា បានធ្វើការរឹតបន្តឹងការពារការត្បាតយ៉ាងយកចិត្តទុកដាក់ក្នុងការទប់ស្កាតពលករចំណាកស្រុក ដើម្បីការពាររីករាលដាលជំងឺកូវីដ-១៩ នៅបរិវេណភូមិទ័ពសះយ៉ាម ឃុំ តាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ។ សមត្ថកិច្ចថៃ សូមធ្វើការអំពាវនាវដល់សមត្ថកិច្ចភាគីកម្ពុជា បង្កើនការយកចិត្តដាក់ខ្ពស់បំផុតការនាំគ្នាសហការគ្នានាំគ្នាទប់ស្កាត់នូវវីរុសកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាលប្រទេសទាំងពីរផងដែរ៕

# ថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ២០២០

## នគរបាលប៉ុស្តិ៍ឆ្លូងចុះផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ

http://cambodiapolice.com/policekh/ 3:37 pm 15 ធ្នូ 2020

ក្រចេះ ៖ នៅព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ នៅក្នុងភូមិជ្រោយថ្មក្រោម ឃុំ ឆ្លូង ស្រុកឆ្លូងខេត្តក្រចេះ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឆ្លូង បានសហការជាមួយកម្លាំងប្រជាការពារចុះ ផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ ដោយក្នុងនោះផ្តោតលើ ៖

១ - សារប្រើប្រាស់សម្រាប់អប់រំ អំពីគ្រោះថ្នាក់គ្រឿងញៀន

២ - ការលេងល្បែងស៊ីសងខុសច្បាប់

៣ - ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកថ្មីអនុក្រឹត្យលេខ៣៩ អនក្រ

៤ - បង្ការ ទប់ស្កាត់ បទល្មើសចោរកម្មគ្រប់ប្រភេទ

៥ - ផ្សព្វផ្សាយ និងបង្ការទប់ស្កាត់ការប្រើអំពើហិង្សាទៅលើស្ត្រី និងកុមារ

៦ - អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៧ -ការងារបង្កាទប់ស្កាត់គ្រោះអគ្គីភ័យ

៨ -ផ្សព្វផ្សាយបង្ការទប់ស្កាត់ប្រឆាំងការងារជួញដូរមនុស្ស

៩ - ផ្សព្វផ្សាយបង្ការទប់ស្កាត់កូវីដ-១៩

១០ - ផ្សព្វផ្សាយការប៉ះពាល់គ្រឿងយុទ្ធភណ្ឌ័មិនទាន់ផ្ទុះ ។

ក្នុងយុទ្ធនាការនេះ កម្លាំងបានផ្សព្វផ្សាយបានចំនួន ២៩ ខ្នងផ្ទះ មានប្រជាពលរដ្ឋចូលរួមចំនួន ៣៨ នាក់ (ស្រី ១៩នាក់) និងចែកខិត្តប័ណ្ណផ្សព្វផ្សាយបានចំនួន៧៥សន្លឹក ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ១៣នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 15-12-2020

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង៤៥នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៣នាក់ ស្រី ០៣នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៥០នាក់

https://www.facebook.com/GDIOfficial 15-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-

១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន៥០នាក់ ស្រី ១៤នាក់៕

## ពលករខ្មែរចំនួន ១៣ នាក់ រួមទាំងមេខ្យល់ម្នាក់ ត្រូវបានតម្រួតថៃ ក្នុងខេត្តសុរិន្ទ ឃាត់ខ្លួន

https://www.cen.com.kh/ December 14, 2020

ភ្នំពេញ ៖ ប្រភពព័ត៌មានពីព្រំដែនកម្ពុជា.ថៃឲ្យដឹងថា រថយន្តតូរីសមួយគ្រឿង ដែលក្នុងនោះមានដឹកពលករខ្មែរសរុបចំនួន ១៣ នាក់ ត្រូវបានកម្លាំងតម្រួតថៃ នៅក្នុងខេត្តសុរិន្ទ ធ្វើការស្ទាក់ចាប់បាន បន្ទាប់ពីម្លាំងមានការសង្ស័យថា អាចជារថយន្តដឹកពលករលបឆ្លងដែនចូលទៅក្នុងប្រទេសថៃ ដើម្បីធ្វើការតាមបណ្តាខេត្តនានា ដោយគ្មានច្បាប់អនុញ្ញាត ។

ការឃាត់រថយន្តម៉ាក តូរីស ពាក់ផ្លាកលេខ អ៊ូប៊ុន រ៉ាតថានី ៥៥៧៦ នេះ បានធ្វើឡើងកាលពីរសៀល ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២០ ត្រង់ចំណុចផ្លូវបំបែកជា៤ ដានផាត់តាណា ក្នុងឃុំដាន ស្រុកកាបឈើង ខេត្តសុរិន្ទ ប្រទេសថៃ ដោយអ្នកបើកបររថយន្តនោះមានឈ្មោះ ថាវ៉ាត់ឆៃ យ៉ាន់តាក់ផាន់ ភេទប្រុស អាយុ ២៤ ឆ្នាំ ជាជនជាតិថៃ រស់នៅភូមិ៣ ឃុំដាន ស្រុកកាបឈើង ខេត្តសុរិន្ទ នេះតែម្តង ។ ប្រភពព័ត៌មានខាងលើបន្តថា ក្រោយពេលឃាត់រថយន្តសង្ស័យ សមត្ថកិច្ចបានពិនិត្យឃើញថា មានពលករខ្មែរ ប្រុស ស្រី សរុបចំនួន ១៣ នាក់ នៅក្នុងរថយន្ត ដែលពួកគេមាបំណងចូលទៅក្នុងទឹកដីថៃដើម្បីរកការងារធ្វើ នៅទីនោះ ដោយម្នាក់ៗគ្មានច្បាប់អនុញ្ញតឡើយ គឺពួកគេនាំគ្នាលបឆ្លងដែនតាមច្រករបៀង ចូលទៅក្នុងទឹកដីថៃតែម្តង ស្របពេលដែលសមត្ថកិច្ចថៃ កំពុងដាក់ពង្រាយកម្លាំងតាមខ្សែបន្ទាត់ព្រំដែន នារដូវ កូវីដ-១៩ ។
សូមជម្រាបថាអ្នកបើកបររថយន្តវ័យក្មេងដែលជាជនជាតិថៃ បានសារភាពថា រូបគេបានធ្វើការណាត់គ្នាជាមួយនឹងពលករខ្មែររួចជាស្រេច ដោយអោយពលករគ្រប់រូប ធ្វើយ៉ាងណាលបឆ្លងដែនចូលទៅក្នុងទឹកដីថៃអោយបាន គឺគេនិងយករថយន្តមកទទួល ហើយដឹកបញ្ជូនទៅតាមខេត្តនានា តាមការសំណូមពររបស់ក្រុមពលករ ដោយយកកម្រៃក្នុង ១ នាក់ ២ ០០០ បាត ។ បច្ចុប្បន្នពលករខ្មែរទាំងអស់ ក៏ដូចជាមេខ្យល់ដែលជាអ្នកបើកបររថយន្ត ត្រូវបានកម្លាំងតម្រួតថៃ រៀបចំបញ្ជូនខ្លួនទៅតាមផ្លូវច្បាប់ ដើម្បីសាកសួរបន្ត ៕**រក្សាសិទ្ធិដោយ៖CEN**

# ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០២០

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៨៥នាក់

https://www.facebook.com/GDIOfficial 16-12-2020

ឧត្តរមានជ័យ៖ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៥នាក់ ស្រី ៣២នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៧នាក់ ស្រី ០៣នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ១៣នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 16-12-2020

បន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង១៥នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៣នាក់ ស្រី ០៦នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

# ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០២០

## រដ្ឋបាលខេត្តបាត់ដំបង និងរដ្ឋបាលខេត្តបន្ទាយមានជ័យ អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយខេត្តស្រះកែវ ប្រទេសថៃ ដើម្បីជំរុញឲ្យមានដំណើរសេដ្ឋកិច្ចក្នុងតំបន់ឡើងវិញ បន្ទាប់ពីបិទមួយរយៈដោយសារជំងឺកូវីដ១៩

https://www.battambang.gov.kh/ ថ្ងៃព្រហស្បតិ៍, 17 ខែធ្នូ, 2020ដោយ Sotheavy

នៅព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ តបតាមការអញ្ជើញរបស់ ខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង ឯកឧត្តម អ៊ុំ រាត្រី អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងឧត្តម សេនីយ៍ទោ ច័ន្ទ រដ្ឋា មេបញ្ជាការរង យោធភូមិភាគទី៥ ទទួលបន្ទុកការងារព្រំដែន បានដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយគណៈប្រតិភូខេត្តស្រះកែវ ដែលដឹកនាំដោយ ឯកឧត្តម កៀត ពិស័ក្តិចាន់ថ្រា អភិបាលខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ ដើម្បីពិភាក្សាការជំរុញឲ្យមានដំណើរសេដ្ឋកិច្ចក្នុងតំបន់ឡើងវិញ នៅតាមច្រកទ្វារព្រំដែនកម្ពុជា ថៃ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ ។

កិច្ចប្រជុំពិភាក្សានេះដែរប្រព្រឹត្តទៅនៅចំណុចព្រំប្រទល់លើស្ពានច្រកទ្វារព្រំដែនភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបង នៃព្រះរាជាណាចក្រកម្ពុជា និងច្រកអន្តរជាតិខៅឌិន ស្រុកខ្លងហាត ខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ ។ គោលបំណងនៃកិច្ចប្រជុំពិភាក្សានេះដែរ គឺផ្តោតសំខាន់ទៅលើការបន្ធូរបន្ថយច្បាប់ស្តីពីការគ្រប់គ្រងស្ថានការក្នុងគ្រាអាសន្ននៅក្នុងប្រទេសថៃ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋក្នុងការចូលទៅធ្វើការ និងប្រកបអាជីវកម្មវិញបានក្រោយពេលដែលមានការផ្អាកជាបណ្តោះអាសន្នក្នុងកំឡុងពេលនៃវិបត្តិកូវីដ-១៩បានផ្ទុះឡើងនៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជា ជាពិសេសដើម្បីសម្រួលដល់ការស្តារសេដ្ឋកិច្ចឡើងវិញនៃប្រទេសទាំងពីរ ក្រោយទទួលរងគ្រោះនូវវិបត្តិកូវីដ-១៩នេះឡើង ហើយកិច្ចប្រជុំនេះមានរបៀបវារៈចំនួន០៣ សំខាន់៖

១-ឱ្យពលករកម្ពុជាចូលមកធ្វើការប្រមូលផលិតផលកសិកម្ម នៅប្រទេសថៃ

២-ឱ្យអាជីវករកម្ពុជាចូលមកប្រទេសថៃ ដើម្បីប្រកបអាជីវកម្មនៅក្នុងផ្សាររោងក្លឿ (ខាងខេត្តបន្ទាយមានជ័យ)។

៣-បើកដំណើរការស្ពានមិត្តភាព ណងអៀន-ស្ទឹងបត់ (ខាងខេត្តបន្ទាយមានជ័យ )។

ក្រោយពីធ្វើការពិភាក្សារួចមក ភាគីកម្ពុជា និងភាគីថៃ បានសម្រេចលទ្ធផលដូចជា :

ទី១ ខេត្តបាត់ដំបង ស្នើឲ្យភាគីខេត្តស្រះកែវ អនុវត្តវិធានការសុខាភិបាល ចត្តាឡីស័ក១៤ថ្ងៃ នៅប្រទេសថៃដល់ប្រជាពលរដ្ឋកម្ពុជាមុននឹងចូលទៅធ្វើការធម្មតា ដែលក្នុងនោះភាគីខាងខេត្តស្រះកែវ បានធ្វើការឯកភាពគ្នា

ហើយថៅកែដែលយកប្រជាពលរដ្ឋខ្មែរទៅធ្វើការ គឺជាអ្នកធានាសុខភាព និងរ៉ាប់រងថ្លៃចំណាយទាំងអស់ក្នុងកំឡុងពេលធ្វើចត្តាឡីស័ក ។

ទី២ រដ្ឋបាលខេត្តបាត់ដំបង បានធ្វើការស្នើសុំដល់ភាគីខេត្តស្រះកែវ ស្នើឱ្យបន្ថែមពេលវេលាបើកច្រកព្រំដែនអន្តរជាតិភ្នំដី (ពីម៉ោង៦ ព្រឹកដល់ម៉ោង ៦ ល្ងាច ទៅជាម៉ោង ៦ ព្រឹកដល់ម៉ោង១០យប់វិញ ភាគីខេត្តស្រះកែវទទួលយកសំណើរ និងយកទៅពិភាក្សាបន្ថែម)

ទី៣គឺ ក្នុងករណីពលករកម្ពុជាមានជំងឺ ឬ វិជ្ជមានកូវីដ-១៩ ស្នើឲ្យភាគីខេត្ត ទទួលរាប់រងព្យាបាល (ដោយភាគីខេត្តស្រះកែវ មិនទាន់ឆ្លើយតប និងយកទៅពិភាក្សាបន្ថែម )

គួរបញ្ជាក់ផងដែរថា ក្នុងកិច្ចប្រជុំពិភាក្សានេះ ភាគីខេត្តស្រះកែវ បានរៀបចំព្រាងកំណត់ហេតុរួមមួយដោយមានការចុះហត្ថលេខាបីភាគី មានខេត្តស្រះកែវ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដោយឡែកខេត្តបាត់ដំបង និងបន្ទាយមានជ័យ ស្នើសុំយកពង្រាងកំណត់ហេតុរួមនេះ មកពិនិត្យជាមុនសិន និងចំណុចដែលខេត្តមិនអាចសម្រេចបានខេត្តនឹងស្នើសុំគោលការណ៍ទៅក្រសួងមហាផ្ទៃជាមុនសិន៕

## ឃាត់ខ្លួនពលរដ្ឋខ្មែរ០២នាក់ ឆ្លងដែនចូលប្រទេសដោយខុសច្បាប់

https://www.facebook.com/GDIOfficial 17-12-2020

កោះកុង៖ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៦និង៣៥នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតក្នុងភូមិសាស្ត្រស្លាបឆ្វេង ពិនិត្យឃើញពលរដ្ឋខ្មែរ ឆ្លងដែនចូលប្រទេសដោយខុសច្បាប់ចំនួន ០២នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង ០២នាក់នេះ មាន ១-ឈ្មោះ ប៉ាវ វីណា ភេទស្រី អាយុ ៤៩ឆ្នាំ, ២-ឈ្មោះ សេង រក្សា ភេទស្រី អាយុ ១១ឆ្នាំ នៅភូមិកោះកាកូវ ឃុំព្រៃក្រាស ស្រុកកំព្រាច ខេត្តកំពត និងបានធ្វើការសាកសួរ អប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័ក ប្រចាំមាត់ច្រក ដើម្បីអនុវត្តនិតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាតនិងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## ប្រជាពលរដ្ឋខ្មែរ ៨៧នាក់ វិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់

https://www.cen.com.kh/ December 17, 2020

ឧត្តរមានជ័យ៖ ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៧នាក់ ស្រី ៣២នាក់ និងបានទទួលពលរដ្ឋខ្មែរចំនួន ១នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន៕**រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ**

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៨៥នាក់

https://www.cen.com.kh/ December 17, 2020

ឧត្តរមានជ័យ៖ ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៥នាក់ ស្រី ៣២នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៧នាក់ ស្រី ០៣នាក់។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកនៅ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៧និង១៥នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៣នាក់ ស្រី ០៦នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕ ***រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ***

## សង្គមស៊ីវិលស្នើរដ្ឋាភិបាលយកចិត្តទុកដាក់ដល់ជនចំណាកស្រុក អំឡុងវិបត្តិជំងឺកូវីដ-១៩

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2020-12-17

នៅក្នុងសេចក្ដីថ្លែងការណ៍ កាលពីថ្ងៃទី១៦ ខែធ្នូ ដែលធ្វើក្រោយកិច្ចពិភាក្សានៅក្លឹបអ្នកកាសែត ក្នុងទីក្រុងបាងកកប្រទេសថៃ បណ្ដាញអង្គការសង្គមស៊ីវិលទាំងនេះ បានថ្លែងសារួមគ្នា ទាមទារសិទ្ធិជូនពលករចំណាកស្រុកនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ រួមទាំងកម្ពុជាផង។ ពីខាងកម្ពុជា មាននាយកប្រតិបត្តិនៃអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) លោក មុំ សុខចារ ដែលរួមចំណែកក្នុងការស្រាវជ្រាវរួមគ្នា ជាមួយអង្គការបណ្ដាញជនចំណាកស្រុកក្នុងមហាអនុតំបន់ទន្លេមេគង្គ បានកត់សម្គាល់ចំណុចខ្វះខាត នៃការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជាលើពលករចំណាកស្រុកខ្មែរ នៅប្រទេសថៃ។ លោក មុំ សុខចារ ទទួលស្គាល់ថា ស្ថានទូតកម្ពុជា បានជួយដល់ពលករចំណាកស្រុកខ្លះដែរ ដូចជាជួយក្នុងការផ្សព្វផ្សាយព័ត៌មាន ជួយខាងរត់ការឯកសារ និងជំនួយសង្គ្រោះបន្ទាន់សម្រាប់អ្នកដែលទាល់ច្រក ឬកំពុងខ្វះស្បៀងអាហារ ប៉ុន្តែលោកថា ការឆ្លើយតបនោះ នៅតិចតួចស្តួចស្តើងណាស់ ហើយពលរដ្ឋខ្មែរចំណាកស្រុកជាច្រើន នៅប្រទេសថៃ កំពុងផុងក្នុងគ្រោះថ្នាក់នៃភាពក្រីក្រ និងខ្វះខាត។

ជុំវិញគោលនយោបាយរដ្ឋាភិបាលកម្ពុជា ក្នុងការជួយពលរដ្ឋខ្មែរចំណាកស្រុកនេះ លោក មុំ សុខចារ បន្ថែមថា បើតាមបទពិសោធន៍ តាំងពីមានផ្ទុះការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋាភិបាលកម្ពុជា មិនមានផែនការច្បាស់លាស់ ក្នុងការជួយពលរដ្ឋខ្មែរចំណាកស្រុកនោះទេ។ លោកស្នើឲ្យរដ្ឋាភិបាល រៀបចំឲ្យមានផែនការច្បាស់លាស់ជាងនេះ ដើម្បីជួយដល់ពលរដ្ឋទាំងនោះ ដើម្បីកុំឲ្យពួកគាត់ជួបប្រទះបញ្ហាដដែលនេះ ទៅថ្ងៃអនាគត។

កាលពីចុងឆ្នាំ២០១៩ ប្រទេសថៃ មានពលករចំណាកស្រុកជាបរទេស ចុះឈ្មោះស្របច្បាប់ ជាង ២លាន ៨សែននាក់ មកពីប្រទេសកម្ពុជា ភូមា និងឡាវ ដែលបម្រើការងារផ្នែកសំណង់ កសិកម្ម និងនេសាទ។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា គិតត្រឹមឆ្នាំ២០១៩ មានពលករខ្មែរធ្វើការនៅប្រទេសថៃប្រមាណមួយលាននាក់។ ប៉ុន្តែ មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍ នៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស

ហៅកាត់ថា អង្គការសង់ត្រាល់ (Central) លោក ឌី ថេហ្គយ៉ា ថា ស្ថានភាពជាក់ស្តែង ពលករខ្មែរធ្វើការទាំងមានច្បាប់ និងខុសច្បាប់ នៅប្រទេសថៃ មានខ្ទង់ពីរលាននាក់៕

## ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០២០

## សារសម្លេង សម្តេចតេជោ ហ៊ុន សែន ផ្ញើជូនបងប្អូនជនរួមជាតិ នាល្ងាចថ្ងៃ២០ ខែធ្នូ ឆ្នាំ២០២០ អំពីស្ថានភាព និងការផ្ទុះឡើងនូវការឆ្លងជម្ងឺកូវីដ-១៩នៅក្នុងប្រទេសថៃ រួមទាំងណែនាំដល់ប្រជាពលរដ្ឋ និងមន្ត្រីរាជការដើម្បីទប់ស្កាត់បង្ការជម្ងឺកូវីដ-១៩

http://nokorwatnews.com/archives/ 20-12-2020

ភ្នំពេញ៖ សម្តេចតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី នៃកម្ពុជា នៅព្រលប់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ បានផ្ញើសារជាសំឡេង អំពីស្ថានភាព និងការផ្ទុះឡើងនូវការឆ្លងជម្ងឺកូវីដ-១៩នៅក្នុងប្រទេសថៃ រួមទាំងបានធ្វើការណែនាំដល់ប្រជាពលរដ្ឋ និងមន្ត្រីរាជការដើម្បីទប់ស្កាត់បង្ការជម្ងឺកូវីដ-១៩។ ក្នុងនោះសម្តេចមានប្រសាសន៍ថា បងប្អូនជនរួមជាតិជាទីស្រឡាញ់ ថ្ងៃនេះគឺខ្ញុំព្រះករុណាខ្ញុំ ផ្ញើសារបន្ទាន់សម្រាប់ផ្តល់ជូន ប្រគេនជូនចំពោះព្រះតេជគុណគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិ ទាក់ទងទៅនឹង ការផ្ទុះឡើងនូវការឆ្លងជាសហាគមន៍ covid-19 នៅប្រទេសថៃ ដែលគិតមកដល់ពេលនេះមានចំនួន៥៧៦នាក់ ក្នុងពេលមួយថ្ងៃ ហើយក្នុងតំបន់១ ។

សម្តេចបានមានប្រសាសន៍ថា , សភាពការណ៍កើតនៅប្រទេសថៃមិនជាធ្ងន់ធ្ងរនោះទេ បើប្រៀបធៀបទៅនឹងប្រជាជនរហូតមានទៅដល់ ជាង៦០លាន នាក់ ។ ប៉ុន្តែបញ្ហាកើតឡើងនៅក្នុងប្រទេសថៃ បានកើតឡើងសម្រាប់ជាការភ័យខ្លាច ដល់កម្មករ កម្មការិនីដែលកំពុងធ្វើការនៅប្រទេសថៃ។ ក្នុងសភាពការណ៍បែបនេះខ្ញុំព្រះករុណាខ្ញុំ សូមធ្វើការអំពាវនាវដល់បងប្អូនកម្មករ កម្មការិនី ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ សូមទុកចិត្តលើរាជរដ្ឋាភិបាលថៃ ដែលនឹងគ្រប់គ្រងនូវសភាពការណ៍បែបនេះ ហើយរឿងបែបនេះព្រះរាជាណាចក្រថៃក៏មានបទពិសោធន៍ ការគ្រប់គ្រងសភាពការណ៍នេះ បានល្អ។ មកទល់នឹងពេលនេះប្រទេសថៃទើបនឹងមានអ្នកឆ្លងចំនួន៤៩០៧នាក់ ហើយអ្នកស្លាប់មានត្រឹមតែ ៦០ នាក់ប៉ុណ្ណោះ។ ដែលអាចចាត់ទុកថាជាប្រទេសគ្រប់គ្រងបានល្អ ។ សម្តេចសង្ឃឹមថាបងប្អូន កម្មករ កម្មការិនី របស់យើងដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ជឿទុកចិត្តទៅលើសមត្ថភាពក្នុងការដោះស្រាយ របស់រាជរដ្ឋាភិបាលថៃ សមត្ថកិច្ចថៃ ដែលធ្វើការនៅទីនោះ។ មិនគួររត់ ពីប្រទេសថៃ ពេលដែលថៃកំពុងមានការលំបាក ដូចជាខ្ញុំព្រះករុណាខ្ញុំធ្លាប់បាននិយាយរួចមកហើយថា, "ស្រឡាញ់គ្នាក្នុងគ្រាក្រ រាប់អានមិត្តល្អក្នុងគ្រាលំបាក" ដូច្នេះយើងគួរស្ថិតនៅទីនោះ ម្ខាងគឺដើម្បីរក្សា ការពារខ្លួននៅនឹងកន្លែង ដែលជាការការពារខ្លួនក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលថៃ ផ្តល់លទ្ធភាពក្នុងការព្យាបាល។ និងមួយផ្នែកទៀត បើមានការចាកចេញ អាចនឹងនាំចូលមកកាន់ប្រទេសកម្ពុជាយើង ។ សម្តេចបានបន្តថា នេះជាការអំពាវនាវដល់បងប្អូនកម្មករ កម្មការិនី កំពុងរស់នៅក្នុងប្រទេសថៃ មានការភ័យខ្លាច ។

សម្តេចក៏សូមអំពាវនាវចំពោះ ឪពុកម្តាយ ប្តី ប្រពន្ធ កូន ដែលមានអ្នកបានទៅធ្វើការនៅក្នុងប្រទេសថៃមេត្តាលើកទឹកចិត្តពួកគាត់ អោយនៅទីនោះបន្តទៀត ដើម្បីខិតខំធ្វើយ៉ាងណា រក្សាឲ្យបាននូវការងារធ្វើរបស់យើង ហើយសង្ឃឹមថាបងប្អូនយើងបន្តធ្វើការនៅទីនោះ ដោយសារប្រជាជនថៃមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហា ។ ចំពោះការចាកចេញពីកន្លែងមួយ ទៅកន្លែងមួយមិនមែនជាការល្អនោះទេ។ សម្តេចក៏បានបញ្ជាក់ផងដែរថា នៅក្នុងពេលនេះបងប្អូនមួយចំនួនដែលចង់ចូលទៅក្នុងប្រទេសថៃ ដោយស្របច្បាប់ក្តី ឬមិនស្របច្បាប់ក្តី ក៏សុំពន្យារនៃការចូល បើសិនជាចូលទៅវាចាំបាច់ណាស់ត្រូវ ទោះជាស្របច្បាប់ក៏ត្រូវធ្វើចត្តាឡីស័ក ១២ថ្ងៃ ហើយបើឆ្លងដែនខុសច្បាប់ ក៏ត្រូវអាជ្ញាធរសមត្ថកិច្ចថៃបញ្ជូនមកវិញ។ ហើយដែលក្នុងនោះសម្តេចក្រឡាហោមស ខេង បានប្រាប់ទៅអាជ្ញាធរខេត្តនៅទីនោះ ធ្វើការជាមួយនឹងអាជ្ញាធរថៃ ហើយឲ្យភាគីថៃមើលការខុសត្រូវក្នុងការ

ចូលទៅ ទាំងការធ្វើចត្តាឡីស័ក និងការចំណាយ រាប់ទាំងផលប្រយោជន៍ដែលកម្មករ កម្មការិនី បាន នៅពេលមានជំងឺ ។ សម្តេចបន្តថា ការអំពាវនាវរបស់ខ្ញុំទៅកាន់បងប្អូន កម្មករ កម្មការិនី ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ពុកម៉ែ ពូមីង បងប្អូនប្រជាពលរដ្ឋ ត្រៀមឆ្លងទៅប្រទេសថៃ ត្រូវផ្អាកខណៈកាលៈទេសៈកំពុងតែកើតមានបែបនេះ។

សម្តេចបានគូសបញ្ជាក់ទៀតថា, ខ្ញុំបានធ្វើការពិភាក្សាជាមួយនឹងក្រសួងសុខាភិបាល ជាមួយនឹងសម្តេចក្រឡាហោមសខេង ជាមួយនឹងការចេញ ផ្នែកការពារជាតិ គឺអគ្គបញ្ជាការ មេបញ្ជាការកងទ័ពជើងគោក រដ្ឋមន្ត្រីក្រសួងការពារជាតិ ធ្វើយ៉ាងណារៀបចំ ឲ្យមានការធ្វើចត្តាឡីស័ក នៅតាមខេត្តជាប់ព្រំដែនប្រទេសថៃ ។ ហើយថ្ងៃនេះខ្ញុំព្រះករុណាខ្ញុំក៏បានបញ្ចេញថវិកា បន្ថែម ទៅកាន់ខេត្តនៅជាប់ព្រំដែននោះ ក្នុងមួយខេត្តបន្ថែមចំនួន ៥០ លានរៀល មានន័យថាបន្ថែមពីលើប្រាក់ដែលមានពីមុន ដើម្បីឲ្យខេត្តនៅតាមព្រំដែនមានលទ្ធភាព ។ ហាមដាច់ខាតមិនឱ្យចូលក្នុងប្រទេស។ ដោយគ្មានការយកសំណាក ត្រូវធ្វើចត្តាឡីស័កចំនួន ១៤ ថ្ងៃ។ ដូច្នេះបងប្អូនដែលកំពុងរស់នៅក្នុងប្រទេសថៃ ត្រឡប់មកវិញ ក៏មិនត្រូវត្រឡប់មកវិញភ្លាមនោះដែរ សំខាន់ទៅធ្វើចត្តាឡីស័កនៅតាមព្រំដែន។ សម្តេចតេជោ ហ៊ុនសែន បញ្ជាក់ថា តាមការបញ្ជាក់ពីលោកអគ្គមេបញ្ជាការ និងមេបញ្ជាការកងទ័ពជើងគោក បានបញ្ជូនរថយន្តទាំងយប់នេះ ទៅកាន់ច្រកដូង អូរស្មាច់ ប៉ោយប៉ែត ប្រមាណជា៧០ គ្រឿង ដើម្បីត្រៀមក្នុងការដឹកជញ្ជូនក្នុងករណីលើសពីលទ្ធភាព ការធ្វើចត្តាឡីស័កនៅតាមព្រំដែន គឺមិនអនុញ្ញាតឲ្យបងប្អូនប្រជាពលរដ្ឋដែលធ្វើដំណើរមកពីប្រទេសថៃ អាចធ្វើដំណើរតាមឡានតាក់ស៊ី តាមធ្យោបាយផ្សេងៗ ដែលមិនបានធ្វើការគ្រប់គ្រង ពីអាជ្ញាធរសមត្ថកិច្ច។ ព្រោះអាចឱ្យមានករណីឆ្លងជាសហគមន៍ ។ ដូច្នេះកងទ័ពមានភារកិច្ចទទួលបន្ទុក ក្នុងការដឹកជញ្ជូន ទាំងអស់នោះ។ កងទ័ពទាំងអស់ ជាមួយនឹងនគរបាលតាមព្រំដែន កម្លាំងកងរាជអាវុធហត្ថ តាមបណ្តាច្រកទាំងអស់នោះ ត្រូវសហការគ្នាអោយបានល្អ។ សម្តេចបានរំលឹកថា យើងមានបទពិសោធន៍ច្រើន យើងត្រូវធ្វើតាមទម្លាប់ដូចកាលសម័យខែមេសា បង្រួញច្រកទាំងអស់ ឱ្យមកនៅមានត្រឹមបីច្រក ឱ្យមានការយល់ស្របពីសាមីខេត្ត នឹងសហការជាមួយនឹងនគរបាលព្រំដែន កម្លាំងកងរាជអាវុធហត្ថ ជាពិសេសនគរបាលអន្តោប្រវេសន៍នេះតែម្តង។ ឱ្យច្រកទាំងនោះមានត្រឹមតែ៣ច្រក ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងការដឹកជញ្ជូន ដូចមានត្រឹមតែច្រកអូស្មាច់ ប៉ោយប៉ែត ច្រកដូង ពេលនេះរថយន្តរបស់កងទ័ពកំពុងតែចេញដំណើរទៅហើយ។

សូមបញ្ជាក់ថា សាររបស់សម្តេចតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានធ្វើឡើងបន្ទាប់ពី ប្រទេសថៃតែក្នុងមួយថ្ងៃមានអ្នកឆ្លង covid-19 ចំនួន៥៧៦ នាក់។ ហើយសារជាសំឡេងលើ page ផ្លូវការរបស់សម្តេចមានរយៈពេលជាង 20 នាទី៕

## ខណៈខេត្តសាមុតសាខន ផ្ទុះជំងឺកូវីដ , សម្តេចតេជោ ហ៊ុន សែន ដាក់បទបញ្ជាទៅអាជ្ញាធរខេត្តចំនួន៧ ដែលនៅជាប់ព្រំដែនកម្ពុជា-ថៃ ឱ្យពង្រឹងការធ្វើចត្តាឡីស័ក សម្រាប់ពលករខ្មែរដែលត្រឡប់មកប្រទេសថៃ

https://www.cen.com.kh/ December 20, 2020

ភ្នំពេញ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់បទបញ្ជាទៅអាជ្ញាធរខេត្តចំនួន៧ ដែលនៅជាប់ព្រំដែនកម្ពុជា-ថៃ ឱ្យពង្រឹងការធ្វើចត្តាឡីស័ក សម្រាប់ពលករខ្មែរដែលត្រឡប់មកប្រទេសថៃ រយៈពេល១៤ថ្ងៃពេញ ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ដែលកំពុងផ្ទុះឡើងយ៉ាងខ្លាំងក្លា ជាង៥០០ករណីក្នុង១ថ្ងៃ នៅខេត្តសាមុតសាខន ប្រទេសថៃ។

នេះបើតាមលោកជំទាវយក់ សម្បត្តិ រដ្ឋលេខាធិការ ក្រសួងសុខាភិបាល។ លោកជំទាវយក់ សម្បត្តិ បានបញ្ជាក់ថា ពាក់ព័ន្ធនឹងការពង្រឹងវិធានការតាមបណ្តាខេត្តជាប់ព្រំដែនថៃនេះ សម្តេចតេជោ ហ៊ុន សែន ក៏បានឧបត្ថម្ភថវិកា៥០លានរៀល ក្នុង១ខេត្តផងដែរ ដើម្បីឱ្យខេត្តទាំងនោះរៀបចំដោះស្រាយបញ្ហាចំពោះមុខ ដើម្បីទប់

ស្កាត់ការចម្លងមេរោគកូវីដ១៩ ពីប្រទេសថៃ។ ខេត្តទាំង៧ ដែលជាប់ព្រំដែនថៃនោះ រួមមានខេត្តបាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ព្រះវិហារ ឧត្តរមានជ័យ ពោធិ៍សាត់ និងកោះកុង។ លោកជំទាវ យក់ សម្បត្តិ បានបន្តទៀតថា តាមបទបញ្ជារបស់ សម្តេចតេជោ ហ៊ុន សែន, រាល់ពលករទាំងអស់ ដែលត្រឡប់មកពីប្រទេសថៃ ពេលនេះត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ពេញពេលចូលមកកម្ពុជា ហើយសម្តេចតេជោ ហ៊ុន សែន បានជំរុញឱ្យអភិបាលខេត្តទាំង៧ ដែលនៅជាប់ព្រំដែនថៃ រឹតបន្តឹង និងពង្រឹងការធ្វើចត្តាឡីស័កឱ្យបាន រយៈពេល១៤ថ្ងៃ ទាំងពលករខ្មែរទៅធ្វើការនៅប្រទេសថៃ និងត្រឡប់មកវិញ ដើម្បីទប់ស្កាត់ការចម្លងកូវីដ១៩ ហើយការធ្វើចត្តាឡីស័កនេះ ត្រូវធ្វើឡើងនៅព្រំដែនតែម្តង។

សូមបញ្ជាក់ថា កាលពីថ្ងៃសៅរ៍សប្តាហ៍នេះ ថៃបានប្រកាសពីការរកឃើញករណីឆ្លង COVID-19 ដល់ទៅជាង៥០០ករណី ក្នុងចំណោមពលករចំណាកស្រុក នៅឯខេត្តសាមុតសាខន (Samut Sakhon) ភាគនិរតីទីក្រុងបាងកក ខណៈវាជាចំនួនករណីឆ្លងដ៏ច្រើនបំផុតដែលត្រូវបានរាយការណ៍ក្នុងរយៈពេលត្រឹម១ថ្ងៃ។ នេះបើតាមការដកស្រង់ការផ្សាយចេញពីសារព័ត៌មាន CNA នៅថ្ងៃអាទិត្យ ទី២០ ខែធ្នូ ឆ្នាំ២០២០។**រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ**

## សម្តេចតេជោ អំពាវនាវពលករកំពុងធ្វើការនៅប្រទេសថៃកុំភ័យតក់ស្លុត និងស្លន់ស្លោ

https://kampucheathmey.com/local-news/ December 20, 2020 By Dy Bunnara

ភ្នំពេញ៖ ប្រមុខរដ្ឋាភិបាលកម្ពុជាបានអំពាវនាវដល់បងប្អូនពលករខ្មែរ ដែលកំពុងសធ្វើការនៅប្រទេសថៃ សុំកុំមានភាពតក់ស្លុត និងភ័យស្លន់ស្លោហួសហេតុ ទាក់ទិននឹងការណីផ្ទុះជំងឺកូវីដ១៩នៅតំបន់មួយនៃប្រទេសថៃ និងត្រូវមានការជឿជាក់ទៅលើរដ្ឋាភិបាលថៃ។ តាមរយៈសារជាសំឡេងតាមប្រព័ន្ធតេឡេក្រាម ដែលបានផ្សព្វផ្សាយនៅល្ងាចនេះ សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន បានមានប្រសាសន៍ថា «មានករណីផ្ទុះជំងឺកូវីដ១៩ ចំនួន៥៧៦នាក់ ក្នុង១ថ្ងៃក្នុងតំបន់មួយនៅប្រទេសថៃ។ ប៉ុន្តែសភាពការណ៍នៅប្រទេសថៃមិនមានការធ្ងន់ធ្ងរទេ បើប្រៀបនឹងប្រជាជនថៃដែលមានជាង៦០លាន ប៉ុន្តែបញ្ហានៅប្រទេសថៃគឺបានបង្កើតជាបញ្ហាចិត្តសាស្ត្រនាំឲ្យមានការភ័យខ្លាចដល់កម្មករពិសេសគ្រួសារកម្មករកម្មការិនី ដែលកំពុងធ្វើការនៅប្រទេសថៃ»។ សម្តេចតេជោបានបន្តថា «ក្នុងសភាពការណ៍បែបនេះ ខ្ញុំអំពាវនាវដល់កម្មករកម្មការិនីនៅប្រទេសសូមទុកចិត្តទុកចិត្តចំពោះរដ្ឋាភិបាលថៃដែលនឹងគ្រប់គ្រងនូវសភាពការណ៍នេះហើយរឿងនេះ ថៃមានបទពិសោធន៍តាំងពីពេលមុនដែលរហូតមកដល់ពេលនេះប្រទេសថៃទើបមានឆ្លង៤៩០៧នាក់ ក្នុងស្លាប់មាន៦០នាក់ប៉ុណ្ណោះ ដែលចាត់ទុកជាប្រទេសដែលអាចគ្រប់គ្រងបានល្អ»។

សម្តេចសង្ឃឹមថា បងប្អូនយើងជឿទុកចិត្តទៅលើសមត្ថភាពការដោះស្រាយរបស់រដ្ឋាភិបាលថៃរបស់សមត្ថកិច្ចពាក់ព័ន្ធថៃមិនគួរចាកចេញពីប្រទេសថៃនៅពេលលថៃមានការលំបាក។ យើងត្រូវស្រលាញ់គ្នាក្នុងគ្រាក្រស្គាល់មិត្តល្អគ្រាលំបាក។ ដូច្នេះគួរស្នាក់នៅទីនោះម្ខាងរក្សានៅការពារខ្លួននៅនឹងកន្លែងដោយមានការការពារជាចាំបាច់ពីសំណាក់ប្រទេសថៃផ្តល់លទ្ធភាពការពារខ្លួន និងមួយផ្នែកទៀតចៀសវាងនូវការវិលត្រឡប់ដែលនឹងនាំមកដល់នូវការនាំចូលប្រសិនបើមានអាចនាំចូលមកក្នុងប្រទេសកម្ពុជារបស់យើង។ ជាមួយគ្នានេះដែរ សម្តេចក៏បានអំពាវនាវដល់ឪពុកម្តាយប្តីប្រពន្ធឬកូន ដែលមានសាច់ញាតធ្វើការនៅប្រទេសថៃសូមលើកតឹកចិត្តដល់ឪពុកម្តាយប្តីប្រពន្ធឬកូននិងបង្អូនដែលរស់នៅទីនោះរស់នៅទីនោះបន្តទៀតដើម្បីខិតខំធ្វើយ៉ាងណារក្សាការងារធ្វើរបស់យើងនៅទីនោះ ហើយសង្ឃឹមថាបងប្អូននឹងបន្តធ្វើការងារនៅទីនោះជាមួយនឹងប្រជាជនថៃ។ សម្តេចបានបន្តទៀតថា«ប្រសិនបើយើងចល័តចេញពីកន្លែងមួយទៅកន្លែងមួយគឺពិតជាមិនល្អទេដូច្នេះកុំអាលចូលមកក្នុងប្រទេសហើយរយៈពេលនេះបងប្អូនចំនួនដែលចូលក្នុងប្រទេសថៃស្របច្បាប់ក្តី ដោយមិនស្របច្បាប់ក្តីសូមពន្យាការចូលប្រសិនចូលទៅចាំបាច់ណាស់ចូលដោយខុសច្បាប់កាន់តែលណបាកហើយថៃចាប់បញ្ជូនមកវិញនិងត្រូវធ្វើចត្តាឡីស័ក១៤ថ្ងៃ»។

សម្តេចបានបញ្ជាក់ថា «ខ្ញុំបានពិភាក្សាជាមួយក្រសួងសុខាភិបាលសម្តេចក្រឡាហោមសខេង អគ្គមេបញ្ជាការ និងក្រសួងការពារជាតិឲ្យមានការរៀបចំធ្វើចត្តាឡីស័កនៅតាមខេត្ត។ហើយថ្ងៃនេះខ្ញុំបានបញ្ចេញថវិកាចំនួន៥០លានរៀល ក្នុង១ខេត្តបន្ថែមពីលើថវិកាដែលមានពីមុនរួចហើយដើម្បីឲ្យខេត្តមានលទ្ធភាពធ្វើចត្តាឡីស័កក្នុងស្ថានភាពធម្មតា។មិនអាចឲ្យចូលក្នុងផ្ទៃប្រទេសដោយមិនមានការធ្វើត្រួតពិនិត្យសំណាកនិងការធ្វើចត្តាឡីស័ក ១៤ថ្ងៃនៅតាមព្រំដែននោះទេ។ ដូចនេះបងប្អូនដែលមានបំណងចូលមកប្រទេសវិញត្រូវធ្វើចត្តាឡីស័ក១៤ថ្ងៃតាមព្រំដែននិងយកសំណាកទៅធ្វើវិភាគ។ បើលទ្ធផលអវិជ្ជមានទើបអាចអនុញ្ញាតឲ្យចាកចេញបាន»។ បើតាមសារព័ត៌មានបរទេសបានឲ្យដឹងថាប្រទេសថៃបានរាយការណ៍ពីករណីឆ្លងជំងឺកូវីដ ១៩ ថ្មីជាង ៥០០ ករណីក្នុងចំណោមពលករចំណាកស្រុកនៅកណ្តាលនៃឧស្សាហកម្មអាហារសមុទ្ររបស់ខ្លួនកាលពីថ្ងៃសៅរ៍ ទី ១៩ ខែធ្នូ ដែលជាការកើនឡើងដ៏ធំបំផុតមួយក្នុងរយៈពេលមួយថ្ងៃ នៅក្នុងប្រទេសដែលបានគ្រប់គ្រងការរីករាលដាលនៃជំងឺនេះអស់ជាច្រើនខែ ។

ការផ្ទុះឡើងនេះបានលេចចេញនៅក្នុងខេត្តសាមុតសាខន (Samut Sakhon) ភាគនិរតីនៃទីក្រុងបាងកកដែលមានករណីឆ្លងចំនួន ៤ ករណីនៅផ្សារបង្គាមួយកាលពីថ្ងៃសុក្រ ។ ករណីដំបូងគឺស្ត្រីអាយុ ៦៧ ឆ្នាំជាអាជីវករលក់ដូរនៅផ្សារនោះ ។ បើតាមលោក Opas Karnkawinpong អគ្គនាយកនៃនាយកដ្ឋានទប់ស្កាត់ជំងឺឆ្លង បានប្រាប់សន្និសីទសារព័ត៌មានថា ករណីថ្មីចំនួន ៥១៦ ករណីត្រូវបានរកឃើញ បន្ទាប់ពីការធ្វើតេស្តដែលរួមមានកម្មករចំណាកស្រុកចំនួន ១,១៩២ នាក់ ។ លោកបានបន្តថាជាង ៩០ ភាគរយមិនបង្ហាញរោគសញ្ញា ។

គួរបញ្ជាក់ថាសរុបមកមានករណីថ្មីជាង ៥៥០ ករណីត្រូវបានគេរាយការណ៍កាលពីថ្ងៃសៅរ៍ដែលធ្វើឲ្យចំនួនសរុបកើនឡើងដល់ទៅជាង ៤,៨០០ ករណី ខណៈមនុស្ស ៦០ នាក់បានស្លាប់នៅក្នុងប្រទេសដែលមានប្រជាជន ៧០ លាននាក់ ៕ សំអឿន

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចំនួន៤ បានទទួលពលរដ្ឋខ្មែរចំនួន ២០៥ ដែលអាជ្ញាធរថៃបញ្ជូនមក ឲ្យអាជ្ញាធរកម្ពុជាវិញ

https://www.cen.com.kh/ September 18, 2020

ព្រំដែន៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបយប៉ែត នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៥នាក់ ស្រី ០៥នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀលបានសហការជាមួយ មន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យ វាស់កំដៅ និងសម្រួលបែបបទចូលប្រទេស ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ដើម្បីធ្វើដំណើរវិលត្រឡប់ទៅគេហដ្ឋានវិញ ស្ថិតនៅរាជធានីភ្នំពេញ និងជនបរទេសចំនួន ០៣នាក់ ដើម្បីធ្វើដំណើរចេញទៅ ប្រទេសឡាវ។ ដោយយោងតាមគោលការណ៍ របស់ក្រសួងសុខាភិបាល ប៉ុស្តិ៍បានប្រគល់ពលរដ្ឋខ្មែរខាងលើ ជូនមន្ត្រីចត្តាឡីស័ក ប្រចាំច្រកទ្វារ ដើម្បីគ្រប់គ្រង និងអនុវត្តន៍នីតិវិធីបន្ត។

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្តាំចំនួន ៥១នាក់ ស្រី ២០នាក់ និងកុមារ ០៨នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយ

ស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពរស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន។

នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣០នាក់ ស្រី ៥០នាក់។

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ បានទទួលពលករខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ សុខ មុំ ភេទស្រី អាយុ ៤០ឆ្នាំ, ២-ឈ្មោះ តុប សុភី ភេទស្រី អាយុ ៣២ឆ្នាំ, ៣-ឈ្មោះ ឯក រីម ភេទស្រី អាយុ ៤២ឆ្នាំ, ៤-អោក ស្រីឡេង ភេទស្រី អាយុ:១៨ឆ្នាំ មានទីលំនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕ ដោយៈកូឡាប

## កូវីដ១៩៖ រដ្ឋាភិបាលកម្ពុជា ដាក់ចេញចំណាត់ការបន្ទាន់ពង្រឹងការធ្វើចត្តាឡីស័ក នៅតាមព្រំដែនថៃ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 20/12/2020 - 11:19 ដោយ៖អោ ស្រីពេជ្រ

រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃនេះ បានចាត់វិធានការពង្រឹងការធ្វើចត្តាឡីស័កសម្រាប់ពលករខ្មែរ នៅតាមព្រំដែនថៃ ក្នុងខេត្តចំនួន៧ ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩។ វិធានការបន្ទាន់នេះ ធ្វើឡើងស្របពេលដែលមានការផ្ទុះករណីវិជ្ជមានកូវីដ១៩ដែលមិនធ្លាប់មាន ក្នុងខេត្តសាមុតសាខនរបស់ប្រទេសថៃ ក្បែរខាងកម្ពុជា ដែលបានរកឃើញករណីវិជ្ជមានកូវីដ១៩ជាង ៥០០ករណី ក្នុង១ថ្ងៃ កាលពីម្សិលមិញនេះ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី២០ធ្នូនេះ បានដាក់ចេញចំណាត់ការបន្ទាន់ ទៅអាជ្ញាធរ ខេត្តទាំង ៧ជាប់ព្រំដែននៃប្រទេសថៃ ឲ្យពង្រឹងការធ្វើចត្តាឡីស័កសម្រាប់ពលករ ដែលត្រឡប់មកពីប្រទេសថៃ រយៈពេល១៤ថ្ងៃ ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ចូលកម្ពុជា ស្របពេលដែរ អាជ្ញាធរថៃ នៅថ្ងៃម្សិលមិញ បានប្រកាសពីករណីវិជ្ជមានកូវីដ១៩ថ្មី ទ្រង់ទ្រាយធំលើមនុស្សចំនួន ៥៤៨នាក់ ក្នុងខេត្តសាមុតសាខន រហូតដល់មានការបិទខ្ទប់ខេត្តមួយនេះទាំងស្រុងចំនួន១៤ថ្ងៃ ដែលនេះពុំធ្លាប់កើតមានឡើងនោះទេ រាប់ចាប់តាំងពីមានការផ្ទុះករណីដំបូងនៅក្នុងប្រទេសថៃ កាលពីដើមខែមករាឆ្នាំ២០២០កន្លងទៅ។ តាមរយៈក្រសួងសុខាភិបាល បានឲ្យដឹងដែរថា រាជរដ្ឋាភិបាលកម្ពុជានឹងបរិច្ចាគទឹកប្រាក់ចំនួន ៣៥០លានរៀលដល់ខេត្តចំនួន៧នោះ រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ព្រះវិហារ ឧត្តរមានជ័យ ពោធិ៍សាត់ និងកោះកុង ដោយអាជ្ញាធរខេត្តនិមួយៗនឹងទទួលបានប្រាក់ចំនួន ៥០លានរៀល ដើម្បីរៀបចំដោះស្រាយនូវបញ្ហាចំពោះមុខ ដើម្បីទប់ស្កាត់ការចម្លងកូវីដ១៩ពីប្រទេសថៃនៅពេលនេះ។ បើតាមក្រសួងមហាផ្ទៃ ពលករខ្មែរជាង៩ម៉ឺននាក់ ក្នុង

ចំណោមពលករខ្មែរជាង១លាននាក់ដែលធ្វើការនៅប្រទេសថៃ បានធ្វើដំណើរមកកម្ពុជាវិញ នៅគ្រាដែលថៃបិទប្រទេសខ្លួនដោយសារជំងឺកូវីដ១៩ កាលពីខែមិនាកន្លងទៅនេះ។

សូមជម្រាបជូនថា រដ្ឋាភិបាលថៃ គិតត្រឹមថ្ងៃនេះ បានធ្វើតេស្តទៅលើមនុស្សជិត១៥០០នាក់ នៅក្នុងខេត្តសាមុតសាខននេះ លទ្ធផលវិជ្ជមាន៥៧៦ ដែលភាគច្រើនជាពលករចំណាកស្រុកមកពីប្រទេសភូមា ដែលក្នុងនោះ មាន១៩ករណីជាករណីឆ្លងចូលសហគមន៍។ នេះបើតាមការចុះផ្សាយរបស់សារព័ត៌មានបាំងកកប៉ុស្ដិ៍ចុះផ្សាយនៅរសៀលថ្ងៃទី២០នេះ៕

## ពលករខ្មែរមកពីថៃ ត្រូវធ្វើចត្តាឡីស័កនៅព្រំដែនភ្លាមៗ សម្តេចបញ្ជាឱ្យអាជ្ញាធរទាំង ៧ ខេត្តរឹតបន្តឹងបំផុត

https://news.sabay.com.kh/ 20-12-2020 ម៉ោង 16:17

តាមការបញ្ជាក់របស់លោកជំទាវ យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល បានឱ្យដឹងថា តាមបទបញ្ជារបស់ សម្តេចតេជោ ហ៊ុន សែន រាល់ពលករទាំងអស់ ដែលត្រឡប់មកពីប្រទេសថៃ ពេលនេះត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ពេញពេលចូលមកកម្ពុជា ។ ក្នុងនោះសម្តេចតេជោ ហ៊ុន សែន បានជំរុញឱ្យអភិបាលខេត្តទាំង ៧ ដែលនៅជាប់ព្រំដែនថៃ រឹតបន្តឹង និងពង្រឹងការធ្វើចត្តាឡីស័កឱ្យបាន រយៈពេល ១៤ ថ្ងៃ ទាំងពលករខ្មែរទៅធ្វើការនៅប្រទេសថៃ និងត្រឡប់មកវិញ ដើម្បីទប់ស្កាត់ការចម្លងកូវីដ១៩ ហើយការធ្វើចត្តាឡីស័កនេះ ត្រូវធ្វើឡើងនៅព្រំដែនតែម្តង ។

គួរឱ្យដឹងថា ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានឧបត្ថម្ភថវិកា ៥០លានរៀល ក្នុង១ខេត្ត សម្រាប់ខេត្តដែលជាប់ព្រំដែនប្រទេសថៃ ដើម្បីឱ្យខេត្តទាំងនោះរៀបចំដោះស្រាយបញ្ហាចំពោះមុខ ដើម្បីទប់ស្កាត់ការចម្លងមេរោគកូវីដ១៩ ពីប្រទេសថៃ ។ ខេត្តទាំង៧ ដែលជាប់ព្រំដែនថៃនោះ រួមមានខេត្តបាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ព្រះវិហារ ឧត្តរមានជ័យ ពោធិ៍សាត់ និងកោះកុង ។

សូមបញ្ជាក់ថា ខេត្តសាមុតសាខន ដែលមានចម្ងាយប្រមាណតែ ៣០០ គីឡូម៉ែត្រពីកម្ពុជា កំពុងផ្ទុះកូវីដ ១៩ ជាថ្មី ដោយក្នុងនោះត្រឹមថ្ងៃទី ១៩ ធ្នូ ២០២០ រកឃើញមានករណីឆ្លងកូវីដ ១៩ ជាង ៥០០ នាក់ឯណោះ ៕

## រថយន្តកងទ័ព ៧០គ្រឿង ចេញទាំងយប់ ទៅព្រំដែនអូរស្មាច់ ដូង និងប៉ោយប៉ែត

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១៩:២៩ មុត ស្រីពៅ

ភ្នំពេញ៖ សម្តេចតេជោ ហ៊ុន សែន បានប្រកាសថា រថយន្តកងទ័ព ៧០គ្រឿង នឹងចេញទៅព្រំដែនយប់នេះចំនួន ៣ច្រក ដើម្បីត្រៀមដឹកពលករខ្មែរ មកពីថៃ តាមច្រកព្រំដែនអូរស្មាច់ ដូង និងប៉ោយប៉ែត។ ក្នុងសារជាសំឡេង កាលពីព្រលប់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ សម្តេចតេជោ ហ៊ុន សែន បានប្រកាស ណែនាំឲ្យអាជ្ញាធរខេត្តជាប់ព្រំដែនថៃ ត្រូវរៀបចំកន្លែងធ្វើចត្តាឡីស័ក នៅតាមព្រំដែន ដើម្បីត្រៀមទទួលពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ។ សម្តេចតេជោ ហ៊ុន សែន ប្រកាសថា នៅថ្ងៃនេះសម្តេច បានបញ្ចេញថវិកា៥០លានរៀល ក្នុង១ខេត្តៗ នៅខេត្តជាប់ព្រំដែន បន្ថែមលើថវិកាកន្លងមក ដើម្បីរៀបចំធ្វើចត្តាឡីស័ក ឲ្យបានគ្រប់ ១៤ថ្ងៃ នៅតាមខេត្តជាប់ព្រំដែនទាំងនោះ ដោយមិនអាចបណ្តោយឲ្យចូលមកពេញផ្ទៃប្រទេសបានទេ។ ដូច្នេះនៅពេលបងប្អូនពលករយើងវិលត្រឡប់មកពីប្រទេសថៃ ចូលមកដល់ប្រទេសកម្ពុជា ក៏ត្រូវតែធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ។ សម្តេចតេជោ ហ៊ុន សែន បន្ថែមថា ក្នុងសភាពការណ៍ចំនួនមនុស្ស ចូលមកហួសការគ្រប់គ្រងយើងត្រូវបញ្ចេញកងទ័ព ទៅជួយអន្តរាគមន៍ ដើម្បីទៅដឹកជញ្ជូនមកខាងក្រោយ។ ដោយទទួលព័ត៌មានពីអគ្គបញ្ជាការកងទ័ព និងមេបញ្ជាការកង

ទ័ពជើងគោក គឺរថយន្តកងទ័ព ចំនួន ៧០គ្រឿង នឹងចេញទៅយប់នេះ ចំនួន ៣ច្រក ដែលបានត្រៀមទុក គឺនៅអូរស្មាច់ ដូង និងប៉ោយប៉ែត។

សម្ដេចតេជោ ហ៊ុន សែន ប្រកាសថា យើងមិនអនុញ្ញាតឲ្យបងប្អូន ដែលវិលត្រឡប់មកពីប្រទេសថៃ ធ្វើដំណើរដោយរថយន្តតាក់ស៊ី ឬបែកខ្ញែក ដែលមិនអាចគ្រប់គ្រងបាន នាំទៅដល់ហានិភ័យនៃការឆ្លងចូលសហគមន៍ ដោយយើងមិនបានដឹងនោះទេ។ ដូច្នេះកងទ័ព នឹងត្រូវទទួលបន្ទុកក្នុងការដឹកជញ្ជូនបងប្អូនទាំងនេះ រាប់ទាំងការផ្គត់ផ្គង់ ដោយសហការជាមួយអាជ្ញាធរខេត្តព្រំដែន នគរបាល និងអាវុធហត្ថ នៅតាមច្រកព្រំដែនទាំងបីផងដែរ។ សម្ដេចតេជោ ហ៊ុន សែន ក៏បានប្រកាស ដោយជ្រើសយកបទពិសោធន៍កាលពីខែមេសា ដែលមានពលករកម្ពុជាចូលមកជាង ១២ម៉ឺននាក់ ដោយពេលនេះ យើងត្រូវបំព្រួញច្រកចេញចូល មកនៅត្រឹម ៣ច្រក គឺអូរស្មាច់ ដូង និងប៉ោយប៉ែត ដើម្បីងាយស្រួលគ្រប់គ្រង និងដឹកជញ្ជូន។ ចំណែកអ្នកចូលមកតាមច្រករបៀង ត្រូវធ្វើចត្តាឡីស័ក នៅតាមច្រកព្រំដែននោះ ហើយបើច្រើន ត្រូវទាក់ទងកងទ័ព ដើម្បីដឹកជញ្ជូនអ្នកទាំងនោះ។ សម្ដេចតេជោ ក៏បានបញ្ជាឲ្យក្រសួងសុខាភិបាល បញ្ចេញម៉ាសក្រណាត់ និងម៉ាសធម្មតា ទៅតាមបណ្ដាខេត្តជាប់ព្រំដែន ពិសេសនៅច្រកព្រំដែនទាំង ៣ អូរស្មាច់ ដូង និងនៅប៉ោយប៉ែត៕

## ដំណឹងល្អ! មិនមានពលករខ្មែរឆ្លងកូវីដ១៩ ដែលកំពុងផ្ទុះឡើងនៅខេត្តសាមុតសាខន ប្រទេសថៃនោះទេ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

(ភ្នំពេញ)៖ មកដល់ម៉ោងនេះ តាមការផ្ដល់ព័ត៌មានបឋមពីស្ថានភាពឆ្លងរីករាលជំងឺកូវីដ១៩ នៅក្នុងខេត្តសាមុតសាខន ប្រទេសថៃ អ្នកឆ្លងជំងឺមានចំនួន ៦៩៤នាក់ហើយ ហើយអ្នកដែលឆ្លងប្រមាណ ៩០ភាគរយ ជាពលករចំណាកស្រុកមកពីប្រទេសមីយ៉ាន់ម៉ា និង១០ភាគរយ ជាពលរដ្ឋថៃ។ សេចក្ដីរាយការណ៍បានកត់សម្គាល់ថា ក្នុងចំណោមអ្នករកឃើញឆ្លងជំងឺកូវីដ១៩ ទាំងជិត ៧០០នាក់នោះ មិនមានពលករខ្មែរនោះទេ។ ដោយឡែក ពាក់ព័ន្ធនឹងការបិទខេត្តសាមុតសាខន គឺពលករខ្មែរដែលធ្វើការនៅទីនោះ មិនអនុញ្ញាតឲ្យចាកចេញនោះទេ និងទាំងអ្នកក្នុងខេត្តទាំងមូល ត្រូវបិទរយៈពេល ១៤ថ្ងៃ។ ក្នុងករណី មានការឆ្លងខេត្តអំឡុងពេលនេះ ត្រូវបានពិនិត្យយ៉ាងលម្អិត និងចាត់ទុកជាករណីខុសច្បាប់៕

## ថៃនឹងធ្វើតេស្ត មនុស្ស១ម៉ឺននាក់ ក្រោយមានករណី ជម្ងឺកូវីដ១៩ កើនឡើងខ្លាំង

https://dap-news.com/international/ ByRC105 Posted on December 20, 2020

បរទេស៖ ប្រទេសថៃគ្រោងធ្វើតេស្តប្រជាជនជាង១ម៉ឺននាក់ ក្រោយមានករណីឆ្លងជម្ងឺកូវីដ១៩ប្រចាំថ្ងៃលើសចំនួន៥០០ករណី ដែលភាគច្រើន គឺកើតមាននៅក្នុងចំណោមកម្មករចំណាកស្រុក ពាក់ព័ន្ធជាមួយផ្សារបង្គាមួយកន្លែងនៅជិតរាជធានី នេះបើតាមសម្ដីរបស់មន្ត្រីថៃមួយរូប នៅថ្ងៃអាទិត្យនេះ។ អ្នកនាំពាក្យឲ្យក្រុមការងារ ជម្ងឺកូវីដ១៩របស់ប្រទេសថៃ បាននិយាយប្រាប់សន្និសីទកាសែតមួយថា នៅត្រឹមថ្ងៃពុធ អាជ្ញាធរមានបំណងធ្វើតេស្តចំនួន១០.៣០០ នៅក្នុងខេត្ត Samut Sakhon ជាទីមានការផ្ទុះឆ្លងខ្លាំង និងខេត្តនៅក្បែរនោះមួយចំនួន ដូចជាខេត្ត Samut Songkhram ខេត្ត Nakhon Pathom និងខេត្ត Taweesin Wisanuyothin ជាដើម។ យោងតាមសេចក្ដីរាយការណ៍មួយ ចេញផ្សាយដោយទីភ្នាក់ងារសារព័ត៌មាន Us News នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ បានឲ្យដឹងថា មន្ត្រីនាំពាក្យរូបនោះ បាននិយាយប្រាប់យ៉ាងដូច្នេះថា "លទ្ធផលរកឃើញករណីថ្មី នឹងនៅតែបន្តនៅក្នុងបណ្ដាខេត្តមានចំនួន ជាជាក់ស្ដែងនៅទូទាំងប្រទេស"៕ ប្រែសម្រួល៖ប៉ាង កុង

# ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២០

## ក្មេងស្រីរងគ្រោះជនជាតិខ្មែរម្នាក់ អាយុ ១៤ ឆ្នាំ ដែលត្រូវបានមេខ្យល់ឆបោកទៅ ប្រទេសចិន ត្រូវបានជួយសង្គ្រោះដោយជោគជ័យ

http://cambodiapolice.com/policekh/ 5:16 pm 19 ធ្នូ 2020

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលព័ត៌មានពីស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពាក់ព័ន្ធនឹងគណនីហ្វេសប៊ុកឈ្មោះ អូនរីនស្រឡាញ់ ម៉ាក់ប៉ា ដែលត្រូវបានជនសង្ស័យជាមេខ្យល់ឆបោកនាំទៅប្រទេសចិនរយៈពេល ៤ ខែកន្លងមកហើយ កាលពី ព្រឹកថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២០នេះ ។ បន្ទាប់ពីទទួលបានព័ត៌មាននេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានដាក់បទបញ្ជាឱ្យកម្លាំងការិយាល័យជំនាញធ្វើការស្រាវជ្រាវ និងបានរកឃើញសាច់ញាតិម្ចាស់គណនីហ្វេសប៊ុក ខាងលើមានឈ្មោះ ឯល ណារី ភេទប្រុស អាយុ៤១ឆ្នាំ មុខរបរជាសន្តិសុខក្រុមហ៊ុនឯកជន កំពុងបម្រើការងារនៅកាស៊ីណូមួយ កន្លែង នៅទីក្រុងប៉ោយប៉ែត និងមានទីលំនៅភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែល ត្រូវជាឪពុកម្ចាស់គណនីហ្វេសប៊ុកខាងលើនោះ ។ តាមរយៈការទំនាក់ទំនងតាមទូរសព្ទ បុរសជាឪពុកបានបញ្ជាក់ថា កូនស្រីរបស់ គាត់មានឈ្មោះ យឿង សុជារីន អាយុ១៤ឆ្នាំ បានចាញ់បោកមេខ្យល់មិនស្គាល់អត្តសញ្ញាណ នាំយកទៅប្រទេសចិន រយៈពេល៤ខែ កន្លងមកហើយ រូបគាត់បានទៅដាក់ពាក្យបណ្តឹងនៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០២០ ស្នើសុំឲ្យសមត្ថកិច្ចនគរបាលជួយអន្តរាគមន៍ដោះស្រាយ។

ឯកឧត្តម ឧត្តមសេនីយ៍ ជីវ ផល្លី បញ្ជាក់ថា នៅរសៀលថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០២០ ក្រោមកិច្ចសហប្រតិបត្តិការល្អរវាងអាជ្ញាធរចិន និងសមត្ថកិច្ចពាក់ព័ន្ធរបស់កម្ពុជា បានស្រាវជ្រាវស្វែងរកឃើញកន្លែងស្នាក់នៅរបស់ក្មេងស្រីរងគ្រោះខាងលើ និងបានជួយសង្គ្រោះបញ្ជូនមកស្នាក់ការនគរបាលនៅខេត្តហឺណាន ប្រទេសចិន ដើម្បីចាត់ការបន្ត ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់ឲ្យដឹងថា មន្ត្រីជំនាញរបស់នាយកដ្ឋាន បាន និងកំពុងធ្វើការទំនាក់ទំនងសម្របសម្រួលផ្តល់ព័ត៌មានខាងលើទៅឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារលេខាធិការដ្ឋានមេគង្គឡានឆាង ដើម្បីធ្វើការបន្តជាមួយស្ថានអគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសចិន ដើម្បីឈានដល់ការ សម្របសម្រួលជាមួយអាជ្ញាធរចិនរៀបចំបែបបទបញ្ជូនក្មេងស្រីរងគ្រោះខាងលើឲ្យវិលត្រឡប់មកកម្ពុជាវិញ។ ឯកឧត្តមឧត្តមសេនីយ៍ឯក ជីវ ផល្លី បានសង្កត់ធ្ងន់ថា ជាទិសដៅបន្តនាយកដ្ឋាននឹងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធរង់ ចាំទទួលជនរងគ្រោះ ហើយក្រោយពេលដែលជនរងគ្រោះបានអនុវត្តវិធានការចត្តាឡីស័ករបស់ក្រសួងសុខាភិបាលរួច មន្ត្រីជំនាញនឹងធ្វើការសម្ភាសន៍ស្វែងរកព័ត៌មានលម្អិតដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យជាមេខ្យល់ និងឈានដល់ការ នាំខ្លួនមកផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានថ្លែងថា ក្នុងនាមថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្នុងនាមនាយកដ្ឋានជំនាញ សូមថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរបស់អាជ្ញាធរចិន និងស្ថាប័នពាក់ព័ន្ធដែលបានរួមចំណែកលើការងារនេះ និងសូមអរគុណចំពោះសាធារណជន អ្នកសារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមដែលតែងតែចូលរួមចំណែកក្នុងកិច្ចការងារ រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងក៏ដូចជាការចូលរួមចំណែកស្វែងរកយុត្តិធម៌សង្គម៕

## ព័ត៌មានបឋម ៖ នៅច្រកអន្តរជាតិដូង ខេត្តបាត់ដំបង ជាប់ព្រំដែនកម្ពុជា ថៃ ក្រុមការងារសុខាភិបាលខេត្តបាត់ដំបង បាននឹងកំពុងធ្វើតេស្តសំណាករកវីរុសកូវីដ-១៩ លើពលករខ្មែរ ចំនួន១៧ នាក់

http://nokorwatnews.com/ 21-12-2020

ខេត្តបាត់ដំបង៖ តាមការបញ្ជាក់របស់ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានឲ្យដឹងថា គិតត្រឹមម៉ោង ១១ ព្រឹក ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២០នេះនៅច្រកអន្តរជាតិដូង ខេត្តបាត់ដំបង ជាប់ព្រំដែនកម្ពុជា ថៃ ក្រុមការងារសុខាភិបាលខេត្តបាត់ដំបង បាននិងកំពុងធ្វើតេស្តសំណាករកវីរុសកូវីដ-១៩ លើពលករខ្មែរ ចំនួន១៧ នាក់ (ក្នុងនោះ មនុស្សចាស់ ១៥នាក់ និងក្មេងចំនួន ២នាក់)។ លោកប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានបញ្ជាក់ទៀតថា ប្រជាពលរដ្ឋដែលមកធ្វើតេស្តយកសំណាកនេះ ភាគច្រើនមកពីខេត្តច័ន្ទបូរី ជាប់ខេត្តបាត់ដំបង ប្រទេសថៃតែម្តង គឺមិនមានករណីបងប្អូនពលករធ្វើដំណើរមកពីខេត្ត សាមុតសាខន នោះទេ។

សូមបញ្ជាក់ថា, ច្រកព្រំដែនជាច្រើននៅជាប់ប្រទេសថៃ ត្រូវបានសម្តេចតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានឲ្យអាជ្ញាធរ សមត្ថកិច្ច កងកម្លាំងនៅទីនោះ បង្រួញឲ្យនៅត្រឹមចំនួន ៣ច្រកតែប៉ុណ្ណោះ គឺច្រកអូរស្មាច់ នៅខេត្តឧត្តរមានជ័យ ច្រកប៉ោយប៉ែត នៅខេត្តបន្ទាយមានជ័យ ហ្នឹងច្រកដូង នៅខេត្តបាត់ដំបង។ សម្តេចបានថ្លែងឲ្យបង្រួញច្រកនៅត្រឹមតែ ៣ ជាប់នេះ ក្នុងគោលបំណងនៅស្រួលឲ្យសមត្ថកិច្ច អាជ្ញាធរ នគរបាលអន្តោប្រវេសន៍ មន្ត្រីសុខាភិបាល ក្នុងការត្រួតពិនិត្យឲ្យបានហ្មត់ចត់ ទាំងការយកសំណាក ការធ្វើចត្តាឡីស័ក។ ដោយសម្តេចបានកំណត់ឱ្យ អនុវត្តតាមកំឡុងខែមេសា ឆ្នាំ២០២០ កន្លងទៅ ធ្វើបានល្អប្រសើរ លើវិធានការទប់ស្កាត់ជំងឺកូវីដ-១៩៕

## ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ៖ ពលករមកពីថៃតាមច្រកអន្តរជាតិអូរស្មាច់១៧៦នាក់មាន៣៥នាក់ បានបញ្ជូនទៅយកសំណាកដោយសារពួកគាត់មកពីតំបន់ផ្ទុះករណីឆ្លងកូវីដ-១៩

http://www.freshnewsasia.com/ 2020-12-21 08:38pm

**(ឧត្តរមានជ័យ)៖** លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានថ្លែងប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ឲ្យដឹងនៅព្រលប់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះថា ក្នុងចំណោមពលករមកពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ចំនួន១៧៦នាក់ មានពលករចំនួន៣៥នាក់ ត្រូវបានបញ្ជូនទៅយកសំណាករកមេរោគកូវីដ-១៩។ លោកឃ្លោក ហួត បានថ្លែងអោយដឹងយ៉ាងដូច្នេះទៀតថា៖ **«មូលហេតុដែលក្រុមគ្រូពេទ្យយកសំណាករបស់ពលករទាំង៣៥នាក់ ក្នុងចំណោម១៧៦នាក់នេះ គឺដោយសារពួកគាត់មកពីខេត្តនិងតំបន់នានាដែលកំពុងផ្ទុះករណីឆ្លងមេរោគកូវីដ-១៩ នៅក្នុងប្រទេសថៃ ហើយចំណែកឯអ្នកមួយចំនួនទៀតគឺមានអាការៈផ្តាសាយនិងហៀសំបោរ»**។ លោកប្រធានមន្ទីរសុខាភិបាល បានថ្លែងបញ្ជាក់ទៀតថា៖ «ពេញមួយថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះ ពលករខ្មែរចំនួន១៧៦នាក់ បានចាកចេញពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញតាមច្រកអន្តរជាតិអូរស្មាច់ ស្ថិតក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ លោកថាក្នុងចំណោមពលករទាំង១៧៦នាក់ គឺមានស្រី ៧៤នាក់ ត្រូវបានដឹកជញ្ជូនតាមរថយន្តយកទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃនៅក្រុងសំរោង ហើយក្នុងចំណោម ១៧៦នាក់ គឺមាន៣៥នាក់ត្រូវបានបញ្ជូនទៅយកសំណាក ដោយសារ ដោយសារពួកគាត់ត្រឡប់មកពីតំបន់ប្រឈមនានានៅក្នុងប្រទេសថៃពាក់ពន្ធ័និងមេរោគកូវីដ-១៩។

តាមរយៈលោក យិន ញ៉ាណ អភិបាលរងខេត្តឧត្តរមានជ័យ លោក ឃ្លោក ហួត សូមថ្លែងនូវការអរគុណដល់លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ ដែលបានផ្តល់នូវធុងបាញ់ថ្នាំសម្លាប់មេរោគដល់មន្ទីរសុខាភិបាល សម្រាប់ធ្វើសកម្មភាពបាញ់ថ្នាំសម្លាប់មេរោគនៅតាមមណ្ឌលចត្តាឡីស័ក ដែលទើបរៀបចំនិងបន្តរៀបចំ។

ជាមួយគ្នានេះដែរ លោកក៏ថ្លែងនូវការអរគុណចំពោះកម្លាំងមានសមត្ថកិច្ច ដែលបានចូលរួមសហការក្នុងការដឹកជញ្ជូនពលករយកទៅគោលដៅធ្វើចត្តាឡីស័ក៕

## គ្រាន់តែ១ថ្ងៃមានពលករខ្មែរចេញពីថៃចូលមកកម្ពុជាចំនួន៥៥១នាក់

https://kampucheathmey.com/ December 22, 2020 By Sokhom Khon

គ្រាន់តែក្នុងរយៈពេល១ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០មានពលករខ្មែរដែលចេញពីប្រទេសថៃចូលកម្ពុជាតាមច្រកព្រំដែននានាមានចំនួន៥៥១នាក់។ យោងតាមទិន្នន័យរបស់ស្ថានកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃដែលបានផ្ញើជូនលោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ បានឲ្យដឹងថា នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០នេះ មានពលករខ្មែរចេញពីប្រទេសថៃ ចូមមកកម្ពុជាសរុបចំនួន៥៥១នាក់ ក្នុងនោះស្រី១៩៥នាក់ និងក្មេងចំនួន១១នាក់។ តាមទិន្នន័យដដែលបានបន្តថា ចំនួន៥៥១នាក់ដែលចេញពីថៃចូលមកកម្ពុជានោះ ចូលតាមច្រកចំនួន៨រួមមាន ច្រកអន្តរជាតិប៉ោយប៉ែតចំនួន៥៤នាក់ ស្រី៦នាក់ ច្រកដូង២៥៤នាក់ ស្រី៩២នាក់ ច្រកព្រំ២០នាក់ ស្រី១នាក់ ច្រកម៉ាឡៃ៦នាក់ស្រី១នាក់ ច្រកអូរបីជាន់១៩៣នាក់ ស្រី៨៥នាក់ ច្រកបឹងត្រកួន៦នាក់ស្រី២នាក់ ច្រកតំបន់ស្ទូកស្ពោរ៦នាក់ ស្រី៣នាក់និងតំបន់ចាន់គីរី១២នាក់ ស្រី៥នាក់។ ការចាកចេញរបស់ពលករខ្មែរពីថៃចូលមកប្រទេសកម្ពុជានេះ បន្ទាប់ពីមានករណីផ្ទុះជំងឺកូវី១៩នៅខេត្តសាមុតសខនប្រទេសថៃ ចូលសហគមន៍។

ដើម្បីទប់ស្កាត់ការឆ្លងរាតត្បាតជំងឺកូវីដ១៩ក្នុងប្រទេសថៃ ខេត្តសាមុតសាខនបានប្រកាសបិទខេត្ត និងដាក់បម្រាមគោចរនិងវិធានការផ្សេងៗ ដូចខាងក្រោមសំរាប់ប្រជាពលរដ្ឋរស់នៅខេត្តសាមុតសាខន ហាមធ្វើដំណើរចេញទៅក្រៅខេត្ត (Lockdown) ចំនួន១៤ថ្ងៃ ចាប់ពីថ្ងៃ១៩ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣ ខែមករា ឆ្នាំ២០២១។ ហាមឃាត់មិនអោយប្រជាពលរដ្ឋចេញពីផ្ទះចាប់ពីម៉ោង ១០យប់ ដល់ម៉ោង៥ភ្លឺ។ ពលករបរទេសហាមផ្លាស់ទីចេញខេត្តសាមុទ្រសាខនជាដាច់ខាតអ្នកបំពាននឹងទទួលទោសនិងផាកពិន័យ។ បិទផ្សារបង្គា និងសន្តេវាសិកដ្ឋានស្រ៊ីមឿង ក្នុងរយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី៣ ខែមករាឆ្នាំ២០២១។ បិទកន្លែងសាធារណទូទៅ ដូចជាពហុកីឡាដ្ឋាន សង្វៀនប្រដាល់ សាលារៀន កន្លែងថែទាំកូនក្មេង ផ្សារទំនើប។ល។ ហាងលក់ម្ហូបអាហារនិងភេសជ្ជៈបើកតែសម្រាប់ទិញខ្ចប់យកទៅផ្ទះ លើកលែងតែមន្ទីរពេទ្យ។ ហាងលក់ទំនិញកំណត់ម៉ោងបិទចាប់ពី ២២.០០ – ០៥.០០ និងមិនមានមនុស្សច្រើន។ ផ្សារណាត់និងផ្សារលក់ម្ហូបស្រស់ អាចលក់បានតែរយៈពេល៦ម៉ោងប៉ុណ្ណោះ ៕ អត្ថបទ ៖ សំអឿន

## គិតត្រឹមរសៀលថ្ងៃទី២១ ធ្នូពលរដ្ឋវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ចំនួន១០២នាក់

https://kampucheathmey.com/ December 21, 2020 By Kang Tola

គិតត្រឹមម៉ោង៣រសៀលនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះ ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ ឬចូលឆ្លងកាត់នោះឡើយ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩ នេះបើតាមប្រភពព័ត៌មានពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលទើបទទួលបាននៅរសៀលនេះ។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែងទំនិញ ដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគីកម្ពុជា និងថៃ ត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកពលរដ្ឋខ្មែរ ដែលវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន១០២នាក់ ស្រី៤១នាក់។ ដោយឡែករថយន្តកងពល

តូចដឹកជញ្ជូនលេខ៩៩ចំនួន១៣គ្រឿង បានត្រៀមជាស្រេចនៅទីនោះ ដើម្បីដឹកជញ្ជូនពលករ ដែលវិលត្រឡប់ពីប្រទេសថៃវិញ យកទៅធ្វើចត្តាឡីស័ក ១៤ថ្ងៃនៅសាលាវិទ្យាល័យតេជោសែន ក្រុងសំរោង ខេត្តឧត្តរមានជ័យ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាវិធានការរបស់ក្រសួងសុខាភិបាល។

សូមបញ្ជាក់ថា ដោយយោងតាមសេចក្តីណែនាំជាបន្ទាន់របស់ក្រសួងសុខាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីការការពារការចម្លងបន្តពីការផ្ទុះនូវការចម្លងវីរុសកូវីដ-១៩ នៅខេត្តសាមុតសាខន នៃប្រទេសថៃ កាលពីពេលថ្មីៗនេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដាក់ចេញវិធានការ ដើម្បីទប់ស្កាត់ការរីករាលដាល នៃជំងឺនេះ និងបានប្រាប់ឲ្យសមត្ថកិច្ចច្រកទ្វារទាំងអស់ យកចិត្តទុកដាក់ និងល្បាត ឃាត់អ្នកដំណើរ ដែលចូលពីប្រទេសថៃ ប្រគល់ឲ្យផ្នែកសុខាភិបាល ដើម្បីត្រួតពិនិត្យសុខភាព និងធ្វើចត្តាឡីស័ក ឲ្យបានត្រឹមត្រូវបំផុត។ បើតាមអគ្គនាយកដ្ឋានអន្តោប្រវេសន៍ វិធានការទាំងនោះមាន៣ចំណុចសំខាន់ៗរួមមាន ទី១- ត្រូវបន្តរួមសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីក្រសួងសុខាភិបាលធ្វើការត្រួតពិនិត្យ ជាពិសេសដំណើរចូលរបស់ភ្ញៀវបរទេស និងពលរដ្ឋខ្មែរដែលចូលមកពីប្រទេសថៃ ឲ្យបានហ្មត់ចត់ ដោយតម្រូវឲ្យពួកគាត់ធ្វើការធ្វើចត្តាឡីស័កត្រឹមត្រូវតាមការកំណត់។
ទី២- យកចិត្តទុកដាក់គ្រប់គ្រង និងល្បាតត្រួតពិនិត្យស្លាបឆ្វេង ស្លាបស្តាំ ក្នុងដែនសមត្ថកិច្ចច្រកទ្វារឲ្យបានច្បាស់លាស់ និងត្រូវឃាត់អ្នកដំណើរចូល ជាពិសេសពលរដ្ឋខ្មែរដែលចូលពីប្រទេសថៃ ដើម្បីយកមកប្រគល់ឱ្យមន្ត្រីភ្នាក់ងារសុខាភិបាល ធ្វើការត្រួតពិនិត្យសុខភាព និងធ្វើចត្តាឡីស័ក ឱ្យបានហ្មត់ចត់។ ទី៣- ត្រូវយកចិត្តទុកដាក់ធ្វើការណែនាំ ក្រើនរំលឹកដល់មន្ត្រីនគរបាលអន្តោប្រវេសន៍ ដែលប្រចាំការនៅច្រកទ្វារឲ្យយកចិត្តទុកដាក់រក្សាគម្លាតបុគ្គល រក្សាអនាម័យលាងដៃនឹងសាប៊ូ អាកុល ឬជែល និង ប្រុងប្រយ័ត្នការឆ្លងពីអ្នកដំណើរដែលចូលមកព្រះរាជាណាចក្រកម្ពុជា៕ ដោយ ៖ កោះកែវ

## ពលករខ្មែរចេញពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជិត២០០នាក់ ត្រូវបាននាំយកទៅធ្វើចត្តាឡីស័ក១៤ថ្ងៃ នៅក្រុងសំរោង

http://www.freshnewsasia.com/ 2020-12-21 03:58pm

**(ឧត្តរមានជ័យ)៖** ពលករខ្មែរប្រុស ស្រី ចំនួន១៧២នាក់ នៅព្រឹកថ្ងៃទី២១ខែ ធ្នូឆ្នាំ២០២០នេះ បានចាកចេញពីប្រទេសថៃ តាមច្រកអន្តជាតិអូរស្មាច់ត្រូវបានអាជ្ញាធរ ខេត្តឧត្តរមានជ័យ និងមន្ត្រីពាក់ព័ន្ធដឹកតាមរថយន្តឱ្យទៅធ្វើចត្តាឡីស័ក រយៈពេល១៤ថ្ងៃ នៅក្រុងសំរោង។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានថ្លែងឱ្យដឹងថា គិតត្រឹមម៉ោង ១១៖០០នាទីព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះ ពលករខ្មែរ ចំនួន១៧២នាក់ បានចាកចេញពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ ស្ថិតក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ហើយពលករទាំងអស់នោះ ត្រូវបានដឹកជញ្ជូនតាមរថយន្ត ទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅក្នុងក្រុងសំរោង។ លោក ឃ្លោក ហួត បន្ថែមថា នៅព្រឹកនេះដែរ សកម្មភាពរថយន្តដឹកជញ្ជូនពលករ ក្រោមការណែនាំរបស់លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានប្រើប្រាស់ រថយន្តរបស់តំបន់ប្រតិបត្តិការសឹករងខេត្តចំនួន៤គ្រឿង និងរថយន្តរបស់ស្នងការដ្ឋានចំនួន១គ្រឿង ជាបណ្តោះអាសន្នសិន។ ស្របពេលរថយន្តរបស់កងទ័ពមកដល់ ចំនួន១៥គ្រឿង គឺឈប់ប្រើរថយន្តសឹករង និងរថយន្តស្នងការនគរបាលខេត្តហើយ។ ពេលនេះរថយន្តកងទ័ពដែលមកដល់គឺចំនួន៧គ្រឿង ត្រៀមចាំនៅមាត់ច្រកអូរស្មាច់ និង៨គ្រឿងទៀតត្រៀមចាំនៅខាងក្រោម។

ក្នុងនាមលោក ប៉ែន កុសល្យ លោកប្រធានមន្ទីរសុខាភិបាលខេត្ត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចតេជោ ហ៊ុន សែន ដែលបានផ្តល់ម៉ាស់ចំនួន ៤០ម៉ឺនម៉ាស់ សម្រាប់ចែកជូនពលករនៅមាត់ច្រក។

លោកបានថ្លែងបញ្ជាក់ថា ថ្ងៃម្សិលមិញនិងថ្ងៃនេះ គឺក្រុមការងារកំពុងខិតខំប្រឹងប្រែង រៀបចំពង្រីកមណ្ឌលចត្តាឡីស័ក បន្ថែមទៀតនៅតាមសាលារៀននានា លោកក៏ថ្លែងនូវការអរគុណដល់កងកម្លាំងនគរបាលនៃស្នងការដ្ឋាននគរបាលខេត្ត ដែលបានចូលរួមក្នុងសកម្មភាពនេះផងដែរ៕

## ពលករខ្មែរដែលត្រឡប់មកកម្ពុជាវិញ តាមច្រកប៉ោយប៉ែតជាង៣០០នាក់ តម្រូវឲ្យធ្វើចត្តាឡីស័ក ១៤ថ្ងៃ

http://btv.com.kh/ 21/12/2020

ភ្នំពេញ៖ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ លោក អ៊ុំ រាត្រី បានថ្លែងអះអាងថា រហូតដល់ម៉ោង១២ ថ្ងៃត្រង់ ទី២១ ខែធ្នូនេះ មានបងប្អូនពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ តាមច្រកប៉ោយប៉ែត បន្ទាប់ពីមានករណីផ្ទុះមេរោគកូវីដ១៩ ចូលសហគមន៍នៅប្រទេសថៃនោះ គឺមានចំនួន៣១៥នាក់ ហើយ ដោយពួកគាត់ទាំងនោះ ត្រូវបានតម្រូវឲ្យធ្វើចត្តាឡីស័ក ដាច់ដោយឡែកពីគ្នាស្របទៅតាមការណែនាំរបស់រាជរដ្ឋាភិបាលនោះ។ ថ្លែងក្នុងកិច្ចសម្ភាសន៍ពិសេសជាមួយប៊ីធីវី នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះ លោក អ៊ុំ រាត្រី បានបញ្ជាក់ឲ្យដឹងថា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធទាំងអស់បានត្រៀមខ្លួនគ្រប់លក្ខណៈរួចជាស្រេច ក្នុងការទប់ស្កាត់បងប្អូនពលករខ្មែរ ដែលទើបតែវិលត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីមានការរីករាលដាលនូវមេរោគកូវីដ១៩នៅប្រទេសថៃ ហើយក្នុងអំឡុងពេលធ្វើចត្តាឡីស័កដល់ពួកគាត់រយៈពេល ១៤ថ្ងៃនោះ នឹងមិនធ្វើឲ្យពួកគាត់ជួបនូវការលំបាកអ្វីទាំងអស់ទាំងការរស់នៅ និងការហូបចុកជូនដល់ពួកគាត់នោះ។

សូមបញ្ជាក់ថា បន្ទាប់មានករណីផ្ទុះមេរោគកូវីដ១៩ចូលសហគមន៍ប្រទេសថៃ កាលពីយប់ថ្ងៃទី១៩ និងថ្ងៃទី២០ ខែធ្នូនោះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជា ឲ្យអាជ្ញាធរខេត្តដែលជាប់នឹងប្រទេសថៃទាំងអស់ ជាពិសេសនៅច្រកដូង អូរស្មាច់ និងប៉ោយប៉ែត ត្រៀមលក្ខណៈឲ្យបានគ្រប់គ្រាន់នឹងត្រូវបង្កើនការត្រួតពិនិត្យប្រជាពលរដ្ឋឆ្លងចូលមកកម្ពុជាវិញឲ្យបានល្អ ហើយនិងត្រូវធ្វើចត្តាឡីស័កឲ្យបានគ្រប់ថ្ងៃស្របតាមការកំណត់របស់ក្រសួងសុខាភិបាលជាដើមនោះ។ ទាក់ទងនឹងករណីឆ្លងនូវមេរោគកូវីដ១៩ ចូលក្នុងសហគមន៍ប្រទេសថៃនេះដែរ សម្តេចតេជោ ហ៊ុន សែន ក៏បានបញ្ជាឲ្យកងទ័ពបញ្ចេញរថយន្តធុនធំជិតមួយរយគ្រឿងផងដែរ ដើម្បីត្រៀមដឹកបងប្អូនពលករទាំងនោះ នៅច្រកចំនួនបី គឺច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ច្រកដូង ខេត្តបាត់ដំបង និងច្រកអូរស្មាច់ខេត្តឧត្តរមានជ័យ៕ អត្ថបទ៖ បាន ចក់

## អភិបាលខេត្តកោះកុង ចុះពិនិត្យស្ថានភាពច្រកទ្វារអន្តរជាតិចាំយាម និងប្រាប់មន្ត្រីប្រចាំការត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតដើម្បីទប់ស្កាត់កូវីដ១៩, លោកឧកញ៉ា លី យ៉ុងផាត់ ផ្តល់បន្ទប់ចំនួន៩៤ ទុកធ្វើចត្តាឡីស័កសម្រាប់ពលករ

http://www.freshnewsasia.com/ 2020-12-21 05:52pm

**(កោះកុង)៖** លោកស្រី មិថុនា ភូថង អភិបាលខេត្តកោះកុង នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះ បានដឹកមន្ត្រីក្រោមឱវាទចុះពិនិត្យមើលពីស្ថានភាព នៃច្រកទ្វារអន្តរជាតិចាំយាម-ហាលិច ដែលមានព្រំប្រទល់ជាប់គ្នាជាមួយប្រទេសថៃ និងអាចមានការបញ្ជូនពលករខ្មែរឲ្យវិលចូលស្រុកវិញ តាមច្រកទ្វារអន្តរជាតិនេះ។ ក្នុងឱកាសនោះ លោកស្រី មិថុនា ភូថង បានលើកឡើងថា ដោយអនុវត្តន៍តាមការណែនាំរបស់រាជរដ្ឋាភិបាល ឲ្យបណ្តាខេត្តដែលជាប់ព្រំដែន នៃប្រទេសជិតខាង មានការយកចិត្តទុក្ខដាក់ឲ្យខ្ពស់ នៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ជាពិសេសព្រំដែនកម្ពុជា-ថៃ ដែលមានហានិភ័យខ្ពស់ ហើយមានពលករខ្មែរធ្វើសំណាក់នៅទីនោះផងដែរ។ អភិបាលខេត្តបានគូសបញ្ជាក់ថា ដើម្បីការពារសុវត្ថិភាព នៃការរីករាលដាលចូលក្នុងសហគមន៍មន្ត្រីប្រចាំការនៅតាមច្រកទ្វារអន្តរ

ជាតិ ព្រំដែនទឹក ព្រំដែនគោក ត្រូវក្តាបឲ្យជាប់ និងតាមដានរាល់សភាពការ នៃការឆ្លងដែនរបស់ ពលករនេះបើសិនអាចមាន។ ម្យ៉ាងត្រូវរង់ចាំមើលជាប់ជានិច្ចក្រែសមត្ថកិច្ចថៃ បានបញ្ជូនពលករខ្មែរត្រឡប់ចូលស្រុកកំណើតវិញ។ ប្រសិនមានសមត្ថកិច្ចថៃបញ្ជូនពលករខ្មែរចូលមក មន្ត្រីសុខាភិបាលត្រូវត្រៀតពិនិត្យធ្វើ ចត្តាឡីស័ក១៤ថ្ងៃសិន។ ជាមួយគ្នានេះ លោកស្រីអភិបាលខេត្ត បានថ្លែងអំណរគុណដល់លោកឧកញ៉ា លី យ៉ុងផាត់ ដែលបានផ្តល់បន្ទប់ចំនួន៩៤បន្ទប់ ក្នុងការសម្រាកធ្វើចត្តាឡីស័ក ពលករឆ្លងដែនពីប្រទេសថៃ។

លោកវេជ្ជបណ្ឌិត ទៅ ម៉ឹង ប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង បានឲ្យដឹងថា ដោយអនុវត្តតាមអនុសាសន៍របស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល លោកបានចាត់ឲ្យមន្ត្រីប្រចាំការច្រកទ្វារអន្តរជាតិចាំយាម-ហាលិក និងសមត្ថកិច្ចផ្លូវទឹក-គោក ត្រូវសហការគ្នាផ្តល់ព័ត៌មានឲ្យបានយ៉ាងឆាប់រហ័សកុំធ្វេសប្រហែស។ លោកបានលើកឡើងថា បើសិនអាជ្ញាធរថៃបញ្ជូនពលករខ្មែរឲ្យវិលចូលស្រុកវិញ អាជ្ញាធរកម្ពុជា មានកន្លែងស្នាក់នៅដើម្បីធ្វើចត្តាឡីស័កគ្រប់គ្រាន់ និងមានអាហារឲ្យឧបត្ថម្ភគ្រប់គ្រាន់ ដោយមិនឲ្យខ្វះឡើយ។ អ្វីដែលសំខាន់ លោកឧកញ៉ា លី យ៉ុងផាត់ សហការជាមួយមន្ទីរសុខាភិបាលផ្តល់កន្លែងស្នាក់នៅ ចំនួន៩៤បន្ទប់ សម្រាប់អ្នកធ្វើចត្តាឡីស័ក នៅផែស្ងួតនេសាទ៕

## ក្រសួងការងារ ចេញសេចក្តីជូនដំណឹងដល់ពលករខ្មែរកំពុងស្នាក់នៅប្រទេសថៃ និងផ្អាកបញ្ជូនពលករទៅថៃជាបណ្តោះអាសន្ន ក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩ នៅខេត្តសាមុតសាខន

http://www.freshnewsasia.com/ 2020-12-21 06:23pm

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះ បានចេញសេចក្តីជូនដំណឹងស្តីពីវិធានការការពារបងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ព្រមទាំងការផ្អាកបញ្ជូនពលករ MOU និងពលករតាមរដូវកាលទៅធ្វើការងារនៅប្រទេសថៃ ជាបណ្តោះអាសន្ន ក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩ នៅខេត្តសាមុតសាខន។ នេះបើយោងតាមសេចក្តីជូនដំណឹងរបស់ រដ្ឋមន្ត្រីក្រសួងការងារ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅល្ងាចថ្ងៃនេះ។ រដ្ឋមន្ត្រីក្រសួងការងារ បានបញ្ជាក់ថា យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ក្នុងការការពារសុខភាព សុវត្ថិភាព និងជីវភាពរបស់បងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅ និង**ធ្វើការនៅប្រទេសថៃ ក្នុងអំឡុងពេលមានការរាតត្បាតជំងឺកូវីដ-១៩ ក្នុងខេត្តសាមុតសាខននៃប្រទេសថៃនោះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដូចខាងក្រោម៖**

**ក. សម្រាប់បងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

១៖ សូមអនុវត្តឱ្យបានល្អនូវអនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន ជាពិសេសគឺត្រូវរក្សាភាពនឹងនរ និងជឿជាក់លើសមត្ថកិច្ចថៃក្នុងការគ្រប់គ្រង បង្ការ និងព្យាបាលជំងឺកូវីដ-១៩។

២៖សូមរក្សាប្រក្រតីភាពការងារ កុំផ្លាស់ប្តូរកន្លែងស្នាក់នៅ ឬកន្លែងធ្វើការងារពីខេត្តមួយទៅខេត្តមួយ ដែលខុសនឹងបម្រាមរបស់អាជ្ញាធរថៃ។

៣៖ត្រូវចូលរួមសហការ និងគោរពឱ្យបាននូវរាល់បទបញ្ជា និងវិធានការសុខាភិបាលដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចថៃ និងនិយោជកថ្ងៃ។

៤៖ត្រូវអនុវត្តតាមការណែនាំ ឬសេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូត ឬអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ ប្រសិនជាមាន។

៥៖ត្រូវលាងដៃជាមួយនឹងសាប៊ូ ឬដៃលឱ្យបានញឹកញាប់ ពាក់ម៉ាស និងរក្សាអនាម័យឱ្យបានល្អ និងជាប្រចាំនៅកន្លែងធ្វើការងារ និងកន្លែងស្នាក់នៅ ព្រមទាំងកុំចេញទៅកន្លែងសាធារណៈដែលមានមនុស្សច្រើន។

៦៖ត្រូវទាក់ទងទៅស្ថានឯកអគ្គរាជទូត ឬអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាជាបន្ទាន់ក្នុងករណីមានបញ្ហា។

៧៖ចំពោះមុខក្រសួង បាននឹងកំពុងទំនាក់ទំនងជាមួយក្រសួងការងារថៃ និងបានស្នើភាគីថៃសម្រួលការងារឯកសារ ផ្សេងៗដល់បងប្អូនពលករដែលកំពុង ស្នាក់នៅ និងធ្វើការនៅប្រទេសថៃឱ្យបានភាពស្របច្បាប់ ជាបណ្តោះអាសន្នក្នុងអំឡុងពេលមានការរាតត្បាតជំងឺកូវីដ-១៩នេះ។

**ខ.សម្រាប់បងប្អូនពលករ ដែលចាំបាច់ត្រូវវិលត្រឡប់មកស្រុកកំណើតវិញ**

១៖ប្រសិនជាចាំបាច់ត្រូវត្រឡប់មកស្រុកកំណើតវិញនោះ ត្រូវជ្រើសរើសច្រកណាមួយក្នុងចំណោមច្រកអូរស្មាច់ ច្រកដូង និងច្រកប៉ោយប៉ែត ជាដាច់ខាត ដែលនៅទីនោះរាជរដ្ឋាភិបាលមានរៀបចំការត្រួតពិនិត្យសុខភាព ដើម្បីការពារសុខភាពរបស់បងប្អូន ក៏ដូចជាបង្ការ និងការពារសុខភាពក្រុមគ្រួសាររបស់បងប្អូនដែលនៅស្រុកកំណើត។

២៖ត្រូវអនុវត្តវិធានការត្រួតពិនិត្យសុខភាព និងត្រូវធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ទៅតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកព្រំដែន។

៣៖ត្រូវប្រើប្រាស់រថយន្តដែលកំណត់ដោយមណ្ឌលចត្តាឡីស័ក ក្រោយពេលបញ្ចប់ការធ្វើចត្តាឡីស័ក ត្រឡប់ទៅភូមិកំណើត។

៤៖ត្រូវជូនដំណឹងដល់អាជ្ញាធរភូមិ ឃុំ និងអ្នកជិតខាងឱ្យជ្រាបថា ខ្លួនទើបវិលត្រឡប់មកពីប្រទេសថៃ។

៥៖ ក្នុងករណីមានបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ ត្រូវជូនដំណឹងទៅអាជ្ញាធរភូមិ ឃុំរបស់ខ្លួន ដើម្បីទទួលបានសេវាអន្តរាគមន៍នានារបស់រាជរដ្ឋាភិបាល។

៦៖សូមចុះឈ្មោះជាមួយ ទីភ្នាក់ងារជាតិមុខរបរនិងការងារ តាមរយៈ ww.nea.gov.kh ឬទូរសព្ទ ០១៧ ៨៩០ ៦៥៦ ប្រសិនជាបងប្អូនមានបំណងស្វែងរកការងារ ធ្វើក្នុងស្រុក និងសូមចុះឈ្មោះស្វែងរក ឱកាសការងារជាមួយភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ ប្រសិនជាមានបំណងស្វែងរកការងារធ្វើនៅប្រទេសណាមួយផ្សេង។

៧៖សូមចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដោយឥតបង់ថ្លៃនៅគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈណាមួយរបស់ក្រសួង ដែលនៅជិតផ្ទះរបស់ខ្លួន។

**គ.សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងមន្ត្រីពាក់ព័ន្ធ**

១៖ផ្អាកការបញ្ជូនពលករ MOU និងពលករតាមរដូវកាលទៅប្រទេសថៃរហូតដល់មានការជូនដំណឹងជាថ្មី។

២៖ត្រូវបន្តទំនាក់ទំនងជាមួយនិយោជកថៃ ឬសមាគមនិយោជកថៃ និងអាជ្ញាធរថៃ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច កម្ពុជាដើម្បីជួយសម្រួលដល់ ពលករ ក្នុងករណីចាំបាច់តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

ក្រសួងការងារសូមអំពាវនាវឲ្យបងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ទីភ្នាក់ងារជ្រើសរើសឯកជន និងមន្ត្រីពាក់ព័ន្ធជ្រាប និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព៕

## សង្គមស៊ីវិលស្នើរដ្ឋាភិបាលយកចិត្តទុកដាក់ដល់ជនចំណាកស្រុក អំឡុងវិបត្តិជំងឺកូវីដ-១៩

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2020-12-17

អង្គការបណ្តាញជនចំណាកស្រុកក្នុងមហាអនុតំបន់ទន្លេមេគង្គ (MNN) ស្នើឲ្យរដ្ឋាភិបាលយកចិត្តទុកដាក់ដល់ពលករចំណាកស្រុក ក្នុងស្ថានភាពមានវិបត្តិដោយសារជំងឺកូវីដ-១៩។ នៅក្នុងសេចក្តីថ្លែងការណ៍ កាលពីថ្ងៃទី ១៦ ខែធ្នូ ដែលធ្វើក្រោយកិច្ចពិភាក្សានៅក្លឹបអ្នកកាសែត ក្នុងទីក្រុងបាងកកប្រទេសថៃ បណ្តាញអង្គការសង្គមស៊ី

វិលទាំងនេះ បានថ្លែងសាររួមគ្នា ទាមទារសិទ្ធិជូនពលករចំណាកស្រុក នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ រួមទាំងកម្ពុជាផង។

ពីខាងកម្ពុជា មាននាយកប្រតិបត្តិនៃអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) លោក មុំ សុខចារ ដែលរួមចំណែកក្នុងការស្រាវជ្រាវរួមគ្នា ជាមួយអង្គការបណ្ដាញជនចំណាកស្រុកក្នុងមហាអនុតំបន់ទន្លេមេគង្គ បានកត់សម្គាល់ចំណុចខ្វះខាត នៃការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជា លើពលករចំណាកស្រុកខ្មែរ នៅប្រទេសថៃ។ លោក មុំ សុខចារ ទទួលស្គាល់ថា ស្ថានទូតកម្ពុជា បានជួយដល់ពលករចំណាកស្រុកខ្លះដែរ ដូចជាជួយក្នុងការផ្សព្វផ្សាយព័ត៌មាន ជួយខាងរត់ការឯកសារ និងជំនួយសង្គ្រោះបន្ទាន់ សម្រាប់អ្នកដែលទាល់ច្រក ឬកំពុងខ្វះស្បៀងអាហារ ប៉ុន្តែលោកថា ការឆ្លើយតបនោះ នៅតិចតួចស្ដួចស្ដើងណាស់ ហើយពលរដ្ឋខ្មែរចំណាកស្រុកជាច្រើន នៅប្រទេសថៃ កំពុងផុងក្នុងគ្រោះថ្នាក់នៃភាពក្រីក្រ និងខ្វះខាត។ ជុំវិញគោលនយោបាយរដ្ឋាភិបាលកម្ពុជា ក្នុងការជួយពលរដ្ឋខ្មែរចំណាកស្រុកនេះ លោក មុំ សុខចារ បន្ថែមថា បើតាមបទពិសោធន៍ តាំងពីមានផ្ទុះការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋាភិបាលកម្ពុជា មិនមានផែនការច្បាស់លាស់ ក្នុងការជួយពលរដ្ឋខ្មែរចំណាកស្រុកនោះទេ។ លោកស្នើឲ្យរដ្ឋាភិបាល រៀបចំឲ្យមានផែនការច្បាស់លាស់ជាងនេះ ដើម្បីជួយដល់ពលរដ្ឋទាំងនោះ ដើម្បីកុំឲ្យពួកគាត់ជួបប្រទះបញ្ហាដដែលនេះ ទៅថ្ងៃអនាគត។

កាលពីចុងឆ្នាំ២០១៩ ប្រទេសថៃ មានពលករចំណាកស្រុកជាបរទេស ចុះឈ្មោះស្របច្បាប់ ជាង ២លាន ៨សែននាក់ មកពីប្រទេសកម្ពុជា ភូមា និងឡាវ ដែលបម្រើការងារផ្នែកសំណង់ កសិកម្ម និងនេសាទ។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា គិតត្រឹមឆ្នាំ២០១៩ មានពលករខ្មែរធ្វើការនៅប្រទេសថៃ ប្រមាណមួយលាននាក់។ ប៉ុន្តែ មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍ នៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា អង្គការសង់ត្រាល់ (Central) លោក ឌី ថេហូយ៉ា ថា ស្ថានភាពជាក់ស្ដែង ពលករខ្មែរធ្វើការទាំងមានច្បាប់ និងខុសច្បាប់ នៅប្រទេសថៃ មានខ្ទង់ពីរលាននាក់៕

## ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០២០

### សម្ដេចតេជោ ហ៊ុន សែន បញ្ចេញកញ្ចប់ឃីត៦ពាន់ ដល់ខេត្ត៣តាមព្រំដែន សម្រាប់ផ្ដល់ឲ្យពលករដែលធ្វើមាតុភូមិនិវត្តន៍ពីថៃ

http://www.freshnewsasia.com/ 2020-12-22 01:18pm

**(ភ្នំពេញ)៖** សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅយប់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ បានសម្រេចបញ្ចេញឃីតចំនួន ៦ពាន់ឃីត ដើម្បីឧបត្ថម្ភដល់ខេត្តចំនួន៣ នៅតាមព្រំដែន សម្រាប់ផ្ដល់ឲ្យពលករដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសថៃ។

លោកស្រី យក់ សម្បត្តិ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល បានថ្លែងប្រាប់បណ្ដាញព័ត៌មាន Fresh News នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០នេះថា ខេត្តទាំង៣ ដែលទទួលបានកញ្ចប់ឃីតទាំង ៦ពាន់នោះ រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ។ ខេត្តទាំង៣នេះដែរ ទទួលបានឃីតចំនួន ២ពាន់កញ្ចប់ តង់ចំនួន៥ និងកៅអីចំនួន១០០ ទៀតផង។ អ្នកនាំពាក្យក្រសួងសុខាភិបាល បានបញ្ជាក់យ៉ាងដូច្នេះថា៖ «ក្នុងកញ្ចប់ឃីត រួមមាន មុង ខ្នើយ និងកន្ទេល។ ក្នុងមួយខេត្តទទួលបានឃីតចំនួន ២ពាន់កញ្ចប់ តង់ចំនួន៥ និងកៅអីចំនួន១០០ ហើយកញ្ចប់ឃីតត្រូវបានដឹកជញ្ជូនភ្លាមៗទាំងយប់ទៅកាន់គោលដៅរួចរាល់ហើយ។ បើតាមលោកស្រី យក់ សម្បត្តិ, មន្ទីរសុខាភិបាលក្នុងខេត្តទាំង៣ បាននិងកំពុងរៀបចំចាត់ចែងឃីតទាំងនោះ ដល់ពលករដែលមានជីវភាពខ្វះខាត។

សូមជម្រាបថា សម្តេចតេជោ ហ៊ុន សែន បានដាក់បទបញ្ជាទៅអាជ្ញាធរខេត្តចំនួន៧ ដែលនៅជាប់ព្រំដែនកម្ពុជា-ថៃ ឱ្យពង្រឹងការធ្វើចត្តាឡីស័កសម្រាប់ពលករខ្មែរ ដែលត្រឡប់មកប្រទេសថៃ រយៈពេល១៤ថ្ងៃពេញ ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ដែលកំពុងផ្ទុះឡើងយ៉ាងខ្លាំងក្លា ជាង៥០០ករណីក្នុង១ថ្ងៃ នៅខេត្តសាមុតសាខន ប្រទេសថៃ។ ពាក់ព័ន្ធនឹងការពង្រឹងវិធានការតាមបណ្តាខេត្តជាប់ព្រំដែនថៃនេះ សម្តេចតេជោ ហ៊ុន សែន ក៏បានឧបត្ថម្ភថវិកា៥០លានរៀល ក្នុង១ខេត្តផងដែរ ដើម្បីឱ្យខេត្តទាំងនោះរៀបចំដោះស្រាយបញ្ហាចំពោះមុខ ដើម្បីទប់ស្កាត់ការចម្លងមេរោគកូវីដ១៩ ពីប្រទេសថៃ។ ខេត្តទាំង៧ ដែលជាប់ព្រំដែនថៃនោះ រួមមាន បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ព្រះវិហារ ឧត្តរមានជ័យ ពោធិ៍សាត់ និងកោះកុង៕

## លោក ស ខេង រំឭកអាជ្ញាធរតាមព្រំដែនកម្ពុជា-ថៃ ចាត់វិធានការពារទប់ស្កាត់កូវីដ ១៩

https://www.postkhmer.com/ នៀម ឆេង | Publication date 22 December 2020 | 09:40 ICT

**ប៉ៃលិន៖** លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានរំឭកអាជ្ញាធរនៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ឱ្យពង្រឹងគោលការណ៍ណែនាំរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលដាក់ចេញពាក់ព័ន្ធនឹងវិធានការទប់ស្កាត់កូវីដ ១៩ បន្ទាប់ពីមានការផ្ទុះឡើងជំងឺនេះនៅខេត្តសាមុតសាខនប្រទេសថៃ។ ប៉ុន្តែសភាពការណ៍ពលករខ្មែរចូលតាមច្រកទ្វារអន្តរជាតិមិនទាន់មានអ្វីគួរឱ្យកត់សម្គាល់ទេកាលពីម្សិលមិញ។ លោក ស ខេង បានថ្លែងក្នុងពេលលោកធ្វើជាអធិបតីភាពនៃការចូលកាន់តំណែងអភិបាលខេត្តប៉ៃលិននៅថ្ងៃទី ២១ ធ្នូ ថា ខេត្តទាំង ៧ ដែលជាប់ព្រំដែនថៃរួមមានខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ និង កោះកុង ត្រូវអនុវត្តតាមគោលការណ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យបានខ្ជាប់ខ្ជួនក្នុងការទប់ស្កាត់ជំងឺកូវីដ ១៩។ លោកបញ្ជាក់ថា កាលពីមុនវិធានការសម្រាប់ពលករខ្មែរត្រឡប់ពីប្រទេសថៃ មានតែការពិនិត្យកម្តៅរួចអនុញ្ញាតឱ្យបន្តដំណើរទៅមូលដ្ឋានរបស់ពួកគេ លើកលែងតែអ្នកដែលមានអាការគួរឱ្យសង្ស័យប៉ុណ្ណោះដែលត្រូវតាមដានពិនិត្យ និងព្យាបាលមុននឹងអនុញ្ញាតឱ្យបន្តដំណើរ។ ប៉ុន្តែលើកនេះ ពលករត្រឡប់មកពីថៃទាំងអស់ត្រូវតែធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ។

លោក ស ខេង មានប្រសាសន៍ដូច្នេះថា៖ «ប៉ុន្តែឥឡូវនេះបញ្ហាគឺដំបូងយើងខិតខំធ្វើម៉េច...ខិតខំយ៉ាងម៉េចធ្វើចត្តាឡីស័កនៅព្រំដែននេះ។ បើធ្វើបានអាហ្នឹងគឺល្អបំផុតដោយសារកុំឱ្យអ្នកជំងឺនាំចូល ឧបមាថាវាឆ្លងតាមពលករយើងនេះនៅព្រៃវែង ស្វាយរៀង កំពង់ចាម តាកែវអីអ៊ីចឹង។ បើយើងទប់នៅកន្លែងនេះ វានៅតែមួយកង្វល់ហ្នឹងទេ ឬនៅបាត់ដំបង ឬបន្ទាយមានជ័យ»។ លោកបន្តថា៖ «ប៉ុន្តែក្នុងករណីដែលខេត្តមានមក ១០ ម៉ឺន, ២០ ម៉ឺន ដោយសារផ្ទុះនៅទីនោះ គាត់ខ្លាច គាត់រត់មក អាហ្នឹងយើងបានត្រៀមហើយ។ សម្តេចនាយកលោកបានបញ្ជាហើយមានឡានសម្រាប់ដឹក មិនឱ្យគាត់ជិះតាក់ស៊ីជិះអីវាយប៉ាយទៅនាំឱ្យឆ្លងប៉ះអ្នកដទៃទេ»។

លោក ហ៊ុន សែន កាលពីសៀលថ្ងៃអាទិត្យបានឱ្យអាជ្ញាធរខេត្តតាមព្រំដែនបង្រួមការឆ្លងកាត់ព្រំដែនអន្តរជាតិជាមួយប្រទេសថៃមកនៅត្រឹម ៣ ប៉ុណ្ណោះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងដំណើរវិលត្រឡប់ចូលមកកម្ពុជានៃពលករកម្ពុជាពីប្រទេសថៃ។ លោកបានបញ្ជាឱ្យធ្វើចត្តាឡីស័កដល់អ្នកដំណើរទាំងអស់ និងបានបន្ថែមថវិកាសម្រាប់ការធ្វើកិច្ចការនេះ។

យោងតាមកាសែតបាងកកប៉ុស្ដិ៍គិតត្រឹមសៀលថ្ងៃទី ២១ ខែធ្នូ មានការឆ្លងជំងឺកូវីដ ១៩ ជាង ៨០០ ករណី នៅផ្សារលក់ដុំបង្គានៅក្នុងខេត្តសាមុតសាខន នៃប្រទេសថៃ។

លោក កែវ វណ្ណថន អ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានឱ្យដឹងកាលពីសៀលថ្ងៃចន្ទថា សភាពការណ៍ពលករខ្មែរចូលតាមច្រកទ្វារអន្តរជាតិ មិនមានអ្វីគួរឱ្យកត់សម្គាល់ទេ កាលពីម្សិលមិញគឺមានសភាពដូចធម្មតា។ ទោះយ៉ាងណាអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក៏បានធ្វើការណែនាំដល់នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិទាំងអស់ ជាពិសេសច្រកទ្វារនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃឱ្យមានការប្រុងប្រយ័ត្ន។ អគ្គនាយកដ្ឋាននេះបានណែនាំឱ្យប៉ុស្តិ៍នគរបាលច្រកទ្វារ-ព្រំដែន រួមសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីក្រសួងសុខាភិបាលដើម្បីធ្វើការ

ត្រួតពិនិត្យដំណើរចូលរបស់ភ្ញៀវបរទេស និងពលរដ្ឋខ្មែរដែលចូលមកពីប្រទេសថៃឱ្យបានហ្មត់ចត់ដោយតម្រូវឱ្យពួកគាត់ធ្វើចត្តាឡីស័កត្រឹមត្រូវតាមការកំណត់។ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ថ្លែងថា៖ «ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្រូវយកចិត្តទុកដាក់គ្រប់គ្រង និងល្បាតត្រួតពិនិត្យស្លាបឆ្វេងស្លាបស្តាំក្នុងដែនសមត្ថកិច្ចច្រកទ្វារឱ្យបានច្បាស់លាស់ និងត្រូវឃាត់អ្នកដំណើរចូល ជាពិសេសប្រជាពលរដ្ឋខ្មែរដែលចូលពីប្រទេសថៃដើម្បីយកមកប្រគល់ឱ្យមន្ត្រីភ្នាក់ងារសុខាភិបាលធ្វើការត្រួតពិនិត្យសុខភាព ធ្វើចត្តាឡីស័ក ឱ្យបានហ្មត់ចត់»។ អគ្គនាយកដ្ឋានក៏បានប្រាប់ឱ្យមន្ត្រីអន្តោប្រវេសន៍យកចិត្តទុកដាក់វិធានការអនាម័យ និងប្រុងប្រយ័ត្នការឆ្លងជំងឺនេះពីអ្នកដំណើរ។

ស្របពេលជាមួយគ្នានេះ មន្ត្រីរបស់អង្គការទេសន្តរប្រវេសន៍ (IOM) ក៏មានវត្តមាននៅតាមច្រកព្រំដែនផងដែរ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការជួយសម្រួលពលករនៅពេលឆ្លងកាត់ព្រំដែនពីប្រទេសថៃចូលមកកម្ពុជា ពេលស្នាក់នៅកន្លែងធ្វើចត្តាឡីស័ក និងនៅពេលពួកគេវិលត្រឡប់ទៅផ្ទះសំបែង។ នេះបើតាមលោកស្រី Kristin Parco ប្រធាន IOM ដែលបានថ្លែងតាមអ៊ីមែលកាលពីថ្ងៃចន្ទ។ លោកស្រីសរសេរថា៖ «យើងកំពុងតែពិភាក្សាជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងមន្ទីរសុខាភិបាលនៅក្នុងខេត្តដែលរងការប៉ះពាល់ដើម្បីវាយតម្លៃពីតម្រូវការសមរម្យបំផុតដូចជាជំនួយស្បៀងអាហារសម្រាប់ពលករដែលត្រូវធ្វើចត្តាឡីស័ក ការចែកសម្ភារអនាម័យសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនដល់ពលករដែលត្រូវធ្វើចត្តាឡីស័ក និងសម្ភារការពារខ្លួនសម្រាប់បុគ្គលិកពេទ្យជួរមុខ និងផ្សព្វផ្សាយព័ត៌មានអំពីការការពារកូវីដ១៩ នៅសហគមន៍តាមព្រំដែន»។ លោកស្រី គ្រិស្ទីន ក៏បានថ្លែង ទៅកាន់ពលករទាំងអស់យ៉ាងដូច្នេះថា៖ «ឆ្នាំនេះគឺជាឆ្នាំដែលមានបញ្ហាប្រឈមធ្ងន់ធ្ងរសម្រាប់យើងទាំងអស់គ្នា ប៉ុន្តែអ្នកទាំងអស់គ្នាមិនត្រូវបានបោះបង់ចោលទេ។ យើងពិតជាទទួលស្គាល់ការចូលរួម និងការងារដ៏ក្លាហានរបស់អ្នកទាំងអស់គ្នាក្នុងពេលមានកូវីដ ១៩ នេះ។ យើងសូមអរគុណ។ សូមអ្នកទាំងអស់គ្នាប្រកាន់ខ្ជាប់វិធានការការពារខ្លួន និងក្រុមគ្រួសារដោយធ្វើតាមការណែនាំរបស់ក្រសួងសុខាភិបាល»៕

## របាយការណ៍៖ ពលករខ្មែរមកពីបរទេសជិត៦០ភាគរយ នៃ១ពាន់នាក់ គ្មានប្រភពចំណូល

https://thmeythmey.com/ 22, Dec 2020 , 5:18 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ អង្គការទេសសន្តរប្រវេសន៍អន្តរជាតិប្រចាំកម្ពុជា(IOM) និងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA)ថា ពលករខ្មែរដែលត្រឡប់ពីបរទេសវិញ បន្ទាប់ពីផ្ទុះកូវីដ-១៩ មាន៦០ភាគរយក្នុងចំណោមជាង១ពាន់នាក់ បានបាត់ប្រភពចំណូល។ IOM និង UNFPA បានចេញផ្សាយរបាយការណ៍វាយតម្លៃមួយពីប៉ះពាល់ដល់ផ្នែកសង្គមនិងសុខភាពដោយសារកូវីដ-១៩ ស្តីពីការវិលត្រឡប់មកវិញរបស់ពលករកម្ពុជា តាមការស្ទង់មតិពលរដ្ឋ ១១០៨នាក់ ក្នុងខេត្តបាត់ដំបង់ បន្ទាយមានជ័យ សៀមរាប និងព្រៃវែង។ របាយការណ៍ចេញថ្ងៃទី១៨ ធ្នូបានបង្ហាញថា គ្រួសារពលករជិត៣០ភាគរយបានបាត់ប្រភពចំណូល ហើយជិត៦០ភាគរយនៃពលករទាំងនោះ គឺគ្មានប្រភពចំណូល។ ក្នុងនោះដែរ ពលករច្រើនជាង៥០ភាគរយមានជាប់បំណុល។ ចំណែកពលករ ត្រឹមតែ២៥ភាគរយប៉ុណ្ណោះ ដែលមានបណ្ណសមធម៌។

លោកស្រី Kristin Parco ប្រធាន IOM ប្រចាំកម្ពុជាបញ្ជាក់ក្នុងរបាយការណ៍ថា ការរាតត្បាតជំងឺកូវីដ១៩ បានបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំង ដែលមិនធ្លាប់មានទៅលើការចំណាកស្រុក និងការផ្លាស់ប្តូរទីតាំងរបស់មនុស្ស។ លោកស្រីសង្កត់ធ្ងន់ថា អ្នកចំណាកស្រុកជាច្រើនប្រឈមមុខនឹងការបាត់បង់ការងារ និងប្រាក់ចំណូល រួមទាំងងាយរងគ្រោះលើសុខភាព និងមានហានិភ័យផ្នែកគាំពារ ការទុកចោល និងការរើសអើង។ «...យើងទាំងអស់គ្នាត្រូវតែគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល អ្នកសិក្សា និងសង្គមស៊ីវិល ដើម្បីធ្វើឱ្យសេដ្ឋកិច្ចដែលរងការប៉ះពាល់ពីកូវីដរស់ឡើងវិញ ហើយស្វែងរកវិធីដែលមានភាពច្នៃប្រឌិត ដើម្បីកាត់បន្ថយការរឹតត្បិតការធ្វើដំណើរ និងសម្របសម្រួលដល់ចលនាទំនិញ សេវាកម្ម និងប្រជាជន»។ នេះបើតាមការលើកឡើងបន្ថែមរបស់លោក Kristtin Parco។

ចំណែកលោក Daniel Alemu តំណាង UNFPA ប្រចាំកម្ពុជាអះអាងតាមរយៈរបាយការណ៍នេះដែរថា ការវាយតម្លៃនៃរបាយការណ៍នេះ មានសារៈសំខាន់ណាស់សម្រាប់អ្នកបង្កើតគោលនយោបាយ ដោយផ្តោតលើផ្នែកសុខភាព និងតម្រូវការរបស់ពលករ ជាពិសេសជនងាយរងគ្រោះ ស្ត្រីមានផ្ទៃពោះ ក្មេង និង យុវជន។ ការធ្វើបែបនេះ គឺដើម្បីធានាបានថាពួកគេនិងគ្រួសារទទួលបានការគាំពារ។ លោក សង្កត់ធ្ងន់ថា «របាយការណ៍នេះជាសញ្ញាបន្ទាន់មួយសម្រាប់ការចាត់វិធានការ ហើយក៏ជាការផ្តល់អនុសាសន៍ដែលយើងគួរតែធ្វើតាម»។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រសួងមហាផ្ទៃ បានលើកឡើងក្នុងរបាយការណ៍ដដែលនេះថា ការរកឃើញ និងវាយតម្លៃខាងលើនេះ នឹងអាចឲ្យអ្នកពាក់ព័ន្ធចូលរួមឆ្លើយតបនឹងបញ្ហាប្រឈម ឲ្យកាន់តែប្រសើរជាងមុន។ លោកស្រី ប៊ុនអេង បានថ្លែងដូច្នេះថា៖ «យើងសង្ឃឹមថា ការរកឃើញនិងអនុសាសន៍ដែលចេញពីការវាយតម្លៃនេះ នឹងជួយ ដល់អ្នកពាក់ព័ន្ធឱ្យឆ្លើយតបទៅនឹងបញ្ហាប្រឈម ក្នុងការស្តារឡើងវិញឱ្យកាន់តែប្រសើរតាមរយៈការបង្កើតផែនការរយៈពេលខ្លី មធ្យម និងរយៈពេលវែងដើម្បីគាំពារដល់អ្នកចំណាកស្រុក ក្រុមគ្រួសារ និងកូនៗរបស់ពួកគេ»។ គិតចាប់ពីខែមីនា ដែលប្រទេសថៃប្រកាសបិទច្រកព្រំដែន ដោយការរីករាលដាលនៃកូវីដ-១៩ មានពលករកម្ពុជាប្រមាណ១២ម៉ឺននាក់បានត្រឡប់កម្ពុជាវិញ៕

## ពលករមកពីថៃជាង៣០នាក់ ត្រូវបានតេស្តរកកូវីដ-១៩ នៅខេត្តឧត្តរមានជ័យ

http://btv.com.kh/ 22/12/2020

ឧត្តរមានជ័យ ៖ អាជ្ញាធរខេត្តឧត្តរមានជ័យ នៅព្រឹកថ្ងៃទី២២ ខែធ្នូ នេះ បានរៀបចំទីតាំងចំនួនបីកន្លែងក្នុងខេត្ត រួមមានវិទ្យាល័យតេជោសែនសំរោង វិទ្យាល័យហ៊ុនសែនឧត្តរមានជ័យ ផ្ទះសំណាក់ឧត្តមរដ្ឋា សំរាប់ឲ្យពលករខ្មែរដែលឆ្លងដែនមកពីប្រទេសថៃតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ស្នាក់នៅ ជាបណ្តោះអាសន្នដើម្បីធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ចៀសវាងការឆ្លងរាលដាលមកក្នុងសហគមន៍។ លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានគូសបញ្ជាក់ថា ចំពោះពលករដែលវិលមកពីខេត្តសាមុតសាខនប្រទេសថៃ ជាតំបន់ដែលប្រឈមទៅនឹងផ្ទុះជំងឺកូវីដ–១៩ ក្នុងសហគមន៍ រយៈពេលប៉ុន្មានថ្ងៃនោះ មានពលករខ្មែរដែលមកខេត្តនោះចំនួន ៣៥នាក់ បានយកសំណាកធ្វើតេស្តរកវីរុសកូវីដ–១៩ផងដែរ។ យ៉ាងណាមិញ រាល់ការរៀបចំទីតាំងស្នាក់នៅខាងលើ មន្ត្រីជំនាញសុខាភិបាលបានផ្តល់នៅសម្ភារៈ កន្ទេល មុង ភួយ ក្រម៉ា នឹងអាហារសំរាប់ពលរដ្ឋគ្រប់រូបក្នុងអំឡុងពេលធ្វើចត្តាឡីស័ក រយៈពេល១៤ថ្ងៃនេះផងដែរ ៕ អត្ថបទ ៖ ឃិនសារិទ្ធ

## មណ្ឌលធ្វើចត្តាឡីស័ក៦កន្លែង ក្នុងខេត្តឧត្តរមានជ័យពេញ មិនអាចទទួលពលករបានទៀតទេ, ស្អែកនេះ ពលករដែលមកពីថៃតាមច្រកអន្តរជាតិអូរស្មាច់ នឹងត្រូវដឹកជញ្ជូនទៅធ្វើចត្តាឡីស័កនៅខេត្តសាមីរបស់ខ្លួន

https://www.khmer-press.com/news/ Khmer pressDecember 22, 2020 at 4:33 pm

(ឧត្តរមានជ័យ)៖ រយៈពេល ២ថ្ងៃ ពោលគឺចាប់ពីថ្ងៃទី២១-២២ ខែធ្នូ ឆ្នាំ២០២០នេះ ពលករខ្មែរសរុប ៣០០នាក់ បានចាកចេញពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ ក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងបានដឹកជញ្ជូនតាមរថយន្តយកទៅធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃនៅក្នុងក្រុងសំរោង។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានថ្លែងប្រាប់ឲ្យដឹងនៅព្រឹកថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០នេះថា ចាប់តាំងពីថ្ងៃទី២១-២២ ខែធ្នូ ឆ្នាំ២០២០ ពលករខ្មែរសរុប ៣០០នាក់ បានធ្វើដំណើរចាកចេញពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ ត្រូវបានដឹកជញ្ជូនតាមរថយន្តយកទៅធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃនៅក្នុងក្រុងសំរោង ដោយឡែកពលករចំនួន៧១នាក់ ដែលមកពីតំបន់ប្រឈម នានានិងមេរោគកូវីដ១៩ ក្នុងប្រទេសថៃ ត្រូវបានបញ្ជូនទៅយកសំណាករកមេរោគកូវីដ១៩។ លោកប្រធានមន្ទីរ បានថ្លែងបញ្ជាក់ថា

នៅថ្ងៃម្សិលមិញពលករខ្មែរចំនួន១៧៦នាក់ បានចាកចេញពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងបានដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅក្រុងសំរោង ក្នុងនោះបានយកសំណាកចំនួន៣៥នាក់ ទៅពិនិត្យរកមេរោគកូវីដ១៩។ ចំណែកនៅព្រឹកថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ពលករចំនួន១២៤នាក់ បានចាកចេញពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ នឹងត្រូវដឹកតាមរថយន្តកងទ័ព យកទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃនៅក្រុងសំរោង ក្នុងនោះពលករចំនួន៣៦នាក់ បានបញ្ជូនទៅយកសំណាករកមេរោគកូវីដ១៩ផងដែរ។ លោក ឃ្លោក ហួត បានថ្លែងទៀតថា នៅទូទាំងខេត្តឧត្តរមានជ័យ មានមណ្ឌលចត្តាឡីស័កសរុបចំនួន៦កន្លែង ដែលចំនួនមណ្ឌលចត្តាឡីស័កនេះមិនមានតុល្យភាពនិងចំនួនពលករដែលមកប្រចាំថ្ងៃក្នុងមួយថ្ងៃជាង១០០នាក់នោះទេ ហើយនៅថ្ងៃនេះដែរមណ្ឌលចត្តាឡីស័កទាំងអស់នៅក្នុងខេត្តគឺពេញមិនអាចឲ្យពលករធ្វើចត្តាឡីស័កនៅថ្ងៃស្អែកទៀតបានទេ។

ដោយឡែកលោក ឃិន ញ៉ាណ អភិបាលខេត្តស្តីទីខេត្តឧត្តរមានជ័យ បានថ្លែងនៅរសៀលថ្ងៃនេះថា បើសិនមណ្ឌលចត្តាឡីស័កទាំងអស់នៅក្នុងខេត្តឧត្តរមានជ័យពេញ មិនអាចដាក់ពលករឲ្យធ្វើចត្តាឡីស័កនៅថ្ងៃស្អែកទៀតបានទេជាគោលការណ៍យើងត្រូវដឹកជញ្ជូនពលករទាំងនោះទៅធ្វើចត្តាឡីស័កបន្តនៅខេត្តសាមីរបស់គេ ជាមួយនិងការជូនដំណឹងឲ្យអាជ្ញាធរខេត្តសាមីទាំងនោះបានដឹងជាមុនដើម្បីគេរង់ចាំទទួលយកទៅធ្វើចត្តាឡីស័កបន្ត។

គួរបញ្ជាក់ថា ក្រោមបទបញ្ជារបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា កាលពីយប់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ រថយន្តរបស់កងទ័ពចំនួន ១៥គ្រឿង ក្នុងចំណោមរថយន្តចំនួន៧០គ្រឿង បានមកអន្តរាគមន៍ដឹកពលករ នៅច្រកព្រំដែនអន្តរជាតិអូរស្មាច់។ ជាមួយនឹងការបទបញ្ជានេះ សម្តេចតេជោក៏បានផ្តល់នូវម៉ាសចំនួន៤០ម៉ឺនម៉ាស់ និងឃីត២០០០ដល់អាជ្ញាធរខេត្តឧត្តរមានជ័យ សម្រាប់ធ្វើការចែកជូនពលករផងដែរ៕

## ពលករជិត៤០០នាក់ត្រឡប់មកពីថៃ កំពុងធ្វើចត្តាឡីស័ក ដើម្បីបង្ការកូវីដ-១៩

https://thmeythmey.com/ 22, Dec 2020 , 2:38 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ រយៈពេលពីរថ្ងៃនេះ មានពលករជិត៤០០នាក់បានត្រឡប់មកពីថៃ ហើយកំពុងធ្វើចត្តាឡីស័កនៅតាមទីតាំងដែលអាជ្ញាធររៀបចំយ៉ាងហ្មត់ចត់ ដើម្បីបង្ការកូវីដ-១៩។ វិធានការរឹតបន្តឹងនេះ ធ្វើឡើងក្រោយពីមានការផ្ទុះនូវការចម្លងកូវីដ-១៩ នៅខេត្តសាមុតសាខនប្រទេសថៃ កាលពីចុងសប្តាហ៍មុន។

អ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍លោក កែវ វណ្ណថន បានបញ្ជាក់ថា ពលករខ្មែរត្រឡប់ពីថៃវិញមាន៣៨៦នាក់ ក្នុងនោះភាគច្រើន មកតាមច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ចាប់ពីថ្ងៃទី២០ដល់២១ ធ្នូ។ បើតាមលោក វណ្ណថន ពលករទាំងនោះ បានត្រឡប់មកតាមច្រកអូរស្មាច់២៨៦នាក់ ប៉ោយប៉ែត៧៤នាក់ ច្រកដូងនិងភ្នំដី២៦នាក់។ លោក វណ្ណថន បានបញ្ជាក់ថា ក្រោយផ្ទុះកូវីដ-១៩នៅថៃ អគ្គនាយកដ្ឋានលោក បានណែនាំឲ្យមន្ត្រីនគរបាលតាមច្រកទ្វារព្រំដែនអន្តរជាតិទាំងអស់ ពិសេសច្រកតាមបណ្តាលព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យសុខភាពអ្នកធ្វើដំណើរចូលកម្ពុជា ។ ជាពិសេសតាមដានការធ្វើចត្តាឡីស័ករបស់ពួកគេឲ្យបានត្រឹមត្រូវតាមពេលកំណត់របស់ក្រសួងសុខាភិបាល។ «...មន្ត្រីនគរបាលតាមច្រកព្រំដែន ពិសេសតាមច្រកតូចៗ ត្រូវល្បាតស្លាបធ្វេង ស្លាបស្តាំ ក្នុងដែនសមត្ថកិច្ចច្រករបស់ខ្លួន យើងក៏ចេញវិធានការឲ្យពួកគាត់ឃាត់អ្នកចូលមកពីថៃ ដើម្បីប្រគល់ឲ្យភ្នាក់ងារសុខាភិបាលពិនិត្យសុខភាពនិងធ្វើចត្តាឡីស័កឲ្យហ្មត់ចត់។ លើសពីនេះ ក៏បានរំលឹកដល់មន្ត្រីរក្សាគម្លាតសុវត្ថិភាព និងរក្សាអនាម័យផងដែរ»។ នេះបើតាមការលើកឡើងរបស់លោក វណ្ណថន។

លោក ឌី រ៉ាដូ អភិបាលរងខេត្តឧត្តមានជ័យ អះអាងប្រាប់សារព័ត៌មានថ្មីៗថា លោកបានត្រៀមទីតាំង៣កន្លែង ដើម្បីដាក់អ្នកចត្តាឡីស័ក ក្នុងនោះមានវិទ្យាល័យសំរោង វិទ្យាល័យហ៊ុនសែន ឧត្តមានជ័យ និងផ្ទះសំណាក់ឧត្តមរង្សី។

ចំណែក លោក ឈឿន ក្រៃយ៉ុង នាយករដ្ឋបាលខេត្តបន្ទាយមានជ័យ ក៏បានបញ្ជាក់ថា ក្រៅពីទីតាំងក្នុងខេត្ត ក៏ត្រៀមបម្រុងទុកទីតាំងនៅគ្រប់ស្រុក សម្រាប់ដាក់ពលករខ្មែរ ដែលត្រឡប់មកពីថៃវិញដែរ។

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី បានផ្តល់ថវិកាសរុប៣៥០លានរៀល ដល់ខេត្តជាប់ប្រទេសថៃ ចំនួន៧ ដើម្បីចាត់ចែងការងារចំពោះមុខរួមមាន ការរើតបន្តឹងការធ្វើចត្តាឡីស័កជាដើម ក្នុងន័យទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ពីប្រទេសថៃ។ខេត្តទាំង៧រួមមាន ខេត្តព្រះវិហារ ឧត្តរមានជ័យ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ពោធិ៍សាត់ និងខេត្តកោះកុង ដោយខេត្តនីមួយៗទទួលបាន ៥០លានរៀល។

សូមជម្រាបថា ខេត្តសាមុតសាខនកាលពីថ្ងៃទី១៩ធ្នូ បានរកឃើញអ្នកឆ្លងកូវីដ-១៩ជាង៥០០ករណី។ បន្ទាប់មករដ្ឋាភិបាលថៃសម្រេចប្រកាសបិទខេត្តសាមុតសាខន រយៈពេល២សប្តាហ៍ ចាប់ពីថ្ងៃទី២០ធ្នូ ដល់ថ្ងៃទី៣ មករាឆ្នាំ២០២១។ បន្ថែមពីនេះ បានដាក់បំរាមគោចរ អនុវត្តពីម៉ោង១០យប់ ដល់ម៉ោង៥ភ្លឺ។ ចំណែកការធ្វើដំណើរចេញពីខេត្តនេះ ក៏ត្រូវបានហាមឃាត់ដែរ៕

## ពលករខ្មែរកើនដល់ជាង១០០នាក់ ចូលធ្វើចត្តាឡីស័ក ក្រោយវិលមកពីប្រទេសថៃ

https://www.rasmeinews.com/ 22 December, 2020

**ដោយ: ភ្នំខៀវ / បាត់ដំបង:** ពលករខ្មែរកើនដល់ឡើងជាង១០០នាក់ តម្រូវឲ្យធ្វើចត្តាឡីស័ក ១៤ថ្ងៃ ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩។ មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបាត់ដំបងបានបញ្ជាក់ឲ្យដឹងនៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២០នេះថា÷ រយៈពេល ២ថ្ងៃកន្លងមកនេះមន្ត្រីមណ្ឌលចត្តាឡីស័កប្រចាំស្រុកកំរៀងបានពិនិត្យ និងទទួលពលករខ្មែរប្រុស ស្រីកើនដល់ ចំនួន ១០៤នាក់ ដោយក្នុងនោះនៅថ្ងៃទី ២១ ក្រុមការងារបានរៀបចំពលករខ្មែរធ្វើចត្តាឡីស័កចំនួន ៣៣នាក់ ស្រីចំនួន ១៣នាក់ និងនៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០២០ នេះពលករដែលទទួលឲ្យចូលអនុវត្តន៍ធ្វើចត្តាឡីស័កមានចំនួន ៧១នាក់ ស្រីចំនួន ៣៥នាក់។

ប្រភពខាងលើបន្ថែមថា គិតត្រឹមម៉ោង ៥:០០នាទីល្ងាច ថ្ងៃទី២២ ខែធ្នូនេះ មន្ត្រីសុខាភិបាលបានយកវត្ថុសំណាក ដើម្បីពិនិត្យលទ្ធផលបានចំនួន ៧៦នាក់ ក្រៅពីនេះនិងបន្តយកនៅពេលបន្តបន្ទាប់ទៀត។ ក្រោមការតម្រូវឲ្យធ្វើចត្តាឡីស័ក តាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល ដែលឆ្លងកាត់តាមច្រកអន្តរជាតិដូងក្នុងស្រុកកំរៀងរយៈពេល ២ថ្ងៃ ពលករមានមកពីបណ្តាខេត្ត បាត់ដំបង បន្ទាយមានជ័យ ខេត្តសៀមរាប ព្រៃវែង ត្បូងឃ្មុំ កំពង់ធំ ខេត្តព្រះវិហារ កំពុងស្ពឺ ស្ទឹងត្រែង និងខេត្តស្វាយរៀងជាដើម។ ទីតាំងដែលមានលក្ខណៈអំណោយ ក្នុងការអនុវត្តរៀបចំធ្វើចត្តាឡីស័កពលករខ្មែរ ដែលវិលត្រឡប់មកប្រទេសថៃ ដោយសារផ្ទុះនូវជំងឺកូវីត-១៩ ទីតាំងទី១ ក្នុងស្រុកកំរៀង មាននៅបរិវេណវិទ្យាល័យកំរៀង មានចំនួន៤២បន្ទប់, ទីតាំងទី២ ឋិតនៅក្នុងមណ្ឌលសុខភាពត្រាងមានច្រើនបន្ទប់ និងទីតាំងទី៣ មាននៅក្នុងបរិវេណសាលាបឋមសិក្សាជ្រៃសីមា ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន ១០បន្ទប់៕

## ប្រជាពលរដ្ឋដែលវិលចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ១២១នាក់

https://www.cen.com.kh/ December 23, 2020

ឧត្តរមានជ័យ៖ ពលរដ្ឋខ្មែរ នៅតែបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២១នាក់ ស្រី ៥៣នាក់។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថ

កិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ **រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ**

## ថៃបន្តចាប់បញ្ជូនពលករខ្មែរជាច្រើននាក់ទៅកម្ពុជា បន្ទាប់ពីផ្ទុះជំងឺកូវីដចូលក្នុងសហគមន៍

https://www.rfa.org/ ដោយ មួង ណារ៉េត 2020-12-22

អាជ្ញាធរថៃចាប់បញ្ជូនពលករខ្មែរជាច្រើននាក់ ត្រឡប់ទៅស្រុកកំណើតវិញតាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យ ជាបន្តបន្ទាប់ អំឡុងពេលមានការរាតត្បាតជំងឺកូវីដ១៩ ចូលក្នុងសហគមន៍នៅប្រទេសថៃ។ មន្ត្រីអង្គការសង្គមស៊ីវិល យល់ថា រឿងនេះប្រឈមនឹងការឆ្លងជំងឺកូវីដ១៩ចូលមកកម្ពុជា ប្រសិនបើអាជ្ញាធរមិនបានធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកផ្នែកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី២២ ធ្នូថា ចាប់តាំងពីផ្ទុះជំងឺកូវីដ១៩ នៅខេត្តសាមុតសាខន (Samut Sakhorn) ប្រទេសថៃមក អាជ្ញាធរថៃ នៅតែបន្តចាប់បញ្ជូនពលករខ្មែរជាច្រើននាក់ត្រឡប់មកកម្ពុជា។ លោកឱ្យដឹងថា កាលពីយប់ថ្ងៃទី២១ ធ្នូ អាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរចំនួន៨៤នាក់ប្រគល់ឱ្យអាជ្ញាធរកម្ពុជាតាមច្រករបៀងអូរបីជាន់ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ លោក អ៊ុំ សុផល បញ្ជាក់ថា អាជ្ញាធរកម្ពុជាបានដឹកពលករទាំងនោះទៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃទើបបញ្ជូនពួកគេត្រឡប់ទៅស្រុកកំណើតវិញ៖ «ខាងខ្ញុំនេះគ្រាន់តែជាអ្នកទទួលទេ ទទួលហើយបញ្ជូនទៅខាងសុខាភិបាល គាត់យកទៅ។ មកដល់គ្រាន់តែយើងទទួលគាត់មកយកទៅ បើមានពលករលួចចេញមកអីចឹងយើងស្ទាក់បាន យើងបញ្ជូនឱ្យគាត់ទៅ។ អត់មានលួចចេញបានទេ យើងឱ្យមានទេ ហ្នឹងវាចេញតែយប់ទេ ថ្ងៃអត់មានចេញទេ»។ មេប៉ូលិសផ្គាយមួយរូបនេះបន្តថា អាជ្ញាធរខេត្តបន្ទាយមានជ័យ បានដាក់កងកម្លាំងប្រចាំការនៅតំបន់ព្រំដែនថៃ ដើម្បីទប់ស្កាត់មិនឱ្យពលករណាម្នាក់ឆ្លងដែនចូលមកកម្ពុជា ដោយមិនបានធ្វើចត្តាឡីស័កនោះឡើយ។ លោក អ៊ុំ សុផល និយាយថា រហូតមកទល់ពេលនេះមិនមានពលករខ្មែរវិលត្រឡប់មកកម្ពុជាវិញ អំឡុងពេលការរាតត្បាតជំងឺកូវីដ១៩ចូលក្នុងសហគមន៍នៅខេត្តសាមុតសាខន នៅឡើយទេ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc)ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា យល់ថា ការចាប់បញ្ជូនពលករខ្មែរត្រឡប់មកកម្ពុជា អំឡុងពេលនេះប្រឈមនឹងការឆ្លងជំងឺកូវីដ១៩ចូលមកកម្ពុជា។ លោកថា អាជ្ញាធរខ្មែរគួរតែស្នើទៅអាជ្ញាធរថៃឱ្យធ្វើចត្តាឡីស័ក ១៤ថ្ងៃលើពលករទាំងនោះជាមុន ហើយប្រសិនបើមិនមានជំងឺលោកផ្លូវដង្ហើមថ្មីទេ ចាំបញ្ជូនពួកគេមកកម្ពុជាជាការល្អ ដោយពុំមែនចេះតែបញ្ជូនពលករពីប្រទេសថៃតាមអំពើចិត្តបែបនេះឡើយ៖ «បើសិនជាថៃចេះតែចាប់បញ្ជូនថា តើថៃបានគិតអំពីសុខុមាលភាពសហគមន៍ សុខុមាលភាពប្រជាពលរដ្ឋអាស៊ានរស់នៅក្បែរគ្នាទេ។ អាហ្នឹងត្រូវយកចិត្តទុកដាក់អីចឹង មិនមែនត្រឹមតែខ្មែរមកដល់ធ្វើចត្តាឡីស័កទេ» គួរតែថៃហ្នឹងធ្វើចត្តាឡីស័កដែរឱ្យបានច្បាស់លាស់បញ្ជាក់ថា មនុស្សហ្នឹងអត់មានមេរោគ ហើយមកដល់ខ្មែរយើងពិនិត្យថែមទៀត ថាតើវាមានអត់។ ព្រោះដោយសារការឆ្លងចូលក្នុងសហគមន៍ បើឆ្លងចូលសហគមន៍យើងត្រូវតែគិតទាំងអស់គ្នា ព្រោះថា មេរោគហ្នឹងបើវាកើតខ្មែរក៏វាឆ្លងដល់ថៃបើកើតថៃឆ្លងដល់ខ្មែរ អីចឹងការរាតត្បាតនៅក្នុងអាស៊ានបញ្ហាពិភពលោក។

អាស៊ីសេរីមិនអាចទាក់ទងអភិបាលខេត្តបន្ទាយមានជ័យ លោក អ៊ុំ រាត្រី ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី២២ ធ្នូ ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។ ចំណែកអ្នកនាំពាក្យក្រសួងសុខាភិបាលលោកស្រី ឱ វណ្ណឌីន ក៏មិនអាចទាក់ទងបានដែរ នៅថ្ងៃទី២២ ធ្នូ។

អភិបាលខេត្តបន្ទាយមានជ័យ លោក អ៊ុំ រាត្រី បានចុះផ្សាយនៅក្នុងហ្វេសប៊ុករបស់លោកកាលពីព្រឹកថ្ងៃទី២១ ខែធ្នូ ថា នៅតំបន់ព្រំដែនខេត្តនេះបានជ្រើសយកវិទ្យាល័យនិមិត្ត ក្រុងប៉ោយប៉ែត និង វិទ្យាល័យកូប ស្រុកអូរ

ជ្រៅ ធ្វើចត្តាឡីស័កពលករខ្មែរត្រឡប់មកពីប្រទេសថៃ។ ចាប់តាំងពីថ្ងៃទី២០ ធ្នូ មក អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរជិត ២០០នាក់ហើយត្រឡប់មកកម្ពុជាវិញតាមច្រកព្រំដែនខេត្តបន្ទាយមានជ័យ។

ចំណែកនៅខេត្តឧត្តរមានជ័យ ក៏មានពលករខ្មែរជាច្រើននាក់ត្រឡប់មកកម្ពុជាវិញអំឡុងពេលមានការរាតត្បាតជំងឺកូវីដ១៩នៅក្នុងប្រទេសថៃដែរ។ គេហទំព័រអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃចុះផ្សាយនៅរសៀលថ្ងៃទី២២ ធ្នូ ថា មានពលករខ្មែរជាង ១២០នាក់ (១២១)បានត្រឡប់មកពីប្រទេសថៃចូលមកកម្ពុជាតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់។ ពលករទាំងនោះត្រូវបានអាជ្ញាធរខេត្តឧត្តរមានជ័យ ដឹកតាមរថយន្តយោធាយកទៅធ្វើចត្តាឡីស័កនៅតំបន់ព្រំដែនមុននឹងបញ្ជូនពួកគេត្រឡប់ទៅស្រុកកំណើតវិញ៕

## ទិន្នន័យបងប្អូនប្រជាពលរដ្ឋខ្មែរដែលមកពីប្រទេសថៃ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ចាប់ពីម៉ោង៧:០០ព្រឹក ដល់ម៉ោង ៥ល្ងាច

http://nokorwatnews.com/ 23-12-2020

ភ្នំពេញ៖ សូមបញ្ជាក់ជូនថា ខាងក្រោមនេះគឺជា ទិន្នន័យបងប្អូនប្រជាពលរដ្ឋខ្មែរដែលមកពីប្រទេសថៃ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ចាប់ពីម៉ោង៧:០០ព្រឹក ដល់ម៉ោង ៥ល្ងាច។ តាមរបាយការណ៍បានបញ្ជាក់ថា៖

**ក្រុមការងារចម្រុះដាក់ចត្តាឡីស័ករួមមាន៖**

១-ខេត្តបន្ទាយមានជ័យ(ចំនួន១៣៤ស្រី៦៥កុមារ១៥ស្រី៩)
២-ខេត្តបាត់ដំបង(ចំនួន៤៤ស្រី១៧.កុមារ១ស្រី០)(ខ្មែរអ៊ិស្លាម២ស្រី០)
៣-ខេត្តកំពង់ធំ(ចំនួន២ស្រី០)
៤-ខេត្តព្រៃវែង(ចំនួន១ស្រី១)
៥-ខេត្តសៀមរាប(ចំនួន៣៩ស្រី១៦.កុមារ៥ស្រី២)
៦-ខេត្តត្បូងឃ្មុំ(ចំនួន៧ស្រី៤)
៧-ខេត្តឧត្តរមានជ័យ(ចំនួន៤ស្រី២)
៨-ខេត្តព្រះសីហនុ(ចំនួន៣ស្រី០)
៩-ខេត្តព្រះវិហារ(ចំនួន១ស្រី០)

**ក្រុមការងារចម្រុះបានបញ្ជូនមកដាក់ចត្តាឡីស័ករួមមាន៖**

(ទី១)-នៅវិទ្យាល័យកូប.ឃុំកូប-ស្រុកអូរជ្រៅ(ចំនួន៥៨ស្រី២៥.កុមារ៥ស្រី១).(ខ្មែរអ៊ិស្លាម២ស្រី
(ទី២)-នៅវិទ្យាល័យនិមិត្ត សង្កាត់និមិត្ត.ក្រុងប៉ោយប៉ែត.(ចំនួន៩២ស្រី៤៦.កុមារ១០ស្រី៧)
(ទី៣)-នៅមន្ទីរពេទ្យបង្អែកប៉ោយប៉ែត.សង្កាត់ប៉ោយប៉ែត.ក្រុងប៉ោយប៉ែត(ចំនួន៨៥ស្រី៣៤.កុមារ៦ស្រី៤)
(សរុប.រួម២៣៥ស្រី១០៥-កុមារ២១ស្រី១១).ក្នុងចំនួនរួម(ខ្មែរអ៊ិស្លាម២ស្រី០)។

សូមបងប្អូន ជនរួមជាតិចូលរួមអនុវត្តតាមការណែនាំ របស់ក្រសួងសុខាភិបាល លើវិធានការ ការពារជំងឺកូវីដ-១៩។ ជាពិសេស បងប្អូនកម្មករ កម្មការិនី ដែលបានធ្វើដំណើរពីប្រទេសថៃ ត្រឡប់មកកាន់កម្ពុជាវិញ ត្រូវតែធ្វើចត្តាឡីស័ក រយៈពេល ១៤ ថ្ងៃ ដើម្បីបញ្ចៀសការឆ្លងជំងឺដ៏កាចសាហាវមួយនេះ៕

## ពលករខ្មែរទាំងអស់ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ ហាមចេញ-ចូល តំបន់ដែលមានការរីករាលដាលជំងឺកូវីដ.១៩

https://www.cen.com.kh/ December 23, 2020

ភ្នំពេញ៖ បើតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ ហាមចល័តពលករបរទេស ជាពិសេសពលករខ្មែរ ចេញ-ចូល តំបន់ដែលមានការរីករាលដាលជំងឺកូវីដ.១៩។ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមជូនព័ត៌មានដល់បងប្អូន ពលករខ្មែរទាំងអស់ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃទាំងអស់មេត្តាជ្រាបថា ដើម្បីគ្រប់គ្រង និងការពារមិន ឱ្យមានការរីករាលដាលជំងឺកូវីដ-១៩ ទៅលើពលករបរទេសទាំងអស់ ដែលជាហេតុបង្កឱ្យមានផលប៉ះពាល់ដល់អាយុជីវិត និង សុខភាពអនាម័យរបស់ប្រជាពលរដ្ឋ ក្រសួងការងារថៃ បានចេញសេចក្តីប្រកាសស្នើសុំកិច្ចសហការពីនិយោជក រោងចក្រ សហគ្រាស និងក្រុមហ៊ុននានាគ្រប់ទីកន្លែងនៅក្នុងប្រទេសថៃ ត្រូវអនុវត្តដូចខាងក្រោម៖ ហាមចល័តពលករបរទេស ចេញ-ចូល តំបន់ដែលមានការរីករាលដាលជំងឺកូវីដ.១៩។

មានវិធានការការពារ និងត្រួតពិនិត្យ ដូចតទៅ វាស់កំដៅពលករបរទេស បើមានកំដៅលើស ឬមានអាការៈខុសប្រក្រតីផ្សេងៗ ដូចជា ក្អក ពិបាកដកដង្ហើម គួរឱ្យពលករនោះសម្រាកពីការងារ និងប្រញាប់រួសរាន់ជូនដំណឹងដល់ទីភ្នាក់ងារសុខាភិបាល ដើម្បីអនុវត្តវិធានការចត្តាឡីស័កភ្លាម។ រៀបចំអាល់កុលសម្រាប់លាងដៃ នៅតាមទីកន្លែងធ្វើការ ច្រកទ្វារចេញ-ចូល និងតាមបន្ទប់ទឹក។ តម្រូវឱ្យពលករបរទេសត្រូវពាក់ម៉ាស ពាក់ស្រោមដៃ និងរក្សាគម្លាតពី ១-២ម៉ែត្រ ក្នុងកំឡុងពេលបំពេញការងារ ព្រមទាំងថែរក្សា និងសម្អាតឧបករណ៍ដែលប្រើប្រាស់ជាប្រចាំ។ ផ្សព្វផ្សាយ និងពន្យល់ណែនាំពលករបរទេសឲ្យយល់ដឹងពីវិធីការពារខ្លួនពីជំងឺកូវីដ-១៩ ដោយខ្លួនឯង។

ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមបងប្អូនពលករខ្មែរនៅប្រទេសថៃទាំងអស់ មេត្តាបន្តចូលរួមសហការ និង អនុវត្តនូវវិធានការនានារបស់រាជរដ្ឋាភិបាលថៃឱ្យបានខ្ជាប់ខ្ជួន មានប្រសិទ្ធភាពខ្ពស់ និងសូមរក្សាសុខភាពអនាម័យ ដើម្បី បង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ បន្តទៀត។ ករណីបងប្អូនមានបញ្ហា សូមទំនាក់ទំនងមកកាន់ស្ថានទូត៕ **រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ**

## លោក លឹង សុផុន៖ អាជ្ញាធរថៃមិនទាន់បញ្ជាក់ទេថា មានពលករខ្មែរប៉ុន្មាននាក់ ក្នុងចំណោមពលករអន្តោប្រវេសន៍៩០% ដែលឆ្លងកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 22/12/2020 - 12:09 ដោយ៖ញឹម សុផល

មន្ត្រីអង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស(Central) ថ្លែងថាមានពលករអន្តោប្រវេសន៍ខ្មែរចំនួនជាង ២៥០ ០០០នាក់ បានកំពុងរស់នៅ និងធ្វើការនៅខេត្តសាមុតសាខន នៃប្រទេសថៃ។ ពលករខ្មែរក៏បានរស់ និងធ្វើការនៅម្តុំផ្សារលក់គ្រឿងសមុទ្រ ដែលមានការផ្ទុះរាលដាលជំងឺកូវីដ១៩ កាលពីប៉ុន្មានថ្ងៃកន្លងទៅនេះដែរ។ ទោះយ៉ាងណា អាជ្ញាធរថៃ នៅមិនទាន់ប្រកាសថាមានពលករខ្មែរ ឬពលករអន្តោប្រវេសន៍ដទៃទៀតប៉ុន្មាននាក់ទេ ដែលបានឆ្លងកូវីដ១៩ ក៏ប៉ុន្តែគ្រាន់តែបញ្ជាក់ថាអ្នកឆ្លងកូវីដ១៩ មកទល់ពេលនេះ ជាង១ពាន់នាក់ ក្នុងនោះ ៩០%ជាពលករអន្តោប្រវេសន៍។ នេះបើតាមលោក លឹង សុផុន មន្ត្រីកម្មវិធីពលករអន្តោប្រវេសន៍នៃអង្គការCentral ប្រចាំនៅប្រទេសថៃ។

# ពលករខ្មែរមួយចំនួនបន្តធ្វើការនៅថៃទាំងភ័យក្នុងតំបន់រាតត្បាតជំងឺកូវីដ១៩ ដោយមិនត្រឡប់មកវិញទេ

https://www.rfa.org/khmer/ ដោយ សុជីវ៉ី 2020-12-22

ពលករខ្មែរមួយចំនួនធ្វើការនៅខេត្តសាមុតសាខន (Samut Sakorn) ប្រទេសថៃ បន្តធ្វើការទាំងភិតភ័យ បន្ទាប់ពីជំងឺកូវីដ១៩ រាតត្បាតចូលក្នុងសហគមន៍នៅតំបន់ស្នាក់នៅ។ ជាមួយគ្នានេះអាជ្ញាធរថៃបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យតាមដងផ្លូវយ៉ាងតឹងតែង ដើម្បីទប់ស្កាត់ពលករបរទេសចេញចូលនៅតំបន់រាតត្បាតជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលយល់ថា អំឡុងពេលនេះពលករខ្មែរគួរតែប្រុងប្រយ័ត្នខ្លួនឱ្យបានខ្ពស់ ដើម្បីការពារកុំឱ្យឆ្លងជំងឺរលាកផ្លូវដង្ហើមថ្មីនេះ។

ពលករមានស្រុកកំណើតនៅខេត្តពោធិ៍សាត់ លោក សូ សុជី ឱ្យអាស៊ីសេរីដឹងនៅរសៀលថ្ងៃទី២១ ធ្នូ ថា លោកស្នាក់នៅចម្ងាយប្រហែល៣០០ម៉ែត្រ ពីកន្លែងផ្ទុះជំងឺកូវីដ១៩ នៅខេត្តសាមុតសាខន ហើយលោកថា ព្រួយបារម្ភខ្លាចឆ្លងជំងឺរលាកផ្លូវដង្ហើមថ្មីនេះ។ ពលករធ្វើការសំណង់រូបនេះ បន្ថែមថា លោកនិងពលករខ្មែរជាច្រើននាក់ទៀតនៅតែបន្តធ្វើការជារៀងរាល់ថ្ងៃដដែល ដោយមិនត្រឡប់ទៅកម្ពុជាអំឡុងពេលនេះឡើយ៖ «មិនដឹងថា ធ្វើម៉េចបើគេមិនឱ្យទៅផ្ទះ ប៉ុន្តែបើទៅផ្ទះគេឃាត់ទុក១៤ថ្ងៃទៀត ម្យ៉ាងទៀតទោះជាទៅផ្ទះក៏វាលំបាកដែរ បើយើងនៅទីនេះទៅមានគ្រូពេទ្យគេនៅមើលយើងបានជិតដល់ដែរ។ ដូចថាវាគេយ៉ាងម៉េចយើងយ៉ាងម៉េចទៅតាមដំណើរទៅ យើងការពាររៀងខ្លួនទៅវាមិនសូវអីទេ យើងចេះតែការពារទៅ គេនៅកន្លែងគេការពារកន្លែងគេអីចឹងទៅ។ គេបិទតែទីផ្សារនិងកន្លែងរោងចក្រដែលសំបូរពលករភូមា និងពលករថៃ បើពលករខ្មែរមិនសូវធ្វើការរោងចក្រប៉ុន្មានទេ ធ្វើតែការងារសំណង់»។

ដូចគ្នានេះដែរ ពលការិនីមានស្រុកកំណើតនៅខេត្តបាត់ដំបង លោកស្រី ព្រុំ ចាន់ឌី ថ្លែងថា លោកស្រី ក៏បារម្ភខ្លាចឆ្លងជំងឺកូវីដ១៩ដែរ ក៏ប៉ុន្តែលោកស្រីនៅតែខំស្មោះធ្វើការទាំងប្រថុយប្រថាននៅខេត្តសាមុតសាខន បន្តទៀត។ ពលការិនីធ្វើការសំណង់រូបនេះ ប្រាប់ថា មូលហេតុដែលគាត់មិនត្រឡប់ទៅស្រុកកំណើតអំឡុងពេលនេះ ដោយសារនៅផ្ទះអត់ការងារធ្វើ និងគ្មានប្រាក់ធ្វើដំណើរត្រឡប់ទៅកម្ពុជាវិញ៖ «ព្រោះឯផ្ទះស្រែក៏គ្មាន ការងារអីក៏គ្មានធ្វើ ដូច្នេះហើយបើខ្ញុំទៅក៏អត់ដឹងថារកអីដើម្បីជីវភាពគ្រួសារអត់មានអីរកទេ។ ខ្ញុំសម្រេចចិត្តថា នៅប្រទេសថៃនេះសិន នៅមានការងារធ្វើក៏នៅសិន ខ្លាចបន្តិចទៀតគេស្ងប់ទៅវិញអ៊ីចឹងទៅ។ ខ្ញុំមានការភ្ញាក់ផ្អើលសឹងថា មិនមានកម្លាំងចិត្តធ្វើការ ព្រោះខ្លាចដែលគេថាកូវីដ តែខ្ញុំមិនទាន់បានឃើញពិតប្រាកដទេ ប៉ុន្តែចេះតែខ្លាចៗ គេថាជំងឺកូវីដហ្នឹងវាសាហាវណាស់»។

ពលករទាំងនេះឱ្យដឹងថា នៅកន្លែងធ្វើការរបស់គេពួកគេមានពលករខ្មែរប្រមាណ២០នាក់ បន្តធ្វើការងារជាធម្មតា ហើយអាចនឹងមានពលករខ្មែររាប់រយនាក់ទៀតធ្វើការនៅខេត្តសាមុតសាខន ប៉ុន្តែពួកគេមិនអាចធ្វើដំណើរចេញពីខេត្តនេះ ទៅកន្លែងផ្សេងបានឡើយ។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី២១ ធ្នូ ដោយទទួលទូរស័ព្ទហើយនៅពេលប្រាប់ថា វិទ្យុអាស៊ីសេរី បានបិទទូរស័ព្ទវិញ។

ទោះជាយ៉ាងណាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវឱ្យពលករខ្មែរ កុំអាលត្រលប់ទៅកម្ពុជាវិញ ក្នុងពេលដែលថៃកំពុងជួបការលំបាក ដោយសារតែការឆ្លងជំងឺកូវីដ១៩នេះ។ លោក ហ៊ុន សែន បានអំពាវនាវតាមរយៈខ្សែអាត់សំឡេងមួយ ដែលចេញផ្សាយដោយសារព័ត៌មានក្នុងស្រុកនៅថ្ងៃទី២០ ធ្នូ ថា ដើម្បីការពារខ្លួន និងកុំឱ្យរីករាលដាលចូលមកកម្ពុជា និងចៀសវាងការបាត់បង់ការងារធ្វើនោះ ឪពុកម្ដាយ និងក្រុមគ្រួសារ ដែលមានសាច់ញាតិធ្វើការនៅប្រទេសថៃ សូមជួយលើកទឹកចិត្តឱ្យពួកគាត់ បន្តនៅប្រទេសថៃ មួយរយៈសិន។ ទោះជាយ៉ាងណារដ្ឋាភិបាលលោក ហ៊ុន សែន បានបញ្ជូនរថយន្តយោធាចំនួន ៧០គ្រឿងដាក់ប្រចាំការនៅតំបន់ព្រំដែន ក្នុងខេត្តបាត់

ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យរួចហើយ ដើម្បីចាំទទួលពលករខ្មែរត្រឡប់មកពីប្រទេសថៃ។ វិធានការរបស់លោក ហ៊ុន សែន នេះ បន្ទាប់ពីជំងឺកូវីដ១៩ បានឆ្លងចូលក្នុងសហគមន៍នៅខេត្តសាមុតសាខន របស់ថៃជាបន្តបន្ទាប់មក។

ក្រសួងសុខាភិបាលរបស់ថៃបានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ថ្មី ចំនួន៣៨២នាក់បន្ថែមទៀត នៅថ្ងៃទី២១ ធ្នូ នៅ ក្នុងនោះចំនួន៣៦០នាក់ឆ្លង នៅខេត្តសាមុតសាខន។ អាជ្ញាធរថៃបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យយ៉ាងតឹងតែងតាមផ្លូវជុំវិញតំបន់ផ្ទុះជំងឺកូវីដ១៩ និងហាមឃាត់មិនឱ្យពលករបរទេសចាកចេញពីខេត្តសាមុតសាខន ធ្វើដំណើរទៅតំបន់ផ្សេងឡើយ ដើម្បីទប់ស្កាត់កុំឱ្យមានការរាតត្បាតជំងឺកូវីដ១៩។

មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា ប្រាប់អាស៊ីសេរីថា អំឡុងពេលនេះ ពលករខ្មែរត្រូវតែអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលថៃឱ្យខ្ជាប់ខ្ជួន ដើម្បីការពារកុំឱ្យឆ្លងជំងឺកូវីដ១៩។ លោកបន្ថែមថា ជំងឺកូវីដ១៩ អាចនឹងឆ្លងលើពលករខ្មែរធ្វើការនៅប្រទេសថៃបានគ្រប់ទីកន្លែងទាំងអស់ ប្រសិនបើពួកគេមិនបានពាក់ម៉ាស់ និងលាងដៃដោយទឹកអាល់កុល និងរក្សាគម្លាតសុវត្ថិភាពឱ្យបានត្រឹមត្រូវនោះ៖ «ហើយត្រូវតាមដានព័ត៌មានឱ្យច្បាស់។ ខ្ញុំគិតថា ការដែលគាត់ស្លន់ស្លោត្រឡប់មកខ្មែរវាមិនមែនជាជម្រើសល្អទេ។ អ្វីដែលជាជម្រើសល្អបំផុតនោះគាត់ត្រូវតែរក្សាការធ្វើការងារនៅប្រទេសថៃដដែល ហើយគាត់បង្កើនការប្រុងប្រយ័ត្នប្រកបដោយការយល់ដឹងតាមការណែនាំរបស់ក្រសួងសុខាភិបាលថៃ»។

គិតត្រឹមថ្ងៃទី២១ ធ្នូ នៅប្រទេសថៃមានអ្នកឆ្លងជំងឺកូវីដ១៩ជិត ៥ពាន់៣០០នាក់(៥ ២៨៩)ក្នុងនោះប្រមាណ ១ពាន់នាក់ នៅឆ្លងក្នុងខេត្តសាមុតសាខន។ របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការស្របច្បាប់ និងមិនស្របច្បាប់ចន្លោះពី១លាន ៨សែន ២លាននាក់ ធ្វើការងារនៅប្រទេសថៃ៕

## ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២០

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ឆ្នាំង ប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារឆ្នាំ២០២០ និងលើកទិសដៅការងារអនុវត្តន៍បន្ត

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 22 ខែ ធ្នូ ឆ្នាំ 2020

AKP កំពង់ឆ្នាំង ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ នៅថ្ងៃ៧កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃចន្ទ ទី២១ ខែធ្នូ ឆ្នាំ២០២០ នៅសាលាខេត្តកំពង់ឆ្នាំង បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារឆ្នាំ២០២០ និងលើកទិសដៅការងារសម្រាប់អនុវត្តន៍បន្តនៅឆ្នាំ២០២១ ក្រោមអធិបតីភាពឯកឧត្តម ឈួរ ច័ន្ទឿន អភិបាលខេត្តនិងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ឆ្នាំងនិងលោកជំទាវ ប៊ន សុភី អភិបាលរងខេត្តនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ឆ្នាំង។ កិច្ចប្រជុំនេះក៏មានការចូលរួមពីលោកព្រះរាជអាជ្ញារងសាលាដំបូងខេត្ត លោកស្រី ឧត្តមសេនីយ៍ត្រី ស្នងការរងខេត្ត លោក លោកស្រី ជាអនុប្រធាន សមាជិកសមាជិកា ក្រុមការងារអន្តរមន្ទីរ អង្គភាពទាំង៦ ក្រុមលេខាធិការដ្ឋាន ព្រមទាំងក្រុមការងារជំនាញក្រុង ស្រុក ទាំង០៨ ផងដែរ។

ឯកឧត្តម ឈួរ ច័ន្ទឿន បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សមត្ថកិច្ចមន្ទីរជំនាញ និងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ដែលបានអនុវត្តន៍សកម្មភាពការងារកន្លងមក ក្នុងការបង្ការ បង្ក្រាប ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការអប់រំផ្សព្វផ្សាយពីការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ នៅទូទាំងខេត្ត យ៉ាងមានប្រសិទ្ធភាព។ ឯកឧត្តម ក៏បានផ្តាំផ្ញើដល់គណៈកម្មាធិការ ក៏ដូចជាលេខាធិការដ្ឋាន សូមបន្តខិតខំអនុវត្តន៍ឱ្យបានជោគជ័យនូវផែនការ

ការងារដែលបានដាក់ចេញសម្រាប់អនុវត្តន៍ក្នុងឆ្នាំ២០២១ខាងមុខ និងទិសដៅការងារដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ សំដៅលុបបំបាត់ឱ្យបានអំពើជួញដូរមនុស្សគ្រប់រូបភាព។ ពិសេសឯកឧត្តមបានណែនាំដល់អាជ្ញាធរក្រុង ស្រុក ត្រូវក្តាប់ឱ្យបានពីពលករចំណាកស្រុក ពលករវិលត្រឡប់ចូលស្រុកវិញ ត្រូវស្រង់ទិន្នន័យឱ្យបានច្បាស់ ចុះពិនិត្យផ្សព្វផ្សាយ ណែនាំឱ្យធ្វើចត្តាឡីស័ក រួមគ្នាបង្ការទប់ស្កាត់ មិនឱ្យមានការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ចូលមកដល់សហគមន៍ជាដាច់ខាត ។

ឯកឧត្តមអភិបាល ក៏បានផ្តាំផ្ញើដល់ក្រុមការងារ និងអង្គភាពពាក់ព័ន្ធទាំងអស់ត្រូវសហការគ្នាដើម្បីបន្តអប់រំផ្សព្វផ្សាយអំពីវិធានការការពារនិងទប់ស្កាត់ការឆ្លងមេរោគ និងសំណើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលដើម្បីដាក់ចេញវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគដ៏កាចសាហាវក្នុងអំឡុងពេលនៃការរីករាលដាលមេរោគកូវីដ-១៩៕ដោយ៖ បៃ ស៊ីថុន សម្រួលផ្សាយដោយ៖ ធូ កុសល

## គិតត្រឹមថ្ងៃទី២៣ ពលរដ្ឋដែលវិលចូលកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មាន ៧៥នាក់ ត្រូវបានដឹកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យតេជោ សែន សំរោង

https://www.khmer-press.com/ Khmer pressDecember 23, 2020 at 4:58 pm

ឧត្តរមានជ័យ៖ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៥នាក់ ស្រី ៣៥នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោសែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ៕ ប្រភព៖ Khmer Note

## អភិបាលខេត្តឧត្តរមានជ័យ និងនាយឧត្តមសេនីយ៍ ហ៊ូ សាគុណ ចុះសួរសុខទុក្ខពលករធ្វើដំណើរមកពីប្រទេសថៃ តាមច្រកព្រំដែនអន្តរជាតិអូរស្មាច់

http://www.freshnewsasia.com/ 2020-12-23 03:08pm

**(ឧត្តរមានជ័យ)៖** លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ និងនាយឧត្តមសេនីយ៍ ហ៊ូ សាគុណ អគ្គស្នងការរងនគរបាលជាតិ អមដំណើរដោយថ្នាក់ដឹកនាំខេត្ត ប្រធានមន្ទីរសុខាភិបាលខេត្ត និងលោកឧត្តមសេនីយ៍ទោ ស្នងការនគរបាលខេត្ត ព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនអង្គភាពទៀតនៅព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ នេះ បានចុះពិនិត្យស្ថានភាពច្រកព្រំដែនអន្តរជាតិអូស្មាច់ និងជួបសំណេះសំណាល សួរសុខទុក្ខពលករ ដែលទើបវិលត្រឡប់មកពីប្រទេសថៃ។

លោក ប៉ែន កុសល្យ និងលោកនាយឧត្តមសេនីយ៍ ហ៊ូ សាគុណ បានថ្លែងថា ការធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ចំពោះពលករនាពេលនេះ ធ្វើឡើងតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងបង្កើនការយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ចូលក្នុងសហគមន៍ ហើយចំពោះការធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃនេះដែរ រដ្ឋបាលខេត្តក៏បានយកចិត្តទុក្ខដាក់ចំពោះការផ្តត់ផ្គង់ចំពោះការស្នាក់នៅ ចំណីអាហារ និងសម្ភារប្រើប្រាស់មួយចំនួនជូនពលករផងដែរ។ ការធ្វើចត្តាឡីស័កនេះ មិនមែនជាការឃុំខ្លួនពលករនោះ

ទេ ដូច្នេះសូមកុំយល់ច្រឡំ ផ្ទុយទៅវិញត្រូវអនុវត្តន៍ឱ្យបានទៀងទាត់តាមការណែនាំរបស់ក្រសួងសុខាភិបាល ក្នុងទិសដៅរួមគ្នាការពារជំងឺកូវីដ១៩ កុំឱ្យមានការចម្លងដល់បងប្អូនក្រុមគ្រួសារក៏ដូចជាសហគមន៍។ ជាមួយគ្នានេះដែរ លោកអភិបាលខេត្ត បានដឹកនាំមន្ត្រីពាក់ព័ន្ធ និងកងកម្លាំងបន្តចុះពិនិត្យតំបន់ភូមិសាស្ត្រអូរខ្លាឃ្មុំ ដែលមានទីតាំងស្ថិតនៅសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងបានបញ្ជាឲ្យលោកស្នងការនគរបាលខេត្ត ដាក់កម្លាំងបន្ថែមតាមខ្សែក្រវ៉ាត់ព្រំដែន ដើម្បីបញ្ចៀសការលួចឆ្លងកាត់ខុសច្បាប់។

ដោយឡែកលោក ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងដែរថា ពលករខ្មែរដែលចាកចេញពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់មាន ចំនួន៩៤នាក់ និងបានដឹកជញ្ជូនតាមរថយន្តយកទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ហើយក្នុងចំណោមពលករទាំង៩៤នាក់ មានចំនួន៤២នាក់ ដែលមកពីតំបន់ប្រឈមនានា និងជំងឺកូវីដ១៩ ក្នុងប្រទេសថៃ ត្រូវបានដាក់ដោយឡែកដើម្បីពិនិត្យយកសំណាករកមេរោគកូវីដ១៩៕

## អាជ្ញាធរខេត្តបាត់ដំបង ធ្វើចត្តាឡីស័កពលករទើបមកពីថៃចំនួន ១២១នាក់ក្នុងរយៈពេល ២ថ្ងៃ

https://www.cen.com.kh/ December 23, 2020

បាត់ដំបង ៖ អាជ្ញាធរខេត្តនិងមន្ត្រីជំនាញ បានពិនិត្យសុខភាពនិងបានធ្វើចត្តាឡីស័កពលករខ្មែរទើបត្រឡប់វិញមកពីថៃសរុបចំនួន ១២១នាក់នៅមណ្ឌលចំនួន២ក្នុងស្រុកកំរៀង បន្ទាប់ពីមានការផ្ទុះឆ្លងជំងឺកូវីដ១៩នៅខេត្តសាមុទសាខនប្រទេសថៃ ជាច្រើនករណី ដោយគិតចាប់ពីថ្ងៃទី២១និង២២ខែធ្នូ ឆ្នាំ២០២០។

លោក សឿម ប៊ុនរិទ្ធ អភិបាលរងខេត្តបាត់ដំបងនិងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង បានឲ្យដឹងថា ពលករទាំង ១២១នាក់គឺមានចំនួន១០៤នាក់ បានធ្វើចត្តាឡីស័កនៅក្នុងសាលាវិទ្យាល័យកំរៀងស្ថិតក្នុងស្រុកកំរៀង។ក្នុងចំណោមនេះ បានយកសំណាកមកពិនិត្យរកជំងឺកូវីដ១៩ បានចំនួន៧៦នាក់និងក្នុងមណ្ឌលចត្តាឡីស័កមួយទៀតនៅក្នុងមណ្ឌលសុខភាពត្រាំងមានចំនួន១៧នាក់ ដែលបានយកសំណាករួចរាល់គ្រប់គ្នា។សម្រាប់ថ្ងៃទី២២ខែធ្នូឆ្នាំ២០២០ មានពលករបានធ្វើដំណើរឆ្លងដែនពីប្រទេសថៃមកតាមច្រកជាប់នឹងខេត្តបាត់ដំបង មានចំនួន១៩នាក់ (ស្រី៦នាក់) ដោយពួកគេទាំងអស់នោះ មិនមានអ្នកណាម្នាក់មកពីខេត្តសាមុទសាខននោះទេ។

យោងតាមរបាយការណ៍ របស់មន្ទីរសុខាភិបាលខេត្តបាត់ដំបង បានឲ្យដឹងថាចាប់តាំងពីមានការផ្ទុះជំងឺកូវីដ១៩នៅលើពិភពលោក សម្រាប់ខេត្តបាត់ដំបង បានយកសំណាកអ្នកសង្ស័យឆ្លងជំងឺកូវីដ១៩ ទៅពិសោធន៍ក្នុងវិទ្យាស្ថានប៉ាស្ទ័រ រាជធានីភ្នំពេញ បានចំនួន២៩៤១សំណាក (ស្រី ១ ១៤៦សំណាក) ដោយមានអ្នកឆ្លងជំងឺកូវីដ១៩ ចំនួន ៩នាក់ (ស្រី៣នាក់) ហើយត្រូវបានក្រុមគ្រូពេទ្យជួរមុខព្យាបាលជាសះស្បើយអស់ហើយផងដែរ៕ រក្សាសិទ្ធិដោយៈអ៊ុងសារុំ

## ពលករជិត២០០នាក់ដែលថៃបញ្ជូនមកវិញ ត្រូវអាជ្ញាធរកម្ពុជាណែនាំឱ្យធ្វើចត្តាឡីស័ក

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១៧:២០ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ ពលករចំនួន១៩៩នាក់ត្រូវបានភាគីថៃបញ្ជូនមកវិញតាមច្រកអូរបីជាន់ ស្ថិតឃុំអូរបីជាន់ ស្រុកអូរជ្រៅ ត្រឹមម៉ោង៤ល្ងាចថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ហើយអាជ្ញាធរកម្ពុជាបានអោយពួកគាត់ធ្វើចត្តាឡីស័ក។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅបានប្រាប់ថា ភាគីថៃបានចាប់បញ្ជូនពលករតាមច្រកអូរជាន់ស្រុកអូរជ្រៅរយៈពេល១ថ្ងៃមានចំនួន១៩៩នាក់ ក្នុងនោះមានស្រីចំនួន៨៧នាក់ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ បើប្រៀបធៀបនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ មានចំនួ១៧០នាក់ ក្នុងនោះមានស្រីចំនួន៦៨នាក់។ លោកបានបញ្ជាក់ថានៅពេលដែលភាគីថៃដេកបញ្ជូនពលករតាមច្រកអូរបីជាន់ត្រូវក្រុមការងារមានគ្រូពេទ្យចាំធ្វើចត្តាឡីស័កដោយពិ

និត្យសុខភាពមានវាស់កំដៅ បើជាប់សង្ស័យត្រូវបានបញ្ជូនទៅមន្ទីពេទ្យបង្អែកក្រុងប៉ោយប៉ែត ហើយមិនជាប់សង្ស័យទេត្រូវបានក្រុមការងារមានកម្លាំងនគរបាល និងកម្លាំងកងរាជអាវុធហត្ថ កម្លាំងយោធា និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើណែនាំដល់ពលករត្រូវបញ្ឈប់សកម្មភាពចំណាកស្រុកខុសច្បាប់ដែលប្រឈមគ្រោះថ្នាក់។ លោក លី សុវណ្ណរិទ្ធ បានបញ្ជាក់ថា ក្រុមគ្រូពេទ្យដែលធ្វើចត្តាឡីស័កត្រូវបានណែនាំដល់ពលករដែលភាគីថៃបញ្ជូនមកត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល នៅពេលដែលទៅផ្ទះត្រូវធ្វើចត្តាឡីស័កខ្លួនរយៈពេល១៤ថ្ងៃ ដោយមិនត្រូវនៅជិត ឬប៉ះពាល់សាច់ញាតិ និងត្រូវពាក់ម៉ាស់ លាងអាកុល ឬដែលលាងសំអាតជាប្រចាំ ដើម្បីបង្កាទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩។

គួររំលឹកថា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចេញសារណែនាំដល់អាជ្ញាធរខេត្តជាប់ជាយដែនប្រទេសថៃត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធ្វើចត្តាឡីស័កដល់ប្រជាពលរដ្ឋខ្មែរដែលត្រឡប់ពីថៃចូលមកកម្ពុជាវិញ ត្រូវតែអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីបង្ការនិងទប់ស្កាត់ការឆ្លងកូវីដ១៩ ស្របពេលដែលប្រទេសថៃកំពុងឆ្លងកូវីដ១៩ចូលក្នុងសហគមន៍៕ (កែសម្រួលដោយ ៖ ធីតា)

## ពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ នៅស្រុកបូទុមសាគរ

https://gdlf-kh.com/ Kao sophy ខេត្តកោះកុង 2020/12/22/

ខេត្តកោះកុង៖ ថ្ងៃអង្គារ ៨កើត ខែបុស្ស ឆ្នាំជូតទោស័ក ពុទ្ធសករាជ២៥៦៤ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ លោក ស្រេង ហុង អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង បានអញ្ជើញជាអធិបតី ក្នុងពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ នៅស្រុកបូទុមសាគរ។ លោកអភិបាលរងខេត្ត បានគូសបញ្ជាក់ថា អំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មដ៏រាំរ៉ៃមួយ ដែលបានកើតឡើងនៅគ្រប់បណ្តាប្រទេស ក្នុងពិភពលោក ក្នុងចំណោមឧក្រិដ្ឋកម្មដទៃផ្សេងទៀត ដែលបាននឹងកំពុងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខមនុស្ស និងប្រទេសជាតិ និងជាពិសេសក្នុងចំណោមពលករទេសន្តរប្រវេសន៍ដែលបានធ្វើចំណាកស្រុក ដល់កុមារ និងស្ត្រី និងអង្គការដៃគូរផ្សេងៗ បានយកចិត្តទុកដាក់ និងសហការជាមួយគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាលេខាធិការដ្ឋាន ជាសេនាធិការ និងអស់លោក លោកស្រីថ្នាក់ដឹកនាំមន្ទីរ-អង្គភាពជុំវិញខេត្ត អ្នកពាក់ព័ន្ធនានា រួមជាមួយនឹង ជំនាញកម្លាំងប្រដាប់អាវុធទាំងបីប្រភេទក្នុងខេត្ត បានរៀបចំជាសិក្ខាសាលាផ្សព្វផ្សាយ ក្នុងការទប់ស្កាត់ និងបង្រ្កាបអំពើជួញដូរមនុស្ស-ជួញដូរពលកម្ម នៅក្នុងខេត្ត ក៏ដូចជានៅតាមបណ្តោយព្រំដែន នៃខេត្តកោះកុង ទទួលបានលទ្ធផលយ៉ាងល្អប្រសើរ៕

## ពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ នៅស្រុកស្រែអំបិល

https://grandnewsasia.com/ 22-12-2020 ម៉ោង 12:52 pm

កោះកុង ៖ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ លោក ស្រេង ហុង អភិបាលរងខេត្តកោះកុង បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ នៅស្រុកស្រែអំបិល។ លោកអភិបាលរងខេត្ត បានគូសបញ្ជាក់ថា អំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មដ៏រាំរ៉ៃមួយ ដែលបានកើតឡើងនៅគ្រប់បណ្តាប្រទេស ក្នុងពិភពលោក ក្នុងចំណោមឧក្រិដ្ឋកម្មដទៃផ្សេងទៀត ដែលបាននឹងកំពុងធ្វើឲ្យប៉ះពាល់ដល់ សន្តិសុខមនុស្ស និងប្រទេសជាតិ និងជាពិសេសក្នុងចំណោមពលករដែលបានធ្វើចំណា

កស្រុក ដល់កុមារ និងស្ត្រី និងអង្គការដៃគូរផ្សេងៗ បានយកចិត្តទុកដាក់ និងសហការជាមួយគណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាលេខាធិការដ្ឋាន ជាសេនាធិការ និងអស់លោក លោកស្រីថ្នាក់ដឹកនាំ មន្ទីរ-អង្គភាពជុំវិញខេត្ត អ្នកពាក់ព័ន្ធនានា រួមជាមួយនឹងជំនាញកម្លាំងប្រដាប់អាវុធទាំងបីប្រភេទក្នុងខេត្ត បាន រៀបចំជាសិក្ខាសាលាផ្សព្វផ្សាយ ក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស-ជួញដូរពលកម្ម នៅក្នុងខេត្ត ក៏ ដូចជានៅតាមបណ្តោយព្រំដែន នៃខេត្តកោះកុង ទទួលបានលទ្ធផលយ៉ាងល្អប្រសើរ៕

## នគរបាលប៉ុស្តិ៍រដ្ឋបាលជ្រោយបន្ទាយ ធ្វើការផ្សព្វផ្សាយនៅតាមខ្នងផ្ទះដល់ប្រជាពលរដ្ឋ ស្តីអំពីលក្ខណៈសម្បត្តិ នៃគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព

http://cambodiapolice.com/policekh/ 3:12 pm 23 ធ្នូ 2020

ខេត្តក្រចេះ ៖ នៅព្រឹកថ្ងៃពុធទី២៣ ខែធ្នូ ឆ្នាំ២០២០ នគរបាលប៉ុស្តិ៍រដ្ឋបាលជ្រោយបន្ទាយ បានធ្វើការ ផ្សព្វផ្សាយនៅតាមខ្នងផ្ទះដល់ប្រជាពលរដ្ឋ នៅចំណុចផ្សារភ្នាវង (ក្នុងភូមិជ្រោយបន្ទាយ) ឃុំជ្រោយបន្ទាយស្រុក ព្រែកប្រសព្វ ខេត្តក្រចេះ ស្តីអំពី ៖

១.ច្បាប់ចរាចរណ៍លេខ៣៩អនក្រ

២.ផលប៉ះពាល់នៃគ្រឿងញៀន៩ចំណុច

៣.ល្បែងស៊ីសងខុសច្បាប់

៤.គ្រោះអគ្គិភយ័ផ្សេងៗ

៥.គ្រោះថ្នាក់អាវុធយុទ្ធភណ្ឌ័មិនទាន់ផ្ទុះ

៦.ជួញដូរស្ត្រីភេទនិងកុមារ

៧.ផ្សព្វផ្សាយអោយប្រុងប្រយ័ត្នអំពីជម្ងឺcovid-19

បានចំនួន ០៦ ខ្នងផ្ទះ មនុស្សចូលរួម ១៥នាក់ ស្រី ៩នាក់ ចែកខិតបណ្ណ័ ១៥សន្លឹក ៕

## ឃាត់ខ្លួនយុវជន ពីរនាក់ លួចឆ្លងដែនចូលប្រទេសថៃ ខុសច្បាប់ យកទៅធ្វើចត្តាឡីស័ក

https://www.rasmeinews.com/archives/ 23 December, 2020

**ដោយៈ ទេព មង្គល / ភ្នំពេញ:** *យោងតាមអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ បានឱ្យដឹង នៅរសៀលថ្ងៃនេះថាៈ នៅវេលាម៉ោង ១០ ព្រឹក ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍ នគរបាលច្រកទ្វារព្រំដែន អន្តរជាតិចាំយាម បានចុះល្បាត ក្នុងភូមិសាស្ត្រស្លាបស្តាំ ពិនិត្យឃើញពលរដ្ឋខ្មែរ ចំនួន ពីរនាក់ ឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់។*

នគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែន អន្តរជាតិចាំយាម បានឲ្យដឹងថាៈ ពលរដ្ឋខ្មែរទាំង ពីរនាក់នោះ មានៈ ១. ឈ្មោះ ស៊ឹម ទូច អាយុ ២៣ ឆ្នាំ, និង២.ឈ្មោះ ផុន ប្រុស អាយុ ២៦ ឆ្នាំ ។ យុវជនពីរនាក់នេះ រស់នៅភូមិត្របែក ឃុំត្របែក ស្រុកកំចាយមា ខេត្តព្រៃវែង ជាមួយគ្នា។ ក្រោយពីបានសាកសួរ និងអប់រំណែនាំរួច សមត្ថកិច្ច បាន ប្រគល់ជូនមន្ត្រីចត្តាឡីស័ក ប្រចាំមាត់ច្រក ដើម្បីអនុវត្តន៍នីតិវិធីបន្ត នូវវិធានការរបស់ ក្រសួងសុខាភិបាល៕/V

# ពលករខ្មែរធ្វើការខុសច្បាប់នៅប្រទេសថៃ បារម្ភពីសុវត្ថិភាព ក្រោយប្រទេសថៃផ្ទុះជំងឺកូវីដ-១៩ ជាលើកទីពីរ

https://www.rfa.org/khmer/ ដោយៈ អាស៊ីសេរី 2020-12-23

ពលករខ្មែរដែលធ្វើការងារដោយខុសច្បាប់នៅប្រទេសថៃ កំពុងព្រួយបារម្ភខ្លាចអាជ្ញាធរថៃចាប់ពួកគេដាក់គុក និងបញ្ជូនត្រឡប់ទៅកម្ពុជាវិញ ក្រោយប្រទេសថៃផ្ទុះជំងឺកូវីដ-១៩ ជាលើកទីពីរ។ នៅពេលនេះ មានពលករខ្លះបានផ្អាកធ្វើការជាបណ្ដោះអាសន្ន រួចលាក់ខ្លួនរកកន្លែងមានសុវត្ថិភាព និងខ្លះទៀតបន្តធ្វើការទាំងភិតភ័យ ដើម្បីរកប្រាក់ដោះស្រាយជីវភាពគ្រួសារ។ អ្នកធ្វើការងារពាក់ព័ន្ធនឹងសិទ្ធិពលករយល់ថា អំឡុងពេលនេះពលករគួរតែនៅមួយកន្លែងដើម្បីរក្សាសុវត្ថិភាពផ្ទាល់ខ្លួន។

ពលករមានស្រុកកំណើតនៅខេត្តបាត់ដំបង លោក ធន សុខឿន ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី២៣ ធ្នូ ថា លោកនៅជាមួយប្រពន្ធ និងកូនគ្នា៥នាក់ កំពុងលាក់ខ្លួននៅក្នុងផ្ទះមួយកន្លែងនៅខេត្តសាមុតសាខន (Samut Sakhon) ដើម្បីគេចចេញពីអាជ្ញាធរថៃត្រួតពិនិត្យជំងឺកូវីដ-១៩។ ពលករសំណង់រូបនេះនិយាយថា នៅតំបន់ដែលលោកធ្វើការនោះមានពលករខ្មែរប្រមាណ១០០នាក់ ក៏រត់គេចរកកន្លែងមានសុវត្ថិភាពដែរ ដោយខ្លាចអាជ្ញាធរថៃចាប់ពួកគេដាក់គុក និងបញ្ជូនត្រឡប់ទៅកម្ពុជាវិញ អំឡុងពេលការត្រួតពិនិត្យជំងឺកូវីដ-១៩ ព្រោះពួកលោកធ្វើការងារដោយខុសច្បាប់៖ «សូម្បីតែទៅទិញម្ហូប ឬទៅផ្សារទៅអីទៅទីណាក៏អត់បានដែរ ព្រោះនៅកន្លែងហ្នឹងគឺគេបិទអត់ឱ្យចេញចូលទេ។ ដល់ពេលអីចឹងទៅហើយអាជ្ញាធរថៃចូលមកទៀតយើង មានការព្រួយបារម្ភខ្លាំងថាតើយើងអាចលាក់ខ្លួនបានប៉ុន្មានថ្ងៃបើតាមស្ដាប់ព័ត៌មានគេឱ្យលាក់ខ្លួន៣ថ្ងៃអីចឹង ថ្ងៃនេះគឺជាថ្ងៃទី១ អីចឹងយើងសង្ឃឹមថារយៈពេល២ថ្ងៃទៅមុខទៀតយើងនឹងអាចគេចផុត»។

ដូចគ្នានេះដែរ ពលករធ្វើការសំណង់ទីក្រុងបាងកក លោក ណែត ស៊ីណា ថ្លែងថា ចាប់តាំងពីផ្ទុះជំងឺកូវីដចូលក្នុងសហគមន៍ជាលើកទីពីរក្នុងប្រទេសថៃមក លោកព្រួយបារម្ភអំពីសុវត្ថិភាពយ៉ាងខ្លាំង ហើយមិនហ៊ានចេញពីកន្លែងធ្វើការឡើយ។ ពលករវ័យ២៩ឆ្នាំរូបនេះប្រាប់ថា ប្រសិនបើអាជ្ញាធរថៃចាប់គាត់ដាក់គុក ឬបញ្ជូនត្រឡប់ទៅខ្មែរវិញ នោះប្រពន្ធនិងកូនរបស់លោកច្បាស់ជាជួបការលំបាកនិងគ្មានអង្ករច្រកឆ្នាំងឡើយ ពីព្រោះពួកគេរស់ដោយសារប្រាក់ដែលលោកផ្ញើពីប្រទេសថៃទៅឱ្យចាយវាយ៖ «និយាយរួម បើមិនប៉ះខ្ញុំក៏ប៉ះបងប្អូនខ្មែរទាំងអស់ដែលខំចំណាកស្រុកមករកស៊ីស្រុកគេហ្នឹងវា មិនដូចក្ដីបំណង។ វាប៉ះគេចាប់ទៅក៏អត់ការងារធ្វើ ហើយបើទៅខ្មែរពឹងអី បើខ្លះជំពាក់អង្គការជំពាក់អីវាច្រើនបែបច្រើនយ៉ាងណាស់និយាយរួមទៅ។ ខ្ញុំមានអីមានតែអាណិតប្រពន្ធអាណិតកូនហ្នឹងឯង បើគ្នាអត់ឃ្លាននៅផ្ទះចិញ្ចឹមកូនផង បើយើងទៀតដាច់បាយទាំងប្រពន្ធទាំងខ្ញុំទាំងអស់គ្នាហ្នឹង»។

ក្រុមពលករទាំងនេះអំពាវនាវដល់រដ្ឋាភិបាលខ្មែរឱ្យជួយអន្តរាគមន៍ទៅភាគីថៃសម្រួលឱ្យពួកគាត់ បានធ្វើការជាធម្មតាដោយពុំចាត់វិធានការផ្លូវច្បាប់អំឡុងពេលនេះ។ ក្ដីបារម្ភ និងសំណើរបស់ពលករខ្មែរនេះ កើតមានក្រោយពីអាជ្ញាធរថៃបានដាក់ចេញវិធានការតឹងរ៉ឹង ក្រោយរកឃើញការផ្ទុះរាលដាលជំងឺកូវីដ-១៩ ជិត១ពាន់ករណីនៅក្នុងខេត្តសាមុតសាខន ដោយឆ្លងចេញពីពលករបរទេសដែលលួចឆ្លងដែនខុសច្បាប់ចូលមកប្រទេសថៃ។ បច្ចុប្បន្ន អាជ្ញាធរថៃបានហាមឃាត់មិនឱ្យរថយន្តដឹកពលករបរទេសចេញនិងចូលនៅខេត្តសាមុតសាខន និងនៅតំបន់ទីក្រុងបាងកកនោះឡើយ ដើម្បីទប់ស្កាត់កុំឱ្យមានការរាតត្បាតជំងឺកូវីដ-១៩។ ចំណែក នាយករដ្ឋមន្ត្រីថៃ លោក ប្រាយុទ្ធ ចាន់អូចា (Prayut Chan-o-cha) បានព្រមានចាត់វិធានផ្លូវច្បាប់លើក្រុមមេខ្យល់ និងថៅកែជនជាតិថៃទាំងឡាយណាដែលលួចនាំ និងជួលពលករបរទេសធ្វើការងារដោយខុសច្បាប់ អំឡុងពេលនេះ។

អាស៊ីសេរី មិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយជុំវិញក្ដីកង្វល់របស់ក្រុមពលករខ្មែរនេះបានទេនៅថ្ងៃទី២៣ ធ្នូ។

ប៉ុន្តែក្រសួងការងារបានចេញលិខិតណែនាំដល់ ពលករត្រូវបន្តធ្វើការងារជាធម្មតា និងកុំប្តូរកន្លែងស្នាក់នៅ ដែលខុសពីបម្រាមរបស់អាជ្ញាធរថៃ អំឡុងពេលមានការរាតត្បាតជំងឺកូវីដ-១៩ នេះ។ ក្រសួងបន្តថា ពលករត្រូវចូលរួមសហការតាមការណែនាំរបស់ក្រសួងសុខាភិបាលថៃឱ្យបានខ្ជាប់ខ្ជួន និងត្រូវលាងដៃជាមួយសាប៊ូ ឱ្យបានញឹកញាប់ និងត្រូវពាក់ម៉ាស់ជាប្រចាំ ហើយកុំចេញដើរទៅកន្លែងដែលមានមនុស្សច្រើន។ ក្រសួងលើកឡើងក្នុងលិខិតចុះថ្ងៃទី២១ធ្នូនោះទៀតថា ប្រសិនបើពលករមានបញ្ហាអ្វីអំឡុងពេលនេះ ត្រូវទាក់ទងទៅស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកជាបន្ទាន់ ដើម្បីជួយដល់ពួកគេបានទាន់ពេលវេលា។ ក្រសួងអះអាងថា ក្រសួងបានទាក់ទងទៅក្រសួងការងារថៃ ឱ្យអនុគ្រោះដល់ពលករខ្មែរបានស្នាក់នៅធ្វើការក្នុងប្រទេសថៃជាបណ្ដោះអាសន្នរួចហើយ។

ទោះជាយ៉ាងណា អ្នកបកប្រែ និងជាអ្នកជួយការពារសិទ្ធិឱ្យពលករខ្មែរនៅប្រទេសថៃ លោក ប្រាក់ គត្រា ប្រាប់អាស៊ីសេរីថា អំឡុងពេលនេះ ពលករខ្មែរទាំងអ្នកធ្វើការស្របច្បាប់ និងមិនស្របច្បាប់ប្រឈមនឹងថៅកែថៃបញ្ឈប់ពីការងារ ដោយសារពួកគេព្រួយខ្លាចឆ្លងជំងឺកូវីដ-១៩ផង និងខ្លាចអាជ្ញាធរថៃចាត់វិធានការផ្លូវច្បាប់ដល់ពួកគេផង៖ «នេះជាបញ្ហាធំ ហើយអ្នកដែលអត់ឯកសារ អ្នកអត់ច្បាប់ហ្នឹង មានសិទ្ធិបាត់បង់ការងារមុនអ្នកដែលមានឯកសារ។ ខ្ញុំថានៅពេលនេះ ពលករគួរតែនៅឱ្យស្ងៀមសិន តាមដានសភាពការណ៍ ហើយកុំព្យាយាមចល័ត។ ព្រោះថា ពេលនេះមានបម្រាមចេញមកច្រើនណាស់ កាលពលករមានការភ្ញាក់ផ្អើល ឬថៅកែបញ្ឈប់អីហ្នឹង វាអាចធ្វើឱ្យពលករអត់មានកន្លែងស្នាក់នៅ អត់មានការងារធ្វើ ដែលធ្វើឱ្យគាត់ត្រូវចល័តទៅខេត្តផ្សេងទៀត អីចឹងធ្វើឱ្យគាត់ប្រឈមបាន»។

របាយការណ៍អង្គការសង់ត្រាល់ (Central) ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការងារស្របច្បាប់ និងមិនស្របច្បាប់ប្រមាណពី ១លាន៨សែន ទៅ ២លាននាក់ (២.០០០.០០០) ធ្វើការនៅប្រទេសថៃ៕

## អាជ្ញាធរថៃថាស្ត្រីខ្មែរម្នាក់វិជ្ជមានកូវីដក្រោយឆ្លងដែន«មិនស្របច្បាប់»

https://khmer.voanews.com/ 23 ធ្នូ 2020 អូន ឆេងប៉រ

ភ្នំពេញ៖ អាជ្ញាធរថៃបានប្រកាសនៅថ្ងៃពុធនេះថា ខ្លួនរកឃើញករណីវិជ្ជមានកូវីដ១៩លើស្ត្រីខ្មែរម្នាក់ ដែលត្រូវបានរាយការណ៍ថា«លួច»ឆ្លងដែនចូលទឹកដីថៃតាំងតែពីសប្តាហ៍មុន។ តែអ្នកឃ្លាំមើលស្ថានភាពពលករបារម្ភពីករណីដែលអាជ្ញាធរថៃយកពលករចំណាកស្រុក ដើម្បីទម្លាក់កំហុសរឿងឆ្លងរាលដាលកូវីដ១៩ក្នុងសហគមន៍របស់ខ្លួន។

លោក Pakarathorn Thienchai អភិបាលខេត្តជលបុរី (Chonburi) របស់ថៃបានប្រកាសក្នុងសន្និសីទសារព័ត៌មានមួយកាលពីរសៀលថ្ងៃពុធនេះថា ស្ត្រីកម្ពុជារូបនោះមានវ័យ១៩ឆ្នាំ។ តាមរយៈវីដេអូនៃសន្និសីទសារព័ត៌មាន ដែលបានបង្ហោះលើទំព័រហ្វេសប៊ុករបស់សាលាខេត្តជលបុរី លោកអភិបាល Pakarathorn Thienchai បានថ្លែងថា ស្ត្រីរូបនោះស្ថិតក្នុងចំណោមពលករកម្ពុជា១១នាក់ ដែលបានមកដល់ស្រុកពានទង«ដោយខុសច្បាប់» កាលពីថ្ងៃទី១៧ខែធ្នូ។ លោកថ្លែងថា៖ «ហេតុដូចនេះទើបបានជាត្រូវយករឿងនេះមកជម្រាបជូនបងប្អូនអ្នកស្រុកជលបុរីឱ្យបានជ្រាបថា នៅខណៈពេលនេះយើងបានត្រួតពិនិត្យរកឃើញអ្នកឆ្លងមេរោគកូវីដជនជាតិកម្ពុជាជាពលករចំណាកស្រុកដែលធ្វើដំណើរចូលមកដោយខុសច្បាប់ចំនួន០១ករណីហើយ»។ លោកអភិបាលខេត្តរូបនេះបន្ថែមថា ស្ត្រីវ័យ១៩ឆ្នាំនេះ ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យហើយមន្ត្រីសុខាភិបាលថៃកំពុងតាមដានរកមើលអ្នកប៉ះពាល់ផ្ទាល់ពីព្រំដែនដល់សហគមន៍។

VOA មិនទាន់ទទួលបានការឆ្លើយបំភ្លឺភ្លាមៗពីស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកកបាននៅឡើយទេ គិតត្រឹមរសៀលថ្ងៃពុធនេះ។ វីអូអេក៏មិនទាន់អាចសុំការអត្ថាធិប្បាយពីលោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលកម្ពុជាបានទេ។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុកនៃអង្គការសង់ត្រាល់ សម្តែងមន្ទិលអំពីការយកករណីកូវីដទម្លាក់បន្ទុកលើពលករចំណាកស្រុកខ្មែរ ក្រោយលោកនាយករដ្ឋមន្ត្រី Prayut Chan-o-cha (ប្រាយុទ្ធ ចាន់អូចា) បានទម្លាក់កំហុសឱ្យពលករបរទេសជុំវិញការផ្ទុះឆ្លងកូវីដ១៩ ដែលកំពុងរាលដាលនៅក្នុងប្រទេសថៃ។ មន្ត្រីសង្គមស៊ីវិលរូបនេះបារម្ភថារដ្ឋាភិបាលថៃ ដែលកំពុងរងសម្ពាធពីបាតុកម្មព្រមៗគ្នារបស់មហាជនទាមទារប្រជាធិបតេយ្យ កំពុងរកហេតុផលដើម្បីប្រកាសច្បាប់សឹកដឹកនាំគ្រាអាសន្ន។ លោកមានប្រសាសន៍ថា៖ «ខ្ញុំបារម្ភថារឿងនេះបើសិនជាវាគ្រាន់តែជាស្វាលាបមាត់ពពែ ខ្ញុំគិតថាវាធ្វើឱ្យពលករយើងរងគ្រោះដោយមិនដឹងខ្លួន ហើយចាប់ផ្តើមមានការរើសអើងពលករបរទេសហើយ។ មានការរើសអើងចាប់ផ្តើមមិនពេញចិត្ត»។ ទោះយ៉ាងណា លោក ឌី ថេហូយ៉ា ក៏លើកឡើងផងដែរអំពីចលនានៃការលួចនាំពលករកម្ពុជាចូលទៅធ្វើការនៅប្រទេសថៃ អំឡុងពេលមានការរាតត្បាតជំងឺកូវីដ១៩តាំងពីដើមឆ្នាំ ដែលការនាំផ្លូវការរងភាពអាក់រអួល តែអំណោយផលឱ្យមេខ្យល់អាចនាំពលករទៅថៃដោយមិនស្របច្បាប់។

ប្រទេសថៃថាខ្លួនកំពុងទប់ទល់នឹងការឆ្លងរាលដាលកូវីដ១៩ ក្នុងសហគមន៍ ដែលធ្ងន់ធ្ងរជាងគេនៅខេត្តសមុទ្រសាគរ(Samut Sakhon) ទីដែលមានករណីឆ្លងច្រើនជាង១០៦៣ករណី គិតត្រឹមថ្ងៃអង្គារ។ នេះបើយោងតាមមន្ទីរជាតិឃោសនាព័ត៌មានផ្លូវការ (National News Bureau of Thailand ឬNNT) របស់ថៃ។ សារព័ត៌មាន NNT បន្ថែមថា មានខេត្តចំនួន៥ហើយ ដែលមានការបិទខ្ទប់ទាំងស្រុងឬដោយផ្នែក គិតត្រឹមថ្ងៃពុធនេះ ក្នុងនោះមាន សមុទ្រសាគរ សមុទ្រសង្គ្រាម សមុទ្រប្រាការ សុពណ៌បុរី និងឈាងម៉ៃ។ បណ្តាខេត្តកម្ពុជាជាប់ព្រំដែនថៃបានប្រុងជើងការតាំងតែពីថ្ងៃអាទិត្យចុងសប្តាហ៍កន្លងទៅ តាមបញ្ជារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យមានការឃាមកាមត្រៀមទទួលពលករកម្ពុជាដែលមកពីប្រទេសថៃ ដោយរៀបចំធ្វើតេស្តរកកូវីដ១៩ និងធ្វើចត្តាឡីស័កនៅទីដ្ឋានដែលរដ្ឋរៀបចំ។

លោក ហ៊ុន សែន បញ្ជាឱ្យចូលតាមច្រកព្រំដែនអន្តរជាតិចំនួន៣ប៉ុណ្ណោះគឺច្រកដូងក្នុងខេត្តបាត់ដំបង ច្រកប៉ោយប៉ែតក្នុងខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ក្នុងខេត្តឧត្តរមានជ័យ។

អភិបាលខេត្តបាត់ដំបងលោក ងួន រតនៈ ប្រាប់វីអូអេថាគិតត្រឹមថ្ងៃពុធនេះ មានពលករកម្ពុជាប្រមាណ ១៣០នាក់ហើយ ដែលវិលត្រឡប់មកកម្ពុជាតាមច្រកខេត្តបាត់ដំបង និងកំពុងស្ថិតក្នុងមណ្ឌលចត្តាឡីស័កក្នុងស្រុកកំរៀង។ លោកបន្ថែមថាក្នុងចំណោមនោះ ក៏មានពលករដែលមិនមានឯកសារផ្លូវច្បាប់តែលោកថាអាជ្ញាធរកម្ពុជាត្រូវតែទទួលពលរដ្ឋខ្លួនទោះក្នុងលក្ខខណ្ឌណាក៏ដោយ។ លោកថ្លែងថា៖ «យើងមានកម្លាំងចាំទទួលគាត់។ កាលណាគាត់មកខុសកន្លែង យើងនៅតែឱ្យមកអ៊ីចឹង យើងមិនអាចឃាត់ពលរដ្ឋខ្មែរយើងឱ្យនៅជីគេ កណ្តាលព្រៃនោះទេ មិនចឹង? យើងត្រូវតែយកហើយ គាត់ឆ្លងមកយ៉ាងម៉េច ក៏ត្រូវយកដែរ»។

លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យឱ្យដឹងថា មានពលករកម្ពុជាប្រមាណ៥០០នាក់ បានចូលមកពីថៃវិញ តាមច្រកអូរស្មាច់ នារយៈពេល៣ថ្ងៃកន្លងមក។ លោកឲ្យដឹងទៀតថា មណ្ឌលចត្តាឡីស័ករបស់ខេត្តដែលមានកម្រិត នឹងត្រូវរកជំនួយពីខេត្តក្បែរខាង និងខេត្តកំណើតរបស់ពលករសាមី ដើម្បីទទួលការដាក់ឱ្យនៅដាច់ដោយឡែកបានគ្រប់គ្រាន់។

ទាំងអភិបាលខេត្តបាត់ដំបង និងឧត្តរមានជ័យបញ្ជាក់ថា មិនទាន់មានពលករណាម្នាក់មានជំងឺកូវីដ១៩នោះទេ គិតត្រឹមរសៀលថ្ងៃពុធនេះ។ វីអូអេមិនទាន់ទាក់ទងអាជ្ញាធរខេត្តបន្ទាយមានជ័យបាននៅឡើយទេ។

# មេដឹកនាំថៃ លោក ប្រាយុទ្ធ ព្រមានចាត់វិធានការលើបណ្តាញឈ្មួញដែលនាំជនចំណាកស្រុកចូលប្រទេសខ្លួន ដោយគ្មានការអត់ឱន

http://nokorwatnews.com/ 23-12-2020

អន្តរជាតិ៖ ស្របពេលករណីឆ្លងកូវីដ-១៩ នៅក្នុងប្រទេសថៃ កំពុងតែកើនឡើង ជាពិសេសក្នុងចំណោមពលករចំណាកស្រុកខុសច្បាប់ មកពីប្រទេសមីយ៉ាន់ម៉ា បានធ្វើឲ្យនាយករដ្ឋមន្ត្រីថៃ លោក ប្រាយុទ្ធ ចន្ទអូចា នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ បានព្រមានចាត់វិធានការលើបណ្តាញឈ្មួញដែលនាំជនចំណាកស្រុកចូលប្រទេសរបស់ខ្លួន ដោយគ្មានការអត់ឱនអ្វីឡើយ។ បើទោះបីជាពួកគេមានខ្នងជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលក៏ដោយ។ នាយករដ្ឋមន្ត្រីថៃ លោក ប្រាយុទ្ធ ចន្ទអូចា ក្នុងសេចក្តីថ្លែងការណ៍ពិសេស ទៅកាន់ប្រជាជនថៃ បានលើកឡើងពីបញ្ហាជាច្រើនជុំវិញកូវីដ-១៩ ដែលបានរាតត្បាតទាំងនៅក្នុងប្រទេសថៃ និងនៅទូទាំងពិភពលោក។ ចំណុចដែលប្រមុខរដ្ឋាភិបាលផ្តោតខ្លាំងជាងគេ គឺបញ្ហាចំណាកស្រុកខុសច្បាប់ ដែលបង្កឲ្យកូវីដ-១៩ បានរាតត្បាតយ៉ាងខ្លាំង នៅក្នុងប្រទេសថៃ ជាពិសេសខេត្តសាមុតសាខន។

បើតាមការចុះផ្សាយរបស់កាសែតបាងកកប៉ុស្តិ៍ បាននិយាយថា លោក ប្រាយុទ្ធ បានព្រមានថា នឹងដាក់ទោស ដោយគ្មានការអត់ឱនលើអ្នកនាំជនចំណាកស្រុកខុសច្បាប់ ចូលមកក្នុងប្រទេស។ ប្រមុខរដ្ឋាភិបាលថៃសង្កត់ធ្ងន់ថា៖« ពួកគេ នឹងត្រូវកាត់ទោសដោយគ្មានការលើកលែងអ្វីទាំងអស់ មិនថាពួកគេមានខ្សែជាមួយមន្ត្រីក្នុងជួររដ្ឋាភិបាលក៏ដោយ»។ ជាមួយគ្នានេះ លោកនាយករដ្ឋមន្ត្រីថៃ ដោយបន្ទោសទៀតថាករណីឆ្លងកើតឡើង ដោយសារតែជនចំណាកស្រុកខុសច្បាប់ ចូលមកថៃ។ ក្រៅពីនេះ លោក ប្រាយុទ្ធ បានប្រកាសថា ថៃនឹងប្រុងប្រយ័ត្នជាងមុន ចំពោះអ្នកដែលបានចូលមកក្នុងប្រទេសថៃទាំងអស់ ដោយសារពេលនេះ កូវីដ-១៩ កំពុងតែរាតត្បាតខ្លាំង នៅក្នុងប្រទេសផ្សេង និងពិភពលោក។ សម្រាប់លោក ប្រាយុទ្ធ ប្រសិនបើមិនប្រយ័ត្នទេ វាអាចបង្កឲ្យប្រព័ន្ធសុខាភិបាលថៃ រងគ្រោះកាន់តែខ្លាំង ចំណែកសេដ្ឋកិច្ច អាចនឹងជួបផលវិបាកជាច្រើនទៀត។

សូមជម្រាបថា លោកនាយករដ្ឋមន្ត្រីថៃ ប្រសិនគ្មានការប្រែប្រួលទេ នឹងត្រូវប្រជុំជាមួយ មជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូវីដ-១៩ ថៃ(CCSA) ជុំវិញស្ថានការណ៍កូវីដ-១៩ នៅក្នុងប្រទេសបន្ថែមទៀត ដើម្បីដាក់ចេញវិធានការបន្ថែម ក៏ដូចជាចំណាត់ការមួយចំនួន ទាក់ទិននឹងការអបអរឆ្នាំថ្មី នាពេលខាងមុខ។ ជាក់ស្តែងនៅថ្ងៃទី២២ ខែធ្នូ គណៈរដ្ឋមន្ត្រីថៃ បានអនុម័ត លើសេចក្តីព្រាងធ្វើវិសោធនកម្មលើច្បាប់ ស្តីពីជំងឺឆ្លងផងដែរ។ វិសោធនកម្មច្បាប់នេះ មានចំណុចមួយចំនួន បានផ្តល់អំណាចដល់អាជ្ញាធរក្នុងការដាក់ទណ្ឌកម្ម និងពិន័យលើជនទាំងឡាយណា ដែលចម្លងវីរុសទៅអ្នកដទៃក៏ដូចជា អ្នកដែលចេញរោគសញ្ញា មិនទៅជួបគ្រូពេទ្យជាដើម។ សេចក្តីព្រាងនេះ ត្រូវដាក់ទៅសភាឲ្យអនុម័តបន្ថែមទៀត។

គួរបញ្ជាក់ថា រដ្ឋាភិបាលថៃ នៅថ្ងៃទី២២ ខែធ្នូ បានរកឃើញថា មានករណីឆ្លងថ្មីចំនួន ៤២៧ករណី ដែលភាគច្រើន គឺជាកម្មករចំណាកស្រុកមកពីមីយ៉ាន់ម៉ា។ ករណីឆ្លងសរុបរបស់ថៃ បានកើនដល់ ៥៧១៦ករណី និងអ្នកស្លាប់មានចំនួន ៦០នាក់។ ចំណែកអ្នកជាសះស្បើយមានចំនួន៤០៧៨នាក់៕ **ដោយៈស** តារា

# ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០២០

## ការចុះត្រួតពិនិត្យលើការអនុវត្តគម្រោងសាកល្បង បន្សាំផលប៉ះពាល់ជំងឺកូវីដ19 ដល់បងប្អូនពលករដែលត្រឡប់មកពីក្រៅប្រទេស

https://www.facebook.com/deputygovernoryousophear/ 25-12-2020

ខេត្តសៀមរាប៖ កិច្ចប្រជុំចុះពិនិត្យ គម្រោងលើកកំពស់ជីវភាពពលករចំណាកស្រុក អំឡុងពេលវិបត្តិជំងឺកូវីដ១៩ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ នៅឃុំចាន់សរ និងឃុំខ្នារពោធិ៍ ដឹកនាំដោយ លោកជំទាវ យូ សុភា អភិបាលរងខេត្ត និងជាប្រធានគម្រោង និងមានការអញ្ជើញចូលរួមពីបណ្តាមន្ទីរ អង្គភាពពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំចាន់ស និងភូមិ។ លទ្ធផលនៃការចុះត្រួតពិនិត្យ ដូចខាងក្រោម៖

១.ពង្រឹងការងារចត្តាឡីស័ករបស់បងប្អូនប្រជាពលរដ្ឋដែលវិលត្រឡប់មកពីក្រៅប្រទេស។ ផ្អាកសកម្មភាពពិធីនៃការជួបជុំនៅតាមមូលដ្ឋាន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល។

២.ឃុំ និងភូមិ ត្រៀមការងារចុះវាយតម្លៃលើកទី១ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ និងគាំទ្រគម្រោងអនុវត្តសាកល្បងឲ្យអនុវត្តទទួលបានជោគជ័យតាមការគ្រោងទុក។

៣.គម្រោងកសិកម្ម ចិញ្ចឹមមាន់ និងដាំបន្លែ សរុបចំនួន៣២គ្រួសារ គឺ ១៤គ្រួសារ បានធ្វើទ្រុង និទទួលពូជមាន់ និងបន្លែរួចរាល់ហើយ ចំណែក១៨គ្រួសារទៀត កំពុងសាងសង់ទ្រុង និងសួនបន្លែ។ចំពោះការចែកសម្ភារៈ និងការបណ្តុះបណ្តាលបច្ចេកទេសដាំដុះ និងចិញ្ចឹមមាន់ បានធ្វើរួចរាល់។

៤.មន្ទីរកិច្ចការនារី គឺបានបណ្តុះបណ្តាលមុខរបរទាំង០៥/ ១០គ្រួសារ រួមមាន បបរគ្រឿង នំចេកចៀន នំគ្រុស ដំណាប់អំបិល និងបង្អែមបាញ់ចានៀក ហើយព្រមទាំងបានដំណើរការដាក់លក់ជាបណ្តើរៗ។

៥.មុខរបរទឹកសណ្តែក ទឹកអំពៅ និងកាត់សក់ ចំនួន៦គ្រួសារ (ទទួលខុសត្រូវដោយមន្ទីរការងារ)បានដំណើរការដោយរលូននិងធ្វើលក់ដូរក៏ដូចជាបានទទួលផលជាបណ្តើរៗ ដោយក្នុងនោះគោលដៅកាត់សក់មួយគ្រួសារសាងសង់រោងមិនទាន់រួចបានមួយរយភាគរយ តែបានដំណើរកាត់សក់ជាបណ្តើរៗ។

៦.បានជំរុញដល់អាជ្ញាធរឃុំ និងភូមិ ពិនិត្យ និងចាត់ប្រជាការពារភូមិ ចុះជួយរៀបចំទ្រុង និងសួនបន្លែ ដល់គ្រួសារក្រីក្រ ឲ្យបានរួចរាល់ទាន់ពេលវេលា។

## ថ្ងៃនេះ មានពលករ១០២នាក់ ចេញពីថៃចូលកម្ពុជាតាមច្រកអូរស្មាច់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១៦:២០ អ.សួស្តី

រាជធានីភ្នំពេញ ៖ ប្រភពពីច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ បានឲ្យដឹងថា រហូតមកដល់ពេលនេះ ភាគីថៃនៅតែបន្តបិទព្រំដែនរបស់ខ្លួន នៅទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ការបិទច្រកនេះ ភាគីថៃបានលើកលែងទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន ។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន១០២នាក់ ស្រី ៥២នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក

នៅសាលាវិទ្យាល័យតេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។ ចំនួន១០២នាក់នេះ សមត្ថកិច្ចគិតត្រឹមម៉ោង១៥ក្នុងថ្ងៃទី២៤ ធ្នូនេះ ។ ចំណែកអាជ្ញាធរខេត្តឧត្តរមានជ័យបានឲ្យដឹងថា គិតត្រឹមថ្ងៃទី២៣ នេះ ពលករចំនួន៤០៣នាក់ បានចូលពីថៃតាមច្រកអូរស្មាច់នៅក្នុងនោះ ១៣១នាក់ ត្រូវបានយកសំណាកទៅធ្វើតេស្ដដោយសារពួកគាត់នៅជិតតំបន់ដែលមានផ្ទុះជំងឺកូវីដ១៩។ ចំណែកនៅក្នុងរយៈពេល ៣ថ្ងៃ គិតចាប់ពីថ្ងៃទី២១-២២-២៣ ខែធ្នូ ឆ្នាំ ២០២០ មានពលករខ្មែរមកពីប្រទេសថៃ ចំនួន ១៩៧ នាក់បានធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កនៅស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង ព្រមទាំងបានយកសំណាកទៅធ្វើតេស្តរកមេរោគកូវីដ-១៩ ផងដែរ ។

ក្នុងនោះពលករខ្មែរចំនួន ១៤៧ នាក់ បានធ្វើចត្តាឡីស័កក្នុងមណ្ឌលចត្តាឡីស័កទី១ ក្នុងវិទ្យាល័យកំរៀង ស្ថិតក្នុងឃុំអូរដា និងមណ្ឌល ចត្តាឡីស័កទី២ ក្នុងមណ្ឌលសុខភាពត្រាង ស្ថិតក្នុងឃុំត្រាងស្រុកកំរៀង និង ក្នុងស្រុកសំពៅលូន មានពលករ៥០នាក់ នៅមណ្ឌលចត្តាឡីស័កក្នុងមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន និងមណ្ឌលចត្តាឡីស័ក ក្នុងសាលាបឋមសិក្សា ហ៊ុន សែន ជ្រៃសីម៉ា ។

អាជ្ញាធរខេត្តបាត់បងបានឲ្យដឹងថា ក្នុងនោះដែរក៏មានពលករខ្មែរចំនួន២ នាក់ មកពីខេត្តសមុទ្រសាខន ប្រទេសថៃ ឆ្លងកាត់តាមច្រកអូរស្មាច់ ខេត្តបន្ទាយមានជ័យ ដែលមានទីលំនៅ នៅក្នុងស្រុកថ្មគោល ហើយបច្ចុប្បន្នត្រូវបានរដ្ឋបាលស្រុកថ្មគោល បានដាក់ឲ្យអ្នកទាំង២ធ្វើចត្តាឡីស័ក នៅក្នុងមន្ទីរពេទ្យបង្អែកស្រុកថ្មគោលផងដែរ៕

## ខេត្តបាត់ដំបងមានពលករខ្មែរមកពីថៃជាង២០០នាក់ហើយ ដែលបានធ្វើចត្តាឡីស័ក

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 24/12/2020

បាត់ដំបង ៖ មន្ត្រីសុខាភិបាលបាន ថ្លែងឲ្យដឹងថា នៅក្នុងរយៈពេល ៣ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២១ រហូតដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ នេះ នៅខេត្តបាត់ដំបង មានពលករចំណាកស្រុក វិលត្រឡប់មកពីប្រទេសថៃជាង ២០០នាក់ ហើយដែលបាននិងកំពុងធ្វើចត្តាឡីស័ក ១៤ ថ្ងៃ នៅច្រកទ្វារព្រំដែនអន្តរជាតិដូង ស្រុកកំរៀង ។

ប្រធានមន្ទីរសុខាភិបាលខេត្តលោកឱសថបណ្ឌិត រឿង ប៊ិនរ៉េត បានថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីរសៀលម្សិលមិញថា រយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី២១-២២ និងល្ងាចថ្ងៃទី ២៣ ខែធ្នូនេះ មន្ត្រីមណ្ឌលចត្តាឡីស័កប្រចាំស្រុកកំរៀង បានទទួលពិនិត្យ ពលករខ្មែរចំណាក ស្រុក ត្រឡប់មកពីប្រទេសថៃ កើនឡើងជាង ២០០ នាក់ ក្នុងនោះ ថ្ងៃទី២១ បានធ្វើចត្តា ឡីស័ក ចំនួន ៣៣ នាក់ (ស្រី ១៣នាក់) ។ ថ្ងៃទី២២ បានធ្វើចត្តាឡីស័ក ចំនួន ៧១ នាក់ (ស្រី ៣៥ នាក់) និងនៅល្ងាចថ្ងៃទី២៣ ខែធ្នូ បានធ្វើចត្តាឡីស័ក ជាង ១០០ នាក់ទៀត ហើយនាំ យកសំណាក ដើម្បីទៅពិនិត្យបន្តនៅវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ។ លោកបញ្ជាក់បន្ថែមថា ក្នុងចំណោមពលករចំណាកស្រុក ទាំងជាង ២០០ នាក់នេះ មានមកពីបណ្តាខេត្តនានា ដូចជាខេត្តបាត់ដំបង ត្បូងឃ្មុំ បន្ទាយមានជ័យ ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ និង សៀមរាប ។ល ៕

## ពលករខ្មែរមកពីប្រទេសថៃចំនួន ១៩៧ នាក់ បានធ្វើចត្តាឡីស័កនៅស្រុកកំរៀង និង ស្រុកសំពៅលូន ខេត្តបាត់ដំបង

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 24 ខែ ធ្នូ ឆ្នាំ 2020 វិទ្យុជាតិកម្ពុជា

បាត់ដំបង៖ ក្នុងរយៈពេល ៣ថ្ងៃ គិតចាប់ពី ថ្ងៃទី ២១ដល់ថ្ងៃ២៣ ខែធ្នូ ឆ្នាំ ២០២០ មានពលករខ្មែរមកពីប្រទេសថៃ ចំនួន ១៩៧ នាក់បានធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង ព្រមទាំងបានយកសំណាក ទៅធ្វើតេស្តរកមេរោគកូវីដ-១៩ផងដែរ។ ក្នុងនោះ ពលករខ្មែរចំនួន ១៤៧ នាក់

បានធ្វើចត្តាឡីស័កក្នុងមណ្ឌលចត្តាឡីស័កទី១ ក្នុងវិទ្យាល័យកំរៀង ស្ថិតក្នុងឃុំអូរដា និងមណ្ឌលចត្តាឡីស័កទី២ ក្នុងមណ្ឌលសុខភាពត្រាង ស្ថិតក្នុងឃុំត្រាង ស្រុកកំរៀង ហើយក្នុងស្រុកសំពៅលូន មានពលករ ៥០ នាក់ នៅមណ្ឌលចត្តាឡីស័ក ក្នុងមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន និងមណ្ឌលចត្តាឡីស័ក ក្នុងសាលាបឋមសិក្សា ហ៊ុន សែន ជ្រៃសីម៉ា ។

ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានជំរុញដល់ក្រុមការងារ គណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក ឱ្យជួយ ណែនាំដល់ពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ បើមិនមានកិច្ចការចាំបាច់ទេ សូមកុំមក ហើយបន្តធ្វើការងារ នៅទីនោះ រកប្រាក់ចំណូលសិន ចាំស្ងប់ព្រឹត្តិការណ៍សហគមន៍កូវីដ- ១៩ សិនចាំមក ។ ឯកឧត្តមបានដាក់ចេញនូវវិធានការមួយចំនួន ដល់រដ្ឋបាលស្រុកដែលនៅជាប់ព្រំដែនថៃ និងកម្លាំងសមត្ថកិច្ចជំនាញពាក់ព័ន្ធ ត្រូវមានវិធានការម៉ឺងម៉ាត់ ដោយមិនត្រូវលើកលែងឱ្យពលករណាម្នាក់ត្រឡប់ទៅគេហដ្ឋានឬភូមិស្រុកឡើយ ដោយត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ ថ្ងៃ និងត្រូវធ្វើតេស្តយកសំណាក ឱ្យបានត្រឹមត្រូវផងដែរ។ មិនតែប៉ុណ្ណោះ ត្រូវមានវិធានការណ៍ ជួយទប់ស្កាត់ពលករខ្មែរចំណាកស្រុក កុំឱ្យឆ្លងដែនខុសច្បាប់ ដោយត្រូវពិភាក្សាជាមួយភាគីថៃ ក្នុងការរៀបចំឱ្យពលករបានវិលត្រឡប់ចូលប្រទេសកម្ពុជាវិញតាមច្រកតែមួយ សម្រាប់ខេត្តបាត់ដំបង ដែលរដ្ឋបាលខេត្តបានកំណត់ ។

ការធ្វើបែបនេះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង រៀបចំឱ្យបងប្អូនពលករខ្មែរទាំងនោះបាន ធ្វើចត្តាឡីស័ក ដោយអនុវត្ត តាមវិធានការរបស់ក្រសួងសុខាភិបាល ដើម្បីការពារកុំឱ្យមេរោគកូវីដ-១៩ រីករាលដាលចូលក្នុងសហគមន៍ ដោយត្រូវអនុវត្ត ឱ្យបានម៉ឺងម៉ាត់តាមការណែនាំរបស់សម្ដេចតេជោ ហ៊ុន សែន និងអនុវត្តវិធានការណ៍បន្ថែមរបស់ក្រសួងសុខាភិបាលនូវ កុំ ៣ ÷ ១- កុំជុំគ្នា , ២- កុំនៅកន្លែងបិទជិត , ៣- កុំប៉ះពាល់គ្នា ( កុំចាប់ដៃគ្នា ) ។ មិនតែប៉ុណ្ណោះ អាជ្ញាធរខេត្តបាត់ដំបង ក៏បានរកឃើញនូវពលករ ចំណាកស្រុក ចំនួន ២ នាក់ ដែលបានមកពីខេត្តសាមុត សាខន ប្រទេសថៃ ឆ្លងកាត់តាមច្រកអូរស្មាច់ ខេត្តបន្ទាយមានជ័យ ដែលមានទីលំនៅ នៅក្នុងស្រុកថ្មគោល ហើយបច្ចុប្បន្ន ត្រូវបានរដ្ឋបាលស្រុកថ្មគោល ដាក់ឱ្យអ្នកទាំង ២ ធ្វើចត្តាឡីស័ក នៅក្នុងមន្ទីរពេទ្យបង្អែកស្រុកថ្មគោល ៕ កែវ ណារ៉េត មន្ទីរព័ត៌មានខេត្តបាត់ដំបង

## ឯកឧត្តម ងួន រតនៈ អញ្ជើញចុះសំណេះសំណាលជាមួយពលករ និងពិនិត្យទីតាំងចត្តាឡីស័ក ក្រុងបាត់ដំបង ដែលទទួលពលករមកពីច្រកព្រំដែនខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

https://www.battambang.gov.kh/ ថ្ងៃព្រហស្បតិ៍, 24 ខែធ្នូ, 2020ដោយ Sotheavy

នៅល្ងាចថ្ងៃព្រហស្បតិ៍ ១០ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្ត អញ្ជើញសំណេះសំណាលជាមួយពលករ និងពិនិត្យទីតាំងមណ្ឌលចត្តាឡីស័កក្រុងបាត់ដំបង (វិទ្យាល័យព្រះមុន្នីវង្ស) ដែលត្រូវទទួលពលករមកពីច្រកព្រំដែនខេត្តបន្ទាយមានជ័យ និងច្រកព្រំដែនខេត្តឧត្តរមានជ័យ ។ ក្នុងនោះក៏មានការអញ្ជើញចូលរួមពី លោក អភិបាលរង នៃគណៈអភិបាលខេត្ត លោក មន្ទីរ អង្គភាពមួយចំនួន លោក ស្នងការនគរបាលខេត្ត លោកមេបញ្ជាការកងរាជអាវុធខេត្ត លោក អភិបាលក្រុង និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។ ឯកឧត្តម ងួន រតនៈ ក៏បានសំណេះសំណាល និងណែនាំដល់បងប្អូនប្រជាពលករត្រូវចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងអនុវត្តវិធានការសុខាភិបាល ដើម្បីការពារការរីករាលដាលជំងឺកូវីដ ១៩ ដោយត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ ហើយកងកម្លាំង រួមជាមួយមន្ត្រីសុខាភិបាល និងធ្វើការយាមការ ដើម្បីធ្វើពិនិត្យសុខភាពជូនបងប្អូនពលកររបស់យើងផងដែរ។

សូមជម្រាបជូនដែរថា ពលករដែលវិលត្រឡប់ពីប្រទេសថៃតាមច្រកព្រំដែនខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ គិតម៉ោង៦ ល្ងាចនេះ នៅក្នុងមណ្ឌលចត្តាឡីស័កក្រុងបាត់ដំបង (វិទ្យាល័យព្រះមុន្នីវង្ស) មាន

ប្រមាណជាង ២០០ នាក់ និងនៅតាមមណ្ឌលចត្តាឡីស័កតាមស្រុកមួយចំនួនទៀតសរុបទូទាំងខេត្តប្រមាណជាង ៤០០ នាក់ផងដែរ។ គូសបញ្ជាក់ផងដែរថា ពលករដែលស្នាក់នៅក្នុងមណ្ឌលចត្តាឡីស័កតាមបណ្តាលក្រុង ស្រុក ទទួលបានឃីត ១កញ្ចប់ អាហារ ៣ពេល៕

## ស្ថានទូតខ្មែរប្រចាំនៅថៃប្រកាសលេខទូរសព្ទ Hotline សម្រាប់ឲ្យពលករខ្មែរទំនាក់ទំនង ពេលមានបញ្ហាខណៈថៃកំពុងផ្ទុះជំងឺកូវីដ

https://kampucheathmey.com/ December 24, 2020 By Kang Tola

ខណៈពេលដែលប្រទេសថៃ កំពុងមានការផ្ទុះជំងឺកូវីដ១៩នោះ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ បានណែនាំដល់ពលករខ្មែរទាំងអស់ ដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃត្រូវប្រញាប់ទំនាក់ទំនងមកកាន់ស្ថានទូត ឬ កុងស៊ុលនៅពេលមានបញ្ហាតាមរយៈលេខទូរសព្ទលេខ ០៩២៨០៥០៥៦១ និង ០៩៤០៩២៥៩០៥ និងលេខ Hotline របស់នាយកដ្ឋានគ្រប់គ្រងជំងឺឆ្លងសម្រាប់ពលករបរទេស១៤២២ ភ្ជាប់ទៅលេខ៨១សម្រាប់ភាសាខ្មែរ។ ការប្រកាសលេខទូរស័ព្ទនេះបន្ទាប់ពីប្រទេសថៃកំពុងមានផ្ទុះជំងឺកូវីដ១៩នៅខេត្តសាមុតសាខននិងកំពុងរាលដាល់នៅតាមបណ្តាខេត្តមួយចំនួនទៀត។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតខ្មែរប្រចាំប្រទេសថៃបានឲ្យដឹងថា ដើម្បីគ្រប់គ្រងនិងការពារមិនឲ្យមានការរីករាលដាលជំងឺកូវីដ១៩ ទៅលើពលករបរទេសទាំងអស់ដែលជាហេតុបង្កឲ្យមានផលប៉ះពាល់ដល់អាយុជីវិត និងសុខភាពអនាម័យរបស់ប្រជាពលរដ្ឋក្រសួងការងារថៃ បានស្នើឲ្យមានការកិច្ចសហការពីនិយោជករោងចក្រសហគ្រាសនិងក្រុមហ៊ុននានាគ្រប់ទីកន្លែងនៅក្នុងប្រទេសថៃ។ បើតាមសេចក្តីប្រកាសព័ត៌មានដដែលក្រសួងការងារថៃបានហាមចល័តពលករបរទេសចេញចូលតំបន់ ដែលមានការរីករាលដាលកូវីដ១៩ ហើយគ្រប់រោងចក្រសហគ្រាសត្រូវមានវិធានការ និងត្រួតពិនិត្យវាស់កំដៅដល់ពលករបរទេស បើមានកំដៅលើស ឬមានអាការៈខុសប្រក្រតីផ្សេងៗ ដូចជាក្អកពិបាកដកដង្ហើមគួរឱ្យពលករនោះសម្រាកពីការងារនឹងប្រញាប់រួសរាន់ជូនដំណឹងដល់ទីភ្នាក់ងារសុខាភិបាលដើម្បីអនុវត្តវិធានការចត្តាឡីស័កភ្លាម។ លើសពីនេះ ត្រូវរៀបចំអាកុលសម្រាប់លាងដៃនៅតាមកន្លែងធ្វើការច្រកទ្វារចេញចូលនិងតាមបន្ទប់ទឹកនិងតម្រូវឲ្យពលករបរទេសពាក់ម៉ាសពាក់ស្រោមដៃនឹងរក្សាគំលាតពីមួយម៉ែត្រទៅពីរម៉ែត្រក្នុងកំឡុងពេលបំពេញការងារព្រមទាំងថៃរក្សា និងសំអាតឧបករណ៍ដែលបានប្រើប្រាស់ជាប្រចាំ និងផ្សព្វផ្សាយ និងពន្យល់ណែនាំពលករបរទេសឲ្យយល់ដឹងពីវិធីការពារខ្លួនពីជំងឺកូវីដ១៩ដោយខ្លួនឯង។

ស្ថានទូតខ្មែរប្រចាំនៅថៃ អំពាវនាវដល់បងប្អូនពលករខ្មែរនៅប្រទេសថៃទាំងអស់ មេត្តាចូលរួមសហការនិងអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាលថៃឲ្យបានខ្ជាប់ខ្ជួនមានប្រសិទ្ធភាពខ្ពស់ និងសូមរក្សាសុខភាពអនាម័យដើម្បីបង្ការនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ ស្ថានទូតបានបន្តថា ក្នុងករណីបងប្អូនមានបញ្ហាសូមទំនាក់ទំនងមកកាន់ស្ថានទូត ឬ កុងស៊ុលតាមរយៈលេខទូរសព្ទ០៩២៨០ ៥០៥៦១ និង០៩៤០៩២៥៩០៥ និងលេខ Hotline របស់នាយកដ្ឋានគ្រប់គ្រងជំងឺឆ្លងសម្រាប់ពលករបរទេស១៤២២ ភ្ជាប់ទៅលេខ៨១ សម្រាប់ភាសាខ្មែរ៕ ដោយ ៖ សំអឿន

## ថៃចាប់ពលករខ្មែរ ចំនួន ៥២ នាក់ ដែលបានលបបោះជំរំនៅក្នុងព្រៃ

https://kampucheathmey.com/local-news/ December 25, 2020 By Bo Do

ពលករខ្មែរប្រុស ស្រី រួមទាំងក្មេងតូចៗ សរុបចំនួន ៥២ នាក់ ត្រូវបានកម្លាំងយោធា ការពារព្រំដែនថៃលេខ ១២១ សហការជាមួយតម្រួតនៅក្នុងតំបន់ ព្រមទាំងកម្លាំងអន្តោប្រវេសន៍ខេត្ត ស្រះកែវ ឃាត់ខ្លួនដើម្បី

សាកសួរ បន្ទាប់ពីទទួលបានសេចក្តីរាយការណ៍ថា ពលករខ្មែរទាំងអស់នេះ បានលបឆ្លងដែនតាមច្រករបៀង ចូលទៅក្នុងទឹកដីថៃ ដោយគ្មានច្បាប់អនុញ្ញាត ហើយបាននាំគ្នាបោះជំរំនៅក្នុងព្រៃក្បែរខ្សែបន្ទាត់ព្រំដែន ។ ការឃាត់ខ្លួនពលករខ្មែរទាំងនេះ បានធ្វើឡើងកាលពីយប់ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២០ ដោយមានការបញ្ជាផ្ទាល់ពីថ្នាក់ដឹកនាំតម្រួតខេត្ត គឺលោក អម្រឹត បុណ្យសុយ៉ា ក្នុងគោលបំណងអនុវត្តតាមបទបញ្ជារបស់រដ្ឋាភិបាល ក្នុងការការពារ និងទប់ស្កាត់ការរីករាលដាល នៃមេរោគ កូវីដ-១៩ ដែលកំពុងឃាយឃីខ្លាំងនៅក្នុងប្រទេសថៃ ដោយកម្លាំងសហការទាំងនេះ បានចេញប្រតិបត្តិការទៅកាន់ចំណុចភូមិ១៤ ឃុំណងមួយ ស្រុកគោកខ្សូង ខេត្តស្រះកែវ ដើម្បីពិនិត្យមើល ។ ជាក់ស្តែងនៅពេលកម្លាំងចម្រុះចុះទៅដល់ព្រៃ ដែលជាតំបន់ឧទ្យានជាតិ ប៉ាសួន ក៏បានប្រទះឃើញពលករខ្មែរជាច្រើននាក់ បានបោះជំរំ និងបានសាងសង់ផ្ទះតូចៗ ស្ទើរក្លាយជាកូនភូមិមួយទៅហើយ គឺសរុបមានចំនួន ៥២ នាក់ ក្នុងនោះស្រី ២៤ ប្រុស ២១ និងក្មេងតូចៗ ចំនួន ៧ នាក់ ហើយភ្លាមៗនោះដែរ ក្រុមមន្ត្រីសុខាភិបាលស្រុក បានចុះពិនិត្យ និងវាស់កម្ដៅ តែគ្មាននរណាម្នាក់ មានកម្ដៅខ្ពស់គួរឱ្យព្រួយបារម្ភឡើយ ។

បន្ទាប់ពីបានសាកសួរ ពួកគេបានសារភាពថា គឺមកពីខេត្តសៀមរាបទាំងអស់គ្នា ដោយបានលបឆ្លងដែនចូលតាមច្រករបៀង ព្រមទាំងបានតែងតាំងមនុស្សម្នាក់ដែលជាពលករខ្មែរដូចគ្នាឱ្យធ្វើជាអ្នកគ្រប់គ្រង និងជាអ្នកចាត់ចែងបញ្ជូនពួកគេចូលទៅធ្វើការការងារកសិកម្ម នៅក្នុងស្រុកគោកខ្សូង និងស្រុកក្បែខាង ដោយបានកម្រៃក្នុង ១ ថ្ងៃ ចាប់ពី ២០០ ទៅ ៣០០ បាត ក្នុងមនុស្សម្នាក់ ដោយមិនចាំបាច់ត្រូវធ្វើដំណើរទៅកាន់ទីក្រុងបាងកកឡើយ ។ បច្ចុប្បន្នពលករខ្មែរទាំងនេះ ត្រូវបានអាជ្ញាធរនៅក្នុងតំបន់ ប្រគល់ទៅឱ្យកម្លាំងការិយាល័យ អន្តោប្រវេសន៍ ខេត្តស្រះកែវ ដើម្បីអនុវត្តតាមនីតិវិធី ៕ **អត្ថបទ ៖ សោ និយមវ័ត្ន**

## ពលករខ្មែរប្រមាណជិត១០០០នាក់ ត្រូវបានអាជ្ញាធរថៃដាក់បម្រាមមិនឲ្យចាកចេញពីខេត្តខនកេន

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 24/12/2020 - 07:58

ពលករចំណាកស្រុកខ្មែរកំពុងធ្វើការនៅប្រទេសថៃ ប្រមាណជាង១០០០នាក់ ត្រូវបានអាជ្ញាធរថៃហាមមិនឲ្យចាកចេញពីខេត្តខនកេន ទៅកាន់ខេត្តណាមួយផ្សេងឡើយ។ ការហាមឃាត់នេះ គឺដើម្បីទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ១៩ ដែលកំពុងផ្ទុះជាសហគមន៍និងរាលដាលដល់២៥ខេត្តនៅប្រទេសថៃ។ នេះបើយោងតាមកាសែតបាងកកប៉ុស្ដ៍ ចេញផ្សាយនៅថ្ងៃទី២៣ធ្នូម្សិលមិញ។ ពលករខ្មែរចំនួន ៨៣៨នាក់ ក្នុងចំណោមពលករដែលបានចុះឈ្មោះធ្វើការដោយស្របច្បាប់សរុប៧១៤០នាក់នឹងត្រូវដាក់បម្រាមមិនឲ្យចាកចេញពីខេត្តខនកេនពីសំណាក់អាជ្ញាធរថៃ បន្ទាប់ពីមានករណីផ្ទុះកូវីដ១៩ក្នុងសហគមន៍នៅខេត្តសាមុតសាខន ចម្ងាយ៤០០គីឡូម៉ែតពីខេត្តខនកេន។ ក្នុងចំណោមពលករទាំងអស់ ពលករចំណាកស្រុករបស់ប្រទេសមីយ៉ាន់ម៉ា មានចំនួន ៣៨៣៤នាក់ និងពលករឡាវ ២៤៦៨នាក់ ក៏កំពុងធ្វើការនៅខេត្តខនកេនដែរ។ នេះបើតាមការបញ្ជាក់របស់លោកស្រី Penwadee Rattakul ប្រធានផ្នែកការងារប្រចាំខេត្តខនកេន។

លោកស្រី Penwadee Rattakul បន្ថែមថា ការដាក់បម្រាមមិនឲ្យធ្វើការចល័តចេញពីខេត្តខនកេន គឺដើម្បីធានាបាននូវការទប់ស្កាត់ការរាលដាលជំងឺកូវីដ១៩ជាបន្តបន្ទាប់នៅក្នុងសហគមន៍ និងដើម្បីធានាបាននូវសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ ក្រៅពីការហាមឃាត់មិនឲ្យមានការចល័តពលករចេញពីខេត្តមួយទៅខេត្តមួយនេះ អាជ្ញាធរថៃក៏បានហាមដាច់ខាតមិនឲ្យថៅកែរោងចក្រក្នុងខេត្តខនកេន ធ្វើការជួលពលករមកធ្វើការដោយខុសច្បាប់ ព្រោះថាវាជាការប្រឈមនឹងហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺកូវីដ១៩។ នេះបើយោងតាមបាងកកប៉ុស្ដ៍។

អាជ្ញាធរថៃក៏បាននិងកំពុងធ្វើការយ៉ាងជិតដិតជាមួយក្រុមពលករ ដើម្បីធ្វើយ៉ាងណាឲ្យស្ថានការណ៍ជំងឺកូវីដ១៩ អាចគ្រប់គ្រងបាន ហើយសម្រាប់យន្តការបន្ត អាជ្ញាធរថៃនឹងបញ្ជូនមន្ត្រីជំនាញទៅធ្វើការត្រួតពិនិត្យចំពោះសហគ្រាសតូចៗ និងការដ្ឋានសំណង់នានា ដើម្បីឲ្យពួកគេចូលរួមទប់ស្កាត់ការចម្លង។ នេះបើតាមប្រធានផ្នែកការងារប្រចាំខេត្តខនកេន លោកស្រី Penwadee Rattakul។

សូមជម្រាបជូន ចាប់តាំងពីការផ្ទុះជំងឺកូវីដ១៩ជាសហគមន៍ នៅឯផ្សារលក់បង្គា ឈ្មោះថា Mahachai នៅឯខេត្តសាមុតសាខន កាលពីថ្ងៃទី១៧ធ្នូមក ខេត្តចំនួន២៥ផ្សេងទៀត ក៏ដូចជាខេត្តខនកេន កំពុងស្ថិតនៅក្នុងស្ថានភាពប្រកាសអាសន្ននៃការរាតត្បាតជំងឺកូវីដ១៩ពីហេតុការណ៍នេះ។ តែយ៉ាងណាខេត្តខនកេន មិនទាន់រកឃើញករណីវិជ្ជមានពីហេតុការណ៍សហគមន៍នៅប្រទេសថៃនេះនៅឡើយទេ ក្រៅពីមួយករណីវិជ្ជមានដែលរកឃើញកាលពីថ្ងៃទី១៧មីនាកន្លងទៅ។ នេះបើតាមកាសែតអនឡាញក្នុងស្រុករបស់ថៃ The Nation។ សូមសរុបជូនថា គិតមកដល់ថ្ងៃទី២៤ធ្នូ ករណីវិជ្ជមានកូវីដ១៩នៅប្រទេសថៃមានចំនួន ៥៧៦២នាក់ ស្លាប់ ៦០នាក់ និងព្យាបាលជាសះស្បើយចំនួន ៤០៩៥នាក់។ លោកវេជ្ជបណ្ឌិត Taweesilp Visanuyothin អ្នកនាំពាក្យមជ្ឈមណ្ឌលសម្រាប់ស្ថានភាពកូវីដ១៩ថៃ ថ្លែងថា ក្រៅពីហេតុការណ៍សហគមន៍នៅខេត្តសាមុតសាខនពីថ្ងៃទី១៧ធ្នូមក អាជ្ញាធរថៃបានរកឃើញករណីវិជ្ជមានកូវីដ១៩ថ្មី ចំនួន៣៩នាក់ នៅឯខេត្តផ្សេងៗទៀត៕

## មេទ័ពថៃ ប្រាប់កម្ពុជា ឲ្យជឿជាក់លើអាជ្ញាធរថៃ ក្នុងការទប់ស្កាត់កូវីដ-១៩

https://thmeythmey.com/ 24, Dec 2020 ,  10:29 pm  ដោយ: សារព័ត៌មានថ្មីៗ

នាយឧត្តមសេនីយ៍ ចាឡឺមពល ស្រ៊ីសាវ៉ាត (Chalermpol Srisawasdi) អគ្គមេបញ្ជាការកងទ័ពភូមិន្ទថៃ អះអាងថា មកដល់ពេលនេះ ថៃមានវិធានការតឹងរ៉ឹង ក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ មិនឲ្យឆ្លងទៅដល់ពលករកម្ពុជាឡើយ ដូច្នេះលោក ប្រាប់ឲ្យភាគីកម្ពុជា មានការជឿជាក់លើវិធានការរបស់អាជ្ញាធរថៃ ក្នុងការទប់ស្កាត់ជំងឺរាតត្បាតនេះ។ ការអះអាងរបស់នាយឧត្តមសេនីយ៍ ចាឡឺមពល ស្រ៊ីសាវ៉ាត ធ្វើឡើងក្នុងជំនួបជាមួយនាយឧត្តមសេនីយ៍ វង្ស ពិសេន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទកម្ពុជា តាមប្រព័ន្ធវីដេអូ កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ហើយត្រូវបានដកស្រង់ទៅចុះផ្សាយក្នុងគេហទំព័រនៃក្រសួងការពារជាតិកម្ពុជា។ មេទ័ពថៃ ថ្លែងទៅកាន់មេទ័ពកម្ពុជាថា ក្នុងករណីមានអ្នកឆ្លងជំងឺកូវីដ-១៩ អាជ្ញាធរថៃ នឹងដាក់ឲ្យនៅដាច់ដោយឡែក ដើម្បីការពារសុវត្ថិភាពក្នុងប្រទេសថៃ។ ក្រសួងការពារជាតិកម្ពុជា បានសរសេរពីសម្ដីរបស់មេទ័ពថៃរូបនេះយ៉ាងដូច្នេះថា៖«...ប្រទេសថៃ បានកត់សម្គាល់ដល់ការធ្វើដំណើរឆ្លងដែនរវាងប្រទេសទាំងពីរ ក្នុងនោះភាគីថៃ បានជួយសម្រួលឲ្យពលរដ្ឋកម្ពុជា ចូលមកព្យាបាលជំងឺ បើទោះជាមានការបិទព្រំដែនក៏ដោយ»។

នាយឧត្តមសេនីយ៍ វង្ស ពិសេន បានថ្លែងអំណរគុណដល់ភាគីថៃ ដែលនៅតែជួយសម្រួលឲ្យពលរដ្ឋកម្ពុជាបានឆ្លងដែនចូលទៅព្យាបាលជំងឺ និងនៅតែទទួលយកពលករស្របច្បាប់របស់កម្ពុជា ឲ្យទៅបំពេញការងារនៅប្រទេសថៃវិញ បើទោះបីថៃ កំពុងស្ថិតក្នុងស្ថានភាពនៃការឆ្លងជំងឺកូវីដ-១៩ក្ដី។ ក្រសួងការពារជាតិកម្ពុជា បានស្រង់សម្ដីរបស់មេទ័ពកម្ពុជារូបនេះ ទៅផ្សាយដូច្នេះថា៖«កងទ័ពប្រទេសទាំងពីរ នឹងបន្តសហការគ្នាយ៉ាងជិតស្និទ្ធក្នុងការផ្លាស់ប្ដូរព័ត៌មានចារកិច្ច និង ពង្រីកកិច្ចសហប្រតិបត្តិការ និងធ្វើលំហាត់សមយុទ្ធរួមគ្នាឲ្យកាន់តែទូលំទូលាយថែមទៀត ពិសេសលំហាត់ទាក់ទងទៅនឹងបញ្ហាសន្តិសុខ និងសង្គ្រោះគ្រោះមហន្តរាយ»។

កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ ខេត្តសាមុត សាខន នៃប្រទេសថៃ បានផ្ទុះការឆ្លងជំងឺកូវីដ-១៩ ជាង ៥០០ករណី។ បន្ទាប់មក រដ្ឋាភិបាលថៃ បានសម្រេចបិទខេត្តសាមុត សាខន រយៈពេលកន្លះខែ ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣ ខែមករា ឆ្នាំ២០២១។ ខេត្តនេះ ស្ថិតនៅចម្ងាយប្រមាណ៣០០គីឡូម៉ែត្រពីកម្ពុជា។

កាសែតបាងកកប៉ុស្ដិ៍របស់ថៃ ចុះផ្សាយថា មកដល់ពេលនេះ ករណីផ្ទុះជំងឺកូវីដ-១៩ ក្នុងខេត្តសាមុត សាខន បានរាលដល់ទៅដល់២២ខេត្តហើយ ក្នុងប្រទេសថៃ។ បើតាមគេហទំព័រ worldometers គិតត្រឹមថ្ងៃទី២៤ ខែធ្នូនេះ ថៃ មានអ្នកជំងឺកូវីដ-១៩ ជិត៦ពាន់នាក់ (៥៨២៩នាក់) ដោយក្នុងនោះ បានជាសះស្បើយវិញជាង៤ពាន់នាក់ (៤១១៦នាក់) និង ស្លាប់៦០នាក់។

ក្រោយថៃមានករណីផ្ទុះជំងឺកូវីដ-១៩ ក្នុងខេត្តសាមុត សាខន សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញមុខអំពាវនាវដល់ពលករខ្មែរនៅថៃ ឲ្យទុកចិត្តលើរដ្ឋាភិបាលថៃ ក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ ដ្បិតថៃ ធ្លាប់មានបទពិសោធក្នុងការគ្រប់គ្រងបានល្អ លើការរាលជំងឺនេះរួចមកហើយ។ តាមរយៈសារជាសំឡេង ដែលបង្ហោះលើទំព័រហ្វេសប៊ុកផ្លូវការរបស់ខ្លួន មេដឹកនាំកម្ពុជា ប្រាប់ទៅពលករខ្មែរដូច្នេះថា៖«មិនគួររត់ចាកចេញពីប្រទេសថៃ ក្នុងពេលដែលថៃ មានការលំបាក ដូចដែលខ្ញុំព្រះករុណា ខ្ញុំ ធ្លាប់បាននិយាយហើយថា ស្រឡាញ់គ្នា ក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុងគ្រាលំបាក»។ ទន្ទឹមនេះ ប្រមុខរដ្ឋាភិបាល បានណែនាំទៅអាជ្ញាធរកម្ពុជា ឲ្យពិភាក្សាជាមួយអាជ្ញាធរថៃ ក្នុងការបិទច្រកព្រំដែននានាជាបណ្ដោះអាសន្នសិន ដើម្បីការពារការរាលជំងឺកូវីដ-១៩ ដោយទុកតែ៣ប៉ុណ្ណោះ គឺច្រកព្រំដែនប៉ោយប៉ែត ច្រកព្រំដែនដូង និង ច្រកព្រំដែនអូរស្មាច់។ នៅកម្ពុជា មកដល់ថ្ងៃទី២៤ ខែធ្នូនេះ ក្រសួងសុខាភិបាល រកឃើញអ្នកជំងឺកូវីដ-១៩ ៣៦៣នាក់ តែបានជាសះស្បើយវិញ៣៥១នាក់ហើយ៕

## អាជ្ញាធរថៃ ឃាត់ខ្លួនពលករឡាវ ៣២នាក់ ពីបទឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ ខណៈថៃកំពុងផ្ទុះកូវីដ-១៩ខ្លាំង

http://nokorwatnews.com/ 24-12-2020

អន្តរជាតិ៖ បើយោងតាមការចុះផ្សាយសារព័ត៌មាន បាងកកប៉ុស្ដិ៍ បាននិយាយថា អាជ្ញាធរថៃ បានចាប់ឃាត់ខ្លួនពលករឡាវ ចំនួន៣២នាក់ ពីបទឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ កាលពីព្រឹកព្រលឹមថ្ងៃអង្គារ ទី២២ ខែធ្នូ ថ្មីៗនេះ ខណៈថៃកំពុងផ្ទុះកូវីដ១៩ខ្លាំង។ សារព័ត៌មាន បាងកកប៉ុស្ដិ៍ បានបន្តទៀតថា ខណៈពលរដ្ឋឡាវទាំង ៣២នាក់នេះ បានធ្វើដំណើរមកពីប្រទេសម៉ាឡេស៊ី ដោយពួកគេបានជិះរថយន្តក្រុងអស់រយៈពេល ២ម៉ោង ទើបមកដល់ចំណុចព្រំដែនម៉ាឡេស៊ី–ថៃ។ បន្ទាប់មកទៀតពួកគេបានជិះទូកកាត់ទន្លេ Sungai Kolok ហើយបានមកដល់ទឹកដីថៃនៅវេលាម៉ោង ៤ព្រឹក និងបន្តដំណើរដោយថ្មើរជើង ២គីឡូម៉ែត្រទៀតចូលនៅក្នុងសហគមន៍មួយ ដែលមានប្រជាពលរដ្ឋថៃរស់នៅដើម្បីសុំជំនួយ។

សូមជម្រាបដែរថា ពលរដ្ឋឡាវទាំងនេះ គឺធ្លាប់ធ្វើការជាកម្មករនេសាទសមុទ្រនៅក្នុងប្រទេសម៉ាឡេស៊ី និងមានបំណងចង់ត្រលប់ទៅស្រុកកំណើតវិញហើយដោយពួកគេមិនអាចសុំឈប់ពីកន្លែងធ្វើការងារ និងត្រលប់ទៅប្រទេសកំណើតដោយត្រឹមត្រូវនោះទេ។ ទើបពួកគេសម្រេចប្រថុយឆ្លងដែនដោយខុសច្បាប់តាមប្រទេសថៃតែម្ដង។ ប៉ុន្ដែបើទោះជាយ៉ាងណា អាជ្ញាធរថៃ ចាំបាច់ត្រូវអនុវត្តច្បាប់ចំពោះពួកគេជាមុនសិន គឺចាប់ខ្លួនពីបទឆ្លងដែនដោយខុសច្បាប់ មុននឹងទំនាក់ទំនងទៅកាន់រដ្ឋាភិបាលឡាវ ឬស្ថានទូតឡាវប្រចាំនៅប្រទេសថៃ ដើម្បីធ្វើអន្តរាគមន៍ចំពោះពួកគេ៕

# ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០២០

## ប្រធានព្រឹទ្ធសភាកម្ពុជា ស្នើឱ្យកូរ៉េខាងត្បូងបង្កើនចំនួនកូតាសម្រាប់ពលករខ្មែរបន្ថែមទៀត ដើម្បីអាចទៅបំពេញការងារនៅទីនោះបានកាន់តែច្រើន

https://business.khmernote.com.kh/ December 26, 2020 Khmernote

ប្រធានព្រឹទ្ធសភាកម្ពុជា ស្នើឱ្យសាធារណរដ្ឋកូរ៉េបង្កើនចំនួនកូតាសម្រាប់ពលករខ្មែរបន្ថែមទៀត ដើម្បីលើកកម្ពស់ជីវភាពក្នុងគ្រួសារ និងកាត់បន្ថយភាពក្រីក្ររបស់បងប្អូនពលករ។ ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តម ប៉ាក ហឹងយ៉ុង ( Park Heung-Kyeong ) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភាបានមានប្រសាសន៍ថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមឯកអគ្គរដ្ឋទូត បានជួយ សម្របសម្រួលក្នុងការបង្កើនចំនួនកូតាសម្រាប់ពលករកម្ពុជាបន្ថែមទៀត ដើម្បីអាចទៅបំពេញការងារនៅប្រទេសកូរ៉េបានកាន់តែច្រើន។ សម្តេចសេនាភក្តីបានបញ្ជាក់ថា ពលករដែលបានទៅធ្វើការនៅកូរ៉េខាងត្បូង គឺបានរួមចំណែកដ៏សំខាន់ដល់ការលើកកម្ពស់ ជីវភាពរស់នៅរបស់ក្រុមគ្រួសាររបស់ពួកគេ និងជួយលើកកម្ពស់សេដ្ឋកិច្ចកម្ពុជាផងដែរ។ សម្តេចប្រធានព្រឹទ្ធសភាក៏បានថ្លែងអំណរគុណរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានយកចិត្តទុកដាក់ ចំពោះពលករកម្ពុជា ដែលបច្ចុប្បន្នកំពុងបំពេញការងារនៅកូរ៉េ។

ជាមួយគ្នានេះ សម្តេចប្រធានព្រឹទ្ធសភាក៏បានស្នើឯកឧត្តមឯកអគ្គរដ្ឋទូតជួយចលនា និងលើកទឹកចិត្តអ្នកវិនិយោគនិង អ្នកទេសចរកូរ៉េ មកបណ្តាក់ទុនវិនិយោគនិងធ្វើទេសចរណ៍ឱ្យកាន់តែច្រើនបន្ថែមទៀតនៅកម្ពុជាផងដែរ។ ឯកឧត្តម ប៉ាក ហឹងយ៉ុង បានសម្តែងនូវសេចក្តីរីករាយដោយឃើញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ មានការរីកចម្រើនជាលំដាប់ ជាពិសេសក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងការផ្លាស់ប្តូររវាងប្រជាជននៃប្រទេសទាំងពីរ។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានកត់សម្គាល់ថា ទំនាក់ទំនង និងទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ បានឡើងដល់ចំនួន ០១កោដិ ដុល្លារ នៅឆ្នាំ២០១៩ ហើយក្នុងនោះទំហំនៃការវិនិយោគរបស់សាធារណៈកូរ៉េនៅកម្ពុជា ស្ថិតក្នុងលំដាប់ទីពីរ ដែលមាន ទឹកប្រាក់ ចំនួន ៥,៧ ប៊ីលានដុល្លារ។

ជាមួយគ្នានេះតាមរយៈការផ្លាស់ប្តូររវាងប្រជាជននៃប្រទេសទាំងពីរ អ្នកទេសចរកូរ៉េបានមកទស្សនាកម្ពុជាមានជាង ៤សែននាក់ ជារៀងរាល់ឆ្នាំ។ ចំណែកឯពលករកម្ពុជាទៅធ្វើការនៅសាធារណៈរដ្ឋកូរ៉េមានចំនួន៤ម៉ឺននាក់ ហើយបើទោះបីជាឆ្នាំនេះ មានការផ្ទុះការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏សាធារណៈរដ្ឋកូរ៉េនៅតែបន្តទទួលយកពលករកម្ពុជាមកធ្វើការនៅសាធារណកូរ៉េដដែល។ ចំណែកការចរចាអំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងប្រទេសទាំងពីរ ត្រូវបានរៀបចំយ៉ាងយកចិត្តទុក ក្នុងឆ្នាំ២០២០នេះ ហើយសាធារណៈកូរ៉េបានផ្តល់សច្ចាប័នទៅលើច្បាប់ស្តីពីការមិនយកពន្ធត្រួតគ្នា លើការផ្លាស់ប្តូរ ពាណិជ្ជកម្មរវាងប្រទេសទាំងពីររួចហើយ។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានគូសបញ្ជាក់ថា ឯកឧត្តមផ្ទាល់នឹងខិតខំឱ្យអស់ពីកម្លាំងកាយចិត្តដើម្បីពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរឱ្យកាន់តែខ្លាំងក្លាថែមទៀត៕

## **ឃុំខ្លួនជនសង្ស័យម្នាក់ជាមេខ្យល់ លួចនាំមនុស្ស ឆ្លងដែនចូលទៅក្នុងប្រទេសថៃដើម្បីចំណាកស្រុកធ្វើ ការងារ ដោយទទួលលុយចំនួន 1500បាត**

https://www.cen.com.kh/ December 26, 2020

ខេត្តឧត្តរមានជ័យ៖ លោក វ៉េង ហិត់ ចៅក្រមស៊ើបសួរ ចេញដីការបង្គាប់ឲ្យឃុំខ្លួនជនសង្ស័យម្នាក់ជាមេខ្យល់ ជាបណ្តោះអាសន្ននៅពន្ធនាគារខេត្ត ដោយចោទពីបទ ការនាំយកចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

តាមបញ្ជារបស់ ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និង តាមការចង្អុលបង្ហាញ ដឹកនាំផ្ទាល់ពី សំណាក់ ឯកឧត្តមនាយឧត្តមសេនីយ៍ ខេង សុមេធ អគ្គស្នងការរងនគរបាលជាតិ និងជា មេបញ្ជាការប្រចាំទិសភូមិភាគ 4 និង 5 ដែលបាន ដាស់តឿន ក្រើនរំលឹកជាប្រចាំ ដល់កងកម្លាំងនគរបាលការពារព្រំដែនគោកតាមខ្សែបន្ទាត់ព្រំដែន ឲ្យយកចិត្តទុកដាក់ រឹតបន្តឹងការចេញចូលខុសច្បាប់តាមច្រករបៀង ដើម្បីទប់ស្កាត់ការរាលដាលជំងឺកូវីដ19ពីប្រទេសថៃ។ នៅយប់ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៩-២០នាទី កម្លាំងនគរបាលការពារព្រំដែនគោកលេខ702 របស់ ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យដែលល្បាតនៅចំណុចច្រករបៀងអូរខ្លាឃ្មុំ ស្ថិតនៅភូមិអូរខ្លាឃ្មុំ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យប បានបង្ក្រាបករណី នាំមនុស្សឆ្លងដែនខុសច្បាប់ 01 ករណី ដែលបង្កឡើងដោយមេខ្យល់ ឈ្មោះ ទ្រី យុន ភេទប្រុស អាយុ ២៩ ឆ្នាំ មានទីលំនៅភូមិគិរីមង្គល សង្កាត់អូរស្មាច់ ក្រុងសំរោង បានធ្វើសកម្មភាពនាំជនរងគ្រោះឈ្មោះ រ៉ន វល័ក្ខ ភេទស្រីអាយុ ៣០ឆ្នាំ មានទីលំនៅភូមិពង្រ ឃុំពង្រ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ លួច ឆ្លងដែនចូលទៅក្នុងប្រទេសថៃដើម្បីចំណាកស្រុកធ្វើ ការងារ ដោយទទួលលុយចំនួន 1500បាត ។

បច្ចុប្បន្ននេះ កម្លាំងរបស់ស្នងការដ្ឋាននគរបាលខេត្តបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ហើយ ត្រូវបានលោក វ៉េង ហិត់ ចៅក្រមស៊ើបសួរចេញ ដីការបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្ត ដោយចោទពីបទ ការនាំយកចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន៕ **រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ**

## **ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប ថា មានប្រជាពលករខ្មែរចំនួន ២៤នាក់វិលមកពីប្រទេសថៃ !**

https://www.facebook.com/tvkchannel7/ 26-12-2020

គិតត្រឹមល្ងាចម៉ោង៦.០០នាទីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ម្សិលមិញ ក្រុមការងារខេត្តខេត្តទទួលបានពលករចំនួន ២៤នាក់ ស្រី១២នាក់ និងកុមារាម្នាក់ ។ លោកស្រី យូ សុភា អភិបាលរងខេត្តទទួលបន្ទុកផ្នែកការងារនេះ បានឲ្យដឹងថា មានប្រជាពលករវិលមកពីប្រទេសថៃជារៀងរាល់ថ្ងៃដោយក្នុងមួយថ្ងៃចន្លោះពី ១០០ ទៅ ៤០០នាក់ ដែលនៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា។ លោកស្រី យូ សុភា បានបន្តថា ក្រុមការងារខេត្តបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមវិធានការរបស់រាជរដ្ឋាភិបាល ដោយរៀបចំពួកគាត់ធ្វើចត្តាឡីស័កទាំងអស់គ្នាគ្រប់ចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កនៃខេត្តសៀមរាប។ លោកស្រី បានបន្ថែមទៀតថា ដោយមានការយកចិត្តទុកដាក់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី បងប្អូនប្រជាពលរដ្ឋត្រូវបានដឹកជញ្ជូនតាមរថយន្តយោធាចំនួន ២គ្រឿង ឆ្ពោះទៅសាលាគរុកោសល្យខេត្តសៀមរាប ដើម្បីធ្វើចត្តាឡីស័កឱ្យស្របតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។

សូមជម្រាបជូនថា ប្រជាពលករទាំង ២៤នាក់នោះ ដឹកចេញពី វិទ្យាល័យម៉ាឡៃ និងច្រកអូរបីជាន់ ខេត្តបន្ទាយមានជ័យ ក្នុងនោះបញ្ជូនចេញមកពី៖

១. ច្រករបៀងម៉ាឡៃចំនួន ១១នាក់ ស្រី ៥នាក់។

២. ច្រករបៀងអូរបីជាន់ចំនួន ១៣នាក់ ស្រី ៧នាក់ កុមារ នាក់ ។

ជាមួយគ្នានេះ ក្នុងនាមអាជ្ញាធរខេត្ត លោកស្រី សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋដែលមកពីក្រៅប្រទេសទាំងអស់ត្រូវចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដោយត្រូវធ្វើចត្តាឡីស័ក និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ចូលក្នុងសហគមន៍៕ ប្រភព: ក្រុមការងារទទួល និងដឹកជញ្ជូនពលកររបស់រដ្ឋបាលខេត្តសៀមរាប កែសម្រួលដោយ លីវ សុខុន

## គិតត្រឹមម៉ោង ១០.០០នាទីព្រឹកថ្ងៃទី២៦ ខែធ្នូ នេះ ប្រជាពលរដ្ឋខ្មែរ របស់ខេត្តកំពង់ចាម ចំនួន ៦០នាក់ ហើយ ដែលត្រូវបានអាជ្ញាធរថៃបញ្ជូនមក កាន់ប្រទេសកម្ពុជា

https://www.facebook.com/tvkchannel7/ 26-12-2020

លោក កែវ នាឬទ្ធិ អភិបាលរង ខេត្តកំពង់ចាម ៖ គិតត្រឹមម៉ោង ១០.០០នាទីព្រឹកថ្ងៃទី២៦ ខែធ្នូ នេះ ប្រជាពលរដ្ឋខ្មែរ របស់ខេត្តកំពង់ចាម ចំនួន ៦០នាក់ ហើយ ដែលត្រូវបានអាជ្ញាធរថៃបញ្ជូនមក កាន់ប្រទេសកម្ពុជា ។ លោក កែវ នាឬទ្ធិ ដឹកនាំមន្ត្រីមន្ទីរ អង្គភាព ស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន របស់ខេត្តកំពង់ចាម អញ្ជើញទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់មកពីប្រទេសថៃ ហើយកំពុងធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កកម្រិត២ ស្ថិតនៅក្នុងវិទ្យាល័យកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ នេះ ។ ដោយ : ជិន សារ៉ាត់

## ពលករខ្មែរ៥២នាក់ ដែលបោះជំរុំនៅក្នុងព្រៃក្បែរព្រំដែនថៃ-កម្ពុជា ត្រូវសមត្ថកិច្ចថៃបញ្ជូនមកកម្ពុជាវិញ

http://www.freshnewsasia.com/ 2020-12-26 10:54am

**(បន្ទាយមានជ័យ)៖** យ៉ាងហោចណាស់មានពលករខ្មែរ៥២នាក់ ដែលនាំគ្នាបោះជំរុំក្នុងព្រៃតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីឆ្លងឆ្លងដែនចូលក្នុងទឹកដីថៃរកការងារធ្វើដោយមិនខ្លាចជំងឺកូវីដ-១៩នោះ ត្រូវបានកម្លាំងយោធាការពារ ព្រំដែនថៃលេខ១២១ សហការជាមួយតម្រួតនៅក្នុងតំបន់ ព្រមទាំងកម្លាំងអន្តោប្រវេសន៍ខេត្តស្រះកែវ បានឃាត់ខ្លួនដើម្បីសាកសួរ បន្ទាប់ពីទទួលបានសេចក្តីរាយការណ៍ថា ពលករខ្មែរទាំងអស់នេះ បានលបឆ្លងដែនតាមច្រករបៀងចូលទៅក្នុងទឹកដីថៃដោយគ្មានច្បាប់អនុញ្ញាត។ ការឃាត់ខ្លួនពលករខ្មែរទាំងននេះនៅព្រលប់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ក្នុងព្រៃដែលជាតំបន់ឧទ្យានជាតិប៉ាសួន ដោយមានការបញ្ជាផ្ទាល់ពីថ្នាក់ដឹកនាំតម្រួតខេត្តលោក អម្រឹត បុណ្យសុយ៉ា ក្នុងគោលបំណង អនុវត្តតាមបទបញ្ជារបស់ប្រមុខរដ្ឋាភិបាល ក្នុងការការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងឃាយីយ៉ាងខ្លាំងនៅក្នុងប្រទេសថៃ ដោយកម្លាំងសហការទាំងនេះ បានចេញប្រតិបត្តិការទៅកាន់ចំណុចភូមិ១៤ ឃុំណងមួយ ស្រុកគោកខ្សូង ខេត្តស្រះកែវ ដើម្បីពិនិត្យ។

បើតាមសមត្ថកិច្ចថៃ បានបញ្ជាក់ប្រាប់សមត្ថកិច្ចខ្មែរឱ្យដឹងថា ការបោះជំរុំនោះមានពលករ៥២នាក់ ក្នុងនោះស្រី២៤ ប្រុស២១ និងក្មេងតូចៗ ចំនួន៧នាក់ ហើយបានបញ្ជូនមកឱ្យសមត្ថកិច្ចខ្មែរ ដើម្បីចាត់ការបន្ត។

សមត្ថកិច្ចខ្មែរ បានប្រាប់ឱ្យដឹងថា ពលករទាំង៥២នាក់ ត្រូវបានក្រុមមន្ត្រីសុខាភិបាលស្រុកត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ និងវាស់កម្តៅ តែគ្មាននរណាម្នាក់ មានកម្តៅខ្ពស់គួរឱ្យព្រួយបារម្ភឡើយ។ បន្ទាប់ពីបានសាកសួរពលករ បាននិយាយថា គឺមកពីខេត្តសៀមរាបទាំងអស់គ្នា ដោយបានលួចឆ្លងដែនចូលតាមច្រករបៀង ដើម្បីស្វែងទៅរកការងារកសិកម្មធ្វើក្នុងស្រុកគោកខ្សូង និងស្រុកក្បែរខាង ដោយបានកម្រៃក្នុង ១ថ្ងៃ គឺម្នាក់ចាប់ពី ២០០ ទៅ៣០០បាត ដោយមិនចាំបាច់ត្រូវធ្វើដំណើរទៅកាន់ទីក្រុងបាងកកឡើយ។ ពលករខ្មែរទាំងនេះ ត្រូវបាន

កម្លាំងសមត្ថកិច្ច និងអាជ្ញាធរនៅក្នុងតំបន់បញ្ជូនតាមរថយន្តយកទៅកន្លែងត្រួតពិនិត្យវាស់កំដៅ និងចត្តាឡីស័ក ទុករយៈពេល១៤ថ្ងៃ តាមវិធានសុខាភិបាល៕

## រយៈពេល១សប្តាហ៍ខេត្តចំនួន៣ទទួលបានពលករខ្មែរចេញពីថៃជិត ៣ ពាន់នាក់

https://kampucheathmey.com/ December 27, 2020 By Sonya

ក្នុងរយៈពេលមួយសប្តាហ៍នេះ ខេត្តចំនួន៣ ដែលជាប់ព្រំដែនជាមួយប្រទេសថៃរួមមាន ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តបាត់ដំបង ទទួលបានពលករខ្មែរឆ្លងមកពីថៃប្រមាណ ២៧២៣ នាក់។ លោកវេជ្ជបណ្ឌិត ឡេ ច័ន្ទសង្វាត ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ បានឲ្យដឹងនៅរសៀលថ្ងៃទី២៧ ធ្នូនេះថា គិតចាប់ពីថ្ងៃទី ២០-២៦ ខែធ្នូឆ្នាំ ២០២០ ខេត្តបន្ទាយមានជ័យទទួលបានពលករខ្មែរឆ្លងមកពីថៃចំនួន ១៣២៣ នាក់ស្រី ៦៨៤ នាក់ ក្នុងនោះបានយកសំណាកសរុបចំនួន ១២៨១ ស្រី ៥៦៣ នាក់។ លោកបានបន្តថា ក្រៅពីនេះខេត្តបានបញ្ជូនប្រជាពលរដ្ឋចេញក្រៅខេត្តសរុបចំនួន ៥០៤ នាក់ ស្រី ២៤៣ នាក់ និងទទួលប្រជាពលរដ្ឋពីខេត្តឧត្តរមានជ័យចំនួន ៥២ នាក់ស្រី ២៩ នាក់។

រីឯលោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យបានឲ្យដឹងដែរថា រយៈពេល១សប្តាហ៍នេះចាប់ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៧ ធ្នូ ខេត្តឧត្តរមានជ័យទទួលបានពលករចូលមកតាមច្រកព្រំដែនអូរស្មាច់ប្រមាណ ១០០០ នាក់ ក្នុងនោះបានយកសំណាកទៅធ្វើតេស្តជិត ៣៣០ នាក់ រួមទាំងថ្ងៃទី ២៧ ធ្នូនេះ ជាង ៥៥ សំណាកនិងកំពុងធ្វើចត្តាឡីស័កចំនួន ៣០០ នាក់។ ក្រៅពីនោះខេត្តបានបញ្ជូនពលករទៅតាមបណ្តាខេត្តនានាដែលជាស្រុកកំណើតរបស់ពលករ។ លោកបានបន្តថា ក្នុង១ថ្ងៃជាមធ្យមមានពលករខ្មែរចូលតាមច្រកព្រំដែនអូរស្មាច់ប្រមាណពី ១៤០ ទៅ ១៥០ នាក់ ក្នុងនោះមានពលករប្រមាណពី ៤០ ទៅ ៥០ នាក់ប៉ុណ្ណោះមកពីខេត្តដែលមានប្រឈមនឹងជំងឺកូវីដ១៩ដូចជាខេត្តសាមុតសាខននិងទីក្រុងបាងកកជាដើម។

ដោយឡែកលោក រឿង ប៊ុនរ៉េត ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបងបានឲ្យដឹងថា រយៈពេលមួយសប្តាហ៍នេះក្នុងខេត្តបាត់ដំបងទទួលបានពលករប្រមាណ ៤០០ នាក់ ដោយយកសំណាកទៅធ្វើតេស្តទាំងអស់និងទទួលពលករពីតាមបណ្តាខេត្តផ្សេងៗដែលមានស្រុកកំណើតនៅបាត់ដំបងជាង ៣០០ នាក់៕

## គិតត្រឹមថ្ងៃទី២៥ធ្នូ ពលរដ្ឋដែលវិលចូលប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មានជាង ១០០នាក់ហើយ

https://khmernote.com.kh/news/ December 26, 2020 srey nuch

ខេត្តឧត្តរមានជ័យ៖ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៧នាក់ ស្រី ៥០ នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអាជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោសែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ៕

# ក្រុមគ្រូពេទ្យជួរមុខបង្កើនការយកចិត្តលើការធ្វើតេស្តបងប្អូនពលករមកពីក្រៅប្រទេស

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១៨:៤៨ ច័ន្ទ ស្មើ

- ខេត្តសៀមរាប ៖ ក្នុងការប្រយុទ្ធប្រឆាំងបង្ការទប់ស្កាត់នៃជម្ងឺកូវីដ១៩ ទៅតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល និងការណែនាំវិធានការរបស់ក្រសួងសុខាភិបាល អាជ្ញាធរខេត្តសៀមរាប។ ក្រោមការដឹកនាំរបស់ លោក ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប បានយកចិត្តទុកដាក់ខ្ពស់ចំពោះបងប្អូនពលករខ្មែរមកពីក្រៅប្រទេសក្នុងពេល ដែលនៅលើពិភពលោកបានកំពុងជួបនូវវិបត្តិកូវីដ១៩ ហើយត្រូវបានវិលត្រឡប់មកកាន់ប្រទេសខ្លួនវិញ គឺតម្រូវឲ្យបងប្អូនត្រូវធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័កសាលាបឋមសិក្សាអនុវត្ត គរុកោសល្យខេត្តសៀមរាប ដែលគិតមកត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០នេះ មានចំនួន ២៦១នាក់ រួមទាំងកុមារតូចៗ ហើយអ្វីដែលជាវិធានចាំបាច់នោះបងប្អូនទាំងអស់ត្រូវធ្វើការយកសំណាកទៅវិភាគឲ្យបានគ្រប់ចំនួន៣ដង តាមការកំណត់របស់ក្រសួងសុខាភិបាល ។
- ក្នុងនោះដែរ រដ្ឋបាលខេត្តសៀមរាប ក៏បានធ្វើការផ្គត់ផ្គង់អាហារដល់ពួកគាត់ក្នុង១ថ្ងៃ៣ដងទៀតផង។ ជាមួយនឹងព្រឹត្តិការណ៍រីករាលដាលនៃជម្ងឺកូវីដ-១៩ ក្នុងសហគមន៍នៅប្រទេសជិតខាង ដែលផ្ទុះឡើងថ្មីៗនេះ សម្រាប់ការប្រុងប្រយ័ត្ននៅកម្ពុជា ក្រោមចំណាត់ការដ៏មានប្រសិទ្ធភាពនៃសម្តេចតេជោ ប្រមុខនៃរាជរដ្ឋាភិបាល ប្រជាពលរដ្ឋខេត្តសៀមរាប ដែលបានធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសចំនួន២៦១នាក់ ក្នុងនោះរួមមាន ទាំងស្ត្រី និងកុមារតូចៗផងដែរនោះត្រូវបានអាជ្ញាធរខេត្តសៀមរាប ទៅទទួលយក ពីមណ្ឌលចត្តាឡីស័ក ខេត្តបន្ទាយមានជ័យ និងតាមច្រកអូរបីជាន់ និងច្រកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដោយអមដំណើរមកដល់មណ្ឌលចត្តាឡីស័កសាលាបឋមសិក្សាអនុវត្តគរុកោសល្យ ដែលជាទីតាំងចត្តាឡីស័កធំជាងគេ ស្ថិតនៅក្នុងក្រុងសៀមរាប ក្រោមការដឹកនាំរបស់លោកជំទាវ យូ សុភា អភិបាលរងខេត្ត និងជាក្រុមការងារទទួលគ្រប់គ្រងពលករចំណាកស្រុកមកពីក្រៅប្រទេស ។
- តាមការបញ្ជាក់របស់លោកជំទាវ យូ សោភា បានឲ្យដឹងថា បងប្អូនទាំងអស់នេះ បានមកដល់គោលដៅប្រកបដោយសុវត្ថិភាព តាមក្បួនរថយន្តដឹកជញ្ជូនរបស់កងពល តូចដឹកជញ្ជូនលេខ៩០ នៃកងយោធពលខេមរភូមិន្ទ ដោយពុំមានអ្នករត់គេចវេសឡើយ ក្រោយពីបានទទួលពីមណ្ឌលចត្តាឡីស័កខេត្តបន្ទាយមានជ័យ និងតាមច្រកអូរបីជាន់ និងច្រកម៉ាឡៃ ។
- តាមការបញ្ជាក់របស់លោកវេជ្ជប ណ្ឌិត ក្រុស សារ៉ាត់ ប្រធានមន្ទីរសុខាភិបាលខេត្តសៀមរាប នៅព្រឹកថ្ងៃទី២៦ ធ្នូនេះបានឲ្យដឹងថា បងប្អូនពលករទាំង២៦១ នាក់ ដែលចូលមកស្នាក់នៅមណ្ឌលចត្តាឡីស័កនេះ ត្រូវបានក្រុមគ្រូពេទ្យយើង បានយកចិត្តទុក ដាក់ខ្ពស់ក្នុងការថែទាំសុខភាពពួកគាត់ដែលកំពុងស្នាក់នៅក្នុងមណ្ឌលនេះ ។ លោកវេជ្ជបណ្ឌិតបានបន្តទៀតថា ក្នុងការស្នាក់នៅតាមដានសុខភាពនេះ ក្រុមគ្រូពេទ្យយើងក៏បានធ្វើការយកសំណាក ទាំងក្មេងទាំងចាស់ ហើយលទ្ធផល ដែលទទួលបាន គឺអវិជ្ជមានទាំងអស់ តែយ៉ាងណាក៏ដោយបងប្អូនទាំងអស់នេះ ត្រូវធ្វើចត្តាឡីស័កបន្តទៀត និងយកសំណាកវិភាគឲ្យបានគ្រប់៣ដងជាកំណត់។ ឆ្លៀតក្នុងឱកាសនោះដែរ លោកវេជ្ជបណ្ឌិតក៏បានធ្វើការណែនាំដល់ក្រុមគ្រូពេទ្យជួរមុខទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការពិនិត្យ តាមដាននូវរាល់សុខភាពរបស់បងប្អូន ព្រមទាំងការយក និង ទុកដាក់សំណាក ក្នុងប្រអប់សុវត្ថិ ភាពឲ្យ បានត្រឹមត្រូវ ដើម្បីជៀស វាងនូវប្រការអាក្រក់ណាមួយកើតឡើង ។ សូមបញ្ជាក់ផងដែរថា ការដឹកជញ្ជូនបងប្អូនពលករមកពីក្រៅប្រទេស គឺនៅតែបន្តធ្វើការដឹកជញ្ជូនយកមកចូលមណ្ឌល ចត្តាឡីស័កជាប្រចាំផងដែរ ៕
-

## លោក ស្រេង ហុង អញ្ជើញជាអធិបតីក្នុងពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ នៅស្រុកមណ្ឌលសីមា

https://grandnewsasia.com/ ថ្ងៃសុក្រ ទី ២៥ ធ្នូ ២០២០

កោះកុង៖ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ លោក ស្រេង ហុង អភិបាលរងខេត្តកោះកុង បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង។ លោក ស្រេង ហុង បានគូសបញ្ជាក់ថា អំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មដ៏រាំរ៉ៃមួយដែលបានកើតឡើងនៅគ្រប់បណ្តាប្រទេសក្នុងពិភពលោកក្នុងចំណោមឧក្រិដ្ឋកម្មដទៃផ្សេងទៀត ដែលបាននឹងកំពុងធ្វើឲ្យប៉ះពាល់ដល់ សន្តិសុខមនុស្ស និងប្រទេសជាតិ និងជាពិសេសក្នុងចំណោមពលករទេសន្តប្រវេសន៍ដែលបានធ្វើចំណាកស្រុកដល់កុមារ និងស្ត្រី និងអង្គការដៃគូរផ្សេងៗ បានយកចិត្តទុកដាក់និងសហការជាមួយគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាលេខាធិការដ្ឋាន ជាសេនាធិការ និងអស់លោក លោកស្រីថ្នាក់ដឹកនាំមន្ទីរ-អង្គភាពជុំវិញខេត្ត អ្នកពាក់ព័ន្ធនានា រួមជាមួយនឹងជំនាញកម្លាំងប្រដាប់អាវុធទាំងបីប្រភេទក្នុងខេត្ត បានរៀបចំជាសិក្ខាសាលាផ្សព្វផ្សាយ ក្នុងការទប់ស្កាត់ និងបង្រ្កាបអំពើជួញដូរមនុស្ស-ជួញដូរពលកម្មនៅក្នុងខេត្ត ក៏ដូចជានៅតាមបណ្តោយព្រំដែន នៃខេត្តកោះកុង ទទួលបានលទ្ធផលយ៉ាងល្អប្រសើរ៕

## ពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ នៅក្រុងខេមរភូមិន្ទ

https://grandnewsasia.com/ ថ្ងៃសុក្រ ទី ២៥ ធ្នូ ២០២០

កោះកុង៖ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ លោក ស្រេង ហុង អភិបាលរងខេត្តកោះកុង បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសសមាសភាពមន្ត្រីទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់នៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ក្នុងឱកាសនោះ លោកអភិបាលរងខេត្ត បានគូសបញ្ជាក់ថា អំពើជួញដូរមនុស្សគឺជាឧក្រិដ្ឋកម្មដ៏រាំរ៉ៃមួយ ដែលបានកើតឡើងនៅគ្រប់បណ្តាប្រទេស ក្នុងពិភពលោកក្នុងចំណោមឧក្រិដ្ឋកម្មដទៃផ្សេងទៀតដែលបាននិងកំពុងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខមនុស្ស និងប្រទេសជាតិ និងជាពិសេសក្នុងចំណោមពលករទេសន្តប្រវេសន៍ដែលបានធ្វើចំណាកស្រុកដល់កុមារ និងស្ត្រី និងអង្គការដៃគូរផ្សេងៗ បានយកចិត្តទុកដាក់ និងសហការជាមួយគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាលេខាធិការដ្ឋាន ជាសេនាធិការ និងអស់លោក លោកស្រីថ្នាក់ដឹកនាំមន្ទីរ-អង្គភាពជុំវិញខេត្ត អ្នកពាក់ព័ន្ធនានា រួមជាមួយនឹងជំនាញកម្លាំងប្រដាប់អាវុធទាំងបីប្រភេទក្នុងខេត្ត បានរៀបចំជាសិក្ខាសាលាផ្សព្វផ្សាយ ក្នុងការទប់ស្កាត់ និងបង្រ្កាបអំពើជួញដូរមនុស្ស-ជួញដូរពលកម្មនៅក្នុងខេត្តក៏ដូចជានៅតាមបណ្តោយព្រំដែននៃខេត្តកោះកុង ទទួលបានលទ្ធផលយ៉ាងល្អប្រសើរ៕

## ពលករខ្មែរប្រមាណ ២៣០នាក់ ត្រូវបញ្ជូនមកពីខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ដើម្បីធ្វើចត្តាឡីស័កនៅបាត់ដំបង

https://www.cen.com.kh/ December 25, 2020

បាត់ដំបង៖ មន្ត្រីជំនាញ បាននិងកំពុងពិនិត្យសុខភាពនិងយកសំណាកជាបន្តបន្ទាប់ លើប្រជាពលករខ្មែររស់នៅខេត្តបាត់ដំបង ដែលធ្វើការនៅប្រទេសថៃចំនួនប្រមាណ ២៣០នាក់ ដោយពលករទាំងអស់នេះត្រឡប់មកស្រុកកំណើតវិញ ចាប់ពីមានការផ្ទុះឡើងនៃការឆ្លងរាលដាលជំងឺកូវីដ១៩ នៅខេត្តសាមុទសាខន នៃប្រទេសថៃ ជាច្រើនករណីហើយឆ្លងចូលមកតាមច្រកនានា ជាប់នឹងខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ត្រូវបានអាជ្ញាធរ

ខេត្តទាំង២នេះ បញ្ជូនតាមរថយន្តរបស់កងពលតូចដឹកជញ្ជូនលេខ៩៩ ឲ្យមកធ្វើចត្តាឡីស័ករយៈពេល ១៤ នៅក្នុងខេត្តបាត់ដំបង ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩។

លោក ផេង សិទ្ធី អភិបាលក្រុងបាត់ដំបង បានមានប្រសាសន៍ថា ពលករខ្មែរ ដែលត្រូវបញ្ជូនមកពីខេត្តទាំង២ខាងលើ កំពុងសម្រាក់ធ្វើចត្តាឡីស័កក្នុងវិទ្យាល័យព្រះមុនីវង្ស ខណៈពួកគាត់ត្រូវបានយកចិត្តទុកដាក់ ក្នុងការរៀបចំកន្លែងស្នាក់នៅ ទទួលបានឃីតម្នាក់មួយ (មុង ភួយ ខ្នើយ) រួមទាំងអាហារ ៣ពេលផងដែរ។

ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបងក្នុងឱកាសចុះពិនិត្យការធ្វើចត្តាឡីស័កនិងទទួលពលករ ទើបមកពីខេត្តបន្ទាយមានជ័យនិងខេត្តឧត្តរមានជ័យ កាលពីល្ងាចថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០២០ បានជំរុញមន្រ្តីសុខាភិបាលនិងសមត្ថកិច្ចប្រចាំការ ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការពិនិត្យសុខភាពឬការពារបងប្អូនពលករ ឲ្យពួកគាត់មានភាពកក់ក្ដៅនិងធ្វើយ៉ាងណាឲ្យពួកគាត់ ចូលរួមធ្វើចត្តាឡីស័កឲ្យបានចំនួន ១៤ថ្ងៃ។ ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានអំពាវនាវដល់ពលករកំពុងធ្វើចត្តាឡីស័ក ត្រូវចូលរួមសហការជាមួយមន្ត្រីសុខាភិបាលនិងសមត្ថកិច្ច ក្នុងការអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងអាជ្ញាធរខេត្ត ដើម្បីទប់ស្កាត់កុំឲ្យមានរីករាលដាលនៃជំងឺកូវីដ១៩ កាន់តែខ្លាំងក្នុងសហគមន៍៕ **រក្សាសិទ្ធិដោយៈអ៊ុងសារុំ**

## អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខេត្តកំពង់ចាម វិលត្រឡប់មកពីប្រទេសថៃ ចំនួន ៤៧ នាក់ ត្រូវបានដឹកបញ្ជូនមកមណ្ឌលចត្តាឡីស័ក នៅខេត្តកំពង់ចាម

https://www.pdikampongcham.info/ ២៦ ខែធ្នូ ២០២០ *អត្ថបទ៖ ចិន សារ៉ាត*

ឯកឧត្តម កែវ នាឫទ្ធិ អភិបាលរង ខេត្តកំពង់ចាម មានប្រសាសន៍ឲ្យដឹងថា គិតត្រឹមម៉ោង ១០.00នាទីព្រឹកថ្ងៃទី២៦ ខែធ្នូ នេះ ប្រជាពលរដ្ឋខ្មែរ របស់ខេត្តកំពង់ចាម ចំនួន ៤៧នាក់ ហើយ ដែលត្រូវបានអាជ្ញាធរថៃបញ្ជូនមកកាន់ប្រទេសកម្ពុជា តាមច្រកអូរបីជាន់ ម៉ាឡៃ ឡែម និងច្រកដូង ។

គួសបញ្ជាក់យ៉ាងដូច្នេះ នៅក្នុងឱកាស ដែលឯឧត្តម ដឹកនាំមន្ត្រីមន្ទីរ អង្គភាព ស្ថាប័នជំនាញ និងអាជ្ញាពាក់ព័ន្ធ ក្នុងមូលដ្ឋាន របស់ខេត្តកំពង់ចាម អញ្ជើញទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់មកពីប្រទេសថៃ ហើយកំពុងធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កកម្រិត២ ស្ថិតនៅក្នុងវិទ្យាល័យកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ នេះ ។ ឯកឧត្តម អភិបាលរង ខេត្តកំពង់ចាម បានបញ្ជាក់ប្រាប់ថា ក្រោយពី សម្តេចអគ្គមហាសេនាតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្ញើសារណែនាំ ដល់អាជ្ញាធរខេត្តជាប់ព្រំដែនប្រទេសថៃ ត្រូវបង្កើនការយកចិត្តទុកដាក់ ពង្រឹងការងារត្រួតពិនិត្យ និងធ្វើចត្តាឡីស័ក ចំពោះ បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញ បន្ទាប់ពីប្រទេសថៃ បានផ្ទុះការឆ្លងរាលដាល នៃជម្ងឺកូវីដ ១៩ ក្នុងសហគមន៍ នៅខេត្តសាមុតសាខន មកនោះ ឯកឧត្តម អ៊ុន ចាន់ដា អភិបាលខេត្តកំពង់ចាម បានចាត់ឲ្យឯកឧត្តមផ្ទាល់ ដឹកនាំមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បី ទទួលប្រជាពលរដ្ឋខេត្តកំពង់ចាម ដែលអាជ្ញាធរថៃ បញ្ជូនមកកម្ពុជា ដើម្បី ដឹកបញ្ជូនពួកគាត់ មកកាន់ខេត្តកំពង់ចាម ។ ឯកឧត្តមបន្តថា ជាមួយនោះ យើងក៏បានរៀបចំរថយន្តចំនួន ០៣គ្រឿង ដើម្បី ដឹកជញ្ជូនបងប្អូនមកធ្វើចត្តាឡីស័ក នៅតាមមណ្ឌលចត្តាឡីស័ក នៃខេត្តកំពង់ចាម ផងដែរ ៕

## ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ ចុះអន្តរាគមន៍ដល់ពលករខ្មែរនៅជាយទីក្រុងបាងកក

https://kampucheathmey.com/ December 25, 2020 By Bo Doula

ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ បានចុះជួប និងចែកស្បៀងមួយចំនួនដល់ប្រជាពលរដ្ឋខ្មែររស់នៅជាយទីក្រុងបាងកក ជប់ព្រំប្រគល់ខេត្តសមុទ្រសាខន ដែលកំពុងប្រឈមការលំបាក ដោយសារកូវីដរាតត្បាតខ្លាំង។ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ បានឱ្យដឹងថា នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ស្ថានទូតបានទទួលដំណឹងពីទុក្ខលំបាកខ្លាំងរបស់ពលរដ្ឋខ្មែរមួយចំនួនដោយសារស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមខេត្តមួយចំនួនក្រោយការ

ផ្ទុះឆ្លងជំងឺ covid-19 រលកថ្មីនៅខេត្តសមុទ្រសាខន ទើបនៅថ្ងៃទី២៥ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារស្ថានទូតបាននាំយកអំណោយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទៅចែកជូនដល់ពលករខ្មែរប្រមាណ ជិត ២០០ គ្រួសារ ។ ស្ថានទូតបានអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរនៅប្រទេសថៃទាំងអស់ ឱ្យបន្តចូលរួមសហការយ៉ាងសកម្មថែមទៀត កុំធ្វើការចល័ត ឬរត់គេចពីមួយកន្លែងទៅមួយកន្លែង នៅក្នុងកំឡុងពេលការរីករាលដាលការឆ្លងជំងឺកូវីដ-១៩ ថ្មីៗនេះ។ ស្ថានទូតបានជំរុញឱ្យពលរដ្ឋទំនាក់ទំនងតាមរយៈ facebook page ឬលេខទូរស័ព្ទ 092 8050561 ផ្នែកកុងស៊ុលសិស្សនិស្សិត និងលេខ 0940925905 ផ្នែកទទួលបន្ទុកពលករ ផងដែរ៕ **អត្ថបទ ៖ សោ និយមរ័ត្ន**

## ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០២០

### ស្ត្រីខ្មែរឥស្លាមម្នាក់ គេនាំទៅលក់នៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត នាងសូមឲ្យសម្តេចតេជោ ជួយផង!

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១១:៥១ សហការី

អារ៉ាប៊ីសាអូឌីត ៖ ស្ត្រីខ្មែរឥស្លាមម្នាក់ នៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត អំពាវនាវដល់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងអង្គការសិទ្ធិមនុស្ស និងអង្គការជួញដូរមនុស្សមេត្តាជួយអន្តរាគមន៍ឲ្យរូបនាងបានវិលមកដល់មាតុភូមិវិញផង។ ប្រភពគណនីហ្វេសប៊ុក Rohimah Binti Mohamad Aly បានអោយដឹងថា នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ នារីរងគ្រោះ លី រ៉ហឺម៉ាស់ អាយុ ២៦ឆ្នាំ រស់នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ បង្ហោះវីដេអូបង្ហាញថា រូបនាងកំពុងរងគ្រោះដោយការចាញ់បោកមេខ្យល់ ដែលបានយកទៅលក់នៅប្រទេសអារ៉ាប៊ីសាអូឌីត តាំងពីឆ្នាំ២០១៧មក រហូតដល់ពេលបច្ចុប្បន្ន ។

### ក្រុមការងារចំណាកស្រុកខេត្តព្រៃវែង ប្រជុំលើកទិសដៅការឆ្លើយតបការវិលត្រឡប់មកវិញ របស់បងប្អូនកម្មករពលករខ្មែរ ពេលផ្ទុះជំងឺកូវីដ១៩ ក្នុងសហគមន៍ នៅប្រទេសថៃ

http://www.freshnewsasia.com/ 2020-12-28 05:25pm

**(ភ្នំពេញ)៖** អនុវត្តតាមប្រសាសន៍ណែនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី, នៅទីស្តីការក្រសួងមុខងារសាធារណៈ នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០នេះ ក្រុមការងារចំណាកស្រុកខេត្តព្រៃវែង បានបើកកិច្ចប្រជុំការងាររបស់ខ្លួន ដើម្បីត្រួតពិនិត្យសកម្មភាពការងារកន្លងមក និងលើកទិសដៅបន្ត ពិសេសផែនការសកម្មភាពជាក់ស្តែង ជាវិធានការបន្ទាន់ចាំបាច់ ឆ្លើយតបចំពោះការវិលត្រឡប់មកវិញ របស់បងប្អូនកម្មករ ពលករចំណាកស្រុក ពេលដែលមានការផ្ទុះជំងឺកូវីដ១៩ ក្នុងសហគមន៍នៅប្រទេសថៃ ។

រយៈពេលចាប់ពីដើមខែមេសា ឆ្នាំ២០២០ មកដល់បច្ចុប្បន្ននេះ លេខាធិការដ្ឋានក្រុមការងារចំណាកស្រុក បានធ្វើជាស្នូលឱ្យក្រុមការងារខេត្ត និងរដ្ឋបាលស្រុក ក្រុងទាំង១៣ នៃខេត្តព្រៃវែងក្នុងកិច្ចសហការរៀបចំបង្គលក្ខណៈ ដល់ការធ្វើចត្តាឡីស័ក ជូនបងប្អូនពលករចំណាកស្រុកប្រមាណ ១២.០០០នាក់ ដែលបានវិលត្រឡប់ មកពីប្រទេសថៃ។ ថ្មីៗនេះ ការផ្ទុះរាលដាលជំងឺកូវីដ១៩ ក្នុងសហគមន៍នៅខេត្តសាមុទ្ទសាខន ប្រទេសថៃ បានបង្កឱ្យមានការវិលត្រឡប់មកវិញ ជារៀងរាល់ថ្ងៃនៃបងប្អូនកម្មករ ពលករចំណាកស្រុកមួយចំនួន។ គិតមកទល់ពេលនេះ មានបងប្អូនពលករចំណាកស្រុក ចំនួន ១៤១នាក់ (ស្រី២៩នាក់) បានវិលត្រឡប់មកដល់មូលដ្ឋាន ស្រុកកំណើតនៃខេត្តព្រៃវែងរួចហើយ។ ក្នុងចំណោមបងប្អូនទាំងនោះ មានចំនួន ៤៥នាក់ ត្រូវបានអាជ្ញាធរ និងកងកំលាំងយោធាទទួល បង្គលក្ខណៈងាយស្រួលនៅព្រំដែន និងដឹកជញ្ជូនមកដល់ខេត្ត។ ក្រោយឆ្លងកាត់ការធ្វើតេស្តរួច បង

ប្អូនទាំងអស់នោះ ត្រូវបានក្រុមការងាររៀបចំបង្គលក្ខណៈបញ្ជូន ឱ្យទៅស្នាក់នៅធ្វើចត្តាឡីស័កនៅថ្នាក់ស្រុក ក្រុង។ ក្រៅពីនោះ ត្រូវបានរៀបចំយកសំណាកធ្វើតេស្ត និងដាក់ឱ្យធ្វើចត្តាឡីស័ក ទៅតាមលទ្ធភាពនៃមូលដ្ឋាននីមួយៗ។

ផ្អែកលើស្ថានភាពជាក់ស្តែងខាងលើ កិច្ចប្រជុំបានលើកឡើង នូវវិធានការចាំបាច់មួយចំនួន ដើម្បីបន្តអនុវត្ត ដោយខិតខំប្រតិបត្តិឱ្យបានហ្មត់ចត់ និងខ្ជាប់ខ្ជួននូវរាល់វិធានវេជ្ជសាស្ត្រ សំដៅសហការឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងដំណើរការត្រៀមរៀបចំជាស្រេច ការទទួលបងប្អូនពលករចំណាកស្រុកវិលត្រឡប់ មកពីប្រទេសថៃវិញជាបន្តទៀត។ ជារួម ក្រៅពីសកម្មភាពការងាររបស់ខ្លួន ក្នុងការចូលរួមសហការដើម្បីរក្សាសុវត្ថិភាព សុខុមាលភាពរបស់បងប្អូនពលករចំណាកស្រុកវិលត្រឡប់ពីក្រៅប្រទេស និងបង្ការទប់ស្កាត់ការរីករាលដាលកូវីដ១៩ចូលក្នុងសហគមន៍ ក្រុមការងារចំណាកស្រុកខេត្តព្រៃវែង នៅតែប្តេជ្ញាបន្តការងារអប់រំ សតិអារម្មណ៍សាធារណជននៅមូលដ្ឋាន ដើម្បីរួមចំណែកពង្រឹងបុព្វហេតុរក្សាការពារសុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិជាដរាបតរៀងទៅ៕

## ប្រធានមន្ទីរសុខាភិបាល ៖ ពលករខ្មែរ មកពីប្រទេសថៃ តាមច្រកទ្វារអន្តរជាតិ និងច្រករបៀង និងតាមផ្លូវទឹក មានចំនួន១៨នាក់

https://dap-news.com/national/ ByPH104 Posted on December 28, 2020

កោះកុង ៖ លោកវេជ្ជបណ្ឌិត ទៅ ម៉ឹង ប្រធានមន្ទីរសុខាភិបាល ខេត្តកោះកុង បានប្រាប់ឲ្យដឹង នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ថា គិតពីថ្ងៃទី២១ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ ពលករខ្មែរ ដែលធ្វើសំណាកស្រុក នៅប្រទេសថៃ បានវិលត្រឡប់ចូលមកស្រុកកំណើត តាមច្រកទ្វាអន្តរជាតិចាំយាម ច្រករបៀង និងតាមផ្ទៃសមុទ្រ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ធ្វើចត្តាឡីស័ក មានចំនួនសរុបចំនួន១៨នាក់ ហើយចំណោម១៨នាក់ នោះមន្ត្រីសុខាភិបាល បានយកកំហាកធ្វើការពិនិត្យ នៅមន្ទីរវិទ្យាស្ថានប៉ាស្ទ័រ ក្រសួងសុខាភិបាល ហើយលទ្ធផលបញ្ជាក់ ពីមន្ទីរវិទ្យាស្ថានប៉ាស្ទ័រ ក្រសួងសុខាភិបាល លទ្ធផលពលករខ្មែរ ១៥នាក់ លទ្ធផលអវិជ្ជមាន ហើយពលករ៣នាក់ទៀត លទ្ធផលមិនទាន់ទទួលបាន ពីមន្ទីរវិទ្យាស្ថាន ប៉ាស្ទ័រនៅឡើយទេ។ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា ចំពោះពលករខ្មែរ ១៥នាក់ ដែលទទួលបានលទ្ធផលអវិជ្ជមាន ក្រុមការងារបានអនុញ្ញាត្តិ ឲ្យគាត់វិលទៅស្រុកកំណើតវិញហើយ។ លោកវិជ្ជបណ្ឌិត ក៏សូមអំពាវនាវ ដល់បងប្អូនប្រជាពលរដ្ឋទាំងក្នុងស្រុក នៅក្រៅស្រុក សូមចូលរួមអនុវត្តន៍ តាមការផ្សព្វផ្សាយ ណែនាំអប់រំ របស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ដែលធ្វើការផ្សព្វផ្សាយណែនាំអប់រំ គ្រប់មូលដ្ឋានហើយយើង ចូលរួមថែរក្សា អនាម័យបរិស្ថាន និងថែរក្សាសុខភាព ដោយខ្លួនឯង ដើម្បីការពារការរីករាលដាល នៃឆ្លងជំងឺកូវិដ១៩ និងជំងឺឆ្លងផ្សេងៗទៀត (ការពារប្រសើរជាងព្យាបាល) ៕

## ត្រឹម៨ថ្ងៃពលរដ្ឋខ្មែរត្រឡប់ពីថៃតាមច្រកអូរបីជាន់១.២៩៦នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២០ ម៉ោង ១៧:១៥ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ តាមរបាយការណ៍បានឱ្យដឹងថា ក្នុងរយៈពេល៨ថ្ងៃ គិតត្រឹមម៉ោង៥ល្ងាចថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ មានប្រជាពលរដ្ឋខ្មែរត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅចំនួន ១.២៩៦នាក់(ស្រី៥៧៨នាក់) ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ ថ្លែងថា ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានចេញសារណែនាំដល់អាជ្ញាធរខេត្តជាប់ព្រំដែនថៃ ត្រូវពង្រឹងការត្រួតពិនិត្យប្រជាពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃ ខណៈដែលនៅប្រទេសនេះបានផ្ទុះជំងឺកូវីដ-១៩ ជាសហគមន៍ នៅខេត្តសាមុតសាខន ។ លោកឲ្យដឹងថា ពលរដ្ឋខ្មែរដែលត្រឡប់មកវិញតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅមាន ៖

-ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ មានចំនួន១៨៣នាក់(ស្រី៩០នាក់)

-ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ មានចំនួន១៨៣នាក់(ស្រី៩០នាក់)
-ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ មានចំនួន២៣៥នាក់ (ស្រី១០៥នាក់)
-ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ មានចំនួន១៧៤នាក់(ស្រី៨០នាក់)
-ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ មានចំនួន៩៣នាក់(ស្រី៣៩នាក់)
-ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ មានចំនួន១១០នាក់(ស្រី៤៩នាក់)
-ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ មានចំនួន១២២នាក់(ស្រី៤៤នាក់) និង
-ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ មានចំនួន១៩៦នាក់(ស្រី៨១នាក់)

សរុបក្នុងរយៈពេល៨ថ្ងៃនេះ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃមានចំនួន១.២៩៦នាក់(ស្រី៥៧៨នាក់) ។

លោកវេជ្ជបណ្ឌិត ឡេ ចាន់សង្វាត ប្រធានមន្ទីរសុខាភិបាលខេត្ត បានឱ្យដឹងថា ចំពោះប្រជាពលរដ្ឋដែលត្រឡប់ពីប្រទេសថៃតាមច្រកអូរបីជាន់ទាំង១.២៩៦នាក់នាក់នេះ ត្រូវបានធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ហើយធ្វើតេស្តសំណាកនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាលើកទី១ ត្រូវបានប្រកាសថាអវិជ្ជមានទាំងអស់ ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្ត បានឲ្យដឹងថា នៅខេត្តបន្ទាយមានជ័យមានត្រៀមមណ្ឌលចំនួន៦កន្លែងនៅតាមក្រុង-ស្រុក សម្រាប់ធ្វើចត្តាឡីស័កប្រជាពលរដ្ឋខ្មែរត្រឡប់ពីប្រទេសថៃ ។ ចំណែកប្រជាពលរដ្ឋនៅតាមខេត្តដទៃត្រូវដឹកតាមរថយន្តក្រសួងការពារជាតិ ទៅធ្វើចត្តាឡីស័កនៅឯស្រុកកំណើត ៕

## ពលករខ្មែរត្រឡប់ មកពីថៃ ៤០ នាក់ កំពុងធ្វើចត្តាឡីស័ក តាមវិធានការរបស់ក្រសួងសុខាភិបាល

https://www.rasmeinews.com/ 28 December, 20200

**ដោយៈ ទេពជ្រី / កំពង់ឆ្នាំងៈ** *លោកវេជ្ជបណ្ឌិត ប្រាក់ វុន ប្រធានមន្ទីរសុខាភិបាល ខេត្តកំពង់ឆ្នាំង នៅព្រឹកថ្ងៃទី ២៨ ខែធ្នូនេះ បានថ្លែងឲ្យក្រុមអ្នក សារព័ត៌មានដឹងថាៈ គិតត្រឹមថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០២០ នេះ មន្ទីរសុខាភិបាល កំពុងគ្រប់គ្រងពលករខ្មែរ ដែលត្រឡប់ មកពីប្រទេសថៃ ធ្វើចត្តាឡីស័ក ចំនួន ៤០ នាក់ ក្នុងនោះចំនួន ៣៧ នាក់ កំពុងធ្វើចត្តាឡីស័ក នៅក្នុងមណ្ឌល កម្រិត ២ សាលាគំរូក្រុងបារិត ក្នុងក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដោយឡែក ចំនួន ៣ នាក់ទៀត ធ្វើចត្តាឡីស័ក តាមផ្ទះនៅក្នុងស្រុក បរិបូណ៌*។ លោកប្រធានមន្ទីរសុខាភិបាល ខេត្តកំពង់ឆ្នាំង ក៏សូមអំពាវនាវផងដែរ ដល់ពលករទាំងអស់ ដែលត្រឡប់មកពីប្រទេសថៃ សូមចូលរួមធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ទៅតាមវិធានការ របស់ក្រសួងសុខាភិបាល ដើម្បីរួមគ្នាទប់ស្កាត់ជំងឺកូវីដ ១៩ កុំឲ្យរាលដាលឆ្លងចូល ក្នុងសហគមន៍យើង ។

ដោយឡែក លោក ស៊ិន ចាន់សារ៉េត ប្រធានមណ្ឌលចត្តាឡីស័ក កម្រិត ២ សាលាគំរូក្រុង បានអោយក្រុមអ្នកសារព័ត៌មាន ឲ្យដឹងថាៈ នៅក្នុងមណ្ឌល ចត្តាឡីស័ក កម្រិត ២ សាលា គំរូក្រុង គិតត្រឹមថ្ងៃទី២៧ ខែធ្នូនេះ កំពុងគ្រប់គ្រង និងព្យាបាលពលករ ដែលធ្វើចត្តាឡីស័ក សរុបចំនួន ៣៦ នាក់ ក្នុងនោះមានស្រី ៧ នាក់ ហើយក៏មានកុមារ ពីរនាក់ផងដែរ គឺប្រុស ម្នាក់ ស្រីម្នាក់។ ប៉ុន្តែពលករទាំងអស់ ខាងលើនេះ ពុំមែនជាពលករ ដែលមកពីខេត្ត សាមុតសាខន ប្រទេសថៃនោះទេ គឺមកពីខេត្តផ្សេងទៀត ក្នុងប្រទេសថៃ។ ដោយឡែក មណ្ឌលចត្តាឡីស័កកម្រិតពីនេះ មានបន្ទប់សរុប ចំនួន ១០ បន្ទប់ ហើយក៏កំពុងរៀបចំ បន្ទប់ថែម ១០ ទៀត ដើម្បីត្រៀមទទួលអ្នកធ្វើចត្តាឡីស័ក ។ លោកប្រធានមណ្ឌលចត្តាឡីស័ក បានបញ្ជាក់ថា គ្រូពេទ្យដែលកំពុងប្រចាំការ ពិនិត្យ និងព្យាបាលអ្នកធ្វើចត្តាឡីស័ក ក្នុងមណ្ឌលសាលាគំរូក្រុងនេះ សរុបមានចំនួន ៣ ក្រុម ដែលក្នុងមួយក្រុមៗ មានពី ៣ នាក់ ទៅ ៤ នាក់ ក្នុងនោះដែរ ក៏មានអ្នកស្ម័គ្រចិត្ត ដែលជា គ្រូពេទ្យចូលនិវត្តន៍ ចំនួន ១១ នាក់ ។ ដោយឡែក ចំពោះពលករ ដែលកំពុងធ្វើចត្តា ឡីស័កនេះ គឺបានធ្វើតេស្តអវិជ្ជមាន ម្តងរួចហើយ ពីព្រំដែន ។ ដូច្នេះគម្រប់ ១៤ ថ្ងៃ ក្រុមគ្រូ

ពេទ្យ នឹងយកសំណាក ទៅពិនិត្យជាលើកទី២ ម្តងទៀត បើពិនិត្យទៅអវិជ្ជមានកូវីដ ១៩ នោះ យើងនឹងអនុញ្ញាតឲ្យពួកគាត់ ត្រឡប់ទៅមូលដ្ឋានវិញ។ ប៉ុន្តែបើមានវិជ្ជមានកូវីដ ១៩ វិញនោះ យើងនឹងបន្តឲ្យពួកគាត់ ធ្វើចត្តាឡីស័ក យ៉ាងត្រឹមត្រូវ នៅក្នុងមណ្ឌលនេះ ជាបន្តទៀត។

ដោយឡែក ពលករ ២ នាក់ ដែលកំពុងធ្វើចត្តាឡីស័ក នៅក្នុងមណ្ឌលសាលាគំរូក្រុង បានបញ្ជាក់ឲ្យដឹងថាៈ ពួកគាត់ មកស្នាក់នៅធ្វើចត្តាឡីស័កនេះ ពុំមានផលលំបាកអ្វីទេ គឺត្រូវបានគ្រូពេទ្យ ឧបត្ថម្ភអាហារ ៣ ពេល យ៉ាងត្រឹមត្រូវ ហើយក៏មានកន្លែងសម្រាក កន្លែងមុជទឹក និងកន្លែងបត់ជើង បទដៃយ៉ាងត្រឹមត្រូវ។ ពួកគាត់ក៏សូមថ្លែងអំណរគុណ ដល់គ្រូពេទ្យ ក៏ដូចជា ប្រមុខរាជរដ្ឋាភិបាល ដែលបានជួយឧបត្ថម្ភថវិកា សម្រាប់ទិញអាហារ ដល់ពួកគាត់ ដែលកំពុងធ្វើចត្តាឡីស័ក តាមវិធានការក្រសួងសុខាភិបាល៕/V-PC

## រយៈពេលមួយសប្តាហ៍ ខេត្តបាត់ដំបងទទួលពលករខ្មែរមកពីប្រទេសថៃ ប្រមាណ១ពាន់នាក់

https://www.rasmeinews.com/ 28 December, 2020

**ដោយៈ គ្រញូង / បាត់ដំបង:** *ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបាត់ដំបង បានឲ្យដឹងថា រយៈពេលមួយសប្តាហ៍ ចាប់ពីថ្ងៃទី២១ ដល់២៨ ខែ ធ្នូ២០២០ ខេត្តបាត់ដំបង ទទួលពលករខ្មែរមកពីប្រទេសថៃប្រមាណ១ពាន់នាក់ ហើយកំពុងដាក់ក្នុងមណ្ឌលចត្តាឡីស័កទាំងអស់ ព្រមទាំងយកវត្ថុសំណាកពីពលករខ្មែរទាំងអស់ជារៀងរាល់ថ្ងៃ ក្នុងនោះមួយចំនួនធំទទួលលទ្ធផលអវិជ្ជមាន និងមួយចំនួនតូចទៀត កំពុងរង់ចាំលទ្ធផលនៃការវិភាគធ្វើតេស្តបន្តទៀត។*

លោកឱសថបណ្ឌិត រឿង ប៊ុនរ៉េត ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបាត់ដំបងបញ្ជាក់ថា ក្នុងចំណោមពលករប្រមាណ១ពាន់នាក់នេះ ភាគច្រើនរស់នៅតាមបណ្តាស្រុកជាប់ព្រំដែន ដូចជាស្រុកកំរៀង ស្រុកសំពៅលូន ភ្នំព្រឹក មោងឫស្សី សំឡូត បវេល ថ្មគោល និងស្រុករុក្ខគីរី នៃខេត្តបាត់ដំបង។ លោកប្រធានមន្ទីរបានឲ្យដឹងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ថា អាជ្ញាធរស្រុកកំរៀង និងអាជ្ញាធរខេត្តបាត់ដំបង បានទទួលយកពលករខ្មែរ និងរៀបចំធ្វើចត្តាឡីស័ក នៅតាមមណ្ឌលផ្សេងៗ សរុបចំនួន ៧៣២នាក់ ក្នុងនោះស្ត្រី និងក្មេង ២៩៥នាក់ ដែលបានសម្រុកចាកចេញពីប្រទេសថៃ កាត់តាមច្រកទ្វារព្រំដែនជាច្រើន ដូចជាច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ច្រកតំបន់មួយចំនួន ច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកទ្វារអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យជាដើម។ លោកបានបន្តថា អាជ្ញាធរខេត្ត បច្ចុប្បន្នបានរៀបចំមណ្ឌលធ្វើចត្តាឡីស័កដាក់ពលករខ្មែរ ឲ្យនៅដាច់ដោយឡែកមានជាច្រើនកន្លែងទៀត ពិសេសនៅតំបន់ជាប់ព្រំដែនដូចជាក្នុងបរិវេណវិទ្យាល័យកំរៀង មណ្ឌលសុខភាពត្រាង ក្នុងស្រុកកំរៀង នៅបរិវេណសាលាបឋមសិក្សាជ្រៃសីមាឃុំជ្រៃសីមាស្រុកសំពៅលូន និងមណ្ឌលចត្តាឡីស័កនៅក្នុងបរិវេណវិទ្យាល័យព្រះមុនីវង្សក្នុងក្រុងបាត់ដំបង ខេត្តបាត់ដំបង ជាដើម។

គួរបញ្ជាក់ថា ក្នុងរយៈពេលធ្វើចត្តាឡីរយៈពេល១៤ថ្ងៃ ពលករទាំងទទួលអាហារ៣ពេល និងព្យាបាលដោយឥតគិតថ្លៃ។ ពេលចប់ចត្តាឡីស័ករួច មានរថយន្តដឹកពលករទៅកាន់ស្រុកដល់ស្រុកកំណើតទៀតផង៕

## ក្នុង១ថ្ងៃ មានពលករខ្មែរចេញពីថៃតាមច្រកទ្វារព្រំដែនអូរស្មាច់១៥០នាក់

https://kampucheathmey.com/ December 28, 2020 By Kang Tola

ភ្នំពេញ ៖ លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យបានឲ្យដឹងដែរថា ក្នុង១ថ្ងៃគិតជាមធ្យមមានពលករខ្មែរចូលតាមច្រកព្រំដែនអូរស្មាច់ប្រមាណពី១៤០ ទៅ ១៥០នាក់ ក្នុងនោះមានពលករប្រមាណពី៤០ ទៅ ៥០នាក់ ប៉ុណ្ណោះមកពីខេត្តដែលមានប្រឈមនឹងជំងឺកូវីដ១៩ ដូចជាខេត្តសាមុតសាខននិង

ទីក្រុងបាងកកជាដើម។ លោកវេជ្ជបណ្ឌិតបានបន្តថា រយៈពេល១សប្តាហ៍នេះ ខេត្តឧត្តរមានជ័យទទួលបានពលករចូលមកតាមច្រកព្រំដែនអូរស្មាច់ប្រមាណ១០០០នាក់ ក្នុងនោះបានយកសំណាកទៅធ្វើតេស្តចំនួនជាង៣៣០នាក់និងកំពុងធ្វើចត្តាឡីស័កចំនួន៣០០នាក់។ ក្រៅពីនេះខេត្តបានបញ្ជូនពលករទៅតាមបណ្តាខេត្តនានាដែលជាស្រុកកំណើតរបស់ពលករ។

ទាក់ទិននឹងការធ្វើចត្តាឡីស័កនេះដែរ លោកអភិបាលខេត្តឧត្តរមានជ័យព្រមានចាត់វិធានការតាមច្បាប់ចំពោះពលករណារត់ចេញឬគេចវេសពីការធ្វើចត្តាឡីស័ក លោក ប៉ែន កុសល្យ អភិបាលនៃគណៈអភិបាលខេត្តនិងជាប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ខេត្តឧត្តរមានជ័យមានធ្វើការព្រមានចាត់វិធានការតាមច្បាប់ចំពោះបងប្អូនពលករខ្មែរទាំងឡាយណាដែលបានរត់គេចវេសមិនព្រមធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ តាមការណែនាំរបស់ក្រសួងសុខាភិបាល។ លោកបានមានប្រសាសន៍ថា«ប្រសិនបើបុគ្គលណាមិនគោរពតាមវិធានការរបស់ក្រសួងសុខាភិបាលដោយចត្តាឡីស័ក១៤ ថ្ងៃ ឬរត់ចេញ ឬគេចវេសពីការធ្វើចត្តាឡីស័កនឹងត្រូវផាកពិន័យចាប់ពី ២០០,០០០ រៀលទៅ១,០០០,០០០ រៀលនិងទោសព្រហ្មទណ្ឌ»។ លោកបានមានប្រសាសន៍បន្តថា ការដាក់បងប្អូនពលករឲ្យនៅដាច់ដោយឡែករយៈពេល១៤ ថ្ងៃនេះគឺក្នុងគោលបំណងបង្កើន ការយកចិត្តទុកដាក់ខ្ពស់បំផុតដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ហើយចំពោះការធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃនេះដែរ រដ្ឋបាលខេត្តក៏បានយកចិត្តទុកដាក់ចំពោះការផ្គត់ផ្គង់ចំពោះការស្នាក់នៅចំណីអាហារ និងសម្ភារប្រើប្រាស់មួយចំនួនជូនពលករផងដែរ៕

## ស្ត្រីម្នាក់ រងគ្រោះកណ្តោចកណ្តែងម្នាក់ឯង នៅប្រទេសចិន អស់រយៈពេលជិត១០ឆ្នាំ ដោយសារតែចាញ់បោកមេខ្យល់ ពេលនេះ នាងបានជួបជុំក្រុមគ្រួសារ វិញហើយ

http://www.arey-news.com/ (ថ្ងៃទី 28 December 2020 ម៉ោង 10:02 am)

ព្រះសីហនុ: នៅល្ងាចថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០នេះ ស្ត្រីម្នាក់រងគ្រោះកណ្តោចកណ្តែងម្នាក់ឯង នៅប្រទេសចិន អស់រយៈពេលជិត១០ឆ្នាំ ដោយសារតែចាញ់បោកមេខ្យល់ ពេលនេះ នាងបានជួបជុំក្រុមគ្រួសារ វិញហើយ បន្ទាប់ពីនាងបានឆ្លងផុតកន្លែងចត្តាឡីសក្ក ១៤ថ្ងៃនៅខេត្តព្រះសីហនុ។

ក្រុមការងារ លោកស្រី អ៊ូ ធីតាពៅ គួច ចំរើន បានជូនមកដល់ស្រុកកំណើតដោយសុវត្ថិភាព និងជួបជុំគ្រួសារវិញហើយ ដោយមានការសហការណ៍ចូលរួមពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស អង្គការរតនៈ និងអាជ្ញាធរមូលដ្ឋាន។ ស្ត្រីរងគ្រោះ ឈ្មោះ ណេ សំណាង ទើបវិលមកពីប្រទេសចិន និងបានបញ្ចប់ការធ្វើចត្តាឡីសក្តិនៅខេត្តព្រះសីហនុ មុននិងជូនដំណើរគាត់ទៅស្រុកកំណើតនៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ លោកស្រីអ៊ូ ធីតាពៅ គួច ចំរើន ក៏បានមានប្រសាសន៍សួរសុខទុក្ខ ផ្តាំផ្ញើ និងបានជួយឧបត្ថម្ភនូវថវិកា ១.០០០.០០០ រៀល( មួយលានរៀល ) ៕

## មន្ត្រីអំពាវនាវកុំឱ្យពលករខ្មែរនៅថៃផ្លាស់ប្តូរកន្លែងស្នាក់នៅ ក្នុងអំឡុងកូវីដកំពុងរាលដាល

https://www.postkhmer.com/ មុំ គន្ធា | Publication date 28 December 2020 | 11:09 ICT

**ភ្នំពេញ:** មន្ត្រីកម្ពុជាបានអំពាវនាវដល់ពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ សូមកុំផ្លាស់ប្តូរទីកន្លែងស្នាក់នៅ និងវិលត្រឡប់មកស្រុកកំណើតវិញ បើមិនមានការចាំបាច់ ដោយប្រាប់ថាក្នុងអំឡុងពេលដែលជំងឺកូវីដ ១៩ កំពុងរីករាលដាល អាជ្ញាធរថៃ មិនចាប់ខ្លួនពលករខ្មែរនោះទេ បើទោះបីជាកំពុងស្នាក់នៅ និងធ្វើការដោយខុសច្បាប់ក៏ដោយ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអំពាវនាវតាមបណ្តាញទំនាក់ទំនងសង្គមរបស់លោកថា ពលករដែលនៅប្រទេសថៃ ទោះខុស ឬត្រូវច្បាប់ សូមកុំផ្លាស់ប្តូរទីកន្លែងស្នាក់នៅ និង

ធ្វើការហើយមិនចាំបាច់វិលមកស្រុកកំណើតវិញទេ បើគ្មានធុរៈចាំបាច់។ លោកថ្លែងថា៖ «អាជ្ញាធរថៃមិនចាប់ខ្លួនពលករដែលស្នាក់នៅមួយកន្លែងនោះទេ។ សូមបងប្អូនរក្សាភាពនឹងនរ និងសហការជាមួយអាជ្ញាធរថៃ»។

ចំណែកលោក គឹម ចំរើន ទីប្រឹក្សាស្ថានទូតកម្ពុជាទទួលបន្ទុកពលករនៅប្រទេសថៃបានឱ្យដឹងថា លោកបានជួបពិភាក្សាជាមួយលោក ស៊ូឆាត ឈុំគ្លីន រដ្ឋមន្ត្រីក្រសួងការងារថៃដើម្បីដោះស្រាយ និងទប់ស្កាត់ការរាតត្បាតជំងឺកូវីដ ១៩។ លោកថ្លែងថា៖ «យើងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលថៃ ដោយភាគីថៃនឹងជូនដំណឹងផ្លូវការ បើមានករណីមានបងប្អូនខ្មែរមានឆ្លងជំងឺកូវីដ ១៩ ព្រមទាំងទទួលព្យាបាលដូចជនជាតិថៃផងដែរ»។ លោកអំពាវនាវសូមឱ្យពលករខ្មែរ រក្សាភាពនឹងនរ កុំចល័ត ឬរត់គេចពីមួយកន្លែងទៅមួយកន្លែងក្នុងអំឡុងមានការរីករាលដាលជំងឺកូវីដ ១៩ ថ្មីៗនេះ ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ ១៩ ទាំងអស់គ្នា។ លោក ចំរើន បន្តថា៖ «ក្នុងអំឡុងពេលនេះ មិនមានការចុះចាប់ឃុំខ្លួន (ពលករ) ឡើយ ហើយអាជ្ញាធរថៃកំពុងរៀបចំគោលនយោបាយដើម្បីជួយបងប្អូនពលករដែលមិនមានឯកសារស្នាក់នៅ និងធ្វើការអាចបន្តស្នាក់នៅ និងធ្វើការជាបណ្ដោះអាសន្នបន្តទៀតបាននៅក្នុងប្រទេសថៃ»។ ស្ថានទូតខ្មែរប្រចាំប្រទេសថៃ បានចែកអំណោយដល់ពលករខ្មែរនៅជាយទីក្រុងបាងកកជាប់ព្រំប្រទល់ខេត្តសាមុតសាខនកាលពីថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ប្រមាណជាជិត ២០០ គ្រួសារដែលកំពុងរងផលប៉ះពាល់ចំពោះជីវភាពប្រចាំថ្ងៃ ក្រោយពីអាជ្ញាធរថៃបានរឹតបន្តឹងការចេញ-ចូល ក្នុងតំបន់មួយចំនួន។ អំណោយរបស់រាជរដ្ឋាភិបាលកម្ពុជាចែកជូនទៅដល់ពលករទាំងនោះមានអង្ករ មី ត្រីខ ទឹកស៊ីអ៊ីវ ស្ករស អំបិល និងម៉ាស់។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលនៅថ្ងៃទី ២៥ ខែធ្នូ ក៏បានឱ្យដឹងថា ពលករខ្មែរម្នាក់ក្នុងចំណោមពលករប្រមាណ ១០ នាក់ បានធ្វើតេស្តវិជ្ជមានកូវីដ ១៩ កាលពីថ្ងៃទី ២៣ ខែធ្នូ ប៉ុន្តែពលកររូបនេះមិនមែនមានកូវីដ១៩ពីកម្ពុជារួចហើយឆ្លងទៅប្រទេសថៃនោះទេ។ លោកស្រីថ្លែងថា៖«អ្វីដែលខ្ញុំទទួលបានព័ត៌មានគឺពលករទាំងនេះបានចេញពីខេត្តឈុនបូរីទៅទីក្រុងបាងកកនៅក្នុងពេលថ្មីៗនេះ ហើយត្រូវបានអាជ្ញាធរថៃរកឃើញមានកូវីដ ១៩ ម្នាក់។ ដូច្នេះមិនមែនគាត់មានកូវីដ១៩ពីកម្ពុជា រួចបានចូលប្រទេសថៃនោះទេ»។ ពួកគាត់បានចេញទៅថៃតាំងពីមុនមានហេតុការណ៍ផ្ទុះឡើងនូវការរកឃើញវីរុសកូវីដ ១៩ នៅខេត្តសាមុតសាខន។ ដោយមានបទបញ្ជាណែនាំពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្រសួងសុខាភិបាលបានសម្រេចអនុញ្ញាតឱ្យគ្រប់ភោជនីយដ្ឋាន និងហាងលក់ទំនិញដែលជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា បើកដំណើរការឡើងវិញចាប់ពីថ្ងៃទី ២៧ ខែធ្នូ ប៉ុន្តែកន្លែងទាំងនោះត្រូវនៅបន្តអនុវត្តតាមវិធានអនាម័យកូវីដរបស់ក្រសួងសុខាភិបាលឱ្យបានត្រឹមត្រូវ។ បើតាមក្រសួងសុខាភិបាល អ្នកជំងឺកូវីដ ១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកាចំនួន ៣៧ នាក់ក្នុងចំណោមអ្នកជំងឺសរុបចំនួន ៤១ នាក់ ត្រូវបានព្យាបាលជាសះស្បើយដែលនៅសល់តែអ្នកជំងឺចំនួន ៤ នាក់ទៀតប៉ុណ្ណោះ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យគិតត្រឹមថ្ងៃម្សិលមិញ។

ជាមួយគ្នានេះដែរ លោកស្រី ឱ វណ្ណឌីន បានចេញសេចក្តីណែនាំដល់ម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់ឱ្យសហការទប់ស្កាត់ កុំឱ្យមានការរាតត្បាតជំងឺកូវីដ ១៩ ទ្រង់ទ្រាយធំក្នុងសហគមន៍ដោយត្រូវបញ្ជូនអ្នកសង្ស័យមានជំងឺកូវីដ ១៩ ពីមូលដ្ឋានរបស់ខ្លួន ទៅមន្ទីរពេទ្យបង្អែករដ្ឋនៅទូទាំងខេត្ត និងមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត។ ក្រសួងមិនអនុញ្ញាតឱ្យធ្វើការពិនិត្យ និងព្យាបាល អ្នកជំងឺដែលសង្ស័យថា ជាជំងឺកូវីដ ១៩ នៅតាមកន្លែងពិនិត្យព្យាបាលអ្នកជំងឺឯកជនរបស់ខ្លួនឡើយ។ បើតាមក្រសួងសុខាភិបាលកាលពីថ្ងៃម្សិលមិញមានអ្នកជំងឺកូវីដ ១៩ ម្នាក់ ដែលជាអ្នកដំណើរបានជាសះស្បើយ និងមានអ្នកដំណើរម្នាក់មានតេស្តវិជ្ជមានកូវីដ ១៩។ អ្នកដែលជាសះស្បើយជាស្ត្រីជនជាតិខ្មែរអាមេរិក អាយុ ៦៦ ឆ្នាំស្នាក់នៅសណ្ឋាគារ ១ ក្នុងរាជធានីភ្នំពេញ ធ្វើដំណើរមកពីសហរដ្ឋអាមេរិកបន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង បានព្យាបាលជាសះស្បើយ បន្ទាប់ពីធ្វើតេស្តអវិជ្ជមានកូវីដ ១៩ ចំនួន ២ ដង និងត្រូវបានអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យផងដែរ។ ចំណែកបុរសជនជាតិឥណ្ឌូនេស៊ីអាយុ

៤៣ ឆ្នាំ ស្នាក់នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញបានធ្វើដំណើរពីប្រទេសសិង្ហបុរីតាមជើងហោះហើរមកដល់កម្ពុជានៅថ្ងៃទី ២៥ ខែធ្នូ និងមានលទ្ធផលតេស្តវិជ្ជមានកូវីដ ១៩ ត្រូវបានដាក់សម្រាកព្យាបាលនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។ អ្នកដំណើរចំនួន ៥០ នា ក់ដែលបានធ្វើដំណើរតាមជើងយន្តហោះជាមួយអ្នកដំណើររូបនេះត្រូវបានធ្វើតេស្តអវិជ្ជមានកូវីដ១៩ និងបានដាក់ឱ្យធ្វើចត្តាឡីស័កចំនួន ១៤ ថ្ងៃនៅសណ្ឋាគារ ២ ផ្សេងគ្នាក្នុងរាជធានីភ្នំពេញ។ គិតត្រឹមថ្ងៃម្សិលមិញ កម្ពុជាមានអ្នកមានវីរុសក្ស៊ូរ៉ណាចំនួន ៣៦៤ នាក់ ក្នុងនោះអ្នកព្យាបាលជាសះស្បើយសរុបចំនួន ៣៥៦ នាក់ និងអ្នកជំងឺកំពុងសម្រាកព្យាបាលចំនួន ៨ នាក់៕

## ពលករខ្មែរម្នាក់ធ្លាក់ខ្លួនពិការបន្ទាប់ពីរងគ្រោះថ្នាក់ការងារក្នុងពេលធ្វើការនៅថៃ

https://www.rfa.org/khmer/ ដោយ វ៉ែន សុមេធ 2020-12-28

ពលករខ្មែរម្នាក់ធ្លាក់ខ្លួនជាជនពិការទាំងវ័យក្មេង បន្ទាប់ពីរូបគេជួបគ្រោះថ្នាក់ក្នុងពេលធ្វើការងារនៅប្រទេសថៃ កាលពីថ្ងៃទី២៣ ធ្នូ។ ពលកររូបនេះកំពុងសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យក្បែរទីក្រុងបាងកក ដោយគ្មានសាច់ញាតិនៅមើលថៃឡើយ។ មន្ត្រីសង្គមស៊ីវិលយល់ថា រឿងនេះពលករមានសិទ្ធិបានទទួលការព្យាបាលរបួសដោយឥតគិតថ្លៃ និងបានប្រាក់សំណងពីថៅកែ។

ពលករមានស្រុកកំណើតនៅខេត្តព្រៃវែង លោក ឈុន ឌី ឱ្យអាស៊ីសេរីដឹងក្នុងពេលសម្រាកព្យាបាលរបួសថា ដៃស្តាំរបស់គាត់ចូលក្នុងម៉ាស៊ីនកាត់ក្រដាសដាច់ម្រាម ៤ចំពាក់កណ្តាលបាតដៃ ក្នុងពេលលោកបំពេញការងារសំអាតម៉ាស៊ីននៅចុងម៉ោងធ្វើការ កាលពីរសៀលថ្ងៃទី២៣ ធ្នូ។ពលករវ័យ២២ឆ្នាំរូបនេះបន្តថា នៅពេលនោះលោកដួលសន្លប់ដោយដៃរបស់លោកជាប់នៅក្នុងម៉ាស៊ីនកាត់ក្រដាស ដោយមានខ្មែរនៅធ្វើការក្បែរនោះមកជួយបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យនៅឆាក់ឈើងសៅ (Chhak Cheurng Sao) ចម្ងាយប្រមាណ៦០គីឡូម៉ែត្រពីទីក្រុងបាងកក។ ពលកររូបនេះនិយាយដោយសំឡេងខ្សាវៗថា ស្ថានភាពរបួសរបស់លោកបានធូរស្រាលខ្លះហើយ បន្ទាប់ពីសម្រាកព្យាបាលអស់រយៈពេល ៥ថ្ងៃ ក៏ប៉ុន្តែលោកបានក្លាយខ្លួនជាជនពិការ បន្ទាប់ពីគ្រូពេទ្យកាត់ម្រាមដៃទាំង៤របស់លោកចេញ ដើម្បីព្យាបាលឱ្យឆាប់ជាសះស្បើយ៖ «ម៉ាស៊ីនហ្នឹងវាវិលទៅខ្ញុំមើលអត់ឃើញទៅម៉ាស៊ីនទាញដៃខ្ញុំចូលក្នុងម៉ាស៊ីនបណ្តោយ វាគាបបែកខ្ទេច។ ខ្ញុំនៅតែឈឺ ហើយបើឈឺខ្លាំងហៅពេទ្យមកចាក់ថ្នាំឱ្យ។ ខ្ញុំមកធ្វើការស្រុកថៃចង់ស្គាល់ប្រទេសគេ ដល់មកទៅជួបគ្រោះថ្នាក់អីចឹង។ ម៉ាក់ខ្ញុំកាលដំបូងគាត់សន្លប់ ដល់ពេលឥឡូវគាត់លែងអីហើយ គាត់កាត់ចិត្តបាន គាត់អត់អាចមកកើតទេ គ្រាន់អ្នកនៅថៃនេះចង់មកលែងគេអត់ឱ្យចូលផង»។

ទោះជាយ៉ាងណា លោក ឈុន ឌី មិនទាន់សម្រេចចិត្តយ៉ាងណានៅឡើយទេ ដោយរង់ចាំមើលការដោះស្រាយរបស់ភាគីក្រុមហ៊ុនសិន ទើបលោកពិភាក្សាជាមួយឪពុកម្តាយនៅស្រុកខ្មែរនៅពេលក្រោយ។ ពលកររូបនេះធ្វើការនៅប្រទេសថៃជាលើកដំបូង ដោយស្របច្បាប់ក្នុងរោងចក្រក្រដាសនៅខេត្តឆាក់ឈើងសៅ (Chhak Cheurng Sao) កាលពីចុងឆ្នាំ២០១៨ រហូតដល់ថ្ងៃគ្រោះថ្នាក់មិនទាន់បានត្រឡប់ទៅផ្ទះនៅឡើយទេ។ លោក ឈុន ឌី ឱ្យដឹងថា ក្នុងពេលសម្រាកព្យាបាលរបួសនោះ បានពលករខ្មែរម្នាក់នៅកំដរតាំងពីថ្ងៃដំបូងរហូតមក ដោយពុំមានសាច់ញាតិមកមើលថៃលោកនោះទេ ដោយសារអំឡុងពេលនេះអាជ្ញាធរកម្ពុជា និងថៃបិទច្រកទ្វារព្រំដែនប្រទេសទាំងពីរបណ្តាលមកពីវិបត្តិជំងឺកូវីដ១៩។ ពលករខ្មែរមានស្រុកកំណើតនៅកំពង់ធំដែលនៅកំដរជនរងគ្រោះប្រាប់អាស៊ីសេរីថា លោករន្ធត់ចិត្តយ៉ាងខ្លាំងនៅពេលឃើញជនរងគ្រោះពិការដៃទាំងវ័យក្មេងបែបនេះ។ ពលករវ័យ៣០ឆ្នាំរូបនេះប្រាប់ថា ក្នុងថ្ងៃកើតហេតុនោះ លោកធ្វើការចម្ងាយប្រមាណ ១៥ម៉ែត្រពីជនរងគ្រោះ និងបានឮសំឡេងលោក ឈុន ឌី ស្រែកហៅឱ្យគេជួយ ដោយប្រាប់ថា ដៃរបស់គាត់ចូលក្នុងម៉ាស៊ីនហើយ។ លោកនិយាយថា ភ្លាមៗនេះលោកបានទៅជួយ និងបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យជាមួយបុគ្គលិករោងចក្រមួយចំនួនទៀត ជាពល

ករខ្មែរដូចគ្នា៖ «ខ្ញុំភ័យហើយណា គឺអាណិតក្មេងណាស់គ្នាអត់មានអ្វីជាជំហរទៀតទេ ទៅអនាគតព្រោះអីគ្នាខូចដៃហើយទៅធ្វើអីកើត បើធ្វើការគ្រប់យ៉ាងគឺដៃស្តាំហ្នឹងយើង។ ដល់ពេលអីចឹងខ្ញុំមានតែការសោកស្តាយប៉ុណ្ណឹងហ្នឹងព្រោះអីខ្ញុំមិនអាចជួយអីឱ្យលើសពីហ្នឹងទៀតបាន។ ដល់ពេលអីចឹងខ្ញុំសុខចិត្តបណ្តោះពីការងារមកជួយមើលថែអីចឹងទៅ ដល់ពេលបានគ្រាន់អាចនៅក្នុងពេទ្យម្នាក់ឯងបានឬក៏អាចជាចេញបណ្តោយអាហ្នឹងចាំគិតតទៅមុខទៀត»។

លោកឱ្យដឹងថា ថៅកែរោងចក្រជានាចេញថ្លៃព្យាបាលរបួសដល់ជនរងគ្រោះរហូតដល់ជាសះស្បើយ ក៏ប៉ុន្តែលោកពុំដឹងថា ខាងក្រុមហ៊ុនមួយនេះនឹងផ្តល់សំណងជាប្រាក់ប៉ុន្មានដល់ជនរងគ្រោះនោះទេ។ ទោះជាយ៉ាងណាលោកថា កន្លងមកមានជនជាតិថៃជួបគ្រោះថ្នាក់ការងារដូចគ្នាដែរ ដោយទទួលបានប្រាក់សំណងពីថៅកែរោងចក្រ៖ «ប៉ុន្តែរោងចក្រគេនិយាយដែរថ្លៃថ្នាំ ថ្លៃសម្រាកពេទ្យហ្នឹងគេចេញឱ្យទាំងអស់ ហើយដល់ពេលដៃហើយគេឱ្យធ្វើការនៅកន្លែងគេហ្នឹងមួយជីវិត។យើងចង់ធ្វើមួយជីវិតក៏ធ្វើទៅ ហើយជាដៃហើយយើងចង់ទៅផ្ទះវិញក៏ទៅ។ ប៉ុន្តែគេថាឱ្យយើងនៅធ្វើហ្នឹងរហូតយើងមិនបាច់ចេញទៅណា គេដើររឿងឱ្យយើងនៅធ្វើការហ្នឹងរហូត ប៉ុន្តែរឿងលុយសំណងគេអត់និយាយត្រូវ។ ថៅកែអត់ទាន់មកផ្ទាល់ទេ តែអ្នករងថៅកែរោងចក្រគេមកនិយាយអីចឹង»។

អាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ និងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី២៧ធ្នូ ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។ ប៉ុន្តែមន្ត្រីស្ថានទូតខ្មែរនៅទីក្រុងបាងកកទទួលបន្ទុកផ្នែកពលករលោក គឹម ចំរើន និយាយនៅក្នុងហ្វេសប៊ុក ស្ថានទូតនៅរសៀលថ្ងៃទី២៧ ធ្នូ ថា អំឡុងពេលជំងឺកូវីដ១៩កំពុងតែផ្ទុះលើកទី២ នៅប្រទេសថៃនេះ ប្រសិនបើពលករខ្មែរណាមានបញ្ហាអ្វីអាចទាក់ទងមន្ត្រីស្ថានទូតតាមរយៈហ្វេសប៊ុកទីប្រឹក្សាស្ថានទូតទទួលបន្ទុកពលករប្រចាំនៅប្រទេសថៃ ដើម្បីផ្តល់ប្រឹក្សានិងជួយដោះស្រាយបញ្ហាផ្សេងៗរបស់ពលករគ្រប់ពេលវេលា។

ទាក់ទិនបញ្ហាពលករគ្រោះថ្នាក់ការងារនេះ អ្នកបកប្រែភាសាថៃ និងជាអ្នកការពារសិទ្ធិពលករខ្មែរនៅប្រទេសថៃ លោក ប្រាក់ ចិត្រា មានប្រសាសន៍ថា ពលករខ្មែរដែលជួបគ្រោះថ្នាក់ការងារ និងរងការរំលោភសិទ្ធិការងារពីសំណាក់ថៅកែ ភាគច្រើនមិនហ៊ានប្តឹងរកយុត្តិធម៌នោះទេ ដោយខ្លាចមានបញ្ហាដល់ពួកគេទៅថ្ងៃក្រោយ។ លោកថា ការធ្វើបែបនេះជារឿងមិនល្អឡើយ ពីព្រោះធ្វើឱ្យពលករខាតបង់អត្ថប្រយោជន៍ ហើយងាយរងការរំលោភបំពានសិទ្ធិការងារពីសំណាក់ថៅកែ។ លោក ឱ្យដឹងថា នៅក្នុងឆ្នាំ២០២០នេះ មានពលករខ្មែរប្រមាណ៣០នាក់បានស្នើឱ្យលោកជួយអន្តរាគមន៍ដល់ពួកគេ ក្នុងនោះមានពលករខ្មែរ៦នាក់ប៉ុណ្ណោះ ដែលទទួលបានយុត្តិធម៌ ចំណែកអ្នកផ្សេងទៀតបានដកខ្លួនវិញ ដោយមិនហ៊ានប្រឈមមុខជាមួយថៅកែឡើយ៖ «ចំពោះករណីនេះខ្ញុំចង់ឱ្យពលករហ្នឹងព្យាបាលឱ្យជារួចរាល់សិន តើខាងភាគីក្រុមហ្នឹងដំណើរការបែបណាដល់គាត់។ បើសិនខាងក្រុមហ៊ុនមិនផ្តល់សំណង ឬមិនផ្តល់យុត្តិធម៌ដល់ពលករ គាត់អាចទំនាក់ទំនងដល់អង្គការអិលភីអ៊ិន(LPN)បានដើម្បីឱ្យអង្គការហ្នឹងចុះទៅពិនិត្យករណីនេះ។ ពីព្រោះនៅពេលនេះគឺជាស្ថានភាពមួយដែលជំងឺកូវីដកំពុងតែរាតត្បាត កាលណាពលករមានគ្រោះថ្នាក់អីគាត់មិនអាចដំណើររឿងរ៉ាវបានទេ ហើយសាច់ញាតិមកមើលថៃ និងមកតាមដានគាត់វាលំបាក»។

ចំណែកមន្ត្រីអង្គការសង់ត្រាល់(CENTRAL) លោក ឌី ថេហូយ៉ា និយាយថា ច្បាប់ការងាររបស់ថៃ គឺពលករស្របច្បាប់នៅពេលពួកគេជួបគ្រោះថ្នាក់ការងារ ថៅកែត្រូវចេញថ្លៃព្យាបាលរបួសនិងផ្តល់ប្រាក់សំណងដល់ពួកគេ។ លោកបន្ថែមថា រឿងនេះ ប្រសិនបើភាគីក្រុមហ៊ុនមិនបានអនុវត្តតាមច្បាប់ការងារទេ ជនរងគ្រោះត្រូវប្តឹងទៅស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ឬអង្គការសង្គមស៊ីវិលដើម្បីឱ្យជួយអន្តរាគមន៍ពួកគាត់។ បន្ថែមពីនេះលោកថាពលករដែលមានបញ្ហាក្នុងពេលធ្វើការងារគួរតែបង្ហោះព័ត៌មានពីទុក្ខលំបាករបស់ពួកគេ ដើម្បីឱ្យស្ថាប័នពាក់ព័ន្ធបានដឹងនិងចុះទៅជួយពួកគេឱ្យទាន់ពេលវេលា៖ «លំបាកហ្នឹងគឺទីមួយគឺកើតចេញពីគាត់ខ្លួនឯងផ្ទាល់តែម្តង អត់ដឹងថា ទាក់ទងទៅអ្នកណាស្ថាប័នណាអាចជួយគាត់បាន។ ទី២ការឆ្លងតបរបស់អង្គការរដ្ឋលើបញ្ហាកើតឡើងរបស់

ពលករខ្មែរ ទី៣រដ្ឋទទួលហ្នឹងគឺមិនសូវយកចិត្តទុកស្វែងរកយុត្តិធម៌ឱ្យជនរងគ្រោះទេ។ កត្តាបីហ្នឹងដែលជាឧបសគ្គដល់ពលរដ្ឋខ្មែរយើងនិយាយរួមការទទួលបានយុត្តិធម៌ហ្នឹងហាក់ដូចជាជួបបញ្ហាលំបាក»។

## ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២០

### ប្រសាសន៍សំខាន់ៗសម្តេចតេជោ ហ៊ុន សែន ក្នុងឱកាសថ្លែងសារផ្ញើជូនជនរួមជាតិខ្មែរ ពាក់ព័ន្ធការបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា, ខួប២២ឆ្នាំនៃនយោបាយឈ្នះឈ្នះ និងការទទួលបានដំណាក់ប្រេងលើកដំបូងរបស់កម្ពុជា

http://www.freshnewsasia.com/ 2020-12-29 12:11pm

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នៅព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០នេះ បានថ្លែងសារពិសេសមួយចេញពីគេហដ្ឋាន នាក្រុងតាខ្មៅ ដោយផ្សាយផ្ទាល់តាមទូរទស្សន៍ជាតិកម្ពុជា និងផ្សាយបន្តផ្ទាល់ដោយប្រព័ន្ធផ្សព្វផ្សាយនានានៅក្នុងប្រទេសកម្ពុជាផងដែរ។ **សម្តេចតេជោ ហ៊ុន សែន បានថ្លែងសារពិសេសជិត៣ម៉ោង ផ្ញើជូនជនរួមជាតិខ្មែរ ពាក់ព័ន្ធការបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា, ខួប២២ឆ្នាំនៃនយោបាយឈ្នះឈ្នះ និងការទទួលបានដំណាក់ប្រេងដំបូងរបស់កម្ពុជា, ខាងក្រោមជាសារសំខាន់ៗរបស់សម្តេចតេជោ៖**

* សម្តេចតេជោ ហ៊ុន សែន ប្រកាសបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០នេះ

* សម្តេចតេជោ ហ៊ុន សែន សម្តែងការកោតសរសើរក្រសួងសុខាភិបាល មន្ត្រីពេទ្យ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋ ដែលចូលរួមទប់ស្កាត់កូវីដ១៩ និងបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា

* សម្តេចតេជោ ហ៊ុន សែន ថ្លែងអំណរគុណដល់ដៃគូ អង្គការសុខភាពពិភពលោក ដែលចូលរួមចំណែកក្នុងការទប់ស្កាត់ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា តាំងពីថ្ងៃទី២០ ខែធ្នូ រហូតមកដល់ពេលនេះ មិនទាន់មានពលករខ្មែរ ដែលនាំជំងឺកូវីដ១៩ ដែលកំពុងផ្ទុះឡើង នៅប្រទេសថៃ ចូលមកកម្ពុជានោះទេ

* សម្តេចតេជោ ហ៊ុន សែន ថ្លែងអំណរគុណដល់ លោកប្រាយុទ្ធ ច័ន្ទអូចា និងរដ្ឋាភិបាល ដែលបានយកចិត្តទុកដាក់ថែទាំពលករខ្មែរនៅក្នុងប្រទេសថៃ ដែលនេះស្តែងឱ្យឃើញពីទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ

* សម្តេចតេជោ ហ៊ុន សែន កោតសរសើរជាថ្មី ដល់ក្រសួងសុខាភិបាល ក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទ ដែលបានផ្តល់រថយន្ត ដល់ការដឹកជញ្ជូនពលករ ដើម្បីធ្វើចត្តាឡីស័ក

* សម្តេចតេជោ ហ៊ុន សែន អំពាវនាវដល់ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ បន្តរស់នៅក្នុងប្រទេសថៃបន្តទៀត ចៀសវាងចល័តពីកន្លែងមួយទៅកន្លែងមួយ

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា សម្តេចបានទទួលលិខិតរបស់ លោក ប្រាយុទ្ធ ច័ន្ទអូចា សុំឱ្យជួយទប់ស្កាត់ពលករខ្មែរចូលទៅប្រទេសថៃ អំឡុងពេលផ្ទុះជំងឺកូវីដ១៩ ហើយរឿងនេះសម្តេចក៏ធ្លាប់បានអំពាវនាវរួចហើយដែរ

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ឆ្លងកាត់ព្រឹត្តិការណ៍សហគមន៍២៨វិច្ឆិកា យើងបានកំពុងប្រយុទ្ធនឹងសមរភូមិ៣ រួមមានទី១៖ គឺការនាំចូល, ទី២៖ គឺការឆ្លងក្នុងសហគមន៍ដែលទើបនឹងឆ្លងកាលពីថ្ងៃទី២៨វិច្ឆិកា និង ទី៣៖ គឺការព្យាបាលឱ្យជាសះស្បើយ

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា មនុស្សមួយចំនួនបានជៀមដាមឱ្យយើងថា ពេទ្យខ្មែរពូកែណាស់ ហេតុអ្វីក៏ទៅរកពេទ្យបរទេស តែគេត្រូវដឹងថា ខ្មែរព្យាបាលអ្នកជំងឺកូវីដ ៣៦០នាក់ហើយជាសះស្បើយ ដែលភាគច្រើនជាជនបរទេស

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា យើងមិនរារាំងជនបរទេស ឬជនជាតិអង់គ្លេសចូលមកកម្ពុជាទេ ប៉ុន្តែយើងត្រូវគ្រប់គ្រងការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ
* សម្តេចតេជោ ហ៊ុន សែន រិះគន់អ្នកនយោបាយដែលនិយាយថា «នាំកូវីដ១៩មកចម្លងដល់គណបក្សប្រជាជនកម្ពុជាឱ្យងាប់ទាំងអស់» តែពួកគេកុំភ្លេចថា នៅកម្ពុជាមិនមែនមានតែគណបក្សប្រជាជនទេ គឺគណបក្សផ្សេងៗ និងសាច់ញាតិរបស់គេដែរ
* សម្តេចតេជោ ហ៊ុន សែន ថ្លែងរំលឹកថា កាលមុនកម្ពុជាចាប់លេខ១នៅអាស៊ី និងលេខ៣ នៅលើពិភពលោក ក្នុងការទប់ស្កាត់កូវីដ១៩ ប៉ុន្តែពេលនេះកម្ពុជាជាប់លេខ១លើពិភពលោក ក្នុងការទប់ស្កាត់កូវីដ១៩
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ទោះជាទទួលបានចំណាត់ថ្នាក់ល្អ ប៉ុន្តែយើងមិនត្រូវត្រេកអរទេ ដោយសារតែបញ្ហាកូវីដ១៩ នៅលើពិភពលោក មិនទាន់បិទបញ្ចប់ទេ
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា បន្ទាប់ពីចប់កូវីដ១៩ទៅ តើមានអីទៀត ឥឡូវនេះ មាន Covid-19 plus កើតនៅអាហ្វ្រិកខាងត្បូងរួចទៅហើយ
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា នៅឆ្នាំ២០២០ នឹងបញ្ចូលក្របខណ្ឌគ្រូពេទ្យ២ពាន់នាក់សិន ហើយឆ្នាំ២០២១ នឹងបញ្ចូល៣ពាន់នាក់ទៀត ប៉ុន្តែបើខ្វះត្រូវបញ្ចូលថែមទៀត
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា គ្រូពេទ្យដែលបញ្ចូលក្របខណ្ឌថ្មី ត្រូវតែហ៊ានប្រយុទ្ធនឹងជំងឺកូវីដ១៩
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ពេលនេះយើងត្រូវមានវិធានការមួយចំនួនដែលត្រូវប្រកាន់យក ក្នុងនោះមាន ៣ការពារ និង៣កុំ
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា សម្តេចបានពិភាក្សាជាមួយក្រសួងសុខាភិបាល និងសម្តេចក្រឡាហោម ស ខេង ដោយកំណត់ស្តង់ដារគម្លាតត្រឹម១,៥ម៉ែត្រឡើង ដើម្បីទប់ស្កាត់កូវីដ១៩ នៅកម្ពុជា ជំនួសឱ្យការកំណត់ចំនួនមនុស្សជួបជុំ
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ឥឡូវនេះនៅកម្ពុជាអាចជួបជុំគ្នាបានច្រើន អាស្រ័យលើទីតាំង ឱ្យតែរក្សាគម្លាតតាមស្តង់ដារសុវត្ថិភាព ដោយយក១,៥ម៉ែត្រជាគោល
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា រៀនតាមអនឡាញ ប្រហែលជាប្រសិទ្ធភាពតិច
* សម្តេចតេជោ ហ៊ុន សែន សម្រេចឱ្យយកថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ជាថ្ងៃបើកបវេសនកាល
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា មានជនខិតខូចមួយចំនួនបានចោទសម្តេចថា ធ្វើឱ្យខូចប្រព័ន្ធអប់រំ នៅពេលសម្រេចឱ្យសិស្សថ្នាក់ទី១២ ជាប់បាក់ឌុបដោយស្វ័យប្រវត្តិ ប៉ុន្តែសម្តេចត្រូវគិតពីសុវត្ថិភាពសិស្សជាអាទិភាពបំផុត
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា «គ្មាននរណាម៉ត់ចត់ជាង ហ៊ុន សែន»
* សម្តេចតេជោ ហ៊ុន សែន ប្រាប់ឱ្យសិស្សទាំងអស់ចំណាំមុខ អ្នកដែលចេញមុខប្រឆាំងជាមួយពួកគេ ដោយសារតែការសម្រេចឱ្យជាប់បាក់ឌុបដោយស្វ័យប្រវត្តិ
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា បើហ៊ុនសែនល្ងង់ មិនអាចដឹកនាំប្រទេសពីបាតដៃទទេរហូតមកដល់ពេលនេះបានទេ មិនអាចដឹកនាំការផ្តួលរំលំ មិនអាចចរចាបញ្ចប់សង្គ្រាមបានទេ។
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា «ជនបរទេសមួយចំនួនដែលប្រមាថ ហ៊ុន សែន គឺគ្រាន់តែជាអ្នករស់នៅបរទេសប៉ុណ្ណោះ ប៉ុន្តែមិនប្រាកដថា ខួរក្បាលរបស់អ្នកឯងល្អជាងហ៊ុនសែនទេ»
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ការជួបជុំណាមួយដែលមិនចាំបាច់ មិនបាច់ជួបជុំទេ ដូចជាការប្រជុំរបស់រដ្ឋអាចបន្តធ្វើតាមអនឡាញបាន
* សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន និងមណ្ឌលសេវាកម្មទេសចរណ៍ រៀបចំវិធានការដើម្បីទប់ស្កាត់កូវីដ១៩ ហើយផ្តល់សិទ្ធិឱ្យអាជ្ញាធរចុះបិទតែម្តង បើសិនមិនអនុវត្តវិធានការសុវត្ថិភាព

* សម្តេចតេជោ ហ៊ុន សែន ចេញមុខការពារជាថ្មីចំពោះ លោក ឆែម សាវុធ និងគ្រួសារ ព្រោះពួកគាត់ជាជនរងគ្រោះដោយសារកូវីដ១៩

* សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យអាជ្ញាធរពិនិត្យមើលអ្នកចំណូលថ្មីក្នុងមូលដ្ឋានខ្លួន ហើយត្រូវចាត់ចែងឱ្យធ្វើចត្តាឡីស័កបើពួកគាត់តើមកពីក្រៅប្រទេស ដោយមិនបានធ្វើចត្តាឡីស័កត្រឹមត្រូវ

* សម្តេចតេជោ ហ៊ុន សែន អំពាវនាវឱ្យរួមគ្នាទប់ស្កាត់ការឆ្លងជាសហគមន៍ជាថ្មីម្តងទៀត ក្រោយបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍២៨វិច្ឆិកា

* សម្តេចតេជោ ហ៊ុន សែន ប្រកាសដំណឹងល្អរបស់កម្ពុជា ថ្ងៃនេះដំណក់ប្រេងលើកដំបូងរបស់ខ្មែរ ដែលត្រូវបានចាប់ផ្តើមហើយ

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា បើគ្មានសន្តិភាព គឺគ្មានទេនូវអ្វីៗដូចសព្វថ្ងៃនេះរួមទាំងដំណក់ប្រេងលើកដំបូងផងដែរ

* សម្តេចតេជោ ហ៊ុន សែន បានរំលឹកពីព្រះបន្ទូលរបស់ ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ដែលថា សម្តេចជាកូនខ្មែរដែលឆ្លាត

* សម្តេចតេជោ ហ៊ុន សែន បានរម្លឹកជាថ្មីអំពីការយកជីវិតទៅប្តូរ កាលពី២ទសវត្សមុន ដើម្បីយកសន្តិភាពមកជូនប្រជាពលរដ្ឋខ្មែរ

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សង្គ្រាមកម្ពុជា ដែលកើតឡើងតាំងពីឆ្នាំ១៩៧០ ត្រូវបានបញ្ចប់ជាស្ថាពរក្រោមនយោបាយឈ្នះឈ្នះ ឆ្នាំ១៩៩៨

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ការបញ្ចប់សង្គ្រាមជាស្ថាពរនៅកម្ពុជា ត្រូវបានរាប់ចាត់តាំងពីថ្ងៃដែលមេដឹកនាំកំពូលរបស់ខ្មែរក្រហម មកចចារជាមួយសម្តេចដល់ផ្ទះ

* សម្តេចតេជោ ហ៊ុន សែន ទម្លាយថា ក្នុងពេលចរចានៅផ្ទះសម្តេច ឆ្នាំ១៩៩៨ សម្តេចបានជូនថវិកាទៅមេដឹកនាំខ្មែរក្រហមមួយគ្រួសារ១ម៉ឺនដុល្លារ

* សម្តេចតេជោ ហ៊ុន សែន ផ្តាំទៅ លោកចាន់ យ៉េត ប្រធានគណបក្សនយោបាយមួយ ឲ្យដកខ្លួនឲ្យឆ្ងាយ អំពីរឿងដីធ្លីនៅភូមិជង្រុក និងការបោកប្រាស់អ្នកដទៃ

* សម្តេចតេជោ ហ៊ុន សែន ប្រាប់ទៅ លោកទេសរដ្ឋមន្រ្តី ឱម យ៉ិនទៀង ឲ្យរកឯកសារឱ្យគ្រប់បើសិនជា លោក ចាន់ យ៉េត មិនដកខ្លួនពីរឿងដីធ្លី និងបោកប្រាស់អ្នកដទៃ ត្រូវចាប់ខ្លួនភ្លាម

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា យើងត្រូវរង់ចាំអស់រយៈពេល៣០ឆ្នាំ ទម្រាំរកឃើញប្រេងលើកដំបូងរបស់កម្ពុជាដូចពេលនេះ

* សម្តេចតេជោ ហ៊ុន សែន ប្រកាសថា គិតត្រឹមម៉ោង៥ល្ងាច ម្សិលមិញនេះ កម្ពុជាមានលុយ ១៣លានលានរៀល នៅក្នុងធនាគារជាតិ ខណៈទុនបម្រុងមានប្រមាណជាង២៣ពាន់លានរៀល ក្នុងនោះក៏មានបរិមាណមាស ៥៤តោន ៤០០គីឡូ ជាកេរមរតកសម្តេចនរោត្តមសីហនុ នៅប្រទេសស្វីស១២តោន៣០០គីឡូ តម្កល់ទុកនៅធនាគារកណ្តាលអង់គ្លេស១៧តោន ១៥តោននៅធនាគារជាតិកម្ពុជា

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា គិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២០ ទំហំពាណិជ្ជកម្ពុជាមានជាង៣០ពាន់លានដុល្លារ ក្នុងនោះកម្ពុជានាំចេញជា១៥ពាន់លានដុល្លារ ទោះបីជាកូវីដ១៩ តែការនាំចេញរបស់កម្ពុជាកើនឡើង

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា រដ្ឋាភិបាល ហ៊ុន សែន អត់ទាន់មានលុយប្រេងចាយ១សេនទេ ប៉ុន្តែរដ្ឋាភិបាល ហ៊ុន សែន នៅតែអាចរស់បាន

* សម្តេចតេជោ ហ៊ុន សែន ប្រកាសជាថ្មីថា សម្តេចនឹងបន្តកាន់តំណែងរហូតដល់អាយុ៧៨ឆ្នាំ គឺ១០ឆ្នាំទៀត

* សម្តេចតេជោ ហ៊ុន សែន៖ បក្សណាមិនដឹងទេ តែបក្សប្រជាជនកម្ពុជា គេធ្វើការជាក្រុម
* សម្តេចតេជោ ហ៊ុន សែន រំលឹកម្តងទៀតថា លោកឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន ជាបេក្ខជនមួយក្នុងចំណោមបេក្ខជននាយករដ្ឋមន្ត្រីដទៃទៀត
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា អ្នកឯងកាន់តែរិះគន់ ខ្ញុំកាន់តែនៅបន្តកាន់តំណែង
* សម្តេចតេជោ ហ៊ុន សែន បង្ហើបថា ពេលនេះក្រុមដែលចង់ផ្តួលរំលំសម្តេច កំពុងចង់ចរចា ប៉ុន្តែសម្តេចប្រកាសមិនចរចាជាមួយឡើយ គឺត្រូវតែអនុវត្តច្បាប់
*សម្តេចតេជោ ហ៊ុន សែន បានប្រកាសថាតំបន់ប្រេងនៅក្នុងសមុទ្ររបស់កម្ពុជាមិនមានការត្រួតស៊ីគ្នាជាមួយថៃទេ
* សម្តេចតេជោ ហ៊ុន សែន បានចាត់ទុកថា ដំណក់ប្រេងលើកដំបូងរបស់កម្ពុជា ជាពរជ័យជូនចំពោះប្រជាជាតិកម្ពុជា។ លុយដែលបានមក នឹងប្រើប្រាស់ក្នុងវិស័យអាទិភាព២ គឺអប់រំ និងសុខាភិបាល
* សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា បន្ទាប់ពីសម្តេចទៅគឺ សម្តេច ទៀ បាញ់ ជាតួអង្គដ៏សំខាន់នៅក្នុងនយោបាយឈ្នះឈ្នះ
* សម្តេចតេជោ ហ៊ុន សែន ប្រកាសបន្តឧបត្ថម្ភដល់កម្មករនិយោជិត ដែលបាត់បង់ការងារធ្វើអំឡុងពេលកូវីដ១៩ រយៈពេល៣ខែទៀត ដោយរដ្ឋាភិបាលជួយ ៤០ដុល្លារ ហើយថៅកែរោងចក្រចេញ៣០ដុល្លារក្នុងម្នាក់ៗក្នុង១ខែៗ
* សម្តេចតេជោ ហ៊ុន សែន បានប្រកាសថា កម្ពុជាកំពុងត្រៀមជំនួយម៉ាស និងបរិក្ខាពេទ្យបីប្រឆាំងកូវីដ១៩ ដល់ប្រទេសនេប៉ាល់ ដែលជាប្រទេសលំបាក
* សម្តេចតេជោ ហ៊ុន សែន ប្រកាសថា គិតត្រឹមម៉ោង២រសៀល ម្សិលមិញ រាជរដ្ឋាភិបាលបានទទួលថវិការ លុយដុល្លារ ៥៣ ៦៧៩ ៧១៤ដុល្លារ និងប្រាក់រៀល ៩ ៩៣៥ ៤៨៨ ៥០០រៀល ពីសប្បុរសជន ដើម្បីទិញវ៉ាក់សាំងប្រឆាំងកូវីដ១៩ ក្នុងនោះមានទាំងព្រះមហាក្សត្រផងដែរ
* សម្តេចតេជោ ហ៊ុន សែន អរព្រះគុណព្រះមហាក្សត្រ និងសម្តេចម៉ែ ដែលបានចូលរួមប្រទានថវិកា ដើម្បីទិញវ៉ាក់សាំង ព្រមទាំងអរគុណដល់សប្បុរសជននានាដែលបានចូលរួមផងដែរ
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ច្រកទ្វារសម្រាប់ទិញវ៉ាក់សាំងកូវីដ១៩ យកមកកម្ពុជា មាន៣ច្រក ក្នុងនោះមានតាមរយៈខូវ៉ាក់ ច្រកទី២ តាមរយៈទំនាក់ទំនងរវាងប្រទេសនិងប្រទេស និងច្រកទី៣ តាមរយៈការចរចាជាមួយក្រុមហ៊ុនផ្ទាល់តែម្តង
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជាត្រូវរង់ចាំរហូតមានការទទួលស្គាល់ជាក់លាក់ដោយ អង្គការសុខភាពពិភពលោក ទើបអាចបញ្ជាទិញវ៉ាក់សាំងបាន ព្រោះយើងមិនអាចយកប្រជាជនកម្ពុជាទៅពិសោធន៍វ៉ាក់សាំងនោះទេ
* សម្តេចតេជោ ហ៊ុន សែន ប្រតិកម្មនឹងអ្នកអត្ថាធិប្បាយថា សម្តេចចង់រំលងចោលនូវវ៉ាក់សាំងរបស់ចិន
* សម្តេចតេជោ ហ៊ុន សែន បញ្ជាក់ថា បើវ៉ាក់សាំងចិន ត្រូវបានទទួលស្គាល់ដោយ អង្គការសុខភាពពិភពលោកនោះ រឹតតែល្អថែមទៀតដោយសារតែចិននៅជិតនឹងកម្ពុជា
* សម្តេចតេជោ ហ៊ុន សែន ព្រមានមិនអត់ឲ្យអ្នកដែលប្រមាថប្រពន្ធ និងកូនរបស់សម្តេចជាកូននិងប្រពន្ធរបស់មេដឹកនាំវៀតណាម
* សម្តេចតេជោ ហ៊ុន សែន សុខចិត្តកាត់ដៃខ្លួនឯង បើសម្តេចអត់អោនឱ្យអ្នកដែលប្រមាថកូន និងប្រពន្ធរបស់សម្តេចថា ជាកូននិងប្រពន្ធរបស់មេដឹកនាំវៀតណាម
* សម្តេចតេជោ ហ៊ុន សែន បានបញ្ចប់ការថ្លែងសុន្ទរកថា នៅវេលាម៉ោង ១១៖៥២នាទីព្រឹកថ្ងៃដដែលនេះ៕

## អាជ្ញាធរខេត្តឧត្តរមានជ័យ ព្រមានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះមេខ្លោងនាំពលករលួចឆ្លងដែនខុសច្បាប់នៅតាមព្រំដែន

http://www.freshnewsasia.com/ 2020-12-29 12:54pm

**(ឧត្តរមានជ័យ)៖** អភិបាលខេត្តឧត្តរមានជ័យ លោក ប៉ែន កុសល្យ បានព្រមានចាត់វិធានការចំពោះមេខ្លោងដែលនាំពលករលួចឆ្លងដែនដោយខុសច្បាប់ បើចាប់បានគឺត្រូវចាប់ដាក់គុក ដូច្នេះសូមបងប្អូនប្រជាពលរដ្ឋ ជួយផ្សព្វផ្សាយបន្តនៅតាមមូលដ្ឋានផង។ ការព្រមានបែបនេះរបស់លោកអភិបាលខេត្តឧត្តរមានជ័យ ក្នុងឱកាសដែលលោកអញ្ជើញចូលរួមចែកមធ្យោបាយ សម្ភារដល់តំណាងប្រជាកសិករចំនួន ៤០រូប ដែលមកពីសហគមន៍កសិកម្មនិងបណ្តុំអាជីវកម្មដំណាំបន្លែ ស្រូវនិងដំណាំដំឡូងមី របស់កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធននិងការប្រែប្រួលអាកាសធាតុហៅកាត់ថាASPIRE «អាស្ព្រាយ» ប្រចាំឆ្នាំ២០២០ ដែលរៀបចំឡើងដោយមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទខេត្តឧត្តរមានជ័យ។ លោក ប៉ែន កុសល្យ បានថ្លែងថា ជំងឺកូវីដ១៩ រលកថ្មីនេះគឺសាហាវជាងមុន ដែលធ្វើឲ្យបងប្អូនពលករមកពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ជាមធ្យម ក្នុងមួយថ្ងៃប្រហែល ១៥០នាក់។ លោកថា បើសិនមានបងប្អូនរត់មកពីប្រទេសថៃត្រូវរាយការណ៍ភ្លាមមកមេភូមិ មេប៉ុស្តិ៍ ដើម្បីយកគាត់មកធ្វើចត្តាឡីសក័រយៈពេល១៤ថ្ងៃ រកសំណាកមេរោគកូវីដ១៩ ប៉ុន្តែបើយើងលាក់បាំងស្របពេលដែលសាច់ញាតិយើង ផ្ទុកមេរោគកូវីដ១៩មកពីប្រទេសថៃនោះ ច្បាស់ជាឆ្លងចូលសហគមន៍ហើយ ដូច្នេះភូមិរបស់យើងត្រូវតែបិទ ហើយយើងក៏មិនអាចដើរទៅណាបានដែរ។

លោកអភិបាលខេត្តថា តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តឧត្តរមានជ័យគឺច្រកបិទជិតទាំងអស់ ប៉ុន្តែបើមានមេខ្លោងនាំពលករលួចឆ្លងដែនដោយខុសច្បាប់ បើចាប់បានគឺត្រូវដាក់គុកហើយ ដូច្នេះសូមបងប្អូនប្រជាពលរដ្ឋ ជួយផ្សព្វផ្សាយបន្តតាមមូលដ្ឋានផង។ លោកថា អ្នកមកពីថៃ ឬមកពីស្រុកគេ បើអត់ធ្វើចត្តាឡីសក័រយៈពេល១៤ថ្ងៃ គឺប្រឈមនិងការមានទោសទណ្ឌ ប៉ុន្តែបើធ្វើចត្តាឡីស័កបាន៥ថ្ងៃ ហើយលួចរត់ បើគេចាប់បានវិញគឺត្រូវពិន័យជាប្រាក់២០ម៉ឺន រៀលទៅ១លានរៀល និងត្រូវជាប់ទោសទណ្ឌទៀត។ ជាមួយគ្នានេះដែរលោក ប៉ែន កុសល្យ បានសន្យានឹងជួយរកទីផ្សារជូនបងប្អូនប្រជាកសិករបន្ថែមទៀត ដើម្បីលើកកម្ពស់ជីវភាពគ្រួសារឲ្យកាន់តែប្រសើរឡើង ហើយលោកសំណូមពរឲ្យបងប្អូនប្រជាកសិករយើង ត្រូវមានភាពស្មោះត្រង់ក្នុងការផលិតក្នុងការដាំដំណាំ ពោលគឺមិនត្រូវប្រើប្រាស់ជីគីមីជ្រុលហួសហេតុ ដែលធ្វើឲ្យបាត់សេចក្តីទុកចិត្តពីអ្នកបញ្ជាទិញក៏ដូចជាប៉ះពាលដល់សុខភាពប្រជាពលរដ្ឋផងដែរ។

ដោយឡែកលោក សូត្រ ស៊ីសុខឃាង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទខេត្តព្រះវិហារ បានថ្លែងបញ្ជាក់ថា បណ្តុំអាជីវកម្មបន្លែចំនួន០៣បណ្តុំ ដោយបណ្តុំនីមួយៗទទួលបាន ម៉ាស៊ីនវាយបំបែកដី និងលើករងចំនួន៣០គ្រឿង ក្នុងនោះបណ្តុំស្រុកអន្លង់វែង១០គ្រឿង និងបណ្តុំស្រុកត្រពាំងប្រាសាទ២០គ្រឿង។ បណ្តុំអាជីវកម្មបន្លែចំនួន០៤បណ្តុំ (ក្រុងសំរោង) គឺផ្តល់ជូនផ្ទះសំណាញ់ដល់កសិករចំនួន០៤គ្រួសារ កសិករនៅភូមិអូរឬស្សី, កសិករនៅភូមិភ្នៀត, កសិករនៅភូមិគោកគរ សង្កាត់សំរោង និងកសិករនៅភូមិត្រពាំងវែង សង្កាត់កូនក្រៀល ក្រុងសំរោង។ បណ្តុំអាជីវកម្មស្រូវចំនួន០៤បណ្តុំ (ក្រុងសំរោង, ស្រុកចុងកាល់ និងស្រុកបន្ទាយអំពិល) គឺផ្តល់ជូន រថយន្ត ចំនួន៤គ្រឿង សំរាប់ ព្រួសស្រូវ បាញ់ថ្នាំ និងបាចជី)ក្នុងបណ្តុំនីមួយៗ ទទួលបាន១គ្រឿង។ បណ្តុំអាជីវកម្មដំឡូងមីចំនួន០២បណ្តុំ (ស្រុកអន្លង់វែង និងស្រុកបន្ទាយអំពិល) គឺគឺផ្តល់រថយន្តសំរាប់បាញ់ថ្នាំ ចំនួន២គ្រឿងសំរាប់ បាញ់ថ្នាំស្មៅ និងជីទឹក ក្នុងបណ្តុំនីមួយៗ ទទួលបាន១គ្រឿង។

**សូមបញ្ជាក់ថា បណ្តុំបន្លែខាងលើ បានកំពុងអនុវត្តកិច្ចសន្យាផលិតជាមួយក្រុមហ៊ុនដូចខាងក្រោម៖**

***ទី១៖** បានរៀបចំកិច្ចសន្យារវាងបណ្តុំអាជីវកម្មបន្លែជាមួយក្រុមហ៊ុនមាសបៃតងចំនួន០១កិច្ចសន្យា លើដំណាំផ្កាខាត់ណាលឿងទិញមួយថ្ងៃចំនួន ៣០០Kg តម្លៃ៤ ០០០រៀល/Kg រយៈពេល១ឆ្នាំ។

*ទី២៖ បានរៀបចំកិច្ចសន្យារវាងបណ្តុំអាជីវកម្មបន្លែជាមួយក្រុមហ៊ុនបន្លែសុវត្ថិភាពខ្មែរលើការផ្គត់ផ្គង់ដូចជា៖ *ឪឡឹកលឿងចំនួន ២ ០០០Kg/មួយថ្ងៃ តម្លៃ១ ៨០០រៀល/Kg រយៈពេល៣ខែ *ត្រសក់ផ្អែមចំនួន ៣០០ Kg/មួយថ្ងៃ តម្លៃ ៣ ០០០រៀល/Kg កិច្ចសន្យារយៈពេល១ឆ្នាំ *ខាត់ណាផ្កាលឿងចំនួន៥០០ Kg/មួយថ្ងៃ តម្លៃ៤ ០០០រៀល/Kg កិច្ចសន្យារយៈពេល៦ខែ និងកំពុងរៀបចរចារឿងកិច្ចសន្យាទិញត្រសក់ទ្រើងចំនួន ២០០០ Kg/មួយថ្ងៃ តម្លៃ៩០០រៀល/Kg។

នៅថ្ងៃនេះកសិករដែល ទទួលបាននូវម៉ាស៊ីនខាងលើ សុទ្ធតែជាកសិករគំរូ ដែលបានកំពុងដាំបន្លែ លក់ផ្គត់ផ្គង់លើទីផ្សារក្នុងស្រុក និងផ្គត់ផ្គង់អោយក្រុមហ៊ុន ឆ្ពោះទៅកាន់ទីផ្សាររាជធានីភ្នំពេញ ដើម្បីសំរួលដល់កំលាំង ពលកម្មរបស់ពួកគាត់ក្នុងការ ដាំដុះនិងមានលទ្ធភាពពង្រីកផ្ទៃដីឲ្យកាន់តែធំជាងមុន ធ្វើយ៉ាងណាឲ្យពួកគាត់ទទួលបានប្រាក់ចំណូលខ្ពស់ពី ខ្សែច្រវាក់ផលិតកម្មបន្លែ នៅតាមបណ្តុំនីមួយៗ។ ជាមួយគ្នាផងដែរ អង្គការ GIZ បានចែកជូននូវឧបករណ៍អូសដាំគ្រាប់ស្រូវ ចំនួន ៥គ្រឿង សំរាប់ផ្តល់ជូន ប្រជាកសិករនៅក្នុងសហគមន៍កសិកម្ម ចំនួន៤គ្រឿង គឺ អូរឫស្សី១ ខ្ញុំ២ ពង្ររុងរឿង១ ស្ថានីយ៍កសិកម្មកូនក្រៀល១គ្រឿង សំរាប់ជំរុញការផលិតស្រូវពូជ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ១១២នាក់ ពីអាជ្ញាធរថៃ

http://nokorwatnews.com/ 29-12-2020

ខេត្តបន្ទាយមានជ័យ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១១២នាក់ ស្រី ៤០នាក់ និងកុមារ ០៦នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរជាង៦០នាក់ឆ្លងដែនខុសច្បាប់ទៅថៃ ខណៈជាង២ពាន់នាក់ទៀត ត្រឡប់មកវិញ

https://thmeythmey.com/ 29, Dec 2020 , 11:29 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ ពលរដ្ឋខ្មែរជាង៦០នាក់ បានឆ្លងដែនខុសច្បាប់ទៅស្វែងរកការងារនៅថៃ ខណៈពលករជាង២ពាន់នាក់ បានត្រឡប់មកកម្ពុជាវិញ ស្របពេលថៃកំពុងផ្ទុះកូវីដ-១៩។ នេះបើតាមរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ។

លោក កែវ វណ្ណថន អ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបញ្ជាក់ថា ពលករខ្មែរ២១៨៥នាក់ ហើយ បានត្រឡប់ពីថៃមកកម្ពុជា ចាប់ពីថ្ងៃទី២០ដល់២៨ធ្នូនេះ ។ បើតាមលោក វណ្ណថន ពលករទាំងនោះ ចូលមកកម្ពុជាតាមច្រកអូរស្មាច់ ១២៩៥នាក់ ,ច្រកប៉ោយប៉ែត៤៤១នាក់ ហើយច្រកចាំយាម ដូង និងភ្នំដី៤៤៩នាក់។

របាយការណ៍ដែលសារព័ត៌មានថ្មីៗទទួលបាន ពីអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបញ្ជាក់ដូច្នេះថា៖ «ពលករដែលត្រឡប់មកពីថៃទាំងអស់ គឺតម្រូវឲ្យធ្វើចត្តាឡីស័កតាមការរៀបចំរបស់អាជ្ញាធរខេត្តយ៉ាងហ្មត់ចត់ ដែលបានសហការជាមួយមន្ត្រីសុខាភិបាល ដោយសារថៃកំពុងផ្ទុះកូវីដ-១៩ ពលរដ្ឋដែលត្រឡប់មកត្រូវតែបង្ការជៀសវាងការរីករាលដាលកូវីដ-១៩កាន់តែធំ»។ ទន្ទឹមនឹងពលករត្រឡប់ពីថៃ ក៏មានពលរដ្ឋខ្មែរជាង៦០នាក់ដែរ បានលួចឆ្លងដែនខុសច្បាប់ទៅថៃ ដើម្បីស្វែងរកការងារធ្វើ។ បើតាមអគ្គស្នងការនគរបាលជាតិ ពលរដ្ឋ៥២នាក់នៅខេត្តសៀមរាប បានឆ្លងដែនតាមច្រករបៀង ហើយបោះជំរំស្នាក់នៅលើទឹកដីថៃជាប់ព្រំដែនថៃ-កម្ពុជា កាលថ្ងៃទី២៥ ខែធ្នូ។ ពលរដ្ឋទាំងនោះ មានត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួនហើយចាប់បញ្ជូនឲ្យអាជ្ញាធរខ្មែរវិញ។ ដោយ

ឡែកពលរដ្ឋ១០នាក់ទៀត ត្រូវបានសមត្ថកិច្ចថៃបញ្ជូនឲ្យសមត្ថកិច្ចខ្មែរ តាមច្រកភពប៉ោយប៉ែតវិញកាលពីថ្ងៃទី២៧ធ្នូ។

កន្លងមកសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់ថវិកាសរុប៣៥០លានរៀល ដល់ខេត្តជាប់ប្រទេសថៃចំនួន៧ ដើម្បីចាត់ចែងការធ្វើចត្តាឡីស័ក និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ពីប្រទេសថៃ។ ខេត្តទាំង៧រួមមាន ខេត្តព្រះវិហារ ឧត្តរមានជ័យ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ពោធិ៍សាត់ និងខេត្តកោះកុង ដោយខេត្តនីមួយៗទទួលបាន ៥០លានរៀលទៀត។

សូមជម្រាបថា ចាប់តាំងពីថ្ងៃទី១៩ធ្នូ ដែលខេត្តសាមុតសាខន ប្រទេសថៃ ផ្ទុះកូវីដ-១៩មក អាជ្ញាធរបានរកឃើញអ្នកឆ្លងជាង១២០០ករណីហើយ។ រដ្ឋាភិបាលថៃ បានសម្រេចប្រកាសបិទខេត្តសាមុតសាខន រយៈពេល២សប្តាហ៍ ចាប់ពីថ្ងៃទី២០ធ្នូ ដល់ថ្ងៃទី៣មករាឆ្នាំ២០២១។ បន្ថែមពីនេះ ថៃបានដាក់បំរាមគោចរ អនុវត្តពីម៉ោង១០យប់ ដល់ម៉ោង៥ភ្លឺ។ ចំណែកការធ្វើដំណើរចេញពីខេត្តនេះ ក៏ត្រូវបានហាមឃាត់ដែរ។ តួលេខសរុប ថៃមានករណីឆ្លងកូវីដ-១៩ ចំនួន ៦៤៤០ករណី និងអ្នកស្លាប់មានចំនួន ៦១នាក់។ ចំណែកអ្នកជាសះស្បើយមានចំនួន ៤,១៨៤នាក់។

## គិតត្រឹមថ្ងៃទី២៩ ប្រជាពលរដ្ឋដែលវិលចូលប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិ អូរស្មាច់មាន ១០១នាក់

https://khmernote.com.kh/ December 29, 2020 srey nuch

ខេត្តឧត្តរមានជ័យ៖ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០១នាក់ ស្រី ៣៩នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ៕

## មេត្តាកុំជាច់ចិត្ត ! ជួយស៊ែរបន្តផង មាននារីម្នាក់ត្រូវ មេខ្យល់បោកយកទៅលក់នៅចិន ពេលនេះកំពុងតែរងគ្រោះដោយសារតែគេធ្វើបាប(មានវីដេអូ)

https://khmernews.news/ 28-12-2020 ស៊ីហៀង

ហ្វេសប៊ុក ៖ ថ្មីៗនេះនៅលើបណ្តាញសង្គមហ្វេសប៊ុកពិតជាមានការភ្ញាក់ផ្អើលខ្លាំងណាស់ដោយសារតែមាននារីម្នាក់ត្រូវបានចាញ់បោកមេខ្យល់ហើយត្រូវមេខ្យល់យកទៅលើនៅឯប្រទេសចិន ពេលនេះនារីម្នាក់នេះកំពុងតែរងទុក្ខវេទនាខ្លាំងណាស់ដោយសារតែមានគេធ្វើបាបទៅលើនាង។ យ៉ាងណាមិញនេះបើយោងទៅតាមការបង្ហោះរបស់នារីរងគ្រោះដែលមានគណនីហ្វេសប៊ុកឈ្មោះ Da Lin បានធ្វើការបង្ហោះរៀបរាប់ឲ្យមហាជនដឹងថា ៖ « នាងខ្ញុំឈ្មោះ គីម ស្រីលីន នាងខ្ញុំមានអាយុ 20 ឆ្នាំ នាងខ្ញុំរស់នៅខេត្តក្រចេះ ស្រុកសំបូរ ហើយនាងខ្ញុំឥឡូវត្រូវចាញ់បោកមេខ្យល់ ខ្ញុំវេទនាណាស់ខ្ញុំមិនដឹងធ្វើយ៉ាងម៉េចទេឥឡូវគេកាន់តែធ្វើបាបខ្ញុំខ្លាំងឡើងហើយគេថែមទាំងទាត់ខ្ញុំ ជាក់ខ្ញុំ សូម្បីតែបាយក៏ខ្ញុំមិនសូវបានញុាំដែរ ខ្ញុំវេទនាណាស់សូមអោយលោកពូប៉ូលិសជួយរកខ្ញុំឲ្យបានឆាប់

បានទៅខ្មែរវិញផងខ្ញុំវេទនាណាស់ខ្ញុំទ្រាំលែងបានហើយទីតាំងកន្លែងខ្ញុំស្នាក់នៅរាល់ថ្ងៃនេះ ផ្លូវ Jiangxiang ផ្លូវខាងលិចស្រុកណាននាងទីក្រុងណាននាងខេត្តជាំងស៊ី »៕

## ស្ត្រីខ្មែរឥស្លាមម្នាក់ ចាញ់បោកមេខ្យល់នាំទៅលក់នៅប្រទេសអារ៉ាប៊ីសាអូឌីត នាងសូមឲ្យសម្ដេចទាំងពីរ ជួយផង!

https://www.cen.com.kh/ December 29, 2020

ភ្នំពេញ៖ ស្ត្រីខ្មែរឥស្លាមម្នាក់ ដែលកំពុងស្ថិតនៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត បានអំពាវនាវទៅដល់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន និងអង្គការសិទ្ធិមនុស្ស និងក៏ដូចអង្គការជួញដូរមនុស្ស មេត្តាជួយអន្តរាគមន៍ឲ្យរូបនាងបានវិលត្រឡប់មកមាតុភូមិវិញផង។ ស្ត្រីរងគ្រោះដែលមានគណនីហ្វេសប៊ុកឈ្មោះ Rohimah Binti Mohamad Aly បានចេញវីដេអូអំពាវនាវខាងលើនេះកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ម្សិលមិញ ដោយភ្ជាប់សារសរសេររៀបរាប់ឲ្យដឹងថា «នាងខ្ញុំឈ្មោះលីហ៊ើម៉ាស់ អាយុ ២៦ ឆ្នាំ សូមគោរពដល់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន និងអង្គការសិទ្ធមនុស្ស និងអង្គការជួញដូរមនុស្ស មេត្តាជួយនាងខ្ញុំដែលកំពុងរងគ្រោះដោយការចាញ់បោកមេខ្យល់ ដែលយកខ្ញុំមកលក់នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត តាំងពីឆ្នាំ 2017 រហូតមកដល់ឥឡូវ»។

ក្រោយពីបានឮបែបនេះ គេក៏បានឃើញគណនីហ្វេសប៊ុកឈ្មោះ «កម្ពុជា នៅអេហ្ស៊ីប» ដែលជាមន្ត្រីធ្វើការនៅស្ថានទូតកម្ពុជាប្រចាំនៅប្រទេសអេហ្ស៊ីប ពិតជាមានការភ្ញាក់ផ្អើល និងបានចេញមកបញ្ជាក់ថា «ស្ថានទូតកម្ពុជានៅអេហ្ស៊ីប បានជួយប្អូនស្រីរូបនេះតាំងពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ ដោយបានចេញលិខិតបើកផ្លូវបណ្ដោះអាសន្ន ជំនួសឲ្យលិខិតឆ្លងដែនដែលបានបាត់ តាមការស្នើសុំរបស់ប្អូនស្រី ហើយប្អូនស្រីបានប្រាប់ស្ថានទូតវិញថាម្ចាស់ផ្ទះនឹងទិញសំបុត្រយន្តហោះជូន ឲ្យតែមានលិខិតបើកផ្លូវ។ ចាប់តាំងពីស្ថានទូតបានផ្ញើលិខិតបើកផ្លូវតាមប្រៃសនីយ៍ បានដល់ដៃប្អូនស្រីហើយ ក៏មិនបានទទួលព័ត៌មានអ្វីបន្ថែមទៀតពីរូបគាត់ ហើយស្ថានទូត គិតថាប្អូនស្រីបានត្រឡប់ទៅដល់ស្រុកកំណើតវិញហើយ។ សូមប្អូនស្រីទាក់ទងមកស្ថានទូតម្ដងទៀត ដើម្បីដោះស្រាយបញ្ហានេះសារជាថ្មី។ សូមអរគុណ»។ ជាមួយគ្នានោះផងដែរ ស្ត្រីរងគ្រោះខាងលើក៏បានឆ្លើយតបថា «ខ្ញុំទៅទិញសំបុត្រហើយ ប៉ុន្តែគេមិនអនុញ្ញាតឲ្យនាងខ្ញុំទិញទេ»។ និងក៏ដូចឆ្លើយតបទៅនឹងសំណួរសួរបន្តថា «ហេតុដូចម្ដេចប្អូនស្រីមិនទាក់ទងមកស្ថានទូតបន្តទៀត?» នាងក៏បានបញ្ជាក់ថា «ដោយសារគេដកហូតយកទូរស័ព្ទបាត់ការទាក់ទងទៅលោកពូ»។

តែយ៉ាងណា តាមរយៈការជួយអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំ នៅប្រទេសអេហ្ស៊ីប ជាថ្មីម្ដងទៀតនេះសង្ឃឹមថាស្ត្រីរងគ្រោះនឹងអាចវិលត្រឡប់មកបាតុភូមិវិញក្នុងពេលឆាប់ៗខាងមុខ៕ **រក្សាសិទ្ធិដោយ៖ លឹម ហុង**

## ពលករខ្មែរនៅថៃប្រឈមនឹងដាច់ស្បៀង ដោយសារខំលាក់ខ្លួនក្នុងបន្ទប់អំឡុងពេលផ្ទុះជំងឺកូវីដ

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2020-12-29

ពលករខ្មែរជាច្រើននាក់ប្រឈមនឹងដាច់ស្បៀងអាហារ បន្ទាប់ពីពួកគេលាក់ខ្លួននៅក្នុងបន្ទប់ ជាច្រើនថ្ងៃអំឡុងពេលផ្ទុះជំងឺកូវីដ១៩ លើកទី២នៅប្រទេសថៃ។ ពួកករទាំងនេះព្រួយបារម្ភខ្លាចអាជ្ញាធរថៃចាប់ពួកគេដាក់គុក និងបញ្ជូនត្រឡប់ទៅកម្ពុជាអំឡុងពេលនេះ។ មន្ត្រីសង្គមស៊ីវិល យល់ថា រឿងនេះ ពលករដែលអត់ការងារធ្វើគួរតែត្រឡប់ទៅកម្ពុជាមួយរយៈប្រសើរជាងនៅប្រទេសថៃ។

ពលការិនីមានស្រុកកំណើតនៅខេត្តតាកែវ លោកស្រី ចាន់ ធី ប្រាប់អាស៊ីសេរី នៅរសៀលថ្ងៃទី២៨ ខែ ធ្នូ ថាពួកលោកស្រីមានគ្នា៥នាក់ លាក់ខ្លួននៅក្នុងបន្ទប់របស់ពលករខ្មែរធ្វើការងារនៅខេត្តឈុនបូរី (Chunbori) ជាង ១ សប្តាហ៍ហើយ ដោយមិនហ៊ានចេញក្រៅបន្ទប់ឡើយ។ ស្ត្រីវ័យ ៣២ ឆ្នាំ រូបនេះ និយាយថា ពួកលោកស្រី ខ្លាចអាជ្ញាធរថៃចាប់ដាក់គុក និងបញ្ជូនត្រឡប់ទៅស្រុកកំណើតវិញ អំឡុងពេលនេះ៖ «ខ្ញុំអត់ហ៊ានចេញទេ នៅតែក្នុងបន្ទប់សុទ្ធតែម្តង ព្រោះអីនៅបន្ទប់ជួលនោះគេមានសន្តិសុខយាម មានបិទបម្រាមអ្នកក្រៅហាមចូល តែពួកខ្ញុំចូលមកមុនហ្នឹងបន្តិច។និយាយទៅពិបាកមែនទែន ខ្វះខាតការហូបចុកយើងលុយកាក់ស្ទួចស្ទើងយកមកពីស្រុក អត់លុយ យើងចងការលុយគេមក ដល់អីចឹងទៅយើងអត់ទាន់បានការងារធ្វើ ត្រូវនៅជាមួយគេ។ហូបដោយសារគេខ្លះអីខ្លះ ដោយសារគេអាណិត»។

ដូចគ្នានេះដែរ ពលការិនីដែលកំពុងលាក់ខ្លួនម្នាក់ទៀត កញ្ញា សុខ ជា ថ្លែងថា កញ្ញាឆ្លងដែនចូលមករកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ តាមរយៈមេខ្យល់ជនជាតិខ្មែរនិងថៃ កាលពីថ្ងៃទី ១៨ ខែ ធ្នូ។ ពលការិនីវ័យ ៣១ ឆ្នាំ រូបនេះ ប្រាប់ថា ពួកកញ្ញាមកដល់ខេត្តឈុនបូរី (Chunbori) មិនទាន់មានការងារធ្វើនៅឡើយទេ ក៏ផ្ទុះជំងឺកូវីដ១៩ ជាលើកទី២ នៅក្នុងប្រទេសថៃតែម្តង។ កញ្ញាឱ្យដឹងទៀតថា មូលហេតុដែលកញ្ញាលាក់ខ្លួន គឺមកពីពួកកញ្ញាជាពលករចំណូលថ្មី ហើយអាជ្ញាធរថៃ នឹងចាប់យកទៅធ្វើតេស្តជំងឺកូវីដ១៩៖ «ខាងបន្ទប់គេមិនឱ្យយើងចូលផងអ្នកប្លែកមុខតែអានេះបងហ្នឹងគាត់អាណិតគាត់ចេះ តែលួចឱ្យចូលមកគាត់ចេះតែជួយហើយគាត់ថាខ្មែរដូចគ្នា។ ខ្ញុំអត់ដែលចេញសោះខ្លាចគេ បើអ្នកនៅហ្នឹងគេថាបើមានអ្នកចំណូលថ្មីអីចឹងចេញឱ្យគេឃើញគេទៅប្តឹងអាជ្ញាធរថៃ ទៅខ្ញុំអត់ហ៊ានចេញទេនៅតែក្នុងបន្ទប់ហ្នឹង។ ទ្វារខាងក្រៅយើងបើកចំហទៅ ហើយរាល់ថ្ងៃហ្នឹងតែពួកបងគាត់មកពីធ្វើការ គាត់ទៅទិញអីឱ្យហូបបានហូប។ ខ្ញុំនឹកឃើញលំបាកមករកការងារអត់បានធ្វើ តែខ្ញុំមិនដឹងធ្វើយ៉ាងម៉េចបើមកដល់ហើយ»។ ក្រុមពលករទាំងនេះ ត្អូញត្អែរថា ពួកគាត់គ្មានប្រាក់ទិញអាហារហូបចុកប្រចាំថ្ងៃឡើយ។ ពួកគាត់រស់ដោយពឹងអាស្រ័យលើពលករខ្មែរឯទៀត ផ្តល់កន្លែងស្នាក់នៅ និងអាហារហូបចុកបណ្តោះអាសន្នប៉ុណ្ណោះ។ ជាមួយគ្នានេះពលករនៅខេត្តសាមុតសាខន ប្រមាណ២០នាក់ទៀត នៅតែបន្តលាក់ខ្លួនក្នុងព្រៃ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនដដែល។ ពួកគាត់ព្រួយបារម្ភ ខ្លាចអាជ្ញាធរថៃចាប់ខ្លួនបញ្ជូនទៅកម្ពុជាវិញ អំឡុងពេលនេះ។

អាជ្ញាធរថៃនៅតែបន្តហាមឃាត់ មិនឱ្យពលករបរទេសធ្វើដំណើរចល័ត ពីតំបន់មួយទៅតំបន់មួយទៀត អំឡុងពេលនេះឡើយ ដើម្បីបង្ការកុំឱ្យឆ្លងជំងឺកូវីដ១៩។

អាស៊ីសេរីមិនអាចទាក់ទងស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយ ជុំវិញពីក្តីកង្វល់របស់ពលករទាំងនេះ បានទេនៅថ្ងៃទី២៨ ធ្នូ ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។ ប៉ុន្តែ មន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកទទួលផ្នែកពលករ លោក គឹម ចំរើន បានប្រកាសនៅក្នុងហ្វេសប៊ុក (Facebook)ស្ថានទូតខ្មែរ កាលពីថ្ងៃទី២៧ធ្នូថា អំឡុងពេលនេះ រដ្ឋាភិបាលថៃបានអនុគ្រោះដល់ពលករបរទេសទាំងអស់ ឱ្យអាចធ្វើការនៅប្រទេសថៃជាបណ្តោះអាសន្នបាន ដោយមិនមានការចាប់ចងនោះទេ។ លោកបន្ថែមថា ប្រសិនបើពលករខ្មែរ ខ្វះខាតស្បៀងអាហារ ពួកគាត់អាចទាក់ទងតាមហ្វេសប៊ុកស្ថានទូតផ្នែកទទួលបន្ទុកពលករ ឱ្យជួយផ្សព្វផ្សាយរកជំនួយជូនពួកគាត់បាន។

មន្ត្រីអង្គការសង់ត្រាល់ Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា អំឡុងពេលនេះ នៅប្រទេសថៃអាចមានពលករខ្មែររាប់ពាន់នាក់ កំពុងលាក់ខ្លួនរកកន្លែងសុវត្ថិភាព ដោយសារពួកគេខ្លាចអាជ្ញាធរថៃចាប់ដាក់គុក។ លោកនិយាយថា ពលករខ្មែរទាំងនោះគួរតែទាក់ទងស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ឱ្យជួយអន្តរាគមន៍ពួកគេត្រឡប់ទៅកម្ពុជាវិញមួយរយៈសិន ប្រសើរជាងស្នាក់នៅប្រទេសថៃ ទាំងអត់ការងារធ្វើ និងប្រថុយប្រថានបែបនេះ៖ «អីចឹងហើយបានជាខ្ញុំទទូចម្តងហើយម្តងទៀត ក្នុងកាលៈទេសៈនេះជាឱកាសរបស់មេ

ខ្យល់ ទុច្ចរិតមួយដែលនាំ យើងទៅយកលុយពីយើងទៅដល់អត់មានការងារធ្វើ អត់មានឯកសារស្របច្បាប់។ ហើយយើងដឹងហើយក្នុងអំឡុងពេលនេះអត់ទាន់មានការនាំចូលពលករជាផ្លូវទេ អីចឹងអានាំចូលមិនផ្លូវការហ្នឹងហើយ ជាដំណើរការនៃការនាំមនុស្សដោយខុសច្បាប់ជាដំណើរការនៃការជួញដូរមនុស្ស ហើយពលរដ្ឋខ្លួនឯងផ្ទាល់តែម្តងអត់ដឹងថា អាហ្នឹងជាការចាញ់បោកគេទេ»។ មន្ត្រីអង្គការសង្គមស៊ីវិលរូបនេះ ឱ្យដឹងថា ពលករធ្វើការខុសច្បាប់ នៅប្រទេសថៃអាចនឹងមានការលំបាកកាន់តែខ្លាំង ប្រសិនបើជំងឺកូវីដ១៩ ផ្ទុះឡើងលើកទី២នេះ បន្តអូសបន្លាយយូរអង្វែង។ បន្ថែមពីនេះលោក ឌី ថេហូយ៉ា និយាយថា ពលរដ្ឋខ្មែរមិនគួរឆ្លងដែនខុសច្បាប់ទៅប្រទេសថៃអំឡុងពេលនេះនោះឡើយ ពីព្រោះការធ្វើបែបនេះ ប្រថុយប្រថាននឹងគ្រោះថ្នាក់ដល់អាយុជីវិតផង ហើយអាចនឹងត្រូវអាជ្ញាធរថៃចាប់ដាក់គុក និងប្រឈមឆ្លងជំងឺកូវីដ-១៩ ដែលកំពុងផ្ទុះឡើងជាថ្មីនៅក្នុងប្រទេសថៃនោះផង៕

## ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២០

### គិតត្រឹមថ្ងៃទី៣០ ពលរដ្ឋដែលវិលចូលប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់មានជិត ១៤០នាក់ នឹងត្រូវធ្វើចត្តាឡីស័កនៅសាលាវិទ្យាល័យ តេជោ សែន សំរោង

https://khmernote.com.kh/ December 30, 2020 srey nuch

ខេត្តឧត្តរមានជ័យ៖ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៩នាក់ ស្រី ៦៧នាក់ ជាពលករពុំបានប្រថាប់ត្រា ត្រូវបានអជ្ញាធរដឹកជញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅសាលាវិទ្យាល័យ តេជោ សែន សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ៕

### បងប្អូនពលករមកពីប្រទេសថៃមកស្រុករមាសហែកដើម្បីធ្វើចត្តាឡីស័កថ្មីកម្រិត២សរុបមានចំនួន៦៥នាក់(ស្រី២៥នាក់)

http://nokorwatnews.com/ 30-12-2020

ខេត្តស្វាយរៀង៖ នៅព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០លោក ស៊ូ ម៉ុល អភិបាលស្រុករមាសហែកបានអញ្ជើញមកទទួលបងប្អូនពលករចំណាកស្រុក ដែលមកពីប្រទេសថៃចំនួន១៨នាក់ (ស្រី៧នាក់) ដើម្បីមកធ្វើចត្តាឡីស័កថ្មីកម្រិត២នៅទីតាំងការិយាល័យកសិកម្មស្រុករមាសហែកស្ថិតក្នុងភូមិគ្រញូង ឃុំមុខដា ស្រុករមាសហែក។ លោក ស៊ូ ម៉ុល អភិបាលស្រុកបានឱ្យដឹងថា បងប្អូនពលករចំណាកស្រុកមកពីក្រៅប្រទេសដែលបានមកធ្វើចត្តាឡីស័កថ្មីកម្រិត២នៅទីតាំងការិយាល័យកសិកម្មស្រុករមាសហែកសរុបតាំងពីថ្ងៃទី១៦ រហូតមកដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០នេះ គឺមានចំនួន៦៥នាក់(ស្រី២៥នាក់)។ លោកបន្តថា ការមកធ្វើចត្តាឡីស័កថ្មី កម្រិត២នេះគឺខាងស្រុកបានផ្តល់ការឧបត្ថម្ភអាហារប្រចាំថ្ងៃជូនដល់ពលករស្នាក់នៅមណ្ឌលចត្តាឡីស័កថ្មី មុខដាដោយបានអប់រំណែនាំឱ្យថែទាំសុខភាព និងរង់ចាំទទួលលទ្ធផលដើម្បីបន្តធ្វើចត្តាឡីស័ក។

បន្ទាប់មកលោកក៏បានផ្តាំផ្ញើដល់បងប្អូនចំណាកស្រុកមកពីក្រៅប្រទេស ដែលបានមកធ្វើចត្តាឡីស័កថ្មីកម្រិត២នៅទីតាំងការិយាល័យកសិកម្មស្រុកត្រូវអនុវត្តការធ្វើអនាម័យជាប្រចាំ ដោយលាងដៃជាមួយសាប៊ូ អាល់

កុល ដែល ពាក់ម៉ាស់ ហើយនៅគម្លាតគ្នា។នៅពេលទំនេរដើម្បីបំបាត់ការអផ្សុកសូមធ្វើពលកម្មក្នុងបរិវេណទីតាំងនៅមណ្ឌលចត្តាឡីស័កទាំងអស់គ្នា៕

## រដ្ឋបាលខេត្តបន្ទាយមានជ័យជម្រុញប្រសិទ្ធភាពការទទួលពលករនិងត្រៀមសម្រួលផ្លាស់ប្តូរទីតាំងមណ្ឌលចត្តាឡីស័ក

https://www.rasmeinews.com/ 30 December, 2020

**ដោយ: ភ្នំស្វាយ / បន្ទាយមានជ័យ:** *រដ្ឋបាលខេត្តបន្ទាយមានជ័យ ជម្រុញប្រសិទ្ធភាពការទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ និងត្រៀមសម្រួលផ្លាស់ប្តូរទីតាំងមណ្ឌលចត្តាឡីស័ក នៅតាមសាលារៀននានា។ ព្រោះទាំងមូល ឬផ្នែកធំ នៃសាលារៀន ត្រូវផ្ទេរអោយដំណើរការសិក្សារបស់សិស្សានុសិស្សឆ្នាំសិក្សាថ្មី២០២០ -២០២១ នាថ្ងៃទី១១ខែមករាឆ្នាំ២០២១។* នេះបើតាមលោក អ៊ុ រាត្រី អភិបាលខេត្តបន្ទាយមានជ័យឲ្យដឹងនៅថ្ងៃទី៣០ខែធ្នូ ឆ្នាំ២០២០ ខណៈដឹកនាំលោក រឿង សុធី តំណាងមន្ទីរសុខាភិបាល លោកលី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ លោកគាត ហ៊ុល អភិបាលក្រុងប៉ោយប៉ែត និងមន្ត្រីក្រុមការងារត្រួតពិនិត្យដំណើរការធ្វើចត្តាឡីស័ក ការទទួលបញ្ជូនពលករខ្មែរពីមណ្ឌលចត្តាឡីស័កកម្រិត២ ទៅកាន់ស្រុកក្រុងដែលលំនៅឋានពួកគេ។ លោក អ៊ុ រាត្រី បានបន្តថា៖ ចំពោះមុខមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត និងផ្នែកពាក់ព័ន្ធ ក៏ត្រៀមកែសម្រួល ផ្លាសប្តូរទីតាំងមណ្ឌលចត្តាឡីស័ក នៅពេលទីតាំងសាលារៀននានា ត្រូវបើកដំណើរការសិក្សាឡើងវិញនាបវេសនកាលឆ្នាំសិក្សាថ្មី២០២០-២១ នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ខាងមុខនេះ។ រដ្ឋបាលខេត្តបានថ្លែងអំណរគុណដល់មន្ត្រីក្រុមការងារស៊ីវិល និងកងកម្លាំងគ្រប់ផ្នែក ដែលបានខិតខំបំពេញការងារបន្ទាន់នេះ ហើយស្នើឲ្យការងារនេះ បានលទ្ធផលល្អនិងមានប្រសិទ្ធភាព។

សូមបញ្ជាក់ថា មានពលករខ្មែរចន្លោះពី១៥០ ទៅ២៥០នាក់ បានវិលវិញ ឬត្រូវអាជ្ញាធរថៃ បញ្ជូនពីថៃមកតាមច្រកព្រំដែនអូរបីជាន់។ ហើយនៅច្រកខ្លះទៀត ក៏មានលំហូរពលករមកដែរ ខណៈពេលមានការផ្ទុះខ្លាំងនូវករណីឆ្លងមេរោគកូវីដ១៩ សហគមន៍ក្នុងប្រទេសថៃនាបច្ចុប្បន្ននេះ។ ហើយបើគិតពីខែមេសា ឆ្នាំ២០២០ មកឬជំនាញហៅថា ដើមគ្រា និងប្រចាំថ្ងៃ ឬហៅថា ក្នុងគ្រា ហើយសរុបចូលគ្នា ឬហៅថាបូកយោងនោះ ឃើញថា មានពលករខ្មែរជិត៦ម៉ឺននាក់ (៥៩២៩០នាក់/ស្រី២៨ .៣៥១នាក់ ) បានត្រូវបញ្ជូនមកកម្ពុជាវិញ ឆ្លងកាត់ច្រកព្រំដែនអូរបីជាន់។ ក្នុងនោះ ពលករច្រើនជាងគេគឺមកពីខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប។ និងក្រៅពីនោះមកពីខេត្ត រាជធានីផ្សេងទៀត៕

## លេខាធិការដ្ឋានខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បើកយុទ្ធនាការផ្សព្វផ្សាយទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយវិធានការទប់ស្កាត់ការការពារ នៃការចម្លងមេរោគកូវីត ១៩ នៅបណ្តាក្រុង ស្រុក គោលដៅចំនួន នៃខេត្តកំពង់ចាម

https://www.pdikampongcham.info/ ៣០ ខែធ្នូ ២០២០ *អត្ថបទ៖ដា គឹមហុង*

ដើម្បី ចូលរួមទាំងអស់គ្នា ក្នុងការទប់ស្កាត់ការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងផ្តន្ទាទោសដាច់ខាត ចំពោះ មេខ្យល់ ដែលតែងតែប្រព្រឹត្តអំពើឆបោក អូសទាញបងប្អូន កូនក្មួយ កេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ លើស្ត្រី និងកុមារ នាព្រឹកថ្ងៃពុធ ទី៣០ ខែធ្នូ ឆ្នាំ២០២០ នេះ ក្រុមការងារលេខាធិការដ្ឋានខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំដោយ លោកជំទាវ ប៉ាង ដានី ប្រធានលេខាធិការដ្ឋានខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះធ្វើយុទ្ធនាការផ្សព្វផ្សាយទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងខ្លឹមសារអប់រំ របស់ក្រសួងសុខាភិបាល ស្តីពីវិធានការទប់ស្កាត់ការការពារ នៃការចម្លងមេរោគកូវីត ១៩ ព្រមទាំង ចែកម៉ាស់

ដល់ប្រជាពលរដ្ឋ ចំនួន ៩ គោលដៅ ក្នុងក្រុងស្រុកគោលដៅ ចំនួន ៦ គឺ ៖ ក្រុងកំពង់ចាម ស្រុកកងមាស ព្រៃឈរ កំពង់សៀម ចំការលើ និងស្រុកស្ទឹងត្រង់ ។

ក្នុងឱកាសចុះផ្សព្វផ្សាយនោះដែរ លោកជំទាវ ប៉ាង ដានី ប្រធានលេខាធិការដ្ឋានខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរ បានបញ្ជាក់លើខ្លឹមសារនៃមាត្រា១៥ ដែលបង្ហាញថា៖ ជនណាដែលលក់ដូរជនដទៃទៀត ដោយមានគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ស្មុំកូន ឬទម្រង់ នៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ដល់១៥ឆ្នាំ ប៉ុន្តែត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំទៅ២០ឆ្នាំ ក្នុងករណីជនរងគ្រោះជាកុមារក្រោមអាយុ១៨ឆ្នាំ ឬជាអនីតិជន ។

ជាមួយគ្នានោះដែរ លោកជំទាវ បានផ្សព្វផ្សាយ សារលិខិត របស់ ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាល ខេត្តកំពង់ចាម និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅកាន់ប្រជាពលរដ្ឋ ៖ ដោយសូមបងប្អូនកូនក្មួយទាំងអស់ ប្រុងប្រយ័ត្នអោយបានខ្ពស់ ចំពោះ ល្បិចកលឆបោករបស់មេខ្យល់ ដែលសន្យាថា នាំបងប្អូនកូនក្មួយទៅធ្វើការនៅក្រៅប្រទេស ហើយទទួលបានប្រាក់ខែខ្ពស់។ ការសន្យាបែបនេះ គឺមានបំណងបោកប្រាស់ ដើម្បី ទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ដោយការលក់បងប្អូន កូនក្មួយ ទៅឲ្យបរទេស ។ លោកជំទាវ បានបញ្ជាក់ថា ប្រសិនបើបងប្អូន លង់ក្នុងការឆបោកបញ្ឆោត ដោយហេតុផលណាមួយ សូមបងប្អូនកូនក្មួយ ដាក់ជាប់ខ្លួនជានិច្ច នូវលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ លេខទូរស័ព្ទ ស្ថានទូតខ្មែរនៅទីនោះ និងលេខទូរស័ព្ទ ឪពុកម្ដាយ បងប្អូន ក្រុមគ្រួសារ ឬលេខទូរស័ព្ទ អាជ្ញាធរភូមិ ឃុំ របស់បងប្អូនកូនក្មួយ ។

ស្ថិតក្នុងឱកាសនោះ លោកជំទាវ ក៏បានផ្ដាំផ្ញើ ទៅដល់បងប្អូនកូនក្មួយ ដែលបាននឹងកំពុងជួបជាមួយជនឆបោក ជាមេខ្យល់ ដែលកំពុងនិយាយបញ្ចុះបញ្ចូល ក្នុងបំណងអូសទាញ ឲ្យធ្លាក់ខ្លួនជាជនរងគ្រោះ ដោយជួញដូរមនុស្សក្នុងប្រទេស និងទៅក្រៅប្រទេស សូមបងផ្តល់ព័ត៌មាន ទាំងនេះទៅកាន់ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬលោកមេឃុំ ចៅសង្កាត់ របស់បងប្អូន ឬក៏ការជួយអន្តរាគមន៍ ពិសេស របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល ដែលមានលេខទូរស័ព្ទ 081 37 38 39 ឬ 011 714 668 ឲ្យបានទាន់ពេលវេលា។

## លម្អិតអត្តសញ្ញាណពលករខ្មែរឆ្លងកូវីដពីថៃ ជាស្ត្រីទាំងពីរ វ័យជាង ៣០ ឆ្នាំ

https://kampucheathmey.com/ December 31, 2020 By Dy Bunnara

ដំណឹងពីក្រសួងសុខាភិបាលពីករណីពលករខ្មែរពីរនាក់ទើបវិលត្រឡប់ពីថៃឆ្លងកូវីដ ១៩ នៅព្រឹកនេះ។ តាមការបង្ហាញអត្តសញ្ញាណពលករទាំងពីរនាក់ជាស្ត្រីក្នុងវ័យជាង ៣០ ឆ្នាំ។ ស្ត្រីទីមួយអាយុ ៣៦ ឆ្នាំ ទីលំនៅនៅឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ធ្វើដំណើរមកពីប្រទេសថៃ មកដល់នៅថ្ងៃ ២៨ ខែធ្នូ ឆ្នាំ ២០២០។ ការធ្វើតេស្តសំណាកពីវិទ្យាស្ថានប៉ាស្ទ័រ មានវិជ្ជមានកូវីដ ១៩។ ស្ត្រីទីពីរដែលឆ្លងកូវីដអាយុ ៣៣ ឆ្នាំ ទីលំនៅនៅឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន បានធ្វើដំណើរមកដល់នៅថ្ងៃ ២៩ ធ្នូ។ បច្ចុប្បន្នស្ត្រីទាំងពីរ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង។

ប្រទេសថៃ បានរាយការករណីផ្ទុះឆ្លងកូវីដសហគមន៍ក្នុងខេត្តសមុទ្រសាខន និងបានរាលដាលដល់ទូទាំងប្រទេស។ អាជ្ញាធរថៃបានបញ្ជាឲ្យបិទខេត្តជាប្រកពគ្រឿងសមុទ្រដ៏ធំរបស់ថៃនេះ ដោយរឹតបន្តឹងការធ្វើដំណើរចេញចូល។

រដ្ឋាភិបាលកម្ពុជាបានបញ្ជាឲ្យអាជ្ញាធរខេត្តជាប់ព្រំដែនថៃ ត្រូវគ្រប់គ្រងលំហូរពលករខ្មែរវិលត្រឡប់ ដោយត្រូវផែកសុខភាពឲ្យបានហ្មត់ចត់ ធ្វើតេស្តសំណាក និងត្រូវបន្តទៅធ្វើចត្តាឡីស័កឲ្យគ្រប់ ១៤ ថ្ងៃ ជាចាំបាច់ ដើម្បីការពារការឆ្លងរាលដាលក្នុងប្រទេស៕

## ពលករខ្មែរដែលភ័យខ្លាចឆ្លងកូវីដ-១៩ បន្តចាកចេញពីប្រទេសថៃតាមច្រកព្រំដែន ខេត្តឧត្តរមានជ័យ

http://btv.com.kh/ 30/12/2020

ឧត្តរមានជ័យ ៖ ពលករខ្មែរ ដែលកំពុងធ្វើការក្នុងប្រទេសថៃបច្ចុប្បន្ននេះ បានបន្តនាំគ្នាចាកចេញដោយសារភ័យខ្លាច ឆ្លងកូវីដ–១៩ បន្ទាប់ពីវាបានផ្ទុះឆ្លងរាលដាលក្នុងសហគមន៍ នៃប្រទេសនេះ។ ពលករ ចំនួនជាងមួយរយនាក់ ក្នុងមួយថ្ងៃៗ បានចាកចេញពីប្រទេសថៃ ចូលមកកម្ពុជា តាមព្រំដែនអន្តរជាតិអូរស្មាច់ និងច្រកជាំសាងាំ តែពួកគេ ត្រូវបានត្រួតពិនិត្យដោយមន្ត្រីសុខាភិបាល យ៉ាងហ្មត់ចត់។

ឯកឧត្តម ប៉ែន កុសល អភិបាលខេត្តឧត្តរមានជ័យ បានជំរុញឱ្យមន្ត្រីសុខាភិបាល ដែលជាគ្រូពេទ្យ ជួរមុខទាំងអស់ ឈរជើងប្រចាំការនៅតាមច្រកព្រំដែន ត្រូវចាត់វិធានការឱ្យបានហ្មត់ចត់ ក្នុងការពិនិត្យ សុខភាព និងធ្វើចត្តាឡីស័កពួកគេគ្រប់រូប មុនអនុញ្ញាតឱ្យទៅស្រុកកំណើត។ ឯកឧត្តម បានបញ្ជាក់ថា ការដែលអាជ្ញាធរខេត្ត បន្តធ្វើការរឹតបន្តឹង និងចាត់វិធានការយ៉ាងតឹងរឹង បែបនេះ គឺដោយសារបច្ចុប្បន្ន ប្រទេសថៃ កំពុងតែរងការរាតត្បាតនៃមេរោគកូវីដ–១៩ ចូលដល់សហគមន៍ ខេត្តមួយចំនួនធំ ដូច្នេះហើយក្នុងនាមអាជ្ញាធរខេត្តឧត្តរមានជ័យ ដែលជាខេត្តមួយប្រឈមជាប់ព្រំដែន ប្រទេសថៃ ត្រូវតែអនុវត្តវិធានបង្ការការនាំមេរោគកូវីដ–១៩ ចូលមក តាមរយៈពលករដែលធ្វើការនៅ ប្រទេសថៃ។

តាមការឱ្យដឹងពីអាជ្ញាធរខេត្តឧត្តរមានជ័យ គិតចាប់ពីថ្ងៃទី២០ រហូតមកដល់ថ្ងៃ៣០ ខែធ្នូនេះ មានពលករខ្មែរចំនួនជាងមួយពាន់នាក់ហើយ បានចាកចេញពីប្រទេសថៃ ចូលមកប្រទេសកំណើតខ្លួន តាមច្រកព្រំដែនខេត្តនេះ ហើយពលករចំនួនជិត៤០០នាក់ ត្រូវបានយកសំណាកទៅធ្វើតេស្ត តែលទ្ធផល គឺអវិជ្ជមានទាំងអស់៕ អត្ថបទ៖ ឃិន សារិទ្ធ

## ពលករខ្មែរជាង ១៤០០នាក់ ត្រូវថាបានភាគីថៃចាប់បញ្ជូន និងត្រឡប់ដោយខ្លួនឯងតាមច្រកអូរបីជាន់ និងកំពុងធ្វើចត្តាឡីស័ក

https://sovannaphumpost.com/kh/ អត្ថបទដោយ: ឈុំ ស្រីនាថ ៣០ ធ្នូ ២០២០

យោងតាមការឱ្យដឹងពីអភិបាលស្រុកអូរជ្រៅ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ មានពលករខ្មែរដែលភាគីថៃចាប់បញ្ជូន និងត្រឡប់ដោយខ្លួនឯងតាមច្រកអូរបីជាន់មានសរុបចំនួន ១,៤៧៩នាក់ (ស្រី៦៦៨នាក់) និង នេះបើកគិតចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០។

ប្រជាពលរដ្ឋដែលត្រូវភាគីថៃចាប់បញ្ជូនរយៈពេលប៉ុន្មានថ្ងៃមកនេះ ភាគីថៃចាប់តាមបន្ទាត់ព្រំដែនដែលប្រជាពលរដ្ឋភាគច្រើន ទៅធ្វើការងារកសិកម្មដូចជា ដកដំឡូងមី ប្រមូលផលស្រូវ និងមើលថែចំការ និងការងារផ្សេងៗ តែត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនតាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅនៅពេលភាគីថៃរឹតបណ្តឹងបង្ការទប់ស្កាត់ជំងឺកូវីដ-១៩។

ទន្ទឹមនឹងនោះ អាជ្ញាធរខេត្តបន្ទាយមានជ័យរួមនឹងកម្លាំងទាំងបីក៏បានត្រៀមកន្លែងធ្វើចត្តាឡីស័ក និងត្រៀមរថយន្តដឹកជញ្ជូនពលករដែលមកពីប្រទេសថៃតាមច្រកអូរបីជាន់ទៅដាក់តាមមណ្ឌលនិមួយៗ រួចនឹងដឹកពួកគាត់ទៅតាមស្រុកកំណើតវិញបន្ទាប់រយៈពេល១៤ថ្ងៃ ប្រសិនមិនមានជំងឺកូវីដ-១៩៕

## ថៃគ្រោងនឹងផ្តល់សិទ្ធការងារស្របច្បាប់ចំពោះពលករកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ប្រមាណជា ១ លាននាក់

https://khmernote.com.kh/ December 30, 2020 lyda

ថៃ៖ ក្រសួងមហាផ្ទៃថៃបានដាក់ដំណើរទៅកាន់គណៈរដ្ឋមន្ត្រីដើម្បីសុំចុះឈ្មោះពលករខុសច្បាប់ប្រមាណជា ១ លាននាក់ ដែលកំពុងមានវត្តមាននៅក្នុងប្រទេសថៃស្រាប់ ឲ្យក្លាយជាពលរកស្របច្បាប់តែម្តង ដោយមិនចាំបាច់ចាត់វិធានការតាមផ្លូវច្បាប់ចំពោះពួកគេនោះទេ។ បើយោងតាមការចុះផ្សាយនៅក្នុងសារព័ត៌មាន បាងកក ប៉ុស្ត៍ បានឲ្យដឹងថា ក្រុមពលករខុសច្បាប់ប្រមាណជា ១ លាននាក់នោះមានដូចជាពលករកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ហើយគេរំពឹងថាការសម្រេចចុះឈ្មោះឲ្យពលករទាំងនេះមានសិទ្ធធ្វើការងារដោយស្របច្បាប់នៅក្នុងប្រទេសថៃ អាចនឹងត្រូវធ្វើឡើងក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីប្រចាំសប្តាហ៍ ដែលនឹងត្រូវរៀបចំឡើងនៅក្នុងថ្ងៃអង្គារសប្តាហ៍ក្រោយនេះ។ បើតាមប្រភពខាងលើបានបន្តថា ការសម្រេចផ្តល់សិទ្ធធ្វើការងារស្របច្បាប់ចំពោះក្រុមពលករទាំងនេះគឺជាកត្តាដ៏សំខាន់មួយក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ ១៩ នៅក្នុងប្រទេសថៃ ព្រោះពលករខុសច្បាប់ទាំងនោះមិនហ៊ានចេញទៅធ្វើតេស្តរកជំងឺកូវីដ ១៩ឡើយដោយខ្លាចអាជ្ញាធរចាប់ខ្លួន ខណៈពួកគេគឺជាក្រុមមនុស្សដែលមានហានិភ័យខ្ពស់ក្នុងឆ្លងជំងឺកូវីដ ១៩ ដែលផ្ទុះចេញពីខេត្តសាមុតសាខន។ យ៉ាងណាក្តីក្រសួងមហាផ្ទៃថៃបានបញ្ជាក់ថា ការផ្តល់សិទ្ធការងារស្របច្បាប់នេះធ្វើឡើងចំពោះតែក្រុមពលករដែលមានវត្តមាននៅក្នុងប្រទេសថៃស្រាប់ត្រឹមថ្ងៃប្រកាសដំណឹងនេះតែប៉ុណ្ណោះ ហើយពលករផ្សេងទៀតដែលចូលមកប្រទេសថៃដោយខុសច្បាប់បន្ទាប់ពីថ្ងៃនេះទៅនឹងត្រូវអនុវត្តទោសទៅតាមផ្លូវច្បាប់។ សូមបញ្ជាក់ថា បច្ចុប្បន្ននេះថៃមានពលករស្របច្បាប់ប្រមាណជា ២,៣-២,៥ លាននាក់ និងពលករខុសច្បាប់ប្រមាណជា ១ លាននាក់៕

## ថៃ នឹងផ្តល់ប័ណ្ណការងារដល់ពលករខុសច្បាប់ដែលគ្មានឯកសារ ដើម្បីបង្ការជំងឺកូវីដ-១៩

https://thmeythmey.com/ 30, Dec 2020 , 5:29 pm ដោយ: គយ រតនបុរិន្ទ

នៅថ្ងៃទី២៩ ធ្នូ រដ្ឋាភិបាលថៃសម្រេចផ្តល់ប័ណ្ណការងារដល់ពលករកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ដែលពុំមានឯកសារឲ្យធ្វើការដោយស្របច្បាប់នៅថៃក្នុងរយៈពេល២ឆ្នាំ ដើម្បីបង្ការជំងឺឆ្លងកូវីដ-១៩។ ចំណែកពលករដែលប័ណ្ណការងារហួសកំណត់ អាចបន្តស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃរយៈពេល២ឆ្នាំបន្ថែមទៀតដែរ។

សេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីថៃ ធ្វើឡើងបន្ទាប់ពីមានករណីផ្ទុះជំងឺឆ្លងកូវីដ-១៩ ជាង១,៥០០ករណីនៅខេត្តសមុទ្រសាគរ ដែលជាប់ពាក់ព័ន្ធទៅនឹងពលករមីយ៉ាន់ម៉ា ធ្វើការនៅផ្សារលក់គ្រឿងសមុទ្រ។ «រដ្ឋាភិបាលមើលឃើញថា ពលករបរទេសប្រឈមនឹងបញ្ហា ដោយសារតែនិយោជកតម្រូវឲ្យពលករប្តូរទីតាំងដើម្បីរួចខ្លួនពីការល្មើសច្បាប់»។ នេះជាការលើកឡើងរបស់លោកTraisuree Taisaranakul អ្នកនាំពាក្យរងរដ្ឋាភិបាលថៃ។ លោកបន្តថា ពលករបរទេសរត់គេចពីកន្លែងមួយ ទៅកន្លែងមួយទៀត ជាហេតុបណ្តាលឲ្យសាយភាយជំងឺកូវីដ-១៩ ។ នេះយោងតាមទីភ្នាក់ងារព័ត៌មាន Reuters ។

ដើម្បីអាចទទួលបានប័ណ្ណការងារ ដែលមានសុពលភាពរហូតដល់ខែកុម្ភៈ ឆ្នាំ២០២៣ ពលករបរទេសត្រូវមានឈ្មោះក្នុងបញ្ជីរបស់និយោជក ចាប់ពីពាក់កណ្តាលខែកញ្ញាទៅ។ បន្ថែមពីនេះ ពលករបរទេសត្រូវឆ្លងកាត់ការធ្វើតេស្តសុខភាព ដែលមានតម្លៃប្រមាណ៣២០ដុល្លារ។ ពលករបរទេស មានពេលវេលាចុះឈ្មោះទទួលប័ណ្ណការងាររហូតដល់ពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០២១។ ថៃមានពលករបរទេស ចំនួន២,២លាននាក់ ដែលចុះបញ្ជីស្របច្បាប់ ដែលមួយភាគធំមកពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ដោយធ្វើការក្នុងវិស័យនេសាទ សាងសង់ និងកសិកម្មជាដើម។ អង្គការក្រុមការងារពលករចំណាកស្រុក(MWG) ប៉ាន់ស្មានថា ពលករបរទេសប្រមាន៦សែន ទៅ៨សែននាក់ អាចនឹងទទួលបានប័ណ្ណការងារយោងតាមសេចក្តីសម្រេចរបស់រដ្ឋាភិបាលថ្មីនេះ។

លោក Adisorn Kerdmongkol អ្នកសម្របសម្រួលអង្គការ MWG និយាយថា រដ្ឋាភិបាលថៃគួរតែអនុញ្ញាតឲ្យពលករបរទេស១សែននាក់ផ្សេងទៀត ដែលទទួលបានប័ណ្ណការងារ ហើយឲ្យចូលមកធ្វើការក្នុងប្រទេសថៃ បើទោះបីជាមានការបិទព្រំដែនក្តី។ លោក Kerdmongkol បន្ថែមថា ពលករបរទេសមួយចំនួនដែលជាប់បំណុល កំពុងរង់ចាំចូលធ្វើការក្នុងប្រទេសថៃដើម្បីបង់ប្រាក់ទៅមេខ្យល់ ឬភ្នាក់ងារស្វែងរកការងារ។ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) សាទរសេចក្តីសម្រេចរបស់រដ្ឋាភិបាល ប៉ុន្តែទទូចឲ្យរដ្ឋាភិបាលថៃផ្តល់ការធ្វើតេស្តជំងឺកូវីដ-១៩ ដល់ពលករដោយគ្មានការរើសអើង។ លោកស្រី Geraldine Ansart ប្រធាន IOM ប្រចាំថៃ អះអាងថា ការភ័យខ្លាចពីការរើសអើង ចាប់ខ្លួន ឃុំខ្លួន និងរឹតត្បិតសេរីភាពក្នុងការធ្វើដំណើរ ជាឧបសគ្គសម្រាប់ពលករក្នុងការទទួលបានការព្យាបាលជំងឺ និងថែទាំសុខភាព។

កាលពីខែមុន ក្រសួងការងារថៃនិយាយថា ពលករកម្ពុជា មីយ៉ាន់ម៉ា និងឡាវចំនួន១សែន៣ម៉ឺននាក់ ដែលចូលមកធ្វើការក្នុងប្រទេសថៃស្របច្បាប់ ហើយដែលប័ណ្ណការងារនឹងត្រូវអស់សុពលភាព អាចបន្តធ្វើការ និងស្នាក់នៅក្នុងប្រទេសថៃរយៈពេល២ឆ្នាំបន្ថែមទៀត។

គិតត្រឹមថ្ងៃទី៣០ ធ្នូ ថៃមានករណីឆ្លងសរុបចំនួន៦,៩៤០ករណី ស្លាប់ចំនួន៦១នាក់ និងជាសះស្បើយចំនួន៤,១៨០ករណី ដោយមានករណីឆ្លងជាមធ្យមចំនួន១៩២ករណីក្នុងមួយថ្ងៃ៕